ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការជួប ឌុច លើកដំបូងរបស់ខ្ញុំ
- សំឡេងពីស្រុកអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៣ ខែកញ្ញា ឆ្នាំ២០១២

ស្វែងរកការពិត

លេខ១៥៣ ខែកញ្ញា ឆ្នាំ២០១២

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ការជួប ឌុច លើកដំបូងរបស់ខ្ញុំ ....................................... ១

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ ឡាច វ៉ារី ហៅ ណាន ....................... ៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សំឡេងពីស្រុកអន្លង់វែង ......................................... ១០

◆ស្គាល់ខ្មែរក្រហមតាមរយៈគិញសម្ងាត់ជនជាតិចិន ........... ២៤

◆រៀនប្រវត្តិសាស្ត្រដើម្បីស្គាល់ខ្លួនឯង ........................... ២៩

◆បទពិសោធន៍ជីវិតរបស់អ្នកទោសស-២១ ..................... ៣៣

**ផ្នែកច្បាប់**

◆ការពិចារណាអំពីទំហំនៃ "សវនាការតូច" ...................... ៣៥

◆បញ្ហាប្រឈម និងលទ្ធភាពដែលនឹងកើតមាន .................. ៣៨

◆សេចក្តីសម្រេចរបស់សាលាដំបូងលើសម្បទា ................. ៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ភាពអាចទទួលបាននៃកំណត់ហេតុស្តាប់ចម្លើយ .................. ៤៣

◆ការប្រើទូរស័ព្ទៈ បញ្ជូនការបកប្រែ ............................. ៤៦

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ បេះដូងក្រហមរបស់យុវជនដាំ ដេង .......................... ៤៩

◆ស៊ីវ ធួនៈ ដំណើរឆ្លងកាត់របបខ្មែរក្រហម ...................... ៥៦

◆៣៦ឆ្នាំក្រោយមក .................................................. ៦១



ផ្ទះរបស់ ប៉ុល ពត នៅស្រុកអន្លង់វែង

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ :*** *ស៊ុំ សារីណា, អេង កុកថាយ, ម៉ែខល លីវ, អាន ហាញខល, ចាន ប្រាថ្នា, ឆាយ ឈុនលី, ស៊ីវ ធួន, ហានស៍ កួច* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា* ***អ្នកបកប្រែ :*** *នូ ស្រស់លក្ខិណា, នង ច័ន្ទមល្លិកា, ភួង ចាន់ប្រានិត* ***និពន្ធនាយកទូទៅ :*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក :*** *ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រ :*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ :*** *អេង វើង* Email: dccam@online.com.kh, Homepage: www.dccam.org

# ការជួប ឌុច លើកដំបូងរបស់ខ្ញុំ

កាលពីនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ កន្លងទៅនេះ ខ្ញុំមានឱកាសជួបសម្ភាស កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវបានស្គាល់ជាទូទៅថាជាមេគុកសម្ងាត់ខ្មែរក្រហមមួយគឺស-២១ ។ ពេលនោះ ខ្ញុំបានធ្វើសម្ភាសជាមួយ ឌុច អស់រយៈពេលប្រហែលជាងពីរម៉ោង ។ គោលដៅចម្បងនៃកិច្ចសម្ភាសន៍នេះគឺដើម្បីឲ្យ ឌុច ជួយខ្ញុំលាតត្រដាងនូវការពិតទាក់ទងនឹងរូបថតពីរសន្លឹករបស់អ្នកទោសបស្ចិមប្រទេសពីរនាក់ដែលគិតថាធ្លាប់ជាប់នៅមន្ទីរស-២១ ។

ខ្ញុំបានត្រៀមសំណួរជាច្រើនដើម្បីសួរ ឌុច ។ នៅពេលកំពុងរៀបចំសំណួរ ខ្ញុំមានការរំពឹងទុកជាច្រើនពី ឌុច ។ ការរំពឹងទុកដំបូងរបស់ខ្ញុំគឺថា ឌុច នឹងរៀបរាប់យ៉ាងវែងអន្លាយក្នុងចម្លើយដែលគាត់នឹងឆ្លើយមកខ្ញុំ ដូចរបៀបដែលគាត់ឆ្លើយនៅអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា កាលពីឆ្នាំ២០០៩ដែរ ។ ខ្ញុំក៏រំពឹងទុកដែរថា គាត់នឹងនៅចាំមុខជនរងគ្រោះរបស់គាត់ ដោយសារតែគាត់ជាមនុស្សដែលមានការចងចាំល្អ ស្តែងចេញតាមរយៈការធ្វើសក្ខីកម្មរបស់គាត់ នៅក្នុងសវនាការ ។ បន្ថែមពីលើនោះ ខ្ញុំក៏រំពឹងដែរថា គាត់នឹងបង្ហាញពីវិប្បដិសារី ឬក៏សុំការអាធ្យាស្រ័យពីជនរងគ្រោះ និងគ្រួសារតាមរយៈការសម្ភាសនេះដែរ ។ ចុងក្រោយ ខ្ញុំរំពឹងថា ខ្ញុំនឹងអាចយល់បានច្បាស់លាស់ជាងមុនពីភាពស្មោះត្រង់របស់គាត់ក្នុងពេលគាត់និយាយ ។ ជាទូទៅ ការរំពឹងទុករបស់ខ្ញុំចំពោះ ឌុច មានលក្ខណៈវិជ្ជមានច្រើន ។

នៅថ្ងៃនោះ ខ្ញុំ និងសហជីវិនរបស់ខ្ញុំឈ្មោះ អេង កុកថាយ បានត្រៀមខ្លួនរួចជាស្រេចដើម្បីទៅជួប ឌុច ។ កុកថាយ បានរៀបចំម៉ាស៊ីនថតរូប និងវីដេអូរួចជាស្រេច ដើម្បីត្រៀមថតកិច្ចសម្ភាសរវាងខ្ញុំ និង ឌុច និងការថតរូប ។ កុកថាយ បានត្រៀមលក្ខណៈរួចរាល់ ។ នេះជាឱកាសតែមួយគត់ក្នុងការជួប ឌុច ដោយផ្ទាល់ ដូច្នេះយើងបាន



ឌុច កំពុងពិនិត្យមើលឯកសារប្រវត្តិរូបអ្នកទោសបស្ចិមប្រទេសពីរនាក់ដែលផ្តល់ជូនដោយ ស៊ីរិ សាវីណា (ឆ្វេង) ។ គ្រាន់តែឃើញប្រវត្តិរូបអ្នកទាំងពីរភ្លាម ឌុច មិនទទួលស្គាល់អ្នកទោសទាំងពីរនាក់នេះថាធ្លាប់ជាប់នៅមន្ទីរស-២១ឡើយ



អ្នកទោសបស្ចិមប្រទេសទាំងពីរនាក់ដែល ឌុច មិនស្គាល់ពីអត្តសញ្ញាណ

រៀបចំយ៉ាងយកចិត្តទុកដាក់ដើម្បីកុំឲ្យថ្លោះធ្លោយជាពិសេសឱកាសក្នុងការថតរូប និងថតសំឡេង ។ កុកថាយ ជាមនុស្សចូលចិត្តថតរូបណាស់ ។ ឌុច ក៏ដូច្នេះដែរ ។ ក្រោយមក ឌុច ប្រាប់ខ្ញុំថា គាត់ចូលចិត្តថតរូប និងគូរគំនូរទោះជាគាត់គ្មានពេលធ្វើវាច្រើនក៏ដោយ ។ ឌុច ប្រាប់ខ្ញុំទៀតថា គាត់ធ្លាប់មានម៉ាស៊ីនថតរូបមួយគ្រឿងម៉ាកអូឡាំភើស និងជើងទ្រម៉ាស៊ីនថតមួយដែលគាត់ប្រើប្រាស់ដើម្បីថតរូបខ្លួនគាត់ រូបគ្រួសារ គាត់ និងអ្នករួមការងារគាត់ ។ រូបមួយចំនួនដែលសល់មកដល់សព្វថ្ងៃដូចជារូបរបស់គាត់ថតជាមួយមិត្ត សុខ នៅមុខផ្ទះក៏ជារូបដែលគាត់ថតដោយខ្លួនឯងដែរ ។ រឿងនេះធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើលដែរព្រោះចំណង់ចំណូលចិត្តរបស់គាត់ស្រដៀងគ្នាទៅនឹងមនុស្សធម្មតាទូទៅដែរ ។

អ្វីដែលគាត់ប្រាប់ខ្ញុំមុនគេក្នុងជំនួបរយៈពេលពីរម៉ោងនេះគឺការតាមរករូបថតគ្រួសារគាត់ដែលក្នុងនោះមានរូបប្រពន្ធគាត់ និងកូនស្រីច្បងគាត់ ។ ឌុច ព្យាយាមស្វែងរករូបថតនេះតាំងពីគាត់ឃើញរូបនេះបោះពុម្ពនៅក្នុងកាសែតថៃមួយកាលពីទសវត្សរ៍៨០ ពេលដែលគាត់រស់នៅជំរំតាមបណ្តោយព្រំដែនថៃ ។ តាមអ្វីដែលគាត់ប្រាប់ខ្ញុំគាត់បានព្យាយាមតាមរករូបថតនេះពីរបីដងមកហើយ ។ ឌុច ធ្លាប់សួររិទ្ធីប៉ាន់ ជាផលិតករភាពយន្តខ្មែរសញ្ជាតិបារាំងម្នាក់ឲ្យជួយរករូបថតនេះដើម្បីផ្ញើមកគាត់ ។ ពេលជួបខ្ញុំ ឌុច បានសុំឲ្យខ្ញុំនិងមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរករូបថតនេះឲ្យគាត់ទៀត ។ គាត់ប្រាប់ខ្ញុំថា ប្រពន្ធគាត់ស្លាប់បាត់ហើយ ដូច្នេះគាត់ចង់រក្សារូបថតនេះទុកដើម្បីឲ្យការចងចាំអំពីប្រពន្ធគាត់ នៅមានជីវិត ។ ខ្ញុំរំជួលចិត្តពេលឮដូច្នេះ ។ ខ្ញុំគិតថា ជនដែលឈាមត្រជាក់ម្នាក់ដែលទទួលខុសត្រូវចំពោះការស្លាប់របស់ជនរងគ្រោះប្រហែល១៤.០០០នាក់នៅមន្ទីរស-២១នៅតែចង់រក្សាការចងចាំពីគ្រួសាររបស់គាត់ ។ គាត់ក៏ប្រហែលជាយល់ពីអារម្មណ៍របស់ជនរងគ្រោះដែលចង់ស្វែងរកព័ត៌មានទាក់ទងនឹងសាច់ញាតិបងប្អូនដែលបាត់ខ្លួននៅស-២១ដែរមើលទៅ ។ សម្តីគាត់ធ្វើឲ្យខ្ញុំអាចប៉ាន់ស្មានបានថា ទោះបីជាយ៉ាងណាក៏ដោយ គាត់ក៏ជាមនុស្សម្នាក់ដែរ គាត់ប្រហែលជាអាចបង្ហាញពីទឹកចិត្តស្រឡាញ់ ការស្តាយក្រោយ ការអាណិត និងអារម្មណ៍ថាមានកំហុសចំពោះមនុស្សទូទៅ ។

ពេលយើងទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងបានឆ្លងកាត់ការត្រួតពិនិត្យសន្តិសុខនិងចុះឈ្មោះក្នុងឯកសាររដ្ឋបាលមួយចំនួន បន្ទាប់មកមន្ត្រីតុលាការបាននាំយើងទៅបន្ទប់មួយ ។ បន្ទប់នោះតូចមានទំហំប្រហែលពីរម៉ែត្របួនជ្រុង លាបពណ៌សទាំងខាងក្រៅនិងខាងក្នុង ។ បន្ទប់នេះប្រើប្រាស់ដើម្បីទទួលភ្ញៀវបណ្តោះអាសន្ន ។ ជាប់នោះមានបន្ទប់មួយដែលមានទំហំប៉ុនគ្នាប្រើប្រាស់ជាការិយាល័យសម្រាប់ប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ បន្ទប់នោះមានធំល្មមសម្រាប់តែដាក់មនុស្សបីបួននាក់និងសម្ភារៈយើងប៉ុណ្ណោះ ។ យើងរៀបនឹងឈានជើងចូលបន្ទប់នោះស្រាប់តែ ឌុច លេចចេញពីកន្លែងណាមួយមកដើរចូលទៅក្នុងបន្ទប់មុនយើងដោយមានអ្នកយាមពីរនាក់ដើរអមគាត់មកជាមួយផង ។ បន្ទប់នោះមានតែតុមួយកៅអីប្រាំ និងម៉ាស៊ីនត្រជាក់មួយ ។

ឌុច បានចូលទៅអង្គុយនៅលើកៅអីមួយ ហើយមានអ្នកយាមនៅសងខាងគាត់ ពេលនោះ ខ្ញុំ និង កុកថាយ កំពុងតែរៀបចំ

សម្ភារថតនិងឯកសារ ។ ខ្ញុំអង្គុយចុះណែនាំខ្លួនខ្ញុំនិងពន្យល់គាត់ពីគោលបំណងនៃការសម្ភាសន៍ ។ ឆ្លៀតពេលនោះ កុកថាយ ក៏បានណែនាំខ្លួនគាត់ដែរ ។ កុកថាយ ប្រាប់ ឌុច ថាគាត់ជាអ្នកស្រុកជីក្រែង ហើយកើតនៅក្នុងគ្រួសារកូនកាត់ចិនមួយ ។ កុកថាយ មានបំណងចង់ទាញការចាប់អារម្មណ៍របស់ ឌុច ដែលគាត់ក៏មានប្រភពចេញមកពីគ្រួសារកូនកាត់ចិនដែរ ។ កុកថាយ បន្ថែមទៀតថា គាត់ធ្លាប់ទៅលេងផ្ទះ ឌុច នៅស្រុកស្ទោង ខេត្តកំពង់ធំ ។ ឌុច សួរមកវិញយ៉ាងលឿនថា «តើទៅធ្វើអ្វីនៅផ្ទះខ្ញុំ?» ឃើញ ឌុច សួរមកយ៉ាងលឿនដូចនោះ កុកថាយ ក៏ពន្យល់ភ្លាម គាត់ធ្លាប់ទៅលេងផ្ទះ ឌុច ដើម្បីចង់ទៅស្គាល់គ្រួសារ ឌុច ហើយម្យ៉ាងទៀតភូមិ ឌុច ស្ថិតនៅតាមផ្លូវពីជីក្រែងមកភ្នំពេញដែលធ្វើឲ្យគាត់ងាយស្រួលឆ្លងកាត់ហើយចូលលេង ។ ខ្ញុំឆ្ងល់ថាហេតុអ្វី ឌុច សម្តែងអាកប្បកិរិយាបែបនេះ ។ គាត់ប្រហែលជាភ្លេចថា មានមនុស្សជាច្រើនស្គាល់គាត់និងតួនាទីរបស់គាត់នៅគុកស-២១ ។ ចំពោះខ្ញុំរឿងនេះ វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ព្រោះមនុស្សម្នាក់ៗតែងតែមានការខ្វល់ខ្វាយចំពោះឪពុកម្តាយនិងគ្រួសារខ្លួន ។ ខ្ញុំយល់ថា មនុស្សម្នាក់មានការអាណិតអាសូរនិងសណ្តានចិត្ត ។ ទោះបីគាត់ជាឧក្រិដ្ឋជនដែលធ្លាប់សម្លាប់មនុស្សមិនរើសមុខ ហើយដែលត្រូវបានកាត់ទោសតាមច្បាប់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិយ៉ាងណា ក៏ខ្ញុំនៅតែព្យាយាមដាក់ចិត្តគិតថាគាត់នៅតែជាមនុស្ស ។ ពេលជួបគាត់ ខ្ញុំគិតពីភាពជាមនុស្សរបស់គាត់ដែរ ។

ពេលដែលយើងរៀបចំរួចរាល់ហើយ ខ្ញុំបានបង្ហាញរូបថតមួយចំនួនទៅគាត់ ហើយសង្ឃឹមថា គាត់នឹងលាតត្រដាងនូវព័ត៌មានមួយចំនួន ។ ដំបូង ខ្ញុំបានដកចេញនូវរូបថតរបស់ជនរងគ្រោះបស្ចិមប្រទេសពីរនាក់មកបង្ហាញគាត់ ។ ខ្ញុំសួរគាត់ថា តើគាត់ស្គាល់ឬចាំបានអ្នកនៅក្នុងរូបថតនេះទេ ។ បន្ទាប់ពីគាត់ពិនិត្យមើលរូបថតមួយសន្ទុះ គាត់ក៏និយាយថា «រូបថតពួកបស្ចិមប្រទេសមានតែបួននាក់ទេដែលចូលមកស-២១ ។ ក្នុងរូបថតទាំងអស់ហ្នឹង នួន ជា ហាមមិនឲ្យទុកទេ ឲ្យដុតទាំងរូបថតចោលទៅទៀត» ។ ឌុច និយាយថា គាត់ទុករូបថតបានមួយសន្លឹកដែលរូបនោះ គាត់ពិពណ៌នាថា ជា «រូបអង្គុយជាប់ខ្នោះជើង» ។ បន្ទាប់មកគាត់បន្ថែមទៀតថា រូបថតជនបរទេសបស្ចិមប្រទេសនៅមន្ទីរស-២១ទាំងពីរនាក់នេះ គាត់មិនដែលឃើញទេ ។ គាត់បានបន្ថែមទៀតថា នៅស-២១ អ្នកទោសស្លៀកពាក់ត្រឹមត្រូវ ហើយមានពាក់ផ្លាកលេខ ។ ឌុច បានប្រាប់ខ្ញុំទៀតថា រូបថតដែលមិនមានបង្ហាញអ្នកទោសពាក់ផ្លាកលេខ ឬស្លៀកពាក់ខោអាវអ្នកទោសមិនមែនជារូបដែលមកពីស-២១ទេ ។ គាត់បដិសេធថា គាត់មិនដែលឃើញរូបថតទាំងនេះពីមុនមក ហើយទទួលស្គាល់ថា មានអ្នកទោសបស្ចិមប្រទេសតែបួននាក់ទេដែលជាប់នៅគុកស-២១ ហើយរូបថតអ្នកទោសទាំងអស់នោះត្រូវបានដុតបំផ្លាញអស់ហើយ ។

ឌុច មិនចងចាំមុខជនរងគ្រោះស-២១ផ្សេងទៀតដែលខ្ញុំបានបង្ហាញរូបថតទៅគាត់ទេ ។ រូបថតទាំងនោះរួមមានរូបអ្នកទោសជនជាតិបារាំងឈ្មោះ អង់ទ្រេ ហ្គាស្តុន គួទីញ៉ោ, ជនជាតិអង់គ្លេសឈ្មោះ ចន ដឺវើស និងជនជាតិខ្មែរ ជួន ហេង ។ គាត់មិនចាំមុខជនរងគ្រោះទាំងអស់នោះ សូម្បីតែម្នាក់ ។ បើសិនជាគ្មានឯកសារមកជាមួយរូបថត ខ្ញុំសន្និដ្ឋានថាគាត់នឹងមិនទទួលស្គាល់ថា ជនរងគ្រោះទាំងអស់នោះធ្លាប់ជាប់នៅមន្ទីរស-២១នោះទេ ។ ក្នុងករណីនេះ គាត់មិនចាំទាំងមុខជនរងគ្រោះ ហើយគាត់ក៏មិនទទួលស្គាល់ថា អ្នកទាំងអស់នោះធ្លាប់ជាប់ឃុំ និងស្លាប់នៅមន្ទីរស-២១ដែរ ។ ទោះជាយ៉ាងណា ខ្ញុំនៅតែមានគំនិតវិជ្ជមាន ។ ខ្ញុំបន្តសួរគាត់បន្តទៀត តើគាត់មានបំណងចង់ផ្តាំផ្ញើអ្វីទៅកាន់គ្រួសារជនរងគ្រោះនៅក្នុងរូបថតនេះទេ ។ គាត់បង្ហាញនូវអកប្បកិរិយាថា គាត់គ្មានបំណងចង់រំលែកទុក្ខគ្រួសារជនរងគ្រោះនៅក្នុងរូបថតនោះទេ ។ គាត់បញ្ជាក់ថា «ខ្ញុំបានសម្តែងការសូមអភ័យទោសខ្ញុំនៅក្នុងសេចក្តីថ្លែងការណ៍នៅសវនាការរួចរាល់អស់ហើយ ខ្ញុំជឿជាក់ថា សេចក្តីសូមអភ័យទោសរបស់ខ្ញុំបានផ្សព្វផ្សាយជាសាធារណៈរួចហើយ» ។ ខ្ញុំរំពឹងថា គាត់នឹងថ្លែងនូវពាក្យសូមទោស និងការសូមអាធ្យាស្រ័យពីប្រជាជនខ្មែរម្តងទៀត ។ ទោះបីជាប្រជាជនកម្ពុជាគ្មានទម្លាប់ក្នុងការសុំទោសដោយពាក្យសម្តីទៅកាន់អ្នកដែលយើងធ្វើខុសជាមួយក៏ដោយ ចំពោះករណី ឌុច ខ្ញុំគិតថាគាត់មានអត្តចរិតខុសពីប្រជាជនខ្មែរទូទៅ ។ បើតាមខ្ញុំគិត ការដែលគាត់មិនចង់សម្តែងចេញនូវការទទួលកំហុសធ្វើឲ្យខ្ញុំនឹកឃើញដល់ពេលដែលគាត់ធ្វើជាប្រធានមន្ទីរស-២១ ។ ឌុច ធ្វើឲ្យខ្ញុំលែងជឿទៅលើពាក្យសូមអភ័យទោសរបស់គាត់ ។

ក្នុងពេលដែលយើងសន្ទនាគ្នា គាត់បង្ហាញថា គាត់ចង់រក្សា

ទុកនូវអនុស្សាវរីយ៍ល្អៗជាមួយគ្រួសារគាត់ ។ គាត់ឲ្យតម្លៃទៅលើអនុស្សាវរីយ៍ជាមួយអ្នកដែលគាត់ស្រឡាញ់ ។ ខ្ញុំឆ្ងល់ថា គាត់មានដែលនឹកឃើញថា រឿងនេះវាសំខាន់សម្រាប់អ្នកដទៃទៀតដែរឬទេ ជាពិសេសចំពោះជនរងគ្រោះ ។ ខ្ញុំគ្មានអារម្មណ៍ថា គាត់មានការអាណិតអាសូរដោយស្មោះត្រង់ចំពោះជនរងគ្រោះសោះ ។ ចំណុចនេះ ធ្វើឲ្យខ្ញុំនៅមានការសង្ស័យពីការសុំអភ័យទោសចំពោះជនរងគ្រោះដែលគាត់បានធ្វើនៅសវនាការ ។ ខ្ញុំយល់ថា ការសម្តែងនូវវិប្បដិសារីរបស់គាត់ខ្វះនូវភាពស្មោះត្រង់ និងភាពជឿជាក់ ។

នៅចុងបញ្ចប់នៃការសន្ទនារបស់យើង ខ្ញុំព្យាយាមសួរគាត់ពីមូលហេតុដែលបណ្តាលឲ្យគាត់ចង់ជួយខ្ញុំក្នុងការស្វែងរកអត្តសញ្ញាណរូបថតទាំងអស់នោះ ។ ចម្លើយរបស់គាត់ខុសពីការរំពឹងទុករបស់ខ្ញុំ ។ គាត់ឆ្លើយថា «ខ្ញុំគឺជាអ្នកនយោបាយ ខ្ញុំហ៊ានធ្វើ ខ្ញុំហ៊ានទទួលខុសត្រូវ ។ ខ្ញុំធ្វើខុស ខ្ញុំហ៊ានទទួលថាខុស ។ ដូច្នេះដើម្បីឲ្យប្រាកដថា ខ្ញុំខុសប៉ុណ្ណា យើងត្រូវតែរកខុសត្រូវទាំងអស់គ្នា» ។ គ្មានសម្តីណាមួយដែល ឌុច បញ្ជាក់ថាគាត់ធ្វើនេះដើម្បីជនរងគ្រោះទេ ។ ចំណុចនេះសំខាន់សម្រាប់ជនរងគ្រោះប៉ុណ្ណោះ វាមិនសំខាន់សម្រាប់គាត់ទេ ។ បន្ទាប់ពីបញ្ចប់ឃ្លានេះមក គាត់ក៏ផ្ទុះសំណើចឡើង ។ សំណើចរបស់គាត់ ធ្វើឲ្យខ្ញុំមានអារម្មណ៍មិនសូវស្ងប់ក្នុងការបន្តសំណួរខ្ញុំតទៅទៀតឡើយ ។ ចុងក្រោយ នៅពេលខ្ញុំសួរគាត់ថា តើគាត់ចង់ឲ្យប្រជាជនខ្មែរអធ្យាស្រ័យឲ្យគាត់ឬទេ? គាត់បែរជាឆ្លើយថា «នេះជារឿងមួយដោយឡែក» ។ ការសន្ទនាជាមួយ ឌុច ធ្វើឲ្យខ្ញុំមានការខកចិត្តជាជាងធ្វើឲ្យខ្ញុំអាណិតអាសូរគាត់ ។ ក្នុងនាមជាមនុស្សម្នាក់ក្រោយពីបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋជាច្រើន ឌុច មើលទៅដូចជានៅតែស្ទាក់ស្ទើរក្នុងការបង្ហាញពីការសោកស្តាយរបស់គាត់ទៅកាន់គ្រួសារជនរងគ្រោះ ។ ឌុច ធ្វើឲ្យខ្ញុំមានអារម្មណ៍ច្បាស់ក្នុងចិត្តថា ខ្ញុំមានការរំពឹងទុកខុសហើយ ធ្វើឲ្យខ្ញុំមានការស្ទាក់ស្ទើរក្នុងការទទួលយកភាពជាមនុស្សរបស់ជនដែលដូចជារូបគាត់ ។

**ស៊ីរ៉ា សាវីណា**



ឌុច សម្តែងកាយវិការពេលនិយាយអំពីមន្ទីរស-២១



## គ្រួសារថ្នាក់ដឹកនាំមន្ទីរ ស-២១ (គុកទួលស្លែង)

អ្នកនៅក្នុងរូបថតនេះគឺជាថ្នាក់ដឹកនាំរបស់មន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានថតក្នុងអំឡុងឆ្នាំ១៩៧៦ ក្នុងបរិវេណមន្ទីរនេះ ។ អ្នកទាំងនេះគឺជាបុគ្គលដែលមានអំណាចខ្លាំងជាងគេនៅក្នុងបរិវេណមន្ទីរដ៏សម្ងាត់មួយនេះ ។ រូបឈរជួរខាងក្រោយ ផ្នែកបុរសនៅខាងឆ្វេងបំផុតគឺ ម៉ម ណៃ ហៅ ចាន់ ដែលជាប្រធានផ្នែកសួរចម្លើយ ។ ចាន់ គឺជាអ្នកសួរចម្លើយអ្នកទោសដែលជាអតីតមន្ត្រីនៃរបបចាស់ អតីតកម្មាភិបាលខ្មែរក្រហម អ្នកទោសមកពីបស្ចិមប្រទេសនិងអ្នកទោសជនជាតិវៀតណាមផ្សេងទៀត ។ ជាអតីតគ្រូបង្រៀនក្នុងរបបសង្គមរាស្ត្រនិយមនិងសព្វថ្ងៃរស់នៅខេត្តបាត់ដំបង ចាន់ បានចូលខ្លួនមកធ្វើសក្ខីកម្មនៅសាលាក្តីខ្មែរក្រហមកាលពីឆ្នាំ២០០៩ ហើយបានអះអាងថា គាត់មិនចាំរឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរស-២១ទេ ។ រូបទីពីររាប់ពីខាងឆ្វេងគឺ អ៊ិន លន ហៅ ណាត ដែលជាអតីតប្រធានមន្ទីរស-២១នេះមុនឌុច ចូលមកជំនួស ។ លេខ២១គឺជាកន្ទុយលេខអាយកូមទាក់ទងរបស់ ណាត ។ ឌុច បានឡើងធ្វើជាប្រធានមន្ទីរស-២១ក្រោយពេលដែល ណាត ត្រូវបានផ្លាស់ទៅធ្វើជាអគ្គលេខាធិការរងនៃក្រសួងការពារជាតិជាមួយ សុន សេន ។ ចំណែករូបទីបីរាប់ពីឆ្វេងគឺ ឌុច ដែលកាលនោះមានអាយុជាងសាមសិបឆ្នាំបន្តិច និង ប្រពន្ធរបស់គាត់ឈ្មោះ ឈឹម សុផល ហៅ រុំ ដែលកំពុងឈរនៅពីមុខ ។ ចំណែកម្នាក់ទៀតគឺជា យូ ប៉េងគ្រី ដែលជាអ្នកបើកបររថយន្តដឹកអ្នកទោសទៅជើងឯកដើម្បីសម្លាប់ ។ រូបស្ត្រីដែលឈរនៅពីមុខគឺជាប្រពន្ធរបស់បុរសនីមួយៗដែលឈរនៅពីក្រោយ ។

**ញាណ សុជាតិ**

# ចម្លើយសារភាពរបស់ ឡាច វ៉ារី ហៅ ណាន ប្រធានក្រុមពេទ្យក្រសួងការបរទេស

### អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព J00៧៨១

ឡាច វ៉ារី ហៅ ណាន មាននាទីជាប្រធានក្រុមពេទ្យក្រសួងការបរទេស ត្រូវបានអង្គការចាប់ដោយសារតែមានការជាប់ទាក់ទងជាមួយនឹងភ្នាក់ងារសេ.អ៊ី.អា ក្នុងការលាក់កម្លាំងវៀតណាម, ថ្នាំពេទ្យ និងអាវុធដើម្បីធ្វើរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជាដែលគ្រោងធ្វើនៅខែមេសា ឆ្នាំ១៩៧៨ ។

ឡាច វ៉ារី ហៅ ណាន ត្រូវបានសួរចម្លើយពីរលើកសរុបចំនួនម្ភៃប្រាំពីរទំព័រ ដោយមាននារី ម៉ុត ជាអ្នកសួរចម្លើយ ។ លើកទីមួយធ្វើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៨ ដែលនិយាយអំពីសកម្មភាពលាក់កម្លាំងវៀតណាម និងលើកទីពីរ ធ្វើនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៨ និយាយពីខ្សែសន្ទាក់ និងសកម្មភាពក្បត់ទូទៅរហូតដល់ថ្ងៃចាប់ខ្លួន ដោយបានរៀបរាប់លម្អិតពីឈ្មោះអ្នកដែលចូលរួមក្នុងសកម្មភាពក្បត់ចំនួន៤៩នាក់ និងកន្លែងដែលលាក់កម្លាំងវៀតណាម ថ្នាំពេទ្យ និងអាវុធដោយភ្ជាប់ជាមួយនឹងប្លង់ទីកន្លែងទាំងនោះ ។ ចំពោះថ្ងៃខែជាក់លាក់ក្នុងការចាប់ខ្លួនមិនបានបញ្ជាក់ច្បាស់លាស់ទេ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ឡាច វ៉ារី ៖

ខ្ញុំសូមរាយការណ៍ជូនអង្គការអំពីប្រវត្តិសកម្មភាពរបស់ខ្ញុំប្រឆាំងបដិវត្តន៍តាំងពីដើមរហូតដល់អង្គការចាប់ខ្លួន ។ ខ្ញុំឈ្មោះ ឡាច វ៉ារី ហៅ ណាន ភេទនារី អាយុ៣៣ឆ្នាំ ស្រុកកំណើតនៅភូមិវត្តគ ឃុំវត្តគ ស្រុកសង្កែ ខេត្តបាត់ដំបង តំបន់៣ ភូមិភាគពាយ័ព្យ (បញ្ជាក់៖ ភូមិវត្តគ ជាភូមិកំណើតរបស់ នួន ជា) ។

នៅឆ្នាំ១៩៦១ ខ្ញុំមានអាយុ១៦ឆ្នាំ រៀននៅអនុវិទ្យាល័យនេតយ៉ង់បាត់ដំបង ដល់ថ្នាក់ទី៣ទំនើប ។ នៅពាក់កណ្តាលឆ្នាំ១៩៦១ គ្រួសារខ្ញុំទាំងអស់ទៅនៅប្រទេសចិន ។

ឆ្នាំ១៩៧១ ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់មកខ្ញុំទៅនៅមន្ទីរពេទ្យ«ព.៩» បានមួយរយៈបានខូចខ្លួនជាមួយបងសាត បច្ចុប្បន្នចាប់ខ្លួន និងឈ្មោះ អាន អតីតសាស្ត្រាចារ្យ បច្ចុប្បន្នអនុប្រធានពាណិជ្ជកម្មភាគកណ្តាល ។ អ្នកទាំងពីរនេះ ខ្ញុំបានខូចជាមួយជាញឹកញាយ ។ បងសាត និងអាន បានអប់រំខ្ញុំឲ្យចូលធ្វើជាសេ.អ៊ី.អា ហើយណែនាំខ្ញុំថា ដើម្បីប្រមូលកម្លាំងបានត្រូវតែលះបង់ខ្លួន ។ ក្រោយមក អ្នកទាំងពីរបានខទ្មេសនាមឲ្យរួមសកម្មភាពជាមួយខ្សែរបស់គាត់ចំនួនប្រាំបួននាក់ផ្សេងទៀត ។ ខ្ញុំនៅជាប់ទាក់ទងខ្សែចាស់រហូតដល់ឆ្នាំ១៩៧៥ ក្រោយរំដោះទូទាំងប្រទេស បងសាត និងបងអាន កសាងកម្លាំងបាន១២នាក់ថែមទៀត ។ ចុងឆ្នាំ១៩៧៥ បងសាត ខទ្មេសនាមខ្ញុំឲ្យទាក់ទងធ្វើសកម្មភាពជាមួយខ្សែគាត់ចំនួនដប់ប្រាំនាក់ទៀត ហើយកម្លាំងដែលខ្ញុំកសាងបានតាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ មានសរុប១១នាក់ ។

នៅខែធ្នូ ឆ្នាំ១៩៧៧ បងស៊ុន នាទីប្រធានសមាជិកក្រសួងការបរទេស បានហៅខ្ញុំទៅប្រជុំនៅផ្ទះទី២ ចំពោះអ្នកចូលរួមប្រជុំខ្ញុំឃើញមានប្រាំមួយនាក់ រួមទាំងខ្ញុំ ។

១.បងសែ អតីតគ្រូបង្រៀន បច្ចុប្បន្នប្រធានផ្នែកការិយាល័យក្រសួងការបរទេស

២.បងផុស អតីតគ្រូបង្រៀន បច្ចុប្បន្នប្រធានផ្សាររដ្ឋក្រសួងការបរទេស

៣.បងជឿន អតីតតស៊ូ បច្ចុប្បន្នប្រធានមន្ទីរ«ប-១» ក្រសួងការបរទេស

៤.បងវ៉ែន អតីតគ្រូបង្រៀនបច្ចុប្បន្នអង្គការចាប់ហើយ

៥.បងស៊ីន អតីតសិស្សថ្នាក់ទី៧ បច្ចុប្បន្នប្រធានសមាជិកក្រសួងការបរទេសនិងដោយឡែកប្រធានផ្ទះទី២ ។

ជួបជុំគ្នាហើយ បងស៊ីន និយាយអំពីផែនការធ្វើរដ្ឋប្រហាររំលំបក្សកុម្មុយនីស្តកម្ពុជាគ្រោងធ្វើនៅខែមេសា ឆ្នាំ១៩៧៨ តែដើម្បីឲ្យសម្រេចផែនការនេះខ្ញុំស្នើឲ្យរៀបចំកម្លាំងនិងរៀបចំផ្ទះឲ្យស្ងាត់លាក់ការណ៍ឲ្យជិតកុំឲ្យអ្នកណាដឹងក្រៅពីកម្លាំងដែលយើងទុក

ចិត្តឲ្យសោះ ព្រោះបើកាលណាដឹងច្រើនគ្នានាំឲ្យបែកការណ៍ ហើយបញ្ហាស្បៀង បើខ្វះត្រូវទាក់ទងជាមួយ បងផុស ។ ចំពោះកម្លាំងដែលយើងយកមកលាក់នេះគឺបងប៉ង់ គាត់បម្រុងឲ្យមកដើម្បីសហការជាមួយគ្នាវាយបក្សកុម្មុយនីស្ត ។ បងស៊ីន សួរ បងសែ ថាចុះអាវុធទុកដាក់យ៉ាងម៉េចហើយ បងសែ ឆ្លើយថា ខ្ញុំរៀបចំរួចហើយ ចុះបងណានឯង មានការរៀបចំថ្នាំពេទ្យយ៉ាងម៉េចហើយ ខ្ញុំឆ្លើយថា ខ្ញុំបានរៀបចំបានមួយចំនួនហើយ តែមិនគ្រប់គ្រាន់ទេ ។ បងស៊ីន ថាមិនអីទេ ចាំទៅទាក់ទងខាង បងសា និងបងប៉ង់ ថែមទៀត រួចហើយក៏បែកគ្នាទៅ ។ ពេលខ្ញុំមកដល់កន្លែង ខ្ញុំក៏សម្រេចថាយកកន្លែងដាក់ថ្នាំពេទ្យ ពីព្រោះកន្លែងនេះស្ងាត់ ។

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ បងស៊ីន បានហៅខ្ញុំទៅប្រជុំនៅផ្ទះទី៣ អ្នកចូលរួមប្រជុំឃើញ មានៈ

១.បងស៊ីន ប្រធានសមាជិកក្រសួងការបរទេស

២.បងសែ ប្រធានការិយាល័យ

៣.បងជឿន ប្រធានមន្ទីរ“ប.១” ក្រសួងការបរទេស

៤.បងវ៉ែន ផ្នែកការិយាល័យក្រសួងការបរទេស

៥.បងផុស ប្រធានផ្សាររដ្ឋ ក្រសួងការបរទេស

ជួបជុំគ្នាហើយ បងស៊ីន បើកប្រជុំក្នុងសភាពប្រញាប់ប្រញាល់ ហើយគាត់និយាយថា កម្លាំងដែល បងប៉ង់ បានប្រគល់ឲ្យយើងនេះមកដល់ហើយ មានចំនួន១៨នាក់ ហើយមកដល់យប់នេះត្រូវយកទៅទុកកន្លែងដែលយើងរៀបចំពីថ្ងៃមុន តែសំខាន់ត្រូវឲ្យសម្ងាត់ កុំឲ្យបែកការណ៍ ហើយពីរឿងបាយទឹក បើមិត្តណាដោះស្រាយមិនចេញទេ ត្រូវទាក់ទងជាមួយ បងផុស ព្រោះគាត់ក្តាប់ស្បៀងស្រាប់ហើយ តែបើដោះស្រាយបានហើយ មិនបាច់ទៅទាក់ទងជាមួយគាត់ទៀតទេ ហើយខាងណាត្រូវយកកម្លាំងយួនប៉ុន្មាននាក់ចាំជម្រាបតាមក្រោយប្រជុំចប់ បងស៊ីន ហៅម្នាក់ម្តងទៅប្រាប់ ។ ប្រាប់មិត្តដទៃរួចហើយ បងស៊ីន បានហៅខ្ញុំទៅខាងក្រោយ ប្រាប់ខ្ញុំថា កម្លាំងយួននេះប្រគល់ឲ្យខ្ញុំបួននាក់ នៅម៉ោង១១យប់នេះស្នើខ្ញុំមកជួបនៅខាងលិចផ្ទះដែលខ្ញុំនៅ ។

នៅម៉ោង១១យប់ ខ្ញុំក៏ទៅខាងលិចផ្ទះខ្ញុំ ហើយក៏បានជួបបងស៊ីន ខ្ញុំសួរគាត់ថាមកដល់ហើយឬនៅបង? គាត់ឆ្លើយថា មកដល់ហើយត្រូវទទួលយកនៅពេលនេះ ។ បងស៊ីន បានប្រាប់ខ្ញុំថាយួនទាំងអស់នេះត្រូវហៅ តែលេខទេ មានលេខ២៣, ៣៦, ៥៦, ០៨ ហើយខ្ញុំឃើញយួនបួននាក់នេះស្លៀកពាក់ខោអាវខ្មៅ ។ ខ្ញុំក៏នាំយួនបួននាក់នេះទៅតាមផ្លូវក្រោយផ្ទះខ្ញុំ ពេលទៅដល់ចូលតាមច្រករបងក្រោយផ្ទះចេញពីច្រករបងនោះដល់ឃ្លាំងថ្នាំ និងកន្លែងលាក់នៅជាប់គ្នា ។ ពេលទៅដល់ ខ្ញុំក៏និយាយប្រាប់ថា បើខ្ញុំមក ខ្ញុំបើកទ្វារដែកនេះបីដងជាសញ្ញា ហើយខ្ញុំក៏នាំចូលទៅក្នុងឃ្លាំងផ្ទះក្រោមដី ។ យួនដែលមានលេខទាំងអស់នោះឈ្មោះ ហាយ លេខ២៣ចេះខ្មែរតិចៗ, ថាញ់ លេខ៥៦, សឺន លេខ៣៦, មិញ លេខ៨ ។

យួននេះ ឃើញមានតែកាំភ្លើងខ្លីម្នាក់មួយដើម និងគ្រាប់បែកគ្រប់ៗគ្នា ។ ក្រោយពីយកពួកយួននេះទៅលាក់ហើយ ខ្ញុំក៏បានយកបាយទៅឲ្យគ្រប់ពេល ហើយបានខូចជាមួយយួននោះជាបន្តបន្ទាប់ក្នុងមួយថ្ងៃពីរនាក់ ។ ពេលខ្លះខ្ញុំដាក់បាយក្នុងកញ្ជើ ហើយយកសំបកថ្នាំពេទ្យដាក់ពីលើ ពេលខ្លះខ្ញុំដាក់ក្នុងស្បោងថ្នាំពេទ្យធ្វើជាទៅយកថ្នាំពេទ្យ ។ បញ្ហាដោះស្រាយបាយនេះ គឺពេលដែលខ្ញុំយកបាយឲ្យអ្នកសម្រាលកូនក៏យកលេសថា អ្នកសម្រាលកូនហូបបាយច្រើនណាស់ ពេលខ្លះខ្ញុំយកផ្លែឈើទៅឲ្យយួនផង ។ ខ្ញុំបានយកយួនទៅទុកបានបីថ្ងៃ បានបង ស៊ីន មកមើលកន្លែងដែលលាក់យួន ។

នៅថ្ងៃ១២ ខែមករា ឆ្នាំ១៩៧៨ បងស៊ីន ឲ្យខ្ញុំមកទាក់ទងបងសា ប្រធានមន្ទីរផលិតថ្នាំបូរាណ “ផ.១” និងបងប៉ក់ ប្រធានមន្ទីរផលិតថ្នាំសម័យ“ផ.៤” ឲ្យខ្ញុំសួរពីបញ្ហាថ្នាំពេទ្យដែលគាត់បានស្នើពីថ្ងៃមុនទុកសម្រាប់ពេលធ្វើរដ្ឋប្រហារវាយរំលំបក្សកុម្មុយនីស្តកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៨នេះ ។ មុនដំបូង ខ្ញុំទៅជួបបងសាខ្ញុំសួរគាត់ថា បងពីរឿងថ្នាំពេទ្យ បងស៊ីន ស្នើនោះយ៉ាងម៉េចហើយ បងសា ឆ្លើយថា បញ្ហាថ្នាំនេះខ្ញុំបានរៀបចំរួចហើយ នៅតែពេលបងស៊ីនដឹកទៅទេ ហើយ បងស៊ីន ឲ្យសួរអំពីកម្លាំងនៅខាងបងឯងយ៉ាងម៉េចដែរ បងសា ឆ្លើយថា កម្លាំងនៅខាងខ្ញុំ ខ្វះបក្សសម្រិតសម្រាំងហើយ ប៉ុន្តែកម្លាំងដែលនៅសល់គឺពង្រីកតទៅទៀត ដើម្បីសម្រេចផែនការរដ្ឋប្រហារវាយរំលំបក្សកុម្មុយនីស្តបាន យើងត្រូវសហការគ្នាឲ្យខ្លាំងក្លាថែមទៀត ។

នៅខែមករា ឆ្នាំ១៩៧៨ដដែល ខ្ញុំបានទាក់ទង បងប៉ក់ ហើយសួរថា បងស៊ីន ឲ្យសួរបងឯងអំពីថ្នាំពេទ្យដែលគាត់ទាក់ទងជាមួយបងឯងកាលពីថ្ងៃមុននោះយ៉ាងម៉េចហើយ បងប៉ក់ឆ្លើយថា ខាងខ្ញុំ

បានរៀបចំរួច ហើយតាមការស្នើរបស់គាត់ ឲ្យគាត់មកដឹកបុះ ។ ខ្ញុំសួរថា មានថ្នាំអ្វីខ្លះ? បងប៉ក់ឆ្លើយថា ថ្នាំចាក់ក៏មាន ថ្នាំគ្រាប់ក៏មាន គឺមានថ្នាំគ្រប់មុខ ។ បងស៊ីន ឲ្យសួរបងឯងពីកម្លាំងនៅខាងបងឯង តើរៀបចំបានស្រួលហើយឬនៅ? បងប៉ក់ ឆ្លើយថា កម្លាំងខាងខ្ញុំ បក្សកំពុងតាមដាន ហើយខ្លះបែកមុខ ប៉ុន្តែអាចដំណើរការតទៅទៀត ខ្ញុំក៏បែកពីគាត់មក ។ ពេលដែលខ្ញុំមកពីទាក់ទង បងសា និងបង ប៉ក់ វិញ ខ្ញុំបានរាយការណ៍ឲ្យ បងស៊ីន អំពីសភាពការណ៍នៅមន្ទីរ “ជ.១ និងជ.៤” អំពីកម្លាំងស្នូលរបស់យើង បក្សដកចេញខ្លះហើយ កំពុងតាមដានខ្លាំងណាស់ ហើយបញ្ជូលកម្មាភិបាលថ្មីមកដឹកនាំ បក្សពួកយើងមានការលំបាកធ្វើសកម្មភាព ដូច្នេះយើងត្រូវមានផែនការប្រមូលកម្លាំងដែលនៅសល់រួមផ្សំកម្លាំងមកពីខាងក្រៅ ។

ក្រោយមក បងស៊ីន បានទៅដឹកថ្នាំពេទ្យយកមកប្រគល់ឲ្យខ្ញុំលាក់ទុក ខ្ញុំក៏បានយកថ្នាំពេទ្យនោះទៅលាក់នៅខាងក្រោមបង្គ្រានដាំបាយកន្លែងដាក់ខសនៅក្បែរបន្ទប់ត្រជាក់សម្រាប់ដាក់ថ្នាំពេទ្យរបស់អង្គការ ។ ផ្ទះនោះ គឺនៅខាងលិចផ្ទះពេទ្យក្នុងល្វែងទី២ ។ ថ្នាំមានចំនួនបួនឡាំង ខ្ញុំដាក់តម្រៀបគ្នា ហើយយកទូសំណាញ់ចាស់មកបាំងពីមុខទៀត ។ អ្នកចូលរួមលាក់ថ្នាំពេទ្យនេះមានបងស៊ីន និងយុទ្ធជនពីរនាក់ គឺ ៈ

១.មិត្ត ពៅ អតីតកូនទាហាននៅខេត្តកំពង់ធំ បច្ចុប្បន្នជាយុទ្ធជននៅផ្ទះទី២ ក្រសួងការបរទេស ។

២.មិត្ត ផន អតីតទាហាននៅក្រុងកំពង់ចាម បច្ចុប្បន្នជាយុទ្ធជននៅផ្ទះទី២ ក្រសួងការបរទេស ។

ក្នុងខែកុម្ភៈ បងសែ បានហៅខ្ញុំទៅកន្លែងគាត់ជាមួយមិត្ត ជឿនដំបូងគាត់ណែនាំអំពីបញ្ហាលាក់យួនត្រូវការលាក់ការណ៍ឲ្យបានដាច់ខាតពេលចេញចូលត្រូវប្រយ័ត្នកុំឲ្យប្រហែសឲ្យសោះ បន្ទាប់មកគាត់ និយាយ ថា បងស៊ីន ឲ្យខ្ញុំប្រគល់អាវុធឲ្យ បងណានឯង និងមិត្ត ជឿនយកទៅទុកខ្លះ ហើយចាំខ្ញុំយកទៅឲ្យនៅយប់នេះ នៅខាងមុខផ្ទះកុមារនៅម៉ោង១០កន្លះ ។ ដល់ម៉ោង១០កន្លះ ខ្ញុំក៏ទៅមុខផ្ទះកុមារឃើញបងសែ និងមិត្ត ជឿន គាត់ក៏នាំខ្ញុំទៅយកអាវុធនៅក្នុងគុម្ពចេក ។ គាត់ពីរនាក់នៅយាម ខាងក្រៅ ខ្ញុំក៏ជញ្ជូនអាវុធមាន កាំភ្លើងអាកាបីដើម កាំភ្លើងវ៉េវ៉ាដេ ពីរដើម និងគ្រាប់បែក ដប់គ្រាប់ ទៅលាក់នៅកន្លែងផងដីតក្រោមជណ្តើរចុះក្នុងឃ្លាំងនោះ ។ ខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំត្រូវទៅកន្លែងបង្កបង្កើនផល ពេលនោះ ខ្ញុំក៏ទៅផ្ទះមិត្ត ជឿន ហើយប្រាប់គាត់ ថាខ្ញុំត្រូវអង្គការដកទៅកន្លែងបង្កើនផល ហើយខ្ញុំអត់បានជួប បងស៊ីនទេ ស្នើប្រាប់ បងស៊ីន ថាកម្លាំងយួនដែលខ្ញុំលាក់នោះ ឲ្យ បងស៊ីន វិញចុះ ហើយស្នើឲ្យគាត់ចាត់តាំងកម្លាំងទៅទាក់ទងខ្ញុំផង ចំពោះរឿងអាវុធ ស្នើមិត្ត ជឿន ប្រាប់ បងសែ ផង ខ្ញុំមិនបាននៅទៀតទេ ថាអាវុធនៅក្នុងឃ្លាំងថ្នាំពេទ្យហើយ នៅក្រោមជណ្តើរចុះប្រាប់តែ ប៉ុណ្ណឹងគាត់ដឹងហើយ បញ្ហាថ្នាំពេទ្យដែលបងស៊ីន លាក់ជាមួយខ្ញុំនោះឲ្យគាត់យកទៅទុកផង ។ មិត្តជឿន ប្រាប់ខ្ញុំថា បងណានឯងទៅដល់ណាក៏ត្រូវតែបន្តធ្វើសកម្មភាពតទៅទៀត ហើយកុំភ័យ បងស៊ីន នឹងឲ្យកម្លាំងទៅទាក់ទងនៅថ្ងៃក្រោយ ។

ក្រោយមក បងស៊ីន បានឲ្យមិត្ត រឿន អតីតប៉ូលីសនៅខេត្តកំពង់ធំ បច្ចុប្បន្នជាអ្នកបើកឡាននៅក្រសួងការបរទេស និងជាខ្មែរសេ.អ៊ី.អា របស់បងស៊ីន បានយកសំបុត្រពីបងស៊ីនមកឲ្យខ្ញុំនៅស្រែ ដោយមានខ្លឹមសារថា បងស៊ីន បានខទ្ទេសនាមឲ្យខ្ញុំទៅទាក់ទងជាមួយ បងយ៉ុន អតីតស្រីបន បច្ចុប្បន្នជាអនុប្រធានកងធំនៅវត្តស្លែង និងមិត្ត រឿន អតីតកូនទាហានចាស់នៅកំពង់ចាម បច្ចុប្បន្នប្រធានក្រុមនៅវត្តស្លែង ពីរនាក់នេះជាខ្សែចាស់របស់ខ្ញុំតាំងពីដើមមក ។ បងស៊ីន បានបញ្ជាក់ថាត្រូវ យកសំបុត្រនេះទៅឲ្យ បងយ៉ុន និង រឿន មើលផង និងបានប្រាប់ថា ខ្ញុំត្រូវនៅក្រោមការដឹកនាំរបស់បងយ៉ុន ។ ពេលដែលខ្ញុំយកសំបុត្រទៅឲ្យ បងយ៉ុន មើលគាត់និយាយថា បងណានឯងនេះស្រួលហើយ តែយើងត្រូវប្រមូលកម្លាំងបន្តធ្វើសកម្មភាពតទៅទៀត ដើម្បីត្រៀមរៀបចំធ្វើរដ្ឋប្រហារនៅ ខែមេសានេះជាផែនការរបស់យើងនៅពេលនេះ ត្រូវពង្រីកកម្លាំងស្នូលរបស់យើងបន្តទៅទៀត ហើយ បងណានឯង ទៅទាក់ទងជាមួយមិត្តរឿនសិនចុះ ។ ខ្ញុំក៏បែកពីគាត់មក ហើយខ្ញុំបានជួបនឹងមិត្ត រឿន និងប្រាប់ថា បងយ៉ុន បានឲ្យខ្ញុំមកជួបមិត្តដើម្បីឲ្យស្គាល់គ្នាសិន ។ ក្រោយមក បងយ៉ុន បានហៅខ្ញុំ និង រឿន ទៅប្រជុំនៅផ្ទះគាត់ ពេលទៅដល់ខ្ញុំបានឃើញមនុស្សប្រាំនាក់នៅទីនោះមាន ៈ

១.បងយ៉ុន អតីតស្រីបន កូនចៅកែស្រូវកំពង់ចាម បច្ចុប្បន្នអនុប្រធានកងធំទី២ នៅមន្ទីរបង្កើនផលនៅវត្តស្លែង ។

២.មិត្តរឿន អតីតកូនទាហាននៅក្រុងកំពង់ចាម បច្ចុប្បន្នប្រធានក្រុមកងតូចទី៣ កងធំទី៣ មន្ទីរបង្កើនផលនៅវត្តស្លែង ។

៣.មិត្តផេន អតីតទាហាននៅក្រុងកំពង់ចាម បច្ចុប្បន្នអនុកងតូចទី២ កងធំទី១ នៅមន្ទីរបង្កើនផលនៅវត្តស្វែង ។

៤.មិត្តយាន អតីតប៉ូលីសនៅខេត្តតាកែវ បច្ចុប្បន្នប្រធានក្រុមកងតូចទី២ កងធំទី១ នៅមន្ទីរបង្កើនផលនៅវត្តស្វែង ។

៥.យឹម អតីតកូនទាហាននៅកំពង់ចាម បច្ចុប្បន្នជាប្រធានក្រុមកងតូចទី២ កងធំទី៣ មន្ទីរបង្កើនផលនៅវត្តស្វែង ។

ជួបជុំគ្នាហើយ បងយ៉ុន បាននិយាយតាមមតិណែនាំរបស់បងហេង ពីរឿងអាវុធដែលមិត្ត ផេន ទុកនេះត្រូវចែកទៅតាមផ្នែកនីមួយៗ ។ ថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៨ បងយ៉ុន ប្រាប់ ផេន ថាយើងត្រូវរៀបចំបំបែកអាវុធជាបួនផ្នែក ។ ផ្នែកទី១ ត្រូវឲ្យមិត្ត យាន មួយផ្នែកទៀតឲ្យ មិត្តរឿន និងមួយផ្នែកទៀតឲ្យមិត្ត យឹម ហើយមិត្ត ផេន ឯងនៅសល់ប៉ុន្មានត្រូវទុកដាក់ឲ្យស្រួលផង ចាំពេលមានផែនការពី បងហេង បានយើងរៀបចំ ហើយខាង បងណាន ត្រូវយកថ្នាំពេទ្យទៅលាក់ទុកផង ពេលមានការបានយកចេញ និងប្រាប់ ផេន ទៀតថា មិត្ត ផេន ត្រូវរៀបចំឲ្យហើយនៅយប់នេះ ដូច្នេះត្រូវយកទៅកន្លែងណា ចាំជួបគ្នាតាមក្រោយ ។ ពេលនេះយើងត្រូវតែសម្ងាត់ដាច់ខាត ក្រោយយើងសម្រេចតាមផែនការរួចហើយ បងយ៉ុន ឲ្យខ្ញុំទៅមុន ចុះទៅរកកន្លែងលាក់ថ្នាំពេទ្យ ។ ខ្ញុំក៏ចុះទៅរកកន្លែងលាក់ថ្នាំពេទ្យ ខ្ញុំបានចូលទៅវត្តស្វែងនៅតាមផ្លូវជាតិលេខ៣ ។ ខ្ញុំឃើញនៅខាងត្បូងព្រះវិហារវត្តស្វែង ខាងកើតជណ្ដើរចុះមានចេតិយបីដង្ហែរគ្នាសុទ្ធតែបែរមុខទៅកើត និងមានដើមចន្ទដែលរលំបាក់មកមុខចេតិយ ហើយខាងក្នុងនិងខាងមុខចេតិយមានកម្ទេចចំបើងដាក់គគ្នាប្រហែលត្រឹមក្បាលជង្គង់ ។ ខ្ញុំចូលទៅមើលចេតិយកណ្ដាលខាងក្នុងមិនមានឃើញអ្វីក្រៅពីកម្ទេចចំបើង និងអម្បែងពាងនោះទេ ។ ដល់យប់ស្អែកម៉ោង១១ ខ្ញុំក៏បានទៅហៅមិត្ត រឿន ទៅយកឡាំងថ្នាំពេទ្យពីផ្ទះបងយ៉ុន ។ ទូលមកដល់ចេតិយ ខ្ញុំកាយចំបើងខាងក្នុងចេតិយកណ្ដាល ហើយយកឡាំងថ្នាំពេទ្យដាក់ចូលទៅក្នុងរួចយកចំបើងដាក់គ្របពីលើឲ្យដូចដើមវិញ ។ ព្រឹកស្អែកទៅផ្ទះ បងយ៉ុន រាយការណ៍ប្រាប់គាត់ថា ខ្ញុំបានយកថ្នាំពេទ្យទៅលាក់ក្នុងចេតិយខាងត្បូងព្រះវិហារវត្តស្វែង ។ បងយ៉ុន សួរខ្ញុំថា បងឯងលាក់កន្លែងនោះធានាលាក់ការណ៍បានដែរឬ? ខ្ញុំឆ្លើយថា ខ្ញុំធានាព្រោះខ្ញុំស្នាក់នៅលើវិហារងាយស្រួលមើលផង ។

នៅដើមខែមេសា បងយ៉ុន បានហៅខ្ញុំទៅប្រជុំនៅផ្ទះបងហេង ។ ពេលទៅដល់ខ្ញុំឃើញមាន ផេន, យាន, រឿន, យឹម និងបងយ៉ុន ។ មួយស្របក់ក្រោយមក ខ្ញុំបានឃើញ បងហេង អតីតគ្រូបង្រៀននៅស្រុកកំពង់ឃ្លាំង ខេត្តសៀមរាប បច្ចុប្បន្នជាប្រធានមន្ទីរបង្កើនផលវត្តស្វែង ឡើងមកលើផ្ទះ ។ បន្ទាប់មក បងហេង និយាយថាយើងមកជុំគ្នាអស់ហើយ ចាប់ផ្ដើមធ្វើការដោយគាត់មានមតិថាសភាពការណ៍កាន់តែទុំហើយ ពេលវេលាកាន់តែខិតជិតហើយ ទូទាំងប្រទេសគ្រប់ផ្នែកទាំងអស់ក៏បានត្រៀមរៀបចំដូចយើងដែរ ហើយសភាពការណ៍ខាងក្រៅ យួនក៏កំពុងវាយសម្រុកខ្លាំង ។ ខែមេសានេះ នឹងវាយសម្រុកកាន់តែខ្លាំងថែមទៀត ដើម្បីវាយរំលំបក្សកុម្មុយនីស្តកម្ពុជាផ្ដាច់ព្រាត់ ដូច្នេះយើងត្រូវបំពាក់អាវុធឲ្យកម្លាំងខាងក្រោមរបស់យើងដែលទុកចិត្តតាមផ្នែកមួយៗ ។ បើអាវុធមិនគ្រប់ទេ មិត្តផេន ដោះស្រាយចែកចាយថែមទៀត ត្រូវចែកឲ្យឈ្មោះណា មិត្តយ៉ុន ចាំពិភាក្សាគ្នាទៀត ។ ដល់ពេលខ្ញុំនឹងឲ្យសញ្ញាជាស្នូរកាំភ្លើង បីដង ពេលឮស្នូរកាំភ្លើង កម្លាំងកងប្រដាប់អាវុធរបស់យើងគ្រប់គ្នាត្រូវមកជួបជុំនៅផ្ទះខ្ញុំ ឯកម្លាំងយួនក៏ត្រូវបញ្ចេញ ទាំងអស់គ្នាចាំស្ដាប់តាមបញ្ជារបស់ខ្ញុំ កុំរហេតរហូតនាំឲ្យគ្រោះថ្នាក់ ។ ខាងមិត្តណាន ត្រូវរៀបចំប្រដាប់ថ្នាំពេទ្យទុកសម្រាប់ពេលត្រូវការ ។ បងហេង បន្តទៀតថា បញ្ហាសំខាន់គឺបញ្ហារក្សាការសម្ងាត់ក្នុងរយៈកាលនេះ បើត្រូវបែកការ ផែនការរបស់យើងត្រូវបរាជ័យ ដូច្នេះដាច់ខាតត្រូវលាក់ការឲ្យបាន ពេលចេញចូលកន្លែងលាក់យួនក៏កាន់តែប្រយ័ត្នថែមទៀត ។ ក្រោយមក បងយ៉ុន ហៅខ្ញុំទៅផ្ទះគាត់ ពេលខ្ញុំទៅដល់គាត់ប្រាប់ខ្ញុំថា នៅម៉ោង១១យប់នេះ បងឯងមកយកអាវុធនៅផ្ទះខ្ញុំ ខ្ញុំសួរគាត់ថា ខ្ញុំយកអាវុធទៅលាក់ជាមួយឡាំងថ្នាំពេទ្យបានទេបង? គាត់ឆ្លើយថាស្រួលហើយ ដល់ពេលត្រូវការគឺបញ្ចេញទាំងអាវុធ ទាំងថ្នាំពេទ្យជាមួយគ្នាតែម្ដងកុំឲ្យពិបាករត់ចុះរត់ឡើង ។ ដល់ម៉ោង ១១យប់ ខ្ញុំទៅផ្ទះ បងយ៉ុន ជួបគាត់ហើយក៏នាំខ្ញុំទៅក្រោយផ្ទះក្រោមដើមអំពិលទឹក គាត់ថានេះជាអាវុធអាកាពីរដើម និងគ្រាប់បែកដៃ បួនគ្រាប់ ខ្ញុំក៏យកអាវុធនេះទៅលាក់ក្នុងចេតិយខាងត្បូងព្រះវិហារវត្តស្វែងជាមួយថ្នាំពេទ្យ ។ ខ្ញុំជាប់ការទាក់ទងជាមួយខ្សែនេះរហូតដល់អង្គការចាប់ខ្លួនតែម្ដង ។

**ឆាង សារៈមុនិន្ទ**



# សំឡេងពីស្រុកអន្លង់វែង

## មរតកអតីតកាល និង ជីវិតបច្ចុប្បន្ន

**(តចប់)**

**លួង ឡៅ**


លួង ឡៅ

លួង ឡៅ មានអាយុ៥៩ឆ្នាំ ។ គាត់បានរៀបការជាមួយនឹង ទុំ លឿន សព្វថ្ងៃមានអាយុ ៦១ឆ្នាំ ជាមេភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ។ ភូមិលំទងចាស់ ស្ថិតនៅចម្ងាយ១៨គីឡូម៉ែត្រពីផ្លូវធំ និងអាចធ្វើដំណើរទៅដល់បានតាមផ្លូវលំដោយឆ្លងកាត់វាលស្មៅដែលមានដើមឈើដុះរកេតរកូត ។ ពេលទៅដល់ភូមិលំទងចាស់ យើងឃើញមានព្រៃស្តុកជាច្រើននៅជុំវិញទីប្រជុំជនដ៏តូចមួយនេះដែលមានប្រជាជនរស់នៅប្រហែលជាមួយរយគ្រួសារ ។ ពីមុនព្រៃនៅជុំវិញនេះសម្បូរទៅដោយសត្វព្រៃជាច្រើនដូចជាសត្វខ្លា និងក្របីព្រៃជាដើម ។ ប៉ុន្តែពីរបីឆ្នាំចុងក្រោយនេះ ការប្រមាញ់សត្វព្រៃមានការកើនឡើងយ៉ាងខ្លាំង ជាហេតុធ្វើឲ្យមានការថយចុះនៃចំនួនសត្វព្រៃនៅក្នុងតំបន់នេះ ។ កាលពីប៉ុន្មានឆ្នាំមុន មានករណីខ្លាខាំមនុស្សពីរបីនាក់ ។

សព្វថ្ងៃនេះ មាននៅសល់សត្វមួយចំនួនដូចជា ជ្រូកព្រៃ ប្រើស និងពពួកសត្វកកេរនានាដូចជាកំប្រុកជាដើម ។ ស្ថានភាពសន្តិសុខនៅក្នុងភូមិមិនសូវជាល្អប៉ុន្មានទេ ។ មីង ឡៅ បានប្រាប់ថា កាលពីពីរខែមុន មានករណីលួចប្លន់កើតឡើងពីរលើក ។ កាលពីពីរបីឆ្នាំមុន កុមារីអាយុ១៨ឆ្នាំម្នាក់បានត្រូវរំលោភពេលដែលធ្វើដំណើរត្រលប់ពីអន្លង់វែងនៅថ្ងៃឈប់សម្រាកដើម្បីមកលេងផ្ទះនៅក្នុងភូមិលំទងចាស់ ។ កុមារីរូបនេះកំពុងសិក្សានៅអនុវិទ្យាល័យមួយក្នុងស្រុកអន្លង់វែង ។ នៅក្នុងភូមិមានសាលាបឋមសិក្សាតូចមួយ ប៉ុន្តែបច្ចុប្បន្ន សិស្សស្ទើរទាំងអស់មិនបានរៀនបន្តឲ្យលើសពីថ្នាក់ទី៥ ឡើយ ដោយសារតែមូលហេតុសន្តិសុខ និងសេដ្ឋកិច្ចដែលបានរារាំងសិស្សទាំងនោះក្នុងការទៅសាលារៀនបាន ។

អ្នកភូមិ ធ្វើការដាំដុះដំណាំនៅលើដីដែលបានកាប់គាស់ជាង១៥ឆ្នាំកន្លងមកហើយ ក្រោយពីគាត់ត្រលប់មកចូលភូមិវិញ ។ សព្វថ្ងៃនេះ ដីចម្ការធំៗគឺជាប្រភពនៃប្រាក់ចំណូលដ៏ច្រើនរបស់អ្នកភូមិ និងជាហេតុផលតែមួយគត់ដែលធ្វើអោយគាត់រស់នៅបន្តក្នុងភូមិដ៏ដាច់ស្រយាលមួយនេះ ។ ឯមន្ទីរពេទ្យវិញ ស្ថិតនៅឆ្ងាយពីភូមិគួរសម ។ កូនស្រីរបស់មីង ឡៅ សម្រាលបានកូនភ្លោះនៅ

ក្នុងឡានដឹកបន្លែពេលធ្វើដំណើរតាមផ្លូវទៅមន្ទីរពេទ្យនៅទីរួមស្រុកអន្លង់វែង ។ ចម្ងាយ១៨គីឡូម៉ែត្រគឺមិនឆ្ងាយប៉ុន្មានទេ ប៉ុន្តែស្ថានភាពផ្លូវសែនលំបាកបានធ្វើឲ្យអ្នកភូមិនេះចំណាយពេលយ៉ាងយូរទម្រាំទៅដល់អន្លង់វែង ។

លំទងចាស់ និងតំបន់ជុំវិញភូមិធ្លាប់ជាភូមិដើមរបស់អន្លង់វែងមុនពេលមិនទាន់ក្លាយជាស្រុក ។ ពេលដែល តាម៉ុក មកដល់ គាត់បានបោះទីតាំងនៅទីប្រជុំជនអន្លង់វែងសព្វថ្ងៃដែលនៅដាច់ពីភូមិលំទងចាស់ដើម្បីឲ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅភ្នំដងរែក និងខេត្តព្រះវិហារ ។ មីង ឡៅ និងប្តី ព្រមជាមួយកូនទាំងប្រាំពីរនាក់របស់គាត់ដែលមានកូនស្រីច្បងកើតនៅឆ្នាំ១៩៨០ បានមករស់នៅលំទងចាស់ក្នុងឆ្នាំ១៩៩៩ មួយឆ្នាំក្រោយពីអន្លង់វែងបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា និងក្រោយពីចលនាខ្មែរក្រហមដួលរលំទាំងរចនាសម្ព័ន្ធនយោបាយ និងយោធា ។ ពេលដែលគ្រួសារ មីងឡៅ មកដល់ដំបូង គាត់ត្រូវដីកគាស់វាលស្រែដែលមានបង្កប់ដោយគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ។ មីង ឡៅ បានទិញដីបន្ថែមទៀតពីអ្នកភូមិដើម្បីមានកន្លែងគ្រប់គ្រាន់សម្រាប់ដាំដុះ និងផ្គត់ផ្គង់គ្រួសាររបស់គាត់ ។ ពីរ បីឆ្នាំក្រោយ ប្តីរបស់មីង ឡៅ បានក្លាយជាមេភូមិ ។ កាលពីរបបគ្រប់គ្រងដោយ តាម៉ុក ប្តីរបស់មីង ឡៅ គឺជាអតីតយោធានៅក្នុងកងពលមួយរបស់តាម៉ុក ។

មុនពេលផ្លាស់ទៅនៅលំទងចាស់ មីង ឡៅ និងគ្រួសារបានផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀត ដោយសារតែស្ថានភាពសង្គ្រាម ។ ក្នុងនាមជាអតីតសមាជិកខ្មែរក្រហមមួយរូប មីង ឡៅ បានចំណាយពេលវេលានៃជីវិតជិតម្ភៃឆ្នាំដោយផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតជាមួយខ្មែរក្រហម ។ អតីតកម្មាភិបាលខ្មែរក្រហមទាំងនោះមានអាហារសម្រាប់បរិភោគគ្រប់គ្រាន់នៅទសវត្សរ៍៨០ និងដើមទសវត្សរ៍៩០ ។

នៅឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមក មីង ឡៅ បានធ្វើដំណើរពីឧត្តរមានជ័យទៅព្រំដែនកម្ពុជា-ថៃ ដើម្បីស្វែងរកអាហារ និងសុវត្ថិភាព ។ ប៉ុន្តែគាត់ក៏បានធ្វើដំណើររួមជាមួយកម្មាភិបាលខ្មែរក្រហមដទៃទៀតដែរ ។ មីង ឡៅ បាននិយាយថា នៅឆ្នាំ១៩៧៩ គាត់កម្របានអាហារសម្រាប់ហូបចុកគ្រប់គ្រាន់ណាស់នៅតាមព្រំដែន ។ ក្រុមរបស់ មីង ឡៅ បានធ្វើដំណើរឆ្លងកាត់ចម្ការមីនពីរដងម្តងនៅតំបន់ព្រំដែនខាងជើងឧត្តរមានជ័យ និងម្តងទៀតពេលដែលត្រូវឆ្លងកាត់ពីប្រទេសថៃទៅព្រះវិហារក្រោយពេលដែលអាជ្ញាធរថៃបដិសេធមិនព្រមទទួលជនភៀសខ្លួនកម្ពុជា ។ នៅពេលដែលអង្គការអន្តរជាតិនានាមានលទ្ធភាពផ្តល់អាហារដល់ជនភៀសខ្លួន ជីវិតរបស់ មីង ឡៅ មានភាពប្រសើរ និងមានអាហារបរិភោគគ្រប់គ្រាន់ ។ មីង ឡៅ បានទៅរស់នៅជំរំអូរត្រាវក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ គាត់បានជួបនឹងបុរសម្នាក់ដែលក្រោយមកក្លាយជាប្តីរបស់គាត់នៅឆ្នាំ១៩៨០ ។ ក្រោយមក មីង ឡៅ បានផ្លាស់ទីលំនៅចុះឡើងនៅតំបន់ភ្នំដងរែក ។ នៅចុងទសវត្សរ៍៨០ មីង ឡៅ បានមករស់នៅក្នុងភូមិអូរថ្កូវដែលមានទីតាំងនៅលើភ្នំដងរែក ។ ពេល តាម៉ុក ផ្លាស់ប្រជាជនទាំងអស់ពីអូរថ្កូវចុះមកអន្លង់វែង នៅឆ្នាំ១៩៩០ មីង ឡៅ មិនបានតាម តាម៉ុក ទេព្រោះតែគាត់ឈឺ និងត្រូវព្យាបាលនៅជំរំអូរត្រាវ ។ បន្ទាប់មក មីង ឡៅ បានផ្លាស់មកនៅភូមិព្រះប្រឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាម៉ុក (សព្វថ្ងៃនៅស្រុកត្រពាំងប្រាសាទ) ។ មីង ឡៅ រស់នៅព្រះប្រឡាយប្រហែលបួនឆ្នាំមុននឹងផ្លាស់ទៅជំរំភូណយ ក្នុងប្រហែលឆ្នាំ១៩៩៨ អំឡុងពេលសមាហរណកម្ម ។ បន្ទាប់ពីនៅជំរុំភូណយបានមួយរយៈ មីង ឡៅ បានផ្លាស់មកទីលំនៅនាពេលបច្ចុប្បន្ននេះវិញ ។ កាលនៅព្រះប្រឡាយ និងអំឡុងពេលរស់នៅអូរថ្កូវ ជីវិតរបស់មីង ឡៅ មានភាពមមាញឹកយ៉ាងខ្លាំង ។ មីង ឡៅ លួចលក់របស់របរដែលគាត់បានទិញពីថៃឲ្យអ្នកភូមិ ។ ដោយសារតែប្តីរបស់គាត់ជាទាហានដ៏សកម្មរបស់ខ្មែរក្រហម ក្រុមគ្រួសារ មីង ឡៅ បានទទួលនូវរបបអាហារគ្រប់គ្រាន់និងអាចធ្វើស្រែចម្ការលើដីដែលបានផ្តល់ឲ្យសម្រាប់ការដាំដុះក្នុងគ្រួសារ ។

មីង ឡៅ ជឿជាក់ថាជីវិតនាពេលបច្ចុប្បន្នល្អប្រសើរជាងជីវិតដែលនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុកក្នុងទសវត្សរ៍ឆ្នាំ៩០ ពីព្រោះពេលនេះគាត់មានសេរីភាពច្រើនជាងមុន និងមិនមានការភ័យខ្លាចពីការជម្លៀស និងសម្លាប់ដោយសង្គ្រាមទៀតទេ ។ ប្តីរបស់គាត់មិនចាំបាច់ទៅសមរភូមិទៀតទេ ។ កូនរបស់ មីង ឡៅ មានដីផ្ទាល់ខ្លួនសម្រាប់ធ្វើស្រែចម្ការដោយខ្លួនឯង ។ ចំពោះ មីង ឡៅ វិញ តាម៉ុក គឺជាមនុស្សល្អ ។ គាត់តែងតែបរិភោគអាហារ និង

និយាយលេងជាមួយនឹងអ្នកភូមិ ។ តាម៉ុក គឺជាមនុស្សសាមញ្ញ ប៉ុន្តែគាត់ជួនកាលក៏ជាមនុស្សឆេវឆាវដែរ ។ មីង ឡៅ និយាយដោយទឹកមុខញញឹមញញែមថា ពេល តាម៉ុក ឲ្យអ្វីមួយដល់យើង យើងត្រូវតែទទួលយកហើយដើរចេញ បើមិនដូច្នោះទេគាត់នឹងឲ្យរបស់នោះទៅអ្នកផ្សេងទៀតមិនខាន ។ មីង ឡៅ ដឹងរឿងតិចតួចណាស់ទាក់ទងនិង សុន សេន និង ប៉ុល ពត ដោយសារគាត់មិនធ្លាប់បានជួបអ្នកទាំងនោះពីមុនមកទេ ។

ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ មីង ឡៅ គឺជាកម្មាភិបាលខ្មែរក្រហមម្នាក់ដែលមានស្រុកកំណើតនៅស្រុកស្ទោង ខេត្តកំពង់ធំ ។ ជីវិតរបស់គាត់ពោរពេញទៅដោយសេចក្តីមេត្តាករុណា ពុះពារដោះស្រាយឧបសគ្គដោយខ្លួនឯង និងជាកូនស្រីដែលចេះមើលថែឪពុកម្តាយ ។ តាមពិត មីង ឡៅ ជាមនុស្សសំខាន់ម្នាក់នៅស្រុកជីក្រែង ។ កាលនោះ គាត់ធ្វើជាប្រធានកងកុមារ និងប្រធានកងនារីនៅក្នុងស្រុក ព្រមទាំងមានភារៈគ្រប់គ្រងលើឃ្លាំងអង្ករ និងសព្វាវុធផ្សេងៗ ។ មីង ឡៅ បានបង្រៀនខ្មែរជាមូលដ្ឋានដល់កុមារ ។ មុននឹងគាត់ចូលជាមួយចលនាខ្មែរក្រហម គាត់ធ្លាប់បានរៀនសូត្រខ្លះៗដែរ ។ មីង ឡៅ បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីពេលដែលគាត់មានអាយុ១៨ឆ្នាំនៅស្រុកស្ទោងនៅឆ្នាំ១៩៧១ ។

មីង ឡៅ បាននិយាយទៀតថា ពេលដែលគាត់ធ្វើជាប្រធានកងចល័តនារី គាត់មានចិត្តអាណិត និងការយោគយល់ច្រើនចំពោះសមាជិកនៅក្នុងកង ។ មីង ឡៅ ព្យាយាមការពារសមាជិកក្នុងកងពីការទទួលទារុណកម្មឬសម្លាប់ពីសំណាក់ខ្មែរក្រហម ។ គាត់បានជួយបុរសម្នាក់និងស្ត្រីម្នាក់ដែលស្រលាញ់គ្នានិងបានប្រព្រឹត្តិខុសសីលធម៌ ។ មីង ឡៅ បាននិយាយថា គាត់ប្រាប់កងឈ្លបខ្មែរក្រហមថា ប្រសិនបើអ្នកទាំងពីរស្រលាញ់គ្នា គួរតែរៀបការនឹងគ្នាតែម្តងទៅ មិនមានការខុសឆ្គងទេ ។ កម្មាភិបាលខ្មែរក្រហមផ្សេងទៀតក៏យល់ព្រម ។ ទាំងកម្មាភិបាលខ្មែរក្រហម និងប្រជាជនសាមញ្ញចូលចិត្តនិងស្រលាញ់ មីង ឡៅ គ្រប់ៗគ្នា ។ ទោះបីជាគាត់ទើបតែមានអាយុ២០ឆ្នាំក៏ដោយ ក៏អ្នកភូមិខ្លះនាំគ្នាហៅមីងថា «ម៉ែ» ពីព្រោះគាត់ធ្វើល្អ និងជួយជីវិតអ្នកទាំងនោះជារាល់ពេលដែលមានកំហុសម្តងៗ ។ កិត្តិនាមរបស់ មីង ឡៅ ដែលជាអ្នកមានចិត្តករុណាចំពោះអ្នកភូមិ និងជាសមាជិកដ៏ស្មោះត្រង់ម្នាក់របស់ខ្មែរក្រហមបានជួយសង្គ្រោះជីវិតគាត់រួចផុតពីការបះបោរក្នុងស្រុកក្រែងដែលកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៧ ។

កម្មាភិបាលជើងចាស់ខ្មែរក្រហមបីនាក់ឈ្មោះ តាសុត តាសៀន និងតាសិន មានការមិនពេញចិត្តនឹងប្រព័ន្ធដឹកនាំរបស់ខ្មែរក្រហម និងមិនពេញចិត្តនូវអ្វីដែលខ្មែរក្រហមបានអនុវត្តដើម្បីកសាងជាតិឡើងវិញក្រោយសង្គ្រាមទេ ។ កម្មាភិបាលទាំងបីមិនសប្បាយចិត្តដោយមានហេតុផលជាច្រើនដែល មីង ឡៅ ផ្ទាល់ក៏មិនយល់ដែរ ។ អ្វីដែលអ្នកទាំងនោះធ្វើត្រូវបានចាត់ទុកថា ជាអំពើក្បត់ជាតិក្រោមច្បាប់ខ្មែរក្រហម ។ តាសុត តាសៀន និងតាសិន បានបញ្ចុះបញ្ចូលកម្មាភិបាលខ្មែរក្រហមនិងអ្នកភូមិដទៃទៀតឲ្យធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយទៀតដើម្បីរកមនុស្សឲ្យមកចូលរួមការបះបោរប្រឆាំងនឹងខ្មែរក្រហម ។ អ្នកណាមិនព្រមចូលរួមនឹងត្រូវសម្លាប់ចោល ។ គ្រប់ផ្ទះសុទ្ធតែប្រមូលមនុស្សមកចូលរួមបានទាំងអស់រួចហើយ អ្នកទាំងអស់នោះបាននាំគ្នាដើរតាមផ្លូវដោយស្រែកជ័យឃោសថា «យើងនាំគ្នាបំផ្លាញខ្មែរក្រហមចោល!» ពេលដែលដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀតចាប់ពីត្បូងទៅជើង ។ ក្រុមបះបោរទាំងនោះបានសម្លាប់ប្រធានកង ប្រធានភូមិ ប្រធានឃុំ និងប្រធានស្រុក ព្រមទាំងអ្នកទាំងឡាយណាដែលគាំទ្រកម្មាភិបាលទាំងនោះ ។ មីង ឡៅ បាននិយាយថាស្ត្រីម្នាក់បានត្រូវដាច់ដៃដោយសារតែស្ត្រីនោះកាន់ត្រចៀកទ្វារ ។ ក្រោយមក ក្រុមបះបោរទាំងនោះត្រូវបានសម្លាប់ដោយទ័ពពេជ្ឈឃាតរបស់ខ្មែរក្រហមមកពីភូមិភាគនិរតី ។ យោធាខ្មែរក្រហមពេជ្ឈឃាតទាំងនោះដឹកនាំដោយ ហឿន មកពីកងអង្គភាព០៧ ។ មីង ឡៅ បានរួចរស់ជីវិតទាំងពីរលើក ។

## មាស ពៅ

មាស ពៅ ភេទស្រី មានអាយុ៥៨ឆ្នាំ ។ ប្តីរបស់គាត់ឈ្មោះ ជួន ណាក់ អាយុ៦០ឆ្នាំ ។ អ្នកទាំងពីររៀបការនៅឆ្នាំ១៩៨០ និងមានកូនចំនួនបីនាក់ ។ កូនប្រុសច្បងមានអាយុ៣១ឆ្នាំ ។ សព្វថ្ងៃនេះ មីង ពៅ ជាប្រធានភូមិអូរគគីរលើ ឃុំលំទង ស្រុកអន្លង់វែង ។

មីង ពៅ មានស្រុកកំណើតនៅភូមិតាំងបន្ទាយ ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ខ្មែរក្រហមបានចូលមកភូមិរបស់គាត់នៅ

ឆ្នាំ១៩៦៨ ។ មីង ពៅ ខ្លាចយោធាខ្មែរក្រហមណាស់ ហើយគាត់មិនដឹងពីគោលបំណងដែលខ្មែរក្រហមចូលភូមិរបស់គាត់ទេ ហើយគាត់ក៏មិនដឹងពីហេតុអ្វីបានជាខ្មែរក្រហមប្រយុទ្ធគ្នាជាមួយរដ្ឋាភិបាលដែរ ។ ឪពុកម្តាយរបស់មីង ពៅ គឺជាកសិករនៅក្នុងភូមិ ។ ប៉ុន្តែនៅឆ្នាំ១៩៧២ គាត់បានចូលរួមបដិវត្តន៍ខ្មែរក្រហម ។ ដំបូងមីង ពៅ ត្រូវបានចាត់តាំងឲ្យសែងយុទ្ធជនរបួស សែងគ្រាប់ និងស្បៀងជាមួយនារីដទៃទៀតនៅក្នុងកងនារី ។ នៅឆ្នាំ១៩៧៣ មីង ពៅ ធ្វើការនៅក្នុងរោងចក្រស្ករស ។ គាត់បាននិយាយថា រោងចក្រនេះមានភាពទំនើបគួរសមដែរ ។ រោងចក្រនេះផលិតស្ករសពីទឹកត្នោត ។ មីង ពៅ មិនចាំថាអ្នកណាជាប្រធានរោងចក្រនេះទេ ។ អ្នកភូមិមិនប្រើប្រាស់លុយទេ ប៉ុន្តែខ្មែរក្រហមបានប្រើប្រាស់ប័ណ្ណម៉្យាងដើម្បីដោះដូរអាហារ សម្លៀកបំពាក់ និងគ្រឿងចាំបាច់ដទៃទៀត ។ មីង ពៅ មិនបានដឹងថាស្ករសដែលផលិតបានយកទៅលក់នៅទីណាឡើយ ។


មាស ពៅ

នៅឆ្នាំ១៩៧៥ មីង ពៅ ត្រូវបានបញ្ជូនមកធ្វើការនៅរោងចក្រផលិតសំណាញ់ត្រីនៅភ្នំពេញ ។ ទីតាំងរបស់រោងចក្រនេះស្ថិតនៅជិតវិទ្យាល័យបាក់ទូក ។ មីង ពៅ ចាំថា រោងចក្រនោះមានទីតាំងជិតនៅពីក្រោយរោងភាពយន្តសរព្រហ្មមាស (បច្ចុប្បន្ននៅផ្លូវសាលដីហ្គោល) ។ រោងចក្រនេះផលិតសំណាញ់ដោយម៉ាស៊ីន ។ ប្រធានរោងចក្រឈ្មោះ គុង ដែលមានប្រពន្ធជាប្រធានរោងចក្រផលិតភួយ នៅខេត្តកណ្តាល ។ មីង ពៅ បាននិយាយទៀតថា អ្នកទាំងពីរត្រូវបានអង្គការយកទៅកសាងនៅក្នុងអំឡុងឆ្នាំ១៩៧៧ ។ មីង ពៅ ក៏មានការភ័យខ្លាចពីសុវត្ថិភាពខ្លួនដែរ ពេលដែល គុង ត្រូវបានយកទៅកសាង ។ មីង ពៅ មានអារម្មណ៍ភិតភ័យដែរ ក្រោយពេលដែលជាលេខាតំបន់ឈ្មោះ ចេង អន ត្រូវបានអង្គការចាប់ខ្លួន ។ គ្មានអ្វីប្រសើរជាងជីវិតរបស់គាត់នៅក្នុងរោងចក្រផលិតសំណាញ់ទេ ។ មីង ពៅ មានអាហារហូបចុកគ្រប់គ្រាន់ និងធ្វើការជាមួយនឹងកម្មកររោងចក្រចាស់ៗ ។ មីង ពៅ និយាយថា គាត់និងក្រុមការងារអាចស្វែងរកអាហារ ថ្នាំ សង្កូវ និងរបស់របរចាំបាច់នៅតាមផ្ទះជិតខាង ។ មីង ពៅ និយាយទៀតថា ជួនកាលគាត់រកឃើញមាសពេជ្រ និងខោអាវថ្លៃៗនៅក្នុងវីឡាមួយចំនួន ប៉ុន្តែគាត់មិនបានយករបស់អស់ទាំងនោះទេ ព្រោះខ្មែរក្រហមបង្រៀនមិនឲ្យមានភាពអាត្មានិយម និងមានមហិច្ឆតាឡើយ ។ មីង ពៅ គ្រាន់តែយកថ្នាំ និងស្ករគ្រាប់ខ្លះៗប៉ុណ្ណោះ ។ មីង ពៅ ធ្វើការនៅក្នុងរោងចក្រនោះរហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ ពេលដែលកងទ័ពវៀតណាមមកដល់ គាត់បានភៀសខ្លួនជាមួយនឹងកម្មាភិបាលខ្មែរក្រហមតាមផ្លូវជាតិលេខ៤ បន្ទាប់មកឆ្លងកាត់ទៅកាន់ផ្លូវជាតិលេខ៥ ដោយកាត់តាមខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង រហូតដល់ព្រំដែនកម្ពុជា-ថៃ ។

ប្រាំខែដំបូងនៃការរត់ភៀសខ្លួន មីង ពៅ បាននិយាយថា ជារយៈពេលដែលគាត់រងនូវការអត់ឃ្លានខ្លាំងបំផុត ។ មីង ពៅ ត្រូវដើររកជីកដំឡូងនិងមើមឈើព្រៃដើម្បីបរិភោគ ។ គាត់ក៏ជីកដំឡូងថៃ ដើម្បីហូបដែរ ប៉ុន្តែដំឡូងនោះមានជាតិពុល ។ មីង ពៅ និងសមាជិកខ្មែរក្រហមដទៃទៀត ជាពិសេសនារី និងកុមារត្រូវជាប់គាំងនៅព្រំដែនដោយសារតែទាហានថៃមានការស្ទាក់ស្ទើរក្នុងការទទួលយកជនភៀសខ្លួន ហើយជាមួយគ្នានោះដែរ កងទ័ពវៀតណាមក៏កំពុងតែរុលចូលជិតដល់ដែរ ។

ក្នុងខែកក្កដា ឆ្នាំ១៩៧៩ ប្រហែលជា តាម៉ុក បានបញ្ជូនឡានឲ្យទៅដឹកជនភៀសខ្លួនពាក់កណ្តាលទៅកាន់ជំរុំខ្មែរក្រហមទៅខេត្តឧត្តរមានជ័យ និងខេត្តភាគខាងជើងរបស់ប្រទេសកម្ពុជាដទៃទៀត ។ មីង ពៅ បានឡើងឡាននោះពីព្រោះអ្នកដែលជិះឡាននោះគឺជាជនជាតិខ្មែរ និងខ្មែរក្រហមដែលគាត់ទុកចិត្ត ។ អ្នកខ្លះមិនបានទៅជាមួយទេ ។ ឡាននោះបានដឹកគាត់ទៅដល់ចំណុចទី១០០១(ចំណុចទី១០០១គឺជាទីតាំងមូលដ្ឋានរបស់យោធាខ្មែរក្រហមនៅតាមព្រំប្រទល់កម្ពុជា ថៃ និងឡាវ) ។ នៅទីនោះ អាហារសម្បូរហូរហៀរណាស់ ។ ប្រជាជនអាចយកអាហារបានតាមតែខ្លួនចង់បរិភោគ ។ ប្រសិនបើអ្នកណាចិញ្ចឹមសត្វ ដូចជាជ្រូកជាដើម អ្នកនោះអាចទុកលក់ឲ្យឈ្មួញថៃ ។ មីង ពៅ ជួបជាមួយនឹងប្តីរបស់គាត់នៅចំណុច១០០២ ។ នៅឆ្នាំ១៩៨០ គាត់បានរៀបការជាមួយគូស្រករផ្សេងទៀតសរុបទាំងអស់ប្រាំគូ ។ ប្តីរបស់ មីង ពៅ ស្រលាញ់គាត់

ណាស់ ហើយក៏សុំប្រធានរបស់គាត់មកជួបជាមួយប្រធានកងនារីរបស់គាត់ដើម្បីសុំរៀបការ ។ ដំបូង មីង ពៅ បដិសេធដោយសារគាត់ចង់នៅទំនេរ និងអាចទៅណាមកណាបានដោយគ្មានកូន ។ មីង ពៅ ក៏នឹកឃើញថា បើសិនជាគាត់រៀបការ គាត់មិនសូវមានពេលចូលរួមបដិវត្តន៍ឲ្យបានពេញលេញទេ ។ ប៉ុន្តែប្តីរបស់គាត់នៅតែចចេស ហើយស្នើឲ្យប្រធានរបស់ មីង ពៅ ម្តងហើយម្តងទៀត តែគាត់នៅតែមិនព្រម ។ ប្តីរបស់ មីង ពៅ គឺជាប្រធានកងម្នាក់ដែរ ។ ក្រោយមកមីង ពៅ ក៏ព្រមរៀបការ ហើយមួយឆ្នាំក្រោយមកគាត់ក៏មានកូន ។ ក្រោយមក មីង ពៅ និងប្តីបានផ្លាស់ទៅនៅចំនុច៨០៨(ត្រពាំងតាវ) ។ អ្នកទាំងពីរផ្លាស់ទៅផ្លាស់មកនៅជុំវិញខ្មែរក្រហមអាស្រ័យទៅលើស្ថានភាពប្រយុទ្ធដែលតែងតែកើតមាននៅតាមព្រំដែនថៃ ។ មីង ពៅ រស់នៅក្នុងស្ថានភាពបែបនេះពេញមួយទសវត្សរ៍៨០ ។ ពេលកងទ័ពវៀតណាមដកចេញនៅឆ្នាំ១៩៨៩ តាម៉ុក បានចាប់ផ្តើមជម្លៀសប្រជាជនចុះពីភ្នំទៅអន្លង់វែង និងតំបន់ជុំវិញនោះ ។ មីង ពៅ ត្រូវបានឲ្យទៅនៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ។ បន្ទាប់មក គាត់បានផ្លាស់ទៅនៅជិតជើងភ្នំនៅឆ្នាំ១៩៩៥ ព្រោះគាត់យល់ថា មានភាពងាយស្រួលជាងក្នុងការរត់គេចពីការប្រយុទ្ធគ្នា ។ នៅឆ្នាំ១៩៩៦ មីង ពៅ បានផ្លាស់មកនៅទីតាំងបច្ចុប្បន្នរបស់គាត់គឺនៅភ្នំអូរគគី ឃុំលំទង ។ នៅឆ្នាំ១៩៩៨ មីង ពៅ បានផ្លាស់ទៅជុំវិញកូណយម្តងទៀត និងត្រលប់មកវិញមួយឆ្នាំក្រោយមក ។ ក្រោមរបបគ្រប់គ្រងរបស់ តាម៉ុក មានអាហារហូបចុកគ្រប់គ្រាន់ ។ មីង ពៅ បាននិយាយទៀតថា ក្នុងអំឡុងឆ្នាំ១៩៩២ មានប្រជាជនអត់ឃ្លានជាច្រើនរយនាក់បានផ្លាស់ពីតំបន់គ្រប់គ្រងរបស់រដ្ឋាភិបាលមកអន្លង់វែងដើម្បីរកអាហារហូប ។ តាម៉ុក បានជួយអ្នកទាំងនោះ ដោយឲ្យអាហារ និងគ្រឿងផ្គត់ផ្គង់ផ្សេងៗទៀត ។ តាម៉ុក មានសមានចិត្តល្អណាស់ចំពោះអ្នកភៀសខ្លួនទាំងនោះរហូតធ្វើឲ្យអ្នកអន្លង់វែងខ្លះមានចិត្តច្រណែនបន្តិចបន្តួចដែរ ។

តាម៉ុក បានឲ្យគោញីមួយក្បាលទៅគ្រួសារនីមួយៗនៅអន្លង់វែង ប៉ុន្តែមិនអាចឲ្យបានគ្រប់គ្រួសារទាំងអស់បានទេ ។ ទោះបីជា តាម៉ុក យកចិត្តទុកដាក់លើប្រជាជនដទៃ គាត់នៅតែយកចិត្តទុកដាក់កូនស្រីទាំង អស់របស់គាត់ស្មើនឹងអ្នកភូមិដែរ ។ តាម៉ុក បានទាញយកធនធានធម្មជាតិអន្លង់វែង ដោយគ្រាន់តែកាប់ដើមឈើចាស់និងពេញវ័យប៉ុណ្ណោះ ។ អំឡុងពេលប៉ុន្មានថ្ងៃចុងក្រោយនៃរបប តាម៉ុក មីង ពៅ បានចូលរួមប្រជុំជាមួយ តាម៉ុក និងពួកគាត់និយាយថា ប្រជាជនរបស់គាត់មានជម្រើសបីគឺ ចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី និងមិនគួរបន្តប្រយុទ្ធគ្នាទៀតទេ ធ្វើដូច្នេះនឹងមិនមានអ្នកណាម្នាក់ក្លាយជាស្ត្រីមេម៉ាយទៀតទេ ។

សាសនាត្រូវបានអនុញ្ញាតអោយប្រណិប័តន៍ ។ នៅថ្ងៃចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ ប្រជាជនក៏អាចប្រារព្ធពិធីបានដែរ ។ មីង ពៅ ធ្វើធូបនិងទៀនដោយខ្លួនឯងពីក្រមួនឃ្មុំ ។ តាម៉ុក បានកសាងវត្តមួយ ប៉ុន្តែមានមនុស្សតិចតួច រឺគ្មានទាល់តែសោះដែលបានយកចង្ហាន់ប្រគេនដល់ព្រះសង្ឃនៅពេលមានពិធីម្តងៗ ។ មីង ពៅ បាននិយាយដោយសើចថា ប្រហែលជាព្រះសង្ឃទទួលរបបអាហារពី តាម៉ុក ដែរហើយបានជាប្រជាជនមិនចាំបាច់ទៅប្រគេនចង្ហាន់នោះ ។

មីង ពៅ មានភាពសប្បាយរីករាយនាពេលសព្វថ្ងៃជាងក្នុងរបបរបស់ តាម៉ុក ។ មីង ពៅ មានផ្ទះមួយ ហើយជីវិតក៏មិនសូវមានការរត់គេចចុះឡើងដូចពីមុនដែរ ។ គាត់មានដីសម្រាប់ធ្វើស្រែ និងដាំដំណាំ ។ មីង ពៅ និយាយថា ប្រជាជននៅអន្លង់វែងបន្តរស់នៅក្នុងសង្គមដោយភាពស្មោះត្រង់ និងមិនមានភាពអាត្មានិយមដែលគ្មាននរណាម្នាក់ត្រូវទុកឲ្យស្រេកឃ្លានពេលដែលមិនមានលទ្ធភាពចិញ្ចឹមខ្លួនឯងទេ ។ អំពើឆបោក ឧក្រិដ្ឋកម្ម និងចោរលួចគឺធ្វើឡើងដោយប្រជាជនមកពីខេត្តផ្សេងៗប៉ុណ្ណោះ មិនមែនជាអ្នកស្រុកអន្លង់វែង ។

## ញ៉ឹក សឹន


ញ៉ឹក សឹន

ញ៉ឹក សឹន មាន កំណើតកើតជានៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ គាត់រៀបការនឹងប្រពន្ធឈ្មោះ សម ឡុន នៅឆ្នាំ ១៩៧០ ។ សព្វថ្ងៃអ្នកទាំងពីរមានកូនបួននាក់ កូនស្រីច្បងមានអាយុ ៣២ឆ្នាំ ។ ពូ សឹន មាន

អាយុ៥៦ឆ្នាំ ហើយប្រពន្ធរបស់គាត់មានអាយុ៥៣ឆ្នាំ ។ ខ្មែរក្រហម ចាប់ផ្តើមកាន់កាប់ភូមិរបស់គាត់នៅស្រុកភ្នំស្រួចក្នុងឆ្នាំ១៩៧០ ក្រោយពេលគាត់រៀបការជាមួយប្រពន្ធគាត់បានបន្តិច ។ ពូ សឹន បន្ត រស់នៅក្នុងភូមិរបស់គាត់រហូតដល់ឆ្នាំ១៩៧៥ ។ ពេលខ្មែរក្រហម វាយយកបានទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ពូ សឹន ត្រូវបានអង្គការ ចាត់តាំងឲ្យធ្វើជាមេក្រុមក្នុងសហករណ៍របស់គាត់ ។ សហករណ៍ នោះមានការបែងចែកជាច្រើនក្រុម ។ នៅក្នុងក្រុមរបស់គាត់មាន សមាជិកពី៥០ទៅ៦០គ្រួសារ ។ តួនាទីសំខាន់របស់គាត់ក្នុងនាម ជាមេក្រុមគឺត្រូវដឹកនាំប្រជាជនធ្វើកសិកម្ម ។

នៅឆ្នាំ១៩៧៨ ពូ សឹន ត្រូវបានជម្លៀសទៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ហើយត្រូវបានតំឡើងតំណែងជាប្រធានសហករណ៍ ។ ពូ សឹន បានឲ្យរៀបរាប់ថា គាត់គឺជាប្រធានសហករណ៍ ប៉ុន្តែគាត់មាន សិទ្ធិនិយាយតិចតួចជាងទំហំនៃតួនាទីរបស់គាត់ ។ គាត់ដឹកនាំមនុស្ស ចូលរួមការប្រជុំជារឿយៗ និងអប់រំប្រជាជនពីមនោគមន៍វិជ្ជាថ្មីៗ និងការបង្រៀនពីគោលនយោបាយរបស់អង្គការ ។ តួនាទីជាប្រធាន សហករណ៍គឺមានឋានៈស្មើនឹងមេឃុំសព្វថ្ងៃ ។ ពេលទៅដល់ទីនោះ បានពីរបីខែ ពូ សឹន ត្រូវបានជម្លៀសម្តងទៀតនៅចុង ឆ្នាំ១៩៧៨ ដោយសារការវាយប្រហារពីសំណាក់កងទ័ពវៀតណាម ។ ពូ សឹន និងគ្រួសារ ក៏ដូចជាសមាជិកក្រុមរបស់គាត់ និងអ្នកភូមិបានភៀស ខ្លួនទៅព្រំដែនជាមួយនឹងខ្មែរក្រហម ។ នៅជិតព្រំដែនថៃ ពូ សឹន មាន ជម្រើសតែមួយគត់គឺត្រូវដើរតាមហ្វូងរបស់មហាជន ។ ចាប់ពីឆ្នាំ ១៩៧៩ដល់១៩៨៩ ពូ សឹន និងគ្រួសារផ្លាស់ពីជំរុំបណ្តោះអាសន្ន ទៅជំរុំមួយទៀតជាមួយខ្មែរក្រហមដទៃទៀតរហូតដល់ចំណុច៨០៣ ដែលមានទីតាំងនៅខាងលិចកន្លែងត្រួតពិនិត្យព្រំដែនជាំស្រង៉ាំ ។ គាត់រស់នៅទីនោះមួយរយៈមុននឹងផ្លាស់ទៅភូមិអូរដ្ឋាវ ។ ពូ សឹន បាននិយាយថា ការរត់ភៀសខ្លួនដំបូងមានការពិបាកណាស់ពិសេស នៅដើមឆ្នាំ១៩៧៩ ពេលដែលមានអាហារតិចតួចសម្រាប់បរិភោគ ។ ពេលឈប់សម្រាកប្រជាជនបានដឹកដំឡូងថៃនិងដំណាំបន្លែដទៃទៀត ដែលបានមកពីមេដឹកនាំខ្មែរក្រហមបង់លុយទៅឲ្យកសិករថៃ ។ ប៉ុន្តែ ក្រោយមកអង្គការអន្តរជាតិបានទិញអាហារជំនួយពីជំរុំខ្មែរក្រហម ដើម្បីចែកចាយឲ្យអ្នកភូមិ ។ ខ្មែរក្រហមបានកសាងឃ្លាំងបីបួនមាន ទំហំ៣០គុណនឹង៦០ម៉ែត្រសំរាប់ផ្ទុកអង្ករ ប្រេង ត្រីងៀត និងអាហារ កំប៉ុង និងរបស់របរចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃ ។ ពូ សឹន និយាយទៀតថា អ្នកភូមិអាចប្រមូលអង្ករពីឃ្លាំងតាមចិត្តចង់ និង អាចរកអាហារបន្ថែមទៀតពីក្នុងព្រៃ ។ ចំពោះ ពូ សឹន ការហូបចុកមាន លក្ខណៈគ្រាប់គ្រាន់ជាងប្រជាជនផ្សេងទៀតដែលរស់នៅក្នុង ប្រទេសកាលពេលនោះ ។

នៅឆ្នាំ១៩៩០ ភូមិអូរដ្ឋាវទាំងមូលត្រូវបានផ្លាស់ប្តូរ ហើយអ្នកភូមិទាំងអស់ត្រូវបានបញ្ជូនចុះពីភ្នំដងរែកឲ្យទៅរស់នៅ អន្លង់វែង ជាកន្លែងដែលអ្នកទាំងនោះអាចសាងសង់ផ្ទះថ្មី និងផ្លូវថ្មី ។ ប៉ុន្តែគ្រួសាររបស់ពូ សឹន មិនបានចុះពីលើភ្នំទេរហូតដល់ឆ្នាំ១៩៩២ ពីព្រោះកូនរបស់គាត់ឈឺ ។ ពូ សឹន ខ្លួនឯងក៏ឈឺដែរ និងមានសុខភាព ខ្សោយផង ហេតុនេះហើយ បានជាគាត់មិនត្រូវបានហៅឲ្យទៅ ប្រយុទ្ធនៅខ្សែត្រៀមខាងមុខ ។ ជាទូទៅ ពូ សឹន ត្រូវបានចាត់តាំង ឲ្យដឹកជញ្ជូនអាវុធនិងស្បៀងទៅកងទ័ពនៅខ្សែត្រៀមខាងមុខ ។ ពេលដែល ពូ សឹន មកដល់អន្លង់វែង គាត់បានមករស់នៅភូមិដែល គាត់រស់នៅសព្វថ្ងៃនេះ ឈ្មោះថាភូមិផ្គៀកជ្រុំ ឃុំដ្ឋាវ ស្រុកត្រពាំង ប្រាសាទ ។

ក្រោមការគ្រប់គ្រងរបស់តាម៉ុក (១៩៩០-១៩៩៨) ត្រពាំងប្រាសាទស្ថិតនៅក្រោមស្រុកអន្លង់វែង ។ ពូ សឹន នៅតែបន្ត រស់នៅសមរភូមិក្រោយជាមួយគ្រួសាររបស់យោធាដែលយោធា ទាំងនោះកំពុងប្រយុទ្ធនៅសមរភូមិមុខ ។ គាត់ជួយធ្វើស្រែនិងលើ របស់ធូន់ៗឲ្យទៅយោធានៅសមរភូមិ ។ ពូ សឹន ក៏ធ្វើស្រែសម្រាប់ ខ្លួនឯងដែរដើម្បីផ្គត់ផ្គង់ការហូបចុកប្រចាំថ្ងៃរបស់គាត់ ។ ពូ សឹន និយាយថា គាត់ទទួលបានរបបអាហារគ្រប់គ្រាន់ ។ បើមិនមាន ទំនាក់ទំនងល្អនិងតួនាទីសំខាន់នៅក្នុងខ្មែរក្រហមទេនោះនឹងអាចទទួល បានរបបអាហារទាល់តែសោះ ។ ករណីរបស់ ពូ សឹន គឺជាករណី ពិសេស ។

ពូ សឹន បានដឹងតិចតួចណាស់ពី តាម៉ុក និងរឿងរបស់ តាម៉ុក ដូចជាជំហររបស់គាត់ក្នុងការប្រណិប័តន៍ សាសនា ជំនួញ និង សន្តិសុខ ។ គាត់ដឹងតែមួយគត់គឺប្រជាជនអាចសូត្រធម៌នៅក្នុងភូមិ បាននៅពេលមានមនុស្សស្លាប់ ។ អ្នកភូមិអាចទិញគ្រឿងសក្ការបូជា ដូចជាទៀន ធូប ដែលនាំចូលពីប្រទេសថៃ ។ ពូ សឹន ក៏អាចទិញអាហារ និងសម្ភារផ្សេងទៀតដែលអ្នកភូមិទិញពីថៃយកមកលក់ក្នុងភូមិ ។

បច្ចុប្បន្ននៅក្នុងភូមិរបស់គាត់ មានប្រជាជនដែលមានស្រុកកំណើតផ្សេងៗគ្នា ខ្លះមកពីកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ និងខេត្តដទៃ ដែលអ្នកទាំងនោះពីមុនជាអតីតកម្មាភិបាលខ្មែរក្រហម ។ ក្រោមរបបគ្រប់គ្រង តាម៉ុក ភូមិរបស់ ពូ សឺន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ៦០៧ ។

## ទូ ណោម


ទូ ណោម

ទូ ណោម មានស្រុកកំណើតនៅភូមិកន្ទួរ ឃុំដើមបុស្ស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ គាត់មានអាយុ៥៧ឆ្នាំ ហើយបានរៀបការនឹង ឃឹម ផន អាយុ៥២ឆ្នាំ នៅឆ្នាំ១៩៨២ ព្រមទាំងមានកូនប្រាំបីនាក់ ។ ពូ ណោម បានចូលរៀននៅសាលាវត្តមួយក្នុងក្រុងភ្នំពេញ ។ កូនរបស់គាត់ធ្លាប់បានចូលរៀនអក្សរខ្លះក្នុងអំឡុងការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងទសវត្សរ៍៨០ និង៩០ ។

ពូ ណោម បានចូលបដិវត្តន៍នៅឆ្នាំ១៩៧៣ ប៉ុន្តែមិនមែនដោយស្ម័គ្រចិត្តទេ ។ ពេលសម្តេច សីហនុ ត្រូវបានទម្លាក់ពីតំណែង ហើយកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមឥណ្ឌូចិន ពូ ណោម បានភៀសខ្លួនមកភ្នំពេញដោយស្នាក់អាស្រ័យនៅក្នុងវត្តមួយ ដើម្បីគេចពីការកេណ្ឌឲ្យធ្វើយោធាខ្មែរក្រហម ។ ប៉ុន្តែពេលដែលគាត់មកលេងបែកចាននៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានចាប់គាត់ឲ្យធ្វើជាយោធាខ្មែរក្រហមតែម្តង ។ ដំបូង ពូ ណោម ត្រូវបានបញ្ជូនទៅអូរជ្រៃដើម្បីធ្វើការផ្នែករដ្ឋបាលនិងផ្គត់ផ្គង់ស្បៀងដល់យោធា ។ នៅខែមេសា ឆ្នាំ១៩៧៥ ពូ ណោម ត្រូវបានបញ្ជូនមកភ្នំពេញ ហើយបញ្ជូនបន្តទៅខេត្តរតនគិរីដែលមានមូលដ្ឋាននៅបរកែវ ដើម្បីការពារព្រំដែន និងសាងសង់ស្ពាននៅទីនោះក្រោមការគ្រប់គ្រងពីមេបញ្ជាការកងពលធំលេខ៨០១ ឈ្មោះ គូ សារឿន ។

ពេលដែលកងទ័ពវៀតណាមវាយចូល ពូ ណោម និងកងពលធំរបស់គាត់បានផ្លាស់ទៅចំណុច១០០១ ។ គាត់ដើរជាមួយនឹងទ័ពរបស់គាត់អស់រយៈពេល២៥ថ្ងៃដោយឆ្លងកាត់ទន្លេធំពីរបី ។ នៅចំណុច១០០១ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ពូ ណោម បានត្រូវបានបញ្ជូនឲ្យទៅបំពេញបេសកកម្មផ្សេងៗក្នុងការវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម និងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅឆ្នាំ១៩៨៣ ពូ ណោម បានផ្លាស់ទៅច្រកចេញចូលព្រំដែនលេខ៨០៨ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់តាម៉ុក ដែរ ហើយច្រកនេះស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រខាងលិចច្រកជាំស្រង៉ាំ ហើយក៏ជាផ្លូវចេញចូលសំខាន់មួយទៀតទៅប្រទេសថៃ នៅពេលដែលកងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាវាយរុញយោធាខ្មែរក្រហមមកដល់នឹងព្រំដែន ជាពិសេសក្នុងអំឡុងការវាយប្រហារនារដូវប្រាំង ។ ខ្មែរក្រហមបានបោះជំរុំនៅតាមច្រកចេញចូលផ្សេងៗតាមជួរភ្នំដងរែក ។ ជំរុំទាំងនេះមិនត្រឹមតែប្រើសម្រាប់ជាចំណុចក្នុងដកថយប៉ុណ្ណោះទេ តែក៏ជាកន្លែងសម្រាប់ស្ត្រី និងកុមាររស់នៅជាមូលដ្ឋានរដ្ឋបាលរបស់ខ្មែរក្រហមដែរ ។

ពូ ណោម ចាំយ៉ាងច្បាស់ថា គាត់ពិការជើងស្តាំនៅខែមករា ឆ្នាំ១៩៨៧ ពេលដែលគាត់ធ្វើដំណើរពីជំរំនៅព្រំដែនខ្មែរក្រហមទៅជំរំមួយទៀត ។ គាត់និយាយថា មីនដែលបានបំផ្លាញជើងរបស់គាត់ម្ខាងគឺគ្រាប់មីនផលិតនៅប្រទេសចិនមានទំហំប៉ុនពែងនំអាកោ ។ គាត់បានបន្ថែមទៀតថា មីននោះមិនមែនកប់ដោយទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជាទេ ព្រោះកន្លែងដែលផ្ទុះគឺស្ថិតនៅក្នុងទឹកដីខ្មែរក្រហម ហើយគ្រាប់មីននោះគឺផលិតនៅប្រទេសចិន ។ ក្នុងចំណោមយោធាខ្មែរក្រហមទាំងអស់ ក៏មានយោធាខ្លះមានគំនិតអាក្រក់ដែរដែលមានបំណងមិនល្អជាមួយអ្នកតស៊ូជាមួយគ្នា ។ នៅឆ្នាំ១៩៨៨ ពូ ណោម បានផ្លាស់ទៅនៅភូមិព្រះប្រឡាយ (សព្វថ្ងៃស្រុកត្រពាំងប្រាសាទ) ដែលស្ថិតនៅចម្ងាយ៣០គីឡូម៉ែត្រខាងកើតចំណុចឆែកឆេរព្រះប្រឡាយ ។ ឥឡូវនេះ ព្រះប្រឡាយបានក្លាយជាភូមិនៅជិតព្រំដែនមួយ ។ ពូ ណោម បន្តរស់នៅព្រះប្រឡាយ រហូតដល់ឆ្នាំ១៩៩៧ ទើបផ្លាស់មកស្រុកអន្លង់វែង ។ មួយឆ្នាំក្រោយមក តំបន់អន្លងវែងក៏ត្រូវបានជម្លៀស ព្រោះតែការប្រយុទ្ធគ្នាចុងក្រោយរវាងរាជរដ្ឋាភិបាលកម្ពុជានិងកងទ័ពដែលនៅសេសសល់របស់តាម៉ុក ។ ពូ ណោម បានត្រឡប់អន្លង់វែង

វិញនៅឆ្នាំ១៩៩៩ ។

ក្នុងនាទីជាយោធាខ្មែរក្រហមម្នាក់ ពូ ណោម មានអាហារហូបចុកគ្រប់គ្រាន់ ជាពិសេសចាប់តាំងពីឆ្នាំ១៩៨២ ពេលដែលមានជំនួយជាស្បៀងអាហារបរិបូរ ។ កូនរបស់គាត់ទទួលការអប់រំខ្លះៗ នៅក្នុងជំរំខ្មែរក្រហម ។ ក្រោយពីបម្រើខ្មែរក្រហមអស់ជិត ៣០ឆ្នាំមក ពូ ណោម បាននិយាយថា គាត់មិនទទួលបានអ្វីទាំងអស់ពីការបូជានិងការលះបង់របស់គាត់ ។ គាត់យល់ថា មេដឹកនាំខ្មែរក្រហមបានកេងប្រវ័ញ្ចលើជីវិតនិងកម្លាំងអ្នកភូមិនិងអ្នកដើរតាមខ្លួនដើម្បីបម្រើតណ្ហាអំណាចរបស់ក្រុមខ្លួន ។ គាត់បានអះអាងទៀតថា ការដឹកនាំរបស់ខ្មែរក្រហមគឺពោរពេញទៅដោយអសមត្ថភាព ។ អ្នកដឹកនាំមានភាពវិកលចរិត និងគ្មានអារម្មណ៍សុវត្ថិភាព ។ អ្នកទាំងនោះមិនមានអ្វីដែលពិសេសទេគឺចេះតែមួយគត់គឺប្រើអំណាចសម្លាប់មនុស្សនិងសម្លាប់គ្នាឯងទៅវិញទៅមក ។ គាត់បាននិយាយដោយអស់សង្ឃឹមថា គាត់បានខាតបង់ពេលវេលាជីវិតអស់៣០ឆ្នាំ និងបាត់បង់ ជើងម្ខាងដោយគ្មានបានអ្វីទាំងអស់ ។ ពេលដែលសួរពីតាម៉ុក ពូ ណោម បាននិយាយថា តាម៉ុក មិនបានធ្វើអ្វីទាំងអស់ក្នុងអំឡុងពេលដែលគាត់កាន់អំណាចនៅអន្លង់វែង ។ ទំនប់ទឹក មន្ទីរពេទ្យ សាលារៀន និងផ្លូវ ថ្នល់ដែល តាម៉ុក បានធ្វើគឺតិចតួចណាស់ បើប្រៀបទៅនឹងការរីកចម្រើនរបស់កម្ពុជាសព្វថ្ងៃនេះ ។ ចំពោះពូ ណោម ជីវិតសព្វថ្ងៃគឺល្អខ្លាំងណាស់ ។

### សឹម ថាន




សឹម ថានមានស្រុកកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ មីង ថាន សព្វថ្ងៃមានអាយុ៦៣ឆ្នាំ ហើយប្តីរបស់គាត់ឈ្មោះ នួន ហែម ។ មីង ថាន និង ពូ ហែម រៀបការនៅឆ្នាំ ១៩៧៦ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងពីរមានកូនស្រីម្នាក់ សព្វថ្ងៃមានអាយុ៣១ឆ្នាំ ។ មីង ថាន បានចូលបដិវត្តន៍ក្នុងឆ្នាំ១៩៧០ ក្រោយពីសម្តេច សីហនុ ត្រូវបានផ្តួលរលំ និងក្រោយពីបានឮសេចក្តីប្រកាសស្នើសុំឲ្យប្រជាជនចូលព្រៃម៉ាគី ដើម្បីវាយរំលំរបប លន់ នល់ ។ ក្រោយពី មីង ថាន ចូលបដិវត្តន៍ក្នុងស្រុកត្រាំកក់ គាត់ទទួលការអប់រំនិងបង្ហាត់បង្រៀនពីមនោគមន៍វិជ្ជាបដិវត្តន៍សំខាន់ៗដូចជាការលុបបំបាត់អ្នកមាន និងលើកស្ទួយកម្មករនិងកសិករក្រីក្រ ។ ក្រោយមក មីង ថាន បានអូសទាញអ្នកផ្សេងទៀតឲ្យចូលបដិវត្តន៍ដែរ ។

ពេល មីង ថាន ចូលបដិវត្តន៍ដំបូង គាត់មានអាយុត្រឹម ១៨ឆ្នាំប៉ុណ្ណោះ និងអាចអាននិងសរសេរបាន ព្រោះគាត់រៀននៅថ្នាក់ទី១០ ។

ពីរបីឆ្នាំក្រោយមក មីង ថាន់ ត្រូវបានអង្គការចាត់តាំងឲ្យទៅភ្នំដិនដើម្បីចូលធ្វើយោធានៅសមរភូមិ ។ គាត់ធ្វើនៅក្នុងកងនារីជាមួយនារី៣០០នាក់ផ្សេងទៀត ។ គាត់កាន់កាំភ្លើង និងឈរនៅខ្សែត្រៀមទីពីរ ។ មីង ថាន បាននិយាយថា គាត់ត្រូវប្រយុទ្ធនឹងសត្រូវតែពេលណាចាំបាច់ប៉ុណ្ណោះ ។ គាត់ឈរជើងនៅភ្នំដិនរហូតដល់ខែមេសា ឆ្នាំ១៩៧៥ ប៉ុន្តែមិនបានចូលរួមក្នុងការប្រយុទ្ធចុងក្រោយភ្នំពេញឡើយ ។ ក្រោយពីទីក្រុងភ្នំពេញដួលរលំ មីង ថាន ត្រូវបានបញ្ជូនមកភ្នំពេញជាមួយនឹងកងរបស់គាត់ដោយទទួលបញ្ជាការពារទីក្រុងពីការវាយបកវិញរបស់សត្រូវ ។ មីង ថាន ប្រចាំការនៅស្ពាតអូឡាំពិកជាមួយនឹងយុទ្ធនារីផ្សេងទៀត ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ៨០១ដែលដឹកនាំដោយ តាសារឿន ។

ចូលដល់ដើមឆ្នាំ១៩៧៦ មីង ថាន និងកងនារីរបស់គាត់ត្រូវបានចាត់ឲ្យទៅឈរជើងនៅស្រុកវ៉ឺនសៃ ខេត្តរតនៈគិរី ដើម្បីការពារព្រំដែន ។ ប៉ុន្តែពេលមកដល់ទីនោះ គាត់បែរជាចាត់តាំងឲ្យជួយធ្វើស្រែប្រជាជននៅទីនោះទៅវិញ ។ នៅឆ្នាំ១៩៧៨ តាសារឿន បានដឹងខ្លួនថាគាត់ត្រូវបានអង្គការសង្ស័យ ។ តាសារឿន បានប្រាប់កូនចៅរបស់គាត់កុំឲ្យធ្វើដំណើរតាមទូកចុះទៅទន្លេមេគង្គពេលដែលអង្គការមានការស្នើសុំបែបនេះ ព្រោះអង្គការអាចនឹងយកទៅសម្លាប់ ។ សំណាងល្អ នៅចុងឆ្នាំ១៩៧៨ ក៏មានការវាយប្រហារពីសំណាក់កងទ័ពវៀតណាម ហើយ តាសារឿន ក៏ត្រូវបានរួចជីវិតពីការសម្លាប់របស់អង្គការនៅពេលនោះដែរ ។ គាត់បានដឹកនាំកងពលធំរបស់គាត់ធ្វើដំណើរតាមព្រំដែនឡាវដើម្បីគេចពីការវាយប្រហាររបស់វៀតណាមរហូតដល់កងពលរបស់ទៅដល់កន្លែងមួយហៅថា ចំណុច

១០០១ ដែលជាចំណុចប្រសព្វព្រំដែនកម្ពុជា ថៃ និងឡាវ ។ ក្រោយពីការធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលប្រមាណជាមួយខែ តាសារឿន ត្រូវបានចាប់ខ្លួននិងសម្លាប់ ក្រោយពីមកដល់ចំណុច ១០០១ ។ នៅទីនោះ មឹង ថាន បានជួបជាមួយ តាម៉ុក ដែលជាមេបញ្ជាដ៏មានអំណាចម្នាក់ ។

នៅចំណុច១០០១ មឹង ថាន ត្រូវចាត់តាំងឲ្យធ្វើការនៅមន្ទីរភស្តុភារក្នុងការផ្តល់ និងរៀបចំអង្ករ និងអាហារសម្រាប់យោធាខ្មែរក្រហមដែលអត់ឃ្លាននិងបានគេចខ្លួនពីតំបន់រដ្ឋាភិបាល ។ មឹង ថាន បានធ្វើដំណើរចុះឡើងពីភូមិទៅជំរំនានានៅតាមព្រំដែនថៃជាមួយ តាម៉ុក និងកងទ័ពនៅចន្លោះឆ្នាំ១៩៧៩និង១៩៨៩ រហូតដល់ខ្មែរក្រហមទៅដល់ភូមិអូរស្មាច់លើជួរភ្នំដងរែក ជាកន្លែងកងពលធំខ្មែរក្រហមជាច្រើនជួបជុំគ្នានៅកន្លែងតែមួយ ដូចជាកងពលធំលេខ ៦១២, ៦១៦, ៧៨៥ និង៩៨០ ។ អ្នកដែលរស់នៅទីនោះភាគច្រើនគឺជាប្រពន្ធ និងកូនរបស់យោធាខ្មែរក្រហមដែលកំពុងច្បាំងគ្នានៅសមរភូមិមុខ ។ អ្នកខ្លះទៀតក៏ជាកម្មាភិបាលនិងយោធិនពិការដែរ ។ មឹង ថាន បានជួយរៀបចំអាហារសម្រាប់យោធាដែលមកទទួលរបប និងសម្ភារសឹកផ្សេង ទៀតចាំបាច់ពីមូលដ្ឋានភ្នំដងរែក ។ គាត់បាននិយាយថា នារីៗត្រូវលីផាវ៉ាន់ចុះពីភ្នំដើម្បីយកមកឲ្យយោធាដែលមានសុខភាពខ្សោយ និងស្រេកឃ្លាននៅពេលយោធាទាំងនោះមកដល់ជើងភ្នំ ។

នៅឆ្នាំ១៩៩០ ក្រោយពីខ្មែរក្រហមវាយដណ្តើមបានតំបន់អន្លង់វែងពីរដ្ឋាភិបាល «រដ្ឋកម្ពុជា» មកវិញ និងក្រោយពីមានស្ថេរភាពក្នុងការរស់នៅគ្រប់គ្រាន់ហើយ តាម៉ុក បាននាំប្រជាជនដែលរស់នៅភូមិអូរស្មាច់ទាំងអស់ឲ្យទៅនៅអន្លង់វែង ។ មឹង ថាន ក៏មកកាន់អន្លង់វែងនិងបានរស់នៅរហូតដល់សព្វថ្ងៃនេះ ។ ក្នុងអំឡុងនៃការរស់នៅអន្លង់វែងនៅពីឆ្នាំ១៩៩០ដល់១៩៩៨ ពេលខ្មែរក្រហមធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា មឹង ថាន និងអ្នកដទៃទៀតបានបោះបង់ចោលអន្លង់វែងពីរ បីដងដែរ ។ មានម្តងនោះគាត់ក៏ដូចជាអ្នកដទៃទៀត ត្រូវបានបង្ខំឲ្យដុតផ្ទះឈើដ៏ធំរបស់ខ្លួនដើម្បីការពារកុំឲ្យសត្រូវតាំងមូលដ្ឋានដែលរឹងមាំនៅទីនោះ ។

មឹង ថាន ដឹងពីចរិតនិងគ្រួសាររបស់ តាម៉ុក គួរសមដែរ ព្រោះគាត់គឺជាមិត្តរបស់កូនស្រីម្នាក់ក្នុងចំណោមកូនស្រីទាំងប្រាំរបស់ តាម៉ុក ដែលកូនស្រីនោះមានឈ្មោះថា ខុម ។ ខុម គឺជាកូនស្រីម្នាក់ទៀតរបស់ តាម៉ុក ដែលប្តីរបស់គាត់ឈ្មោះវិន ត្រូវ តាម៉ុក សម្លាប់ចោល ។ តាម៉ុក ជឿទុកចិត្តកូនស្រីនេះណាស់ ។ មឹង ថាន បាននិយាយថា តាម៉ុក គឺជាមនុស្សដែលស្រលាញ់នរណាដែលខិតខំធ្វើការ និងស្អប់មនុស្សដែលខ្ជិល និងចូលចិត្តអង្គុយនិយាយគ្នាលេង ។ មឹង ថាន និយាយថាពេល តាម៉ុក មកមើលភូមិរបស់គាត់ និងមើលឃើញអ្នកភូមិជួបជុំនិយាយគ្នាដោយមិនធ្វើអ្វីទាំងអស់ តាម៉ុក នឹងនិយាយថា «ប្រសិនបើនៅតែបន្តនិយាយគ្នា និងនិយាយដើមអ្នកដទៃគង់តែនិងឈ្លោះគ្នាមិនខាន ។» ប្រសិនបើគាត់ឃើញមនុស្សធ្វើការនៅឡានក្រោយផ្ទះរបស់ខ្លួន គាត់នឹងនិយាយថា «ធ្វើបានល្អណាស់! នឹងមានអាហារសម្រាប់ហូបចុកគ្រប់គ្រាន់ ។ នៅពេលយើងស្លាប់ទៅ អ្នកនៅរស់និងចងចាំដើមឈើដែលយើងដាំ ។ ខ្ញុំសាងសង់ផ្លូវ ទំនប់ទឹក និងអាគារ ដូច្នេះពេលដែលខ្ញុំស្លាប់ទៅប្រជាជននឹងនៅតែមើលឃើញស្នាដៃរបស់ខ្ញុំ ។»

តាម៉ុក គឺមនុស្សសាមញ្ញម្នាក់ដែលហៅអ្នកភូមិរបស់គាត់ថា ងែង រី អ្អែង ។ គាត់ពូកែធ្វើការជាមួយអ្នកភូមិណាស់ ។ អំឡុងពេលរដូវភ្លៀង ពេលដែលពួកផ្កែបបុកឹផ្កក់យំ តាម៉ុក ប្រមូលមនុស្សដប់ទៅម្ភៃនាក់ដើម្បីឆ្ពុះសម្រាប់ធ្វើជាម្ហូបនិងបញ្ជូនទៅអោយយោធា ។ គាត់ក៏ចូលរួមដើរចាប់កង្កែបនិងត្រីជាមួយអ្នកទាំងនោះដែរ ។ គាត់សប្បាយនឹងការងារនេះណាស់ ។ តាម៉ុក ជួនកាលគឺចិត្តល្អតែពេលខ្លះក៏ជាមនុស្សប្រើហិង្សាដែរ ។ ប្រសិនបើគាត់ឲ្យលុយឬនាឡិកាមកយើង យើងត្រូវតែទទួល ហើយដើរចេញភ្លាម បើមិនដូច្នោះទេ ពេលមានអ្នកណា ម្នាក់មកសុំគាត់ គាត់និងប្តូរចិត្តនឹងឲ្យទៅអ្នកក្រោយវិញ ។ តាម៉ុក ស្អប់មនុស្សណាដែលមិនស្មោះត្រង់និងកុហកណាស់ ហើយគាត់នឹងដាក់ទារុណកម្មយ៉ាងខ្លាំងទៅលើចោរលួចនិងប្លន់ ។

តាម៉ុក បានបាត់បង់ជើងម្ខាងនៅក្នុងឆ្នាំ១៩៨២ ពេលគាត់បញ្ជាទាហានឲ្យធ្វើផ្លូវដោយគ្រាក់ទ័រឈូសដីដែលប៉ះនឹងគ្រាប់មីន ។ អម្បែងគ្រាប់បានផ្ទាតទៅប៉ះជើងគាត់ ។ ក្នុងឆ្នាំ១៩៧៩ តាម៉ុក បានបញ្ជាឲ្យសម្លាប់កូនប្រសារប្រុសរបស់គាត់ម្នាក់ឈ្មោះ វិន ក្រោយពីគាត់រកឃើញថា វិន បានជួញដូរអាវុធទៅឲ្យចោរព្រៃ ថៃ ។ មឹង ថាន បាននិយាយថា តាម៉ុក មានភ័ស្តុតាងមុននឹងគាត់សម្រេចធ្វើបែប

នេះ ។ តាម៉ុក និយាយថា "ខ្ញុំនឹងចេញបញ្ជាឲ្យសម្លាប់អា វិន ។ វាគឺជាជនក្បត់ដែលចាញ់បញ្ឆោតពួកសេ.អ៊ី.អា ហើយពុករលួយជាមួយខ្មាំង ។ ខ្ញុំមិនដឹងថានឹងមានអ្វីអាចកើតឡើងចំពោះយើងទាំងអស់គ្នាទេបើទុកជីវិត អា វិន" ។ មីង ថាន បាននិយាយទៀតថា ក្រោយពេលគិតពិចារណារួច តាម៉ុក ក៏បញ្ជាឲ្យកូនចៅរបស់គាត់ទៅបាញ់សម្លាប់ វិន ពេលដែល វិន កំពុងដេកលើអង្រឹងក្រោមផ្ទះ ។ តាម៉ុក មានកូនស្រីទាំងអស់ប្រាំនាក់ ក្នុងចំណោមអ្នកទាំងប្រាំ មានម្នាក់ស្លាប់ ។

តាម៉ុក អនុញ្ញាតឲ្យប្រជាជនគោរពជំនឿ ប៉ុន្តែកុំឲ្យជឿខ្លាំងពេក ។ គាត់ខ្លួនឯងក៏ជឿលើអបិយជំនឿដែរ ។ គាត់អនុញ្ញាតឲ្យមានការកសាងវត្តដែលគាត់បានដាក់ឲ្យមានព្រះសង្ឃពីរ បីអង្គ និងកសាងចេតិយមួយចំនួនដែរ ។ សព្វថ្ងៃវត្តនេះបានក្លាយជាវត្តអន្លង់វែង ។ ប៉ុន្តែដោយសារព្រះសង្ឃមួយអង្គមានជាប់ពាក់ព័ន្ធនឹងរឿងស្នេហា តាម៉ុក ក៏បិទវត្តនេះតែម្តង ។ តាម៉ុក មិនចូលចិត្តនរណាដែលជួបប្រជុំគ្នា និងមានជំនឿលើប្អូអ្វីមួយឡើយ ព្រោះគាត់ជឿថាការធ្វើបែបនេះអាចប៉ះពាល់ដល់ការគ្រប់គ្រងរបស់គាត់នៅអន្លង់វែង ។ តាម៉ុក អនុញ្ញាតឲ្យមានការដោះដូរទំនិញ ប៉ុន្តែនៅពេលដែលវាហួសពីការគ្រប់គ្រង គាត់ក៏បិទមិនឲ្យមានការដោះដូរ ។ គាត់អនុញ្ញាតឲ្យមានវត្តអារាម ប៉ុន្តែនៅពេលដែលប្រជាជនមានជំនឿខ្លាំង គាត់ក៏បិទមិនឲ្យមានវត្តទៀត ។ ឧទាហរណ៍ មានករណីនារីម្នាក់ឈ្មោះ កា ពុំ ដែលត្រូវបានសម្លាប់ជាមួយនឹងគ្រួសាររបស់គាត់ដោយសារជឿលើការព្រលឹងចូលរូប ។ ប៉ុន្តែ មីង ថាន និយាយថាមុនពេល តាម៉ុក ចង់ចាប់ខ្លួននរណាម្នាក់ គាត់បាន ព្រមានអ្នកនោះមុនរួចហើយ ។

មីង ថាន ក៏ធ្លាប់បានលក់នំបញ្ចុកនៅអន្លង់វែងដែរ ប៉ុន្តែពេលដែល តាម៉ុក ប្រាប់គាត់ឲ្យឈប់លក់គាត់ក៏ឈប់ដែរទៅ ។ ប្រាំខែក្រោយមក តាម៉ុក ក៏បានចាប់ខ្លួនមនុស្សមួយចំនួនដែលនៅតែបន្តលក់ដូរ ព្រោះគាត់មិនចង់ឲ្យមានការដោះដូរគ្នាទេ ។ អ្នកដែលត្រូវបានចាប់ខ្លួននោះ ក្រោយមកត្រូវបានហៅថា "ចិនយាំ" ។ អ្នកទាំងនោះត្រូវបានយកទៅរស់នៅក្នុងភូមិមួយខាងកើតភូមិទួលគ្រួស ។

### សុខ ខាន់

សុខ ខាន់ មានអាយុ៦០ឆ្នាំ មានស្រុកកំណើតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ប្តីរបស់គាត់ជាប្រធានអង្គភាពយោធាមួយរបស់ខ្មែរក្រហម ។ ពេលដែលកងទ័ពវៀតណាមចូលមកនៅឆ្នាំ១៩៧៩ មីង ខាន់ និងកូនបួននាក់ត្រូវបានជម្លៀសជាមួយយោធាខ្មែរក្រហមទៅព្រំដែនថៃ ។ ប្តីរបស់គាត់នៅពីខាងក្រោយដើម្បីបង្អាក់ដំណើររបស់ទាហានវៀតណាម ។


សុខ ខាន់

ក្នុងអំឡុងពេលដែលខ្មែរក្រហមកំពុងដកថយ មីង ខាន់ បាននិយាយថា កាលនោះមិនមានអាហារហូបទេ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៩ គាត់បានមកដល់ជំរំខ្មែរក្រហមលើភ្នំដងរែក ។ ដោយសារតែជាប្រពន្ធរបស់យោធាសកម្មម្នាក់របស់ខ្មែរក្រហម មីង ខាន់ និងកូនបានទទួលអាហារបរិភោគគ្រប់គ្រាន់ពេលមកដល់ជំរំខ្មែរក្រហម ។ របបអាហារត្រូវបានផ្តល់យ៉ាងទៀងទាត់ រួមមានអង្ករ ប្រេង ស្ករស ត្រីខកំប៉ុង ត្រីងៀត និងសាច់ ។ មីង ខាន់ បាននិយាយថា គាត់មិនដែលទទួលបានត្រីស្រស់ហូបទេ គឺហូបតែអាហារកំប៉ុង ។ ដោយសារជំរំខ្មែរក្រហមនៅលើភ្នំ ការដឹកត្រីស្រស់គឺជាការលំបាកណាស់ ។ កូនប្រុសពីរនាក់របស់គាត់ត្រូវបានបញ្ជូនឲ្យទៅដឹកសព្វាវុធនិងបើកឡានទាហាន ។ ពេលខ្លះ មីង ក៏ត្រូវបានខ្មែរក្រហមស្នើឲ្យជួយចម្អិនម្ហូបសម្រាប់កងទ័ព និងកាន់អាវុធដើម្បីការពារខ្លួន ។ នៅឆ្នាំ១៩៨៦-១៩៨៧ ប្តីរបស់គាត់បានរត់ចោលជួរជាមួយនឹងកូនចៅរបស់គាត់ប្រាំបីនាក់ទៀត ។ គាត់បានលង់ស្រលាញ់នារីម្នាក់នៅអង្គភាពជាមួយគ្នាមុននឹងគាត់ផ្តាច់ខ្លួន ។ មីង ខាន់និយាយថា ប្តីរបស់គាត់មានជម្លោះជាមួយនឹងមេកងម្នាក់ទៀតមុនពេលគាត់រត់ ពេលដែលសួរថា តើគាត់បានដឹងដំណឹងនេះដោយវិធីណា? មីង ខាន់បានឆ្លើយថាទាហានខ្មែរក្រហមម្នាក់បានប្រាប់នូវដំណឹងនេះមកគាត់ ។ ទាហានម្នាក់នោះបានប្រាប់ថា "ប្តីរបស់ខ្ញុំបានរត់ចោលជួរហើយ ។ ចាប់ពីពេលនេះទៅ ខ្ញុំនឹងរស់នៅជាមួយទាហាននោះ" ។ មីង ខាន់ ត្រូវបានអនុញ្ញាតឲ្យដើរហើរដោយសេរីនៅតំបន់ខ្មែរក្រហម ។ គាត់មិននៅឯកោទេ ហើយរបបអាហាររបស់

គាត់ក៏មិនកាត់បន្ថយដែរ ទោះបីជាប្តីរបស់គាត់រត់ចោលជួរក៏ដោយ ។ នេះប្រហែលជាមកពីគាត់មានកូនៗនៅបម្រើការខ្មែរក្រហម ។

បច្ចុប្បន្ននេះប្តីរបស់មីង ខាន់ កំពុងរស់នៅស្រុកព្រែកប្រសប់ ខេត្តក្រចេះជាមួយនឹងប្រពន្ធក្រោយ និងកូនៗរបស់គាត់ ។ មីង ខាន់ បាននិយាយថា ប្រពន្ធក្រោយរបស់ប្តីគាត់មានសាច់ញាតិនៅខេត្តក្រចេះដែលមានទំនាក់ទំនងល្អជាមួយនឹងមេបញ្ជាការរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ប្រពន្ធក្រោយនេះជាអ្នកជួយរៀបចំក្នុងការរត់គេចនេះ ។ មីង ខាន់ បាននិយាយថា គាត់សប្បាយចិត្តណាស់ដែលដឹងថាប្តីរបស់គាត់នៅមានជីវិតរស់ ។ គាត់បានមកលេងមីង ខាន់ម្តងនៅអន្លង់វែង ។ មីង ខាន់ បាននិយាយថា តាម៉ុកគឺជាមនុស្សល្អ ។ គាត់មិនដែលមានអារម្មណ៍មិនល្អចំពោះតាម៉ុក ទេ ។




**សួន ធី**

សួន ធី មានអាយុ ៦៥ឆ្នាំ មានស្រុកកំណើតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់១៩៧៩ គាត់រស់នៅស្រុកកោះសូទិនជាមួយគ្រួសារ ។ មីង ធី រៀបការនឹងប្តីទីមួយរបស់គាត់ និងមានកូនប្រាំពីរនាក់មុនរបបខ្មែរក្រហម ។ គាត់បានឆ្លងកាត់រឿងរ៉ាវជាច្រើននៅរបបខ្មែរក្រហម ។

សមាជិកគ្រួសារទាំងអស់របស់គាត់បានរួចរស់មានជីវិតពីរបបនេះ ។ នៅឆ្នាំ១៩៧៩ ប្តីទីមួយរបស់មីង ធី បានចាកចោលគាត់ និងកូនៗ ទៅរៀបការជាមួយស្រ្តីម្នាក់ទៀត ។ ដោយសារតែការឈឺចាប់នេះ មីង ធី បានចាកចោលកូនៗ ដោយទុកឲ្យឪពុកម្តាយរបស់គាត់ជាអ្នកមើលថែ ។ គាត់មានបំណងធ្វើដំណើរទៅជំរំជនភៀសខ្លួននៅប្រទេសថៃដើម្បីស្វែងរកការងារនិងឱកាសទៅរស់នៅបរទេស ។ នៅពេល ដែលមីង ធី មកដល់ស្រុកសូត្រនិគម ខេត្តសៀមរាប គាត់បានជួបខ្មែរក្រហមមួយក្រុម ហើយបញ្ចុះបញ្ចូលគាត់ឲ្យចូលរួមជាមួយក្រុមខ្លួននិងប្រាប់គាត់ថា ផ្លូវទៅប្រទេសថៃពោរពេញទៅដោយចោរព្រៃនិងមីន ។ មីង ធី ក៏យល់ព្រមចូលរួមដំណើរជាមួយក្រុមនោះ ។ ប៉ុន្តែខ្មែរក្រហមក៏បានតាមដានគាត់ព្រមទាំងសួរគាត់ថា តើគាត់ជាចារកម្មឬមិនមែន? មីង ធី បាននិយាយថា មិនមែនទេ ។

មីង ធី បាននិយាយថា ពេលធ្វើដំណើរនោះ ក្រុមរបស់គាត់ត្រូវជួយមនុស្សដែលរស់នៅក្បែរសមរភូមិប្រយុទ្ធ ។ មីង ធី ត្រូវចាត់តាំងធ្វើអ្នកបញ្ចុះបញ្ចូលអ្នកភូមិឲ្យចូលជាមួយខ្មែរក្រហម ។ ជួនកាលគាត់នាំអ្នកភូមិមកពីភាគីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅទទួលរបបអាហារពីខ្មែរក្រហម និងមិនបានបង្ខំអ្នកទាំងនោះចុះចូលជាមួយក្រុមរបស់ខ្លួនទេ ។ រយៈពេលប៉ុន្មានឆ្នាំកន្លងផុតទៅ មីង ធី បានក្លាយជាប្រធានចាត់ចែងកិច្ចការសង្គម ។ គាត់ត្រូវបានទទួលប្រាក់ខែមួយពាន់បាតក្នុងមួយខែដែលខ្ពស់ជាងប្រាក់ខែរបស់យោធាថ្មើរជើងបន្តិចដែលទទួលបាន៦០០បាតក្នុងមួយខែ ។ គោលការណ៍របស់ខ្មែរក្រហមបានផ្លាស់ប្តូរ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមមិនបានបើកប្រាក់ខែឲ្យយោធា ឬកម្មាភិបាលឡើយ ។

មីង ធី ជួបជាមួយនឹងប្តីក្រោយរបស់គាត់នៅឆ្នាំ១៩៨២ ដែលមានអាយុក្មេងជាងគាត់១០ឆ្នាំ និងរស់នៅជាមួយគ្នារហូតដល់បច្ចុប្បន្ន ប៉ុន្តែមិនមានកូនចៅទេ ។ នៅអំឡុងឆ្នាំ១៩៨៧ មីង ធី ត្រូវបានបំពុលក្រោយពីផឹកទឹកបឹងមានលាយថ្នាំពុលដែលកងទ័ពវៀតណាមបានដាក់ចូល ។ ក្នុងអំឡុងសង្គ្រាមភាគីទាំងពីរបានប្រើថ្នាំពុលនិងខស្ម័នពុលប្រឆាំងគ្នាទៅវិញទៅមក ។ ក្រោយពីផឹកទឹកនោះរួចហើយ មីង ធី បានធ្លាក់ខ្លួនឈឺ និងត្រូវបានដឹកទៅមន្ទីរពេទ្យខ្មែរក្រហមនៅជំរំភៀសខ្លួនអូរត្រាវ នៅតាមព្រំដែនកម្ពុជា-ថៃ ។ ប្តីក្រោយរបស់គាត់ត្រូវបានអនុញ្ញាតឲ្យមកជាមួយគាត់ដើម្បីមើលថែគាត់ ។ ប៉ុន្តែពេលដែល មីង ធី ជាសះស្បើយ អ្នកទាំងពីរមិនបានត្រលប់មកស្រុកសូត្រនិគមវិញទេគឺស្នាក់នៅភូមិតាមព្រំដែនលើភ្នំដងរែកដែលមានឈ្មោះថា ភូមិថ្កូវ ឬភូមិទឹកខៀវ បច្ចុប្បន្នមានទីតាំងនៅច្រកព្រំដែនជាំស្រងាំកម្ពុជា-ថៃ ។ តាម៉ុក បានបញ្ជាក់ថាភូមិនោះគឺជាភូមិរបស់ខ្មែរក្រហម តែសព្វថ្ងៃខ្ញុំគឺជារបស់ភូមិថៃ ។

ក្រោយពីនៅភូមិថ្កូវបានពីរបីឆ្នាំមក មីង ធី និងប្តីត្រូវបាន

បញ្ជូនទៅនៅអន្លង់វែង ដែលមានទីតាំងនៅជិតផ្សារអន្លង់វែងសព្វថ្ងៃនេះ ។ រស់នៅទីនោះបានពីរបីឆ្នាំ ប្តីរបស់គាត់បានឈ្លោះវាយតប់គ្នាជាមួយនឹងកម្មាភិបាលម្នាក់ ។ មីង ធី បាននិយាយថា កម្មាភិបាលម្នាក់នោះបានកិបលុយប្រាក់ខែរបស់ប្តីគាត់ ។ ពេលប្តីរបស់គាត់ទៅសុំលុយកម្មាភិបាលនោះមិនព្រមប្រគល់ឲ្យទេ ។ ដោយមានអារម្មណ៍ថាមានភាពមិនស្មោះត្រង់ ប្រព្រឹត្តអំពើពុករលួយ ប្តីរបស់គាត់បានខឹងយ៉ាងខ្លាំង ហើយក៏សម្រេចចិត្តមករស់នៅភូមិទួលគ្រួសក្នុងនាមប្រឆាំងនឹងអំពើអយុត្តិធម៌ ។

ភូមិទួលគ្រួស មិនមែនជាភូមិធម្មតាទេនៅអន្លង់វែង គឺជាភូមិមួយដែលខ្មែរក្រហមឲ្យមនុស្សដែលបានប្រព្រឹត្តបទឧក្រិដ្ឋដូចជាអតីតទាហានរដ្ឋាភិបាល ទាហានរបស់លោកតា សឺន សាន ទាហានហ៊ុនស៊ិនប៉ិច និងអ្នកដែលលួចលក់គោក្របី និងអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗទៀត ។ មីង ធី និងប្តីខ្លួនត្រូវបានបញ្ជូនទៅភូមិនោះដោយសារប្រវត្តិរូបរបស់គាត់ធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ។ តាមសម្តី របស់ មីង ធី ទួលគ្រួសគឺជាគុកមួយដែលគ្មានជញ្ជាំង ។ មនុស្សជាច្រើនដែលត្រូវបានបញ្ជូនមកភូមិនេះជាការធ្វើទារុណកម្ម និងមានមួយចំនួនត្រូវបានគេសម្លាប់ចោល ។ នៅសម័យមុន ភូមិនេះមានផ្ទះពីរបីជួរ ។ បច្ចុប្បន្ន មានភាពតូចជាងមុន និងមានតែផ្ទះពីរជួរតែនៅអមសងខាងផ្លូវប៉ុណ្ណោះ ។ មនុស្សជាច្រើនបានបោះបង់ទីនេះចោលក្រោយឆ្នាំ១៩៩៨ ប្រហែលមកពីកេរ្តិ៍ឈ្មោះរបស់ភូមិនេះថាជាភូមិ «សាច់ហើម សាច់ស្អុយ» ដែលត្រូវបានស្គាល់ក្នុងអំឡុងដើមទសវត្សរ៍៩០ ក្រោមរបបខ្មែរក្រហម និងការចងចាំដ៏អាក្រក់មួយដែលអ្នកទាំងនោះមិនចង់រំឭកនិងជាប់ទាក់ទងជាមួយទៀត ។

ភូមិទួលគ្រួសនៅតែជាតំណាងឲ្យរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមដដែល ។ អ្នកភូមិនេះ ត្រូវភ្ញាក់ពីព្រលឹមម៉ោងប្រាំព្រឹកដើម្បីហាត់ប្រាណ និងរៀបចំខ្លួនសម្រាប់ការប្រជុំមុនពេលចេញទៅធ្វើស្រែ ។ ប្រជាជនធ្វើនៅក្នុងក្រុមសាមគ្គីដែលជួយធ្វើស្រែចម្ការនៅលើដីគ្នាទៅវិញទៅមក ប៉ុន្តែអាចរក្សាទុកផលខ្លះសម្រាប់ហូបចុកផ្ទាល់ខ្លួន ។ រៀងរាល់ថ្ងៃមានការប្រជុំបីលើកដែល មីង ធី បាននិយាយថា គ្មានអ្វីទាំងអស់ក្រៅពីការគំរាមគំហែងនិងបន្ទាចអ្នកភូមិ ។ គាត់បាននិយាយទៀតថា នៅអំឡុងពេលនោះ ខ្មែរក្រហមប្រើវិធីសាស្ត្របីក្នុងការកែប្រែមនុស្ស ។ ដំបូងពេលដែលមនុស្សម្នាក់ត្រូវបានរកឃើញថា បានប្រព្រឹត្តខុសអ្នកនោះនឹងត្រូវហៅមកអប់រំ និងប្រាប់ឲ្យកែប្រែ ។ វិធីទីពីរគឺ ពេលដែលនរណាម្នាក់ប្រព្រឹត្តកំហុសដដែលៗ អ្នកនោះនឹងត្រូវគេវាយដំដើម្បីជាការព្រមាន ។ វិធីទីបី គឺពេលកំហុសដដែលៗជាលើកទីបី ខ្មែរក្រហមនឹងបញ្ជូនទៅភូមិទួលគ្រួសឲ្យធ្វើការយ៉ាងធ្ងន់ដោយមានការគំរាមដាក់ទណ្ឌកម្មនិងសម្លាប់ចោល ។ ជំហានដំបូងខ្មែរក្រហមហៅថា «ការអប់រំ» ជំហានទីពីរហៅថា «ការព្រមាន» និងជំហានទីបីហៅថា «ទុកចោលម្តុំ» ។

មីង ធី បានឃើញមនុស្សពីរបីនាក់ត្រូវបានសម្លាប់នៅជាយភូមិ ។ គាត់ភ័យខ្លាំងណាស់ ។ គាត់បាន ដឹងថាមានមនុស្សត្រូវបានយកទៅសម្លាប់ដោយបានគាត់អើតមើលតាមបង្អួច ហើយគាត់មិនហ៊ានចេញមកក្រៅទេ ។ គ្មាននរណាម្នាក់ហ៊ានធ្វើអ្វីទាំងអស់នៅទួលគ្រួស ។ មនុស្សម្នាក់ត្រូវបានចាប់បញ្ចូលក្នុងឡានតូច ។ មួយរយៈក្រោយមក ខ្មែរក្រហមបានជីកគុកឃុំឃាំងនៅខាងក្រោមដី ។ មានរណ្តៅមួយចំនួននៅភូមិនោះ ។ អ្នកភូមិនេះមិនទទួលបានរបបអាហារហូបចុកទេ ។

មីង ធី បាននិយាយថា តាម៉ុក គឺជាមនុស្សចិត្តល្អ ប៉ុន្តែឆេវឆាវ និងហិង្សាពេលដែលគាត់ខឹង ។ គាត់ជួនកាលស្រែកជេរពាក្យអាក្រក់ៗដាក់អ្នកភូមិដែលមិននិយាយជាមួយគាត់ពេលដែលគាត់ខឹង ។ តាម៉ុក នឹងឲ្យលុយឬអ្វីមួយពេលដែលនរណាម្នាក់សុំគាត់ ។ កំហឹងរបស់គាត់គឺដូចជាភ្លើងចំបើងអ៊ីចឹង ។ មីង ធី បានជួប តាម៉ុក លើកដំបូងនៅជំរំភៀសខ្លួនអូរត្រាវ ។ មីង ធី បាននិយាយថា តាម៉ុក ដឹងពីវិធីធ្វើថ្នាំសម្រាប់ព្យាបាលជំងឺកុមារទៀតផង ។ ចំពោះគាត់ តាម៉ុក គឺជាមនុស្សសេរីនិយមនិងមានការចេះដឹងគួរសមដែរ ។ គាត់បានកសាងវត្តមួយដែលឥឡូវនេះហៅថាវត្តអន្លង់វែង ។ ប៉ុន្តែមានព្រះសង្ឃមួយអង្គធ្វើឲ្យខូចកិត្តិនាមរបស់វត្ត តាម៉ុក ក៏រំលាយវត្តនេះចោលតែម្តង ។ មីង ធី បាននិយាយទៀតថា តាម៉ុក ក៏ធ្លាប់ឲ្យអាហារទៅអ្នកដែលអត់ឃ្លានដែរ ។

ករណីស្ត្រីក្មេងម្នាក់ឈ្មោះ ក្រពុំ គឺជាករណីចម្លែកមួយ ។ មីង ធី បាននិយាយថា ក្រពុំគឺជាក្មួយស្រីម្នាក់របស់ តាម៉ុក ប៉ុន្តែគ្រួសារទាំងអស់របស់ ក្រពុំ ត្រូវបានសម្លាប់ក្រោយពីរកឃើញថា គ្រួសារ

ធ្វើពិធីចូលរូបដែលជាអបិយជំនឿមួយ ហៅព្រលឹងខ្មោចចូលសន្និត នៅលើរូបកាយរបស់មនុស្ស ។ ក្រពុំ និងគ្រួសារត្រូវបាននាំទៅ សម្លាប់នៅភូមិទួលគ្រួស ប៉ុន្តែអ្នកភូមិបានទុកឲ្យនៅរស់ប្រហែល មួយឆ្នាំ ។ ខ្មែរក្រហមដឹងថា ក្រពុំ នៅមានជីវិតរស់ ខ្មែរក្រហមក៏សម្លាប់ ក្រពុំ និងគ្រួសារចោលតែម្តង ។ តាម៉ុក គឺជាមនុស្សដែលចេះគិត ពិចារណានិងមានគំនិតធូររលុងចំពោះមនោគមន៍វិជ្ជាកម្មុនីស្តរបស់ គាត់ ហើយគាត់ថែមទាំងកសាងវត្តមួយ ។ ទង្វើរបស់ តាម៉ុក ជា មនុស្សចេះគិតបែបនេះមិនគួរសម្លាប់ ក្រពុំ និងក្រុមគ្រួសារទេ ។ អ្នកភូមិខ្លះបាននិយាយថាក្រពុំគឺទទួលរងកំហុសនៃអំពើក្បត់ជំនួស អ្នកដទៃ ។

## យាយ គៀក

យាយ គៀក មាន អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំថ្លាត ស្រុកអន្លង់វែង ។ គាត់បានរៀបការនឹង សៀង ឌី ដែលជាអតីត យោធាម្នាក់របស់ខ្មែរក្រហមក្នុងរបប តាម៉ុក ។ អ្នកទាំងពីរមានកូន ប្រាំនាក់ ។ កូនប្រុសច្បងមានអាយុ៣២ឆ្នាំ និងធ្លាប់មានឡានដឹកទំនិញ សម្រាប់ដឹកទំនិញឲ្យសហគមន៍ ។ កូនប្រុសនោះធ្លាប់ជាអ្នកមាន ជីវភាពធូរធារជាងបងប្អូនដទៃទៀត ប៉ុន្តែចាប់តាំងពីគាត់ត្រូវបាន ចាប់ខ្លួនដោយសារតែគាត់ដឹកឈើប្រណិតកាលពីពីរឆ្នាំមុន គាត់ក៏ ធ្លាក់ខ្លួនក្រ ព្រោះលុយដែលធ្លាប់រកបានត្រូវយកទៅបង់ធានាឲ្យគាត់ ចេញពីគុក ។ កូនប្រុសពៅរបស់ យាយ គៀក បច្ចុប្បន្នកំពុងសិក្សា នៅសាលាទាហាននៅខេត្តកំពង់ស្ពឺ ។ កូនប្រសារប្រុសទីពីររបស់គាត់ ថ្មីៗនេះជួបនឹងគ្រោះថ្នាក់ចរាចរណ៍ និងកំពុងព្យាបាលជើងបាក់ ។ ក្រៅពីបញ្ហាទាំងអស់នោះ យាយ គៀក រស់នៅដោយសុខសាន្ត ។

យាយគៀក មានស្រុកកំណើតនៅស្រុកបារាយណ៍ ខេត្ត កំពង់ធំ ។ ពី១៩៧៥ ដល់១៩៧៩ គាត់ជាប្រជាជនមូលដ្ឋាន ។ ពេល ដែលកងទ័ពវៀតណាមចូលមក គាត់និងប្រជាជនដទៃជាច្រើន ទៀតបានភៀសខ្លួនទៅជាមួយនឹងទាហានខ្មែរក្រហមដោយបាន និយាយថា ទាហានវៀតណាមនឹងសម្លាប់ដោយចាក់នឹងកាំភ្លើង ជំពុះទង់មិនខានបើសិនជាចាប់បាន ។ យាយ គៀក រស់នៅតាម ព្រំដែន ហើយក្រោយមកបានផ្លាស់ទៅតាមជំរំខ្មែរក្រហមវិញ ។ ក្រោយមក គាត់បានផ្លាស់ចុះពីភ្នំដងរែកមកឃុំថ្លាតបច្ចុប្បន្ន ។ អ្នក ដែលមកដល់ទីនេះដំបូងបានកាប់រុករានព្រៃដើម្បីធ្វើលំនៅស្ថាន និង ដាំដំណាំដែលពីមុនជាព្រៃស្តុកសម្បូរដោយដើមឈើខ្ពស់ៗ ។

ក្រោមរបប តាម៉ុក យាយ គៀក រស់នៅដោយជីវិត សាមញ្ញជាម្តាយនិងប្រពន្ធម្នាក់ដែលមិនខ្វល់ពីនយោបាយឬបដិវត្តន៍ អ្វីឡើយ ។ ប្តីរបស់គាត់មិនមែនជាទាហានសំខាន់ និងពេញសិទ្ធិទេ ។ ដូចនេះ គ្រួសារគាត់តែងតែទទួលការស្តីបន្ទោសពីខ្មែរក្រហម ។ មាន ម្តងនោះខ្មែរក្រហមបានគំរាមនឹងយកដីទាំងអស់របស់គាត់ និងបញ្ជូន គ្រួសារទៅភូមិទួលគ្រួសដើម្បីជាការធ្វើទារុណកម្ម ។ យាយ គៀក បាននិយាយថា គាត់មិនបានទទួលរបបអាហារគ្រប់គ្រាន់ពីរបប តាម៉ុក ទេ ។ គាត់និយាយថា ពេលនោះមានអំពើពុករលួយ និងបក្ស ពួកនិយមដែរក្នុងការបែងចែកអាហារ ។ អ្នកដែលមានសាច់ញាតិ និង មានតួនាទីសំខាន់ក្នុងចលនាខ្មែរក្រហម និងមានរបបអាហារទៀងទាត់ និងច្រើន ។ ចំពោះគ្រួសាររបស់ យាយ គៀក វិញ មិនមានខ្សែបក្ស ពួកញាតិមិត្តទេ ។

ក្រោមរបបតាម៉ុក យាយ គៀក មានកងមួយដែលជាហេតុ នាំឲ្យមានការរិះគន់ពីសំណាក់ខ្មែរក្រហម ។ ប្រជាជនជាច្រើនមិនមាន កង់ ម៉ូតូ ឬរថយន្តជិះទេ ។ ផ្លូវគឺសម្រាប់តែឡានយោធាប៉ុណ្ណោះ ។ ជីវិតរស់នៅមានលក្ខណៈបណ្តោះអាសន្ន និងមិនទៀងទាត់ ដោយ ត្រៀមរួចជាស្រេចសម្រាប់ការភៀសខ្លួននៅពេលមានការបាញ់ ប្រហារគ្នាកើតឡើង ។ យាយ គៀក ប្រាកដក្នុងចិត្តថា របស់របរគាត់ មិនមានច្រើនទេ គឺអាចយួរដោយដៃបាន ដូចនេះគាត់មិនដែលទុក គោ ក្របី កង់សម្រាប់ប្រើទេ ហើយក៏មិនទុកអង្ករច្រើននៅក្នុងជង្រុក ដែរ ។ ម្យ៉ាងវិញទៀត តាម៉ុក មិនចង់ឲ្យគាត់មានរបស់ច្រើនដែរ ទោះបីជាគាត់មានលទ្ធភាពទិញរបស់ទាំងនោះជាមួយប្រាក់ចំណូល ដែលបានមកពីការដួញដូរក្របីក៏ដោយ ។

ថ្ងៃមួយប្តីរបស់គាត់ស្ទើរតែត្រូវខ្មែរក្រហមចាប់បាន ។ យាយ គៀក បាននិយាយថាគាត់រង់ចាំរថយន្តខ្មែរក្រហមអស់រាប់ ម៉ោងដើម្បីយកគាត់ទៅបំពេញតួនាទីជាយោធានៅខេត្តព្រះវិហារ ប៉ុន្តែមិនឃើញរថយន្តមកទទួលទេ ។ គាត់ក៏ត្រលប់មកផ្ទះវិញ ។ ថ្ងៃបន្ទាប់ មានយោធាខ្មែរក្រហមពីរនាក់មកផ្ទះគាត់ និងនិយាយ ជាមួយគាត់ពីការអវត្តមាននេះ ។ យាយ គៀក បាននិយាយថា យោធាខ្មែរក្រហមពីរនាក់នោះបានគំរាមនឹងចាប់ខ្លួនប្តីរបស់គាត់ និងរឹបអូសយកដីទាំងអស់ ។ ប៉ុន្តែអ្នកទាំងពីរមិនបានធ្វើអ្វីទាំងអស់ ។

ពេលនោះខ្មែរក្រហមបានបញ្ជាឲ្យប្ដីរបស់គាត់ដើរទៅព្រះវិហារដោយថ្មើរជើង ។ គាត់បានបាត់ខ្លួនអស់រយៈពេលជាច្រើនខែ ។ រៀងរាល់ថ្ងៃគាត់នៅរង់ចាំប្ដីត្រឡប់មកវិញ ។ ពេលណាដែលគាត់ឮសំឡេងរថយន្តបើកកាត់ភូមិ គាត់មានការព្រួយបារម្ភណាស់ ព្រោះរថយន្តតែងតែនាំអ្នករបួសនិងស្លាប់មកពីសមរភូមិ ។ ប៉ុន្តែជាភព្វសំណាង ប្ដីរបស់គាត់បានត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព ។

## យឿង អឿន


យឿង អឿន

យឿង អឿនអាយុ ៥៥ឆ្នាំ មានប្រពន្ធឈ្មោះ ឃីម ខុន អាយុ ៥០ឆ្នាំ ។ អ្នកទាំងពីររៀបការនៅឆ្នាំ១៩៨៣ និងមានកូនបីនាក់ ។ ប្រពន្ធរបស់គាត់ គឺអនុប្រធានភូមិលំទងថ្មី ឃុំលំទងថ្មី ស្រុកអន្លង់វែង ។ ពូ អឿន មានស្រុកកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់ចូលបដិវត្តន៍នៅឆ្នាំ១៩៧១ នៅស្រុកត្រាំកក់ ពីព្រោះគាត់ចង់ជួយឲ្យសម្ដេចសីហនុ មកកាន់តំណែងវិញ ។ ដំបូងគាត់បានត្រូវបានចាត់ឲ្យធ្វើជានិរសារស្រុកត្រាំកក់ដែលមាននិរសារក្មេងៗពីរបីនាក់ ។ ពូ អឿន និយាយថា គាត់ពេញចិត្តការងារជានិរសារណាស់ ។ គាត់នៅក្មេងហើយរីករាយ នឹងធ្វើអ្វីតាមតែការបញ្ជាឲ្យធ្វើ ។ ការងារជានិរសាររបស់គាត់គឺត្រូវបញ្ជូនសំបុត្រក្នុងឃុំនិងពាំនាំពាក្យទៅប្រាប់នរណាម្នាក់ ។ ពូ អឿន ដើរនិងជិះកង់ ប៉ុន្តែគាត់មិនដែលប្រើសេះដូចជាអ្នកឯទៀតទេ ព្រោះគាត់ខ្លាចសត្វ ។

នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមកាន់កាប់ប្រទេស ពូ អឿន កំពុងតែនៅក្នុងស្រុកត្រាំកក់ ប៉ុន្តែក្រោយមកគាត់ត្រូវចាត់តាំងឲ្យទៅសាងសង់ស្ពាននៅស្រុកគិរីវង្ស ។ នៅឆ្នាំ១៩៧៦ គាត់ត្រូវបានបញ្ជូនទៅរតនគិរីដើម្បីជួយសាងសង់ស្ពានកាត់ទន្លេស្រែពក ។ នៅទីនោះ ពូ អឿន បានឃើញខ្មែរក្រហមបោសសម្អាត និងសម្លាប់កម្មាភិបាលអស់ជាច្រើននាក់ ។ ពូ អឿន បន្តរស់នៅរតនគិរីរហូតដល់ចុងឆ្នាំ១៩៧៨ ពេលដែលកងទ័ពវៀតណាមចូលមកដល់ ។ កាលនោះ គាត់ចង់ទៅស្រុកត្រាំកក់ ដើម្បីជួបឪពុកម្ដាយ និងបងប្អូនរបស់គាត់ ព្រោះគាត់នឹកអ្នកទាំងអស់គ្នាខ្លាំងណាស់ ។ ប៉ុន្តែគាត់មិនអាចធ្វើបានដោយសារកម្មាភិបាលខ្មែរក្រហមជាច្រើនបានភៀសខ្លួនទៅព្រំដែនថៃ ។ គាត់ដើរតាមយោធានិងកម្មាភិបាលទាំងនោះរហូតដល់ម៉ាឡៃដែលជាទីកន្លែង គាត់ធ្វើការងារជាចុងភៅ និងជាអ្នកបញ្ជូនអាហារទៅឲ្យទ័ពជួរមុខ ។ គាត់ស្នាក់នៅចំនុច១០០២ អស់រយៈពេលបីឆ្នាំ ដោយធ្វើការងារចម្រុះដូចជា ធ្វើលំពែងឬស្សី និងឈើសម្រាប់ធ្វើជាអន្ទាក់ ។ ទីបញ្ចប់ នៅដើមទសវត្សរ៍៩០ ពូ អឿន បានត្រលប់មកអន្លង់វែង និងបានក្លាយជាសមាជិកកងពលធំលេខ៩១២គ្រប់គ្រងដោយ តាគង់ ។

ពូ អឿនដឹងតិចតួចណាស់ពី តាម៉ុក, សុន សេន និងអ្នកដឹកនាំសំខាន់ៗដទៃទៀត ។ គាត់មានសុទិដ្ឋិនិយមចំពោះជីវិតនៅក្នុងអន្លង់វែងសព្វថ្ងៃ ដែលគាត់គិតថា ល្អជាងឆ្ងាយពីរបបគ្រប់គ្រងរបស់តាម៉ុក ។ អ្វីដែលគាត់ចង់បានពេលនេះគឺកូនរបស់គាត់អាចរកការងារធ្វើបាន ព្រោះគាត់មិនមានដីសម្រាប់ចែកឲ្យកូនៗទេ ។

## សេចក្ដីបញ្ចប់

នៅក្នុងរឿងរ៉ាវទាំង១២របស់ប្រជាជនអន្លង់វែងខាងលើ យើងអាចដឹងពីបទពិសោធន៍ជីវិតផ្សេងៗគ្នាអំពីមូលហេតុនិងវិធីដែលអ្នកទាំងនោះចូលបម្រើក្នុងចលនាខ្មែរក្រហម និងចំណាប់អារម្មណ៍របស់អ្នកទាំងនោះ ទាក់ទងទៅនឹងអន្លង់វែងនាពេលបច្ចុប្បន្ន ។ ក្នុងចំណោមអ្នកត្រូវបានសម្ភាសមានបីនាក់មកពីខេត្តតាកែវ ។ ក្នុងនោះមានពីរនាក់បានចូលបម្រើចលនាខ្មែរក្រហមនៅទសវត្សរ៍៨០ និង៩០ ។ ស្ត្រីពីរនាក់ប្ដីនិងបងប្រុសផ្ដាច់ខ្លួនចូលជាមួយរដ្ឋាភិបាលកម្ពុជា ពេលដែលស្ត្រីនោះនៅតំបន់ខ្មែរក្រហមអន្លង់វែង ។ មានគ្រួសារមួយបានលួចលាក់ជួញដូរគោក្របីជាមួយនឹងឈ្មួញថៃ ។ ការសិក្សាបានបង្ហាញថា គ្រួសារដែលមានសមាជិកចូលបម្រើជាយោធាខ្មែរក្រហមបានទទួលរបបអាហារទៀងទាត់ និងច្រើនជាងអ្នកឯទៀត ។ មនុស្សចំនួនដប់មួយនាក់ក្នុងចំណោមទាំងដប់ពីរនាក់យល់ថា តាម៉ុក ជាមនុស្សល្អ លើកលែងតែអតីតយោធាខ្មែរក្រហមម្នាក់ដែលគិតថា អ្វីដែល តាម៉ុក បានធ្វើមិនមានអ្វីសំខាន់ទាល់តែសោះ ។

**អេង កុកថាយ**

# ស្គាល់ខ្មែរក្រហមតាមរយៈគិញសម្ងាត់ជនជាតិចិនចូលនិវត្តន៍ម្នាក់ "នៅលើទឹករលកនៃទន្លេមេគង្គ" និពន្ធដោយ អ៊ីង ស៊ីម៉េង




មានការប៉ាន់ស្មាន និងការសរសេរជាច្រើនស្តីអំពីតួនាទីរបស់ជនកុម្មុយនីស្តប៉េកាំងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមនៅប្រទេសកម្ពុជា (១៩៧៥-១៩៧៩) ។ ប៉ុន្តែ ទាក់ទិនទៅនឹងបទពិសោធន៍ បុគ្គលរបស់ជនជាតិចិនម្នាក់ៗដែលពាក់ព័ន្ធក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រកម្ពុជានេះគឺមិនមានការដឹងច្រើនទេ ។ បញ្ហានេះ មួយផ្នែកគឺប្រហែលមកពីតួនាទីរបស់ទីក្រុងប៉េកាំងនៅក្នុងរបបខ្មែរក្រហម ដែលត្រូវបានចាត់ទុកថាគួរឲ្យខ្មាស់អៀន ហើយតែងតែត្រូវបានលើកឡើងជារឿយៗពីសំណាក់អង្គការការពារសិទ្ធិមនុស្សជាច្រើន ។ ការជំរុញឲ្យមានការចែករំលែករឿងរ៉ាវអាចនាំឲ្យមានការខ្មាស់អៀនផ្នែកនយោបាយកាន់តែខ្លាំងសម្រាប់ទីក្រុងប៉េកាំង ។ ប៉ុន្តែ នាពេលថ្មីៗនេះ ដោយសារប្រទេសចិននិងប្រជាជនរបស់ខ្លួនកាន់តែមានជំនឿចិត្តថា នេះមិនមែនអ្វីចឹងទេ ទើបធ្វើឲ្យមានការចេញផ្សាយសៀវភៅជាភាសាចិនជាច្រើនស្តីអំពីរបបខ្មែរក្រហម ។ សៀវភៅដែលមានចំណងជើងថា "នៅលើទឹករលកនៃទន្លេមេគង្គ" គឺជាឧទាហរណ៍មួយស្រាប់ ។

អ្នកនិពន្ធសៀវភៅនេះ អ៊ីង ស៊ីម៉េងគឺជា "អ្នកស៊ើបការណ៍" ជនជាតិចិនកុម្មុយនីស្តម្នាក់ដែលធ្វើការដោយសម្ងាត់នៅក្នុងប្រទេសកម្ពុជា ។ អ៊ីង ស៊ីម៉េង ធ្លាប់រស់នៅក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) សម័យសាធារណរដ្ឋខ្មែររបស់ លន់ នល់

(១៩៧០-១៩៧៥) និងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ។ ទោះបីជាសៀវភៅនេះត្រូវបានសរសេរឡើងជាលក្ខណៈប្រលោមលោកយ៉ាងណាក្តី អ៊ុឹង ស៊ីម៉េង បានទទួលស្គាល់ជាសាធារណៈថា សៀវភៅនេះគឺជាកំណត់ហេតុនៃប្រវត្តិជីវិតរបស់គាត់ ។ សាច់រឿងរបស់តួឯកក្នុងសៀវភៅនេះ គឺផ្អែកទៅលើបទពិសោធន៍ជីវិតពិតផ្ទាល់ខ្លួនរបស់គាត់ ។ នៅក្នុងសៀវភៅរបស់ "អ្នកស៊ើបការណ៍សម្ងាត់" គឺជាឈ្មោះដ៏អស្ចារ្យសម្រាប់គិញសម្ងាត់ម្នាក់ ។ ដូចដែលអត្តសញ្ញាណរបស់គាត់បានបង្កប់អត្ថន័យអ៊ីចឹង រឿងរ៉ាវក្នុងសៀវភៅរបស់គាត់ពិតជាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ។ សៀវភៅនេះធ្វើឲ្យអ្នកអានមើលឃើញជ្រុងមួយដ៏ពិសេសនៅក្នុងផ្នែកមួយនៃឆាកជីវិតរបស់ អ៊ុឹង ស៊ីម៉េង ដែលជាសាច់រឿងបុគ្គលពិតប្រាកដមួយកាលពីសម័យនោះ ។ ម្យ៉ាងទៀតសៀវភៅនេះក៏បានឆ្លុះបញ្ចាំងពីជោគវាសនាដ៏អភ័ព្វរបស់បុគ្គលរស់នៅក្នុងសម័យកាលនោះដែលត្រូវបានបង្ខំឲ្យជ្រើសរើសរវាងអត្តសញ្ញាណនយោបាយនិងមនោគមន៍វិជ្ជានយោបាយផ្សេងៗគ្នា ។

## ជីវប្រវត្តិរបស់អ្នកនិពន្ធ

អ្នកនិពន្ធប្រើឈ្មោះក្លែង (នាមប៉ាកា) ធីខ នៅពេលសរសេរសៀវភៅនេះ ។ យើងមានការលំបាកក្នុងការប្រើប្រាស់បរិបទច្បាប់នាពេលបច្ចុប្បន្ននេះមកធ្វើការកំណត់នូវសញ្ជាតិរបស់គាត់ ។ ក្រុមគ្រួសាររបស់គាត់មានដើមកំណើតមកពីស្រុកដូវឡេងក្រុងទាជីវ នៃខេត្តក្វាងទុង ប្រទេសចិន ។ ប៉ុន្តែ គាត់បានចាប់កំណើតនិងធំលូតលាស់នៅទីក្រុងភ្នំពេញ ។ ប្រសិនបើករណីនេះកើតឡើងក្នុងពេលបច្ចុប្បន្ននេះវិញ គាត់ប្រហែលជាត្រូវបានចាត់ទុកថាជាប្រជាជនខ្មែរដែលជាមនុស្សម្នាក់ក្នុងចំណោមជនជាតិចិនកម្ពុជា(កូនកាត់ចៅចិន) ជាងប្រាំពីរសែននាក់នៅក្នុងប្រទេស ។

ទោះជាដូច្នេះក្តី ការសិក្សារបស់ប្រវត្តិវិទូនានាបានរកឃើញថា នៅមុនសម័យ លន់ នល់ សហគមន៍ជនជាតិមួយភាគធំនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈស្វ័យ័តបំផុត ហើយនេះពិតជាប្រាកដណាស់នៅក្នុងករណីទីក្រុងភ្នំពេញ ។ ជនជាតិចិនទាំងនោះចូលរៀនសាលាចិន ប្រើប្រាស់ភាសាចិនតាមតំបន់ផ្សេងៗពីគ្នាធ្វើការរកស៊ីជួញដូរនៅក្នុងសហគមន៍ ហើយថែមទាំងមានទំនាក់ទំនងជាមួយជនជាតិចិនដែលរស់នៅប្រទេសចិន ។ ជនជាតិចិនទាំងនោះខិតខំប្រឹងប្រែងក្នុងការថែរក្សាអត្តសញ្ញាណជនជាតិរបស់ខ្លួន ហើយសហគមន៍កាន់តែរីកធំធាត់ទៅជាដរាប ។ ចៀសមិនផុតទេ ដែលថាជនជាតិចិនមួយចំនួនក្នុងចំណោមជនជាតិចិនទាំងនោះមាននិន្នាការទៅរកស្ថានភាពបុ្រចលនាបដិវត្តន៍នៅប្រទេសចិនវិញ ។ អ៊ុឹង ស៊ីម៉េង គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះ ។ ឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់ប្រធាន ម៉ៅ នៅក្នុងទសវត្សរ៍៥០ ដើម្បីឲ្យជនជាតិចិនទាំងអស់ដែលរស់នៅបរទេសត្រឡប់មកជួយកសាងសង្គមនិយមថ្មីនិងអស្ចារ្យមួយនៅប្រទេសចិន អ៊ុឹង ស៊ីម៉េង ក៏បានធ្វើដំណើរវិលត្រឡប់ទៅប្រទេសចិនវិញ ហើយបានស្នើសុំសញ្ជាតិជាជនជាតិចិនរបស់ខ្លួនថែមទៀតព្រមទាំងធ្វើការផ្ញើខ្លួនផ្ញើប្រាណទៅលើចលនាបដិវត្តន៍ទាំងស្រុង ។ ដោយសារតែគាត់និយាយភាសាខ្មែរបានច្បាស់និងធ្លាប់រស់នៅក្នុងសង្គមខ្មែរស្រាប់ អ៊ុឹង ស៊ីម៉េង ក៏ត្រូវបានជ្រើសរើសឲ្យធ្វើជាអ្នកស៊ើបការណ៍នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានបញ្ជូនត្រឡប់មកទីក្រុងភ្នំពេញវិញនៅចុងទសវត្សរ៍៥០ ។

ទោះបីជាឥឡូវគាត់មានសញ្ជាតិជាជនជាតិចិន "ភាពជាខ្មែរ" របស់គាត់បានស្តែងចេញឡើង តាមរយៈសេចក្តីស្រឡាញ់របស់គាត់ចំពោះទន្លេមេគង្គ (ជាជាងទន្លេយ៉ាងសេ ឬហៅថាទន្លេលឿង ដែលតែងតែត្រូវបានលើកឡើងនៅក្នុងអក្សរសិល្ប៍ចិន) ។ ដូចដែលគាត់បានលើកឡើងយ៉ាងរំជួលចិត្តអំពីទន្លេមេគង្គថា ៖ "ខ្ញុំស្រឡាញ់ទន្លេនេះ ហើយគោរពទន្លេនេះខ្លាំងណាស់ ខ្ញុំមានអារម្មណ៍ថាទន្លេមួយនេះជះឥទ្ធិពលយ៉ាងខ្លាំងដល់ឆាកជីវិតរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ផ្សារភ្ជាប់ជានិច្ចជាមួយទន្លេនេះ" ។

## ការជម្លៀស និងការវិលត្រឡប់មកទីក្រុងភ្នំពេញ

អ៊ុឹង ស៊ីម៉េង រស់នៅបង្កប់ខ្លួនជាអ្នកជំនួញជនជាតិចិនម្នាក់បន្ទាប់ពីគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ក្នុងអំឡុងពេលនោះ គាត់បានធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗជុំវិញប្រទេសកម្ពុជា និងវៀតណាម ។ នៅពេលមានការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញកើតឡើងនៅក្នុងឆ្នាំ១៩៧៥ រូបគាត់ និងក្រុមគ្រួសារត្រូវបានជម្លៀសចេញទាំងអស់ទៅកាន់ទីជនបទ ហើយបន្ទាប់មកទៅកាន់ព្រៃជ្រៅ ។ ដូចគ្នាទៅនឹងប្រជាជនដទៃទៀតភាព

អត់ឃ្លាន និងជំងឺបានកើតមានឡើងចំពោះសមាជិកគ្រួសាររបស់គាត់ ។ ភ្លាមនោះ ក្មួយប្រុសរបស់គាត់ក៏ស្លាប់ ។ គ្រោះកាចចង្រៃក៏ចាប់ផ្តើមធ្លាក់មកលើក្រុមគ្រួសាររបស់គាត់ ។ ម្តាយ ប្រពន្ធ និងរូបគាត់ក៏ធ្លាក់ខ្លួនឈឺ ។

នៅពេលដែលខ្លួនប្រឡូកក្នុង«ការងារបដិវត្តន៍» អ៊ីង ស៊ីម៉េង យល់ឃើញថាខ្លួនកំពុងជួយប្រទេស និងប្រជាជនកម្ពុជាវាយប្រឆាំងនឹងចក្រពត្តិនិយមរបស់អាមេរិក ។ ហេតុដូចនេះ គាត់មិនមានការលំបាកក្នុងការសបញ្ជាក់អំពីតួនាទីរបស់គាត់ជាគិញសម្ងាត់ធ្វើការងារឲ្យប្រទេសមួយផ្សេងទៀតនោះទេ ។ ការយល់ដឹងអំពីភាពខ្ពង់ខ្ពស់នៃមនោគមន៍វិជ្ជារបស់គាត់មានលក្ខណៈស្របគ្នាទៅនឹងការយល់ដឹងរបស់ពួកខ្មែរក្រហម ដែលជាសម្ព័ន្ធមិត្តម្នាក់នៅក្នុងការវាយប្រឆាំងទៅនឹងពួកចក្រពត្តិនិយម និងជាមិត្តកុម្មុយនីស្តម្នាក់របស់ទីក្រុងប៉េកាំង ។ គាត់ប្រហែលជាមិនដែលនឹកគិតសោះឡើយថា«រង្វាន់» លើកដំបូងដែលខ្មែរក្រហមជូនដល់គាត់នោះគឺការលំបាកវេទនាបែបនេះនោះទេ ។ ប៉ុន្មានខែកន្លងផុតទៅគាត់កាន់តែអស់ជំនឿទៅលើការឃោសនារបស់ខ្មែរក្រហម និងទៅលើខ្មែរក្រហមខ្លួនឯងផ្ទាល់តែម្តង ។ គាត់ក៏សម្រេចចិត្តល្មើសនឹងវិន័យបក្ស ដោយធ្វើការលាតត្រដាងអំពីអត្តសញ្ញាណរបស់ខ្លួនឲ្យកម្មាភិបាលខ្មែរក្រហមក្នុងភូមិបានដឹង ។ បន្ទាប់ពីធ្វើការរាយការណ៍អស់មួយជុំ គាត់ក៏អាចត្រឡប់មកទីក្រុងភ្នំពេញវិញ ។

បន្ទាប់ពីវិលត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ប៉ុន្មានឆ្នាំក្រោយមក គាត់ក៏បានដឹងដំណឹងពីជោគជតាដ៏គួរឲ្យព្រឺព្រួចរបស់ក្រុមការងារគាត់ ។ បន្ទាប់ពីភ្នំពេញដួលរលំ នាយប់នោះ ទីក្រុងប៉េកាំងបានដាច់ទំនាក់ទំនងទាំងអស់ជាមួយអ្នកស៊ើបការណ៍សម្ងាត់របស់ខ្លួននៅប្រទេសកម្ពុជា ។ ទីក្រុងប៉េកាំងអស់សង្ឃឹមយ៉ាងខ្លាំង ដោយខ្លួនមិនអាចក្តោបក្តាប់សភាពការណ៍នៅមូលដ្ឋានបាន ហើយខ្លួនមិនអាចធ្វើអ្វីបានទាំងអស់ ។ ជាងនេះ ខ្លួនមិនអាចមើលឃើញថា នឹងមានអ្វីកើតឡើងបន្តទៀត ។ ដូចដែលអ្នកនិពន្ធបានកត់សម្គាល់អឺចឹងថា អ្នកស៊ើបការណ៍សម្ងាត់ទាំងអស់សុទ្ធតែមានសន្តិសុខល្អ នៅក្រោមការគ្រប់គ្រងរបស់សត្រូវខ្លួននោះគឺរបបលន់ នល់ ។ ប៉ុន្តែ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាច ប៉េកាំងមិនអាចទាក់ទងទីតាំងរបស់អ្នកស៊ើបការណ៍សម្ងាត់ទាំងអស់បាននោះទេ ។ ខុសគ្នាពីអ្នកនិពន្ធ អ្នកស៊ើបការណ៍សម្ងាត់សម្រេចចិត្តដើរតាមវិន័យបក្សយ៉ាងខ្ជាប់ខ្ជួនរហូតដល់ទីបញ្ចប់ ដូចដែលពួកគេត្រូវបានណែនាំនិងអប់រំអឺចឹង ។

## ការអស់ជំនឿលើខ្មែរក្រហម

ដោយមើលឃើញពីស្ថានភាពទៅថ្ងៃមុខ អ៊ីង ស៊ីម៉េង បានធ្វើការសម្រេចចិត្តដ៏វៃឆ្លាតមួយ ដោយងាកចេញពីវិន័យរបស់បក្ស ។ ជម្រើសបែបនេះប្រហែលជាមិនអាចកើតឡើងទេចំពោះមិត្តរួមអាជីពរបស់គាត់ភាគច្រើន ។ ការប្រកាន់ខ្ជាប់នូវវិន័យបក្សគឺជាការទទួលខុសត្រូវមួយចាំបាច់ជាងគេបង្អស់របស់សមាជិកបក្សកុម្មុយនីស្តម្នាក់ៗ ។ ចំពោះអ្នកទាំងនោះ ការល្មើសនឹងវិន័យនេះគឺខុសទាំងស្រុង មិនថានៅក្រោមកាលៈទេសៈណានោះទេ ។ អ្នកនិពន្ធហ៊ានធ្វើការងាកចេញពីគោលការណ៍នេះដោយសារតែខ្លួនមើលឃើញពីសោកនាដកម្មនៃគោលនយោបាយដ៏ហួសហេតុរបស់ខ្មែរក្រហម ។

«ប៉ុល ពត និងបរិវា តាំងពីទ្រឹស្តីរហូតដល់ការអនុវត្តបានចាត់ទុកអ្នកទីក្រុងទាំងអស់ថាជោគជាំទៅដោយជាតិពុលមូលធននិយមដែលមិនអាចសម្រាលបាននោះទេ ។ លើកលែងតែក្មេងៗមិនដឹងអីនោះទេ ក្រៅពីនេះត្រូវតែកម្ទេចទាំងអស់» ។ អ៊ីង ស៊ីម៉េង បានអធ្លេតថែមទៀតថា «មេដឹកនាំខ្មែរក្រហមបញ្ចូលមនោគមន៍វិជ្ជាទាំងងងឹតងងុលឲ្យមនុស្សគ្រប់រូបស្អប់អ្នកទីក្រុង» ។ យោធាខ្មែរក្រហមម្នាក់ថែមទាំងចោទសួរគាត់ថា «មេខ្ញុំប្រាប់ថា អ្នកក្រុងសុទ្ធតែស៊ីសាច់មនុស្ស ហើយសូម្បីតែឆ្អឹងក៏មិនខ្ជាក់ចេញដែរ ។ តើនេះពិតទេ»? អ៊ីង ស៊ីម៉េង មើលមិនឃើញសង្ឃឹមអ្វីសោះចំពោះគោលនយោបាយរបស់ខ្មែរក្រហម ។ ដោយលែងមានការជឿជាក់បែបនេះគួបផ្សំនឹងសេចក្តីអស់សង្ឃឹម គាត់ក៏ជ្រើសរើសលាតត្រដាងពីអត្តសញ្ញាណរបស់ខ្លួន ។

## អំពើសាហាវឃោរឃៅនិងមេដឹកនាំខ្មែរក្រហម

ប្រសិនជា អ៊ីង ស៊ីម៉េង មិនបានសុំចូលសញ្ជាតិចិននោះទេ គាត់ប្រហែលក្លាយទៅម្នាក់ក្នុងចំណោមជនជាតិចិនកម្ពុជាជាងប្រាំសែននាក់ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ ឬក៏ក្លាយជាម្នាក់ក្នុងចំណោមពាក់កណ្តាលនៃចំនួននេះដែលត្រូវបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ គាត់បានប្រើប្រាស់

សៀវភៅរបស់គាត់ដើម្បីកត់ត្រាអំពើសាហាវឃោរឃៅមួយចំនួនដែលជនជាតិចិននៅក្នុងប្រទេសកម្ពុជាបានជួបប្រទះ ។

«មានជនជាតិចិនម្នាក់ដែលមិនចេះនិយាយភាសាខ្មែរទាល់តែសោះ ថ្ងៃមួយ មិនដឹងជាយ៉ាងម៉េចទេ គាត់ម្នាក់ហ្នឹងត្រូវបានចាប់ចង ។ កម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិបានរៀបចំអង្គប្រជុំមួយយ៉ាងធំគគ្រឹកគគ្រេង ។ ភ្លាមនេះក៏ប្រកាសថា ជនជាតិចិនម្នាក់នេះជាមនុស្សខ្ជិលអត់ធ្វើការងារ ជាឈ្លើងជញ្ជក់ឈាមសង្គមថ្មីមួយនេះ ។ កម្មាភិបាលជាច្រើននាក់បានឆ្លាស់គ្នាយកអង្កឹសម្រាប់មួលរឹតមកកាត់សាច់គាត់ជាដំនិតៗជាដុំៗ ។ បុរសម្នាក់នោះខ្លួនប្រឡាក់សុទ្ធតែឈាម ហើយក៏ដួលលើដីស្រែកយំដោយក្តីឈឺចាប់» ។

បទពិសោធន៍ផ្ទាល់ខ្លួនរបស់ អ៊ឹង ស៊ីម៉េង ធ្វើឲ្យគាត់លែងមានជំនឿអ្វីទាំងអស់លើការដឹកនាំរបស់ខ្មែរក្រហម ។ គាត់ហៅខ្មែរក្រហមថាជា «មនុស្សឆ្កួតមួយក្រុមដែលជោគជាំទៅដោយមនោគមន៍វិជ្ជាធ្មេងនិយមជ្រុលហួសហេតុទទឹកជោគជាំទៅដោយឈាម ដែលចាត់ទុកមនុស្សគ្នាឯងដូចជាសត្វតិរច្ឆាន» ។

ទោះបីជាមានជំនឿពេញនិយមមួយដែលថាគោលនយោបាយសង្គមដ៏ហួសហេតុរបស់ខ្មែរក្រហមទទួលបានការជះឥទ្ធិពលយ៉ាងខ្លាំងពីកុម្មុយនីស្តប៉េកាំង ក៏មានការសិក្សាស្រាវជ្រាវមួយចំនួនមានមន្ទិលសង្ស័យទៅលើកម្រិតនៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហមដែលទទួលបានពីប្រទេសចិន ។ នៅក្នុងការពិភាក្សាវែកញែកដាច់ដោយឡែកមួយ អ៊ឹង ស៊ីម៉េង បានផ្តល់នូវការយល់ឃើញរបស់ខ្លួន ។ គាត់បានធ្វើការចោទប្រកាន់យ៉ាងច្បាស់លាស់ថានោះគឺមកពី «ក្រុមអ្នកលេងទាំងបួន» ក្រុមដែលមានជំនឿលើមនោគមន៍វិជ្ជាដូចគ្នាដែលត្រូវបានដាក់ឲ្យទទួលខុសត្រូវជាទូទៅ(សម្រាប់ការប្រឆាំងទៅនឹងបដិវត្តន៍វប្បធម៌នៅប្រទេសចិន) និងបរិវាររបស់អ្នកទាំងបួននេះ ដែលជាអ្នកបញ្ចូលមនោគមន៍វិជ្ជានិងវិធីសាស្ត្រដ៏អន្តរាយរបស់ខ្លួនទៅឲ្យ ប៉ុល ពត និងបរិវា ។ នៅក្នុងទស្សនៈរបស់ អ៊ឹង ស៊ីម៉េង ប៉ុល ពត និងគ្នីគ្នា ខិតខំប្រឹងប្រែងឲ្យក្លាយទៅជាសិស្ស«ល្អជាងគេ» ដែលអាចវាយ ឈ្នះគ្រូរបស់ខ្លួន ហើយធ្វើការគ្រប់គ្រងប្រទេសកម្ពុជាឲ្យធ្លាក់ចូលទៅក្នុង «ការសាកល្បង» ផ្នែកនយោបាយដ៏គួរឲ្យអស់សង្ឃឹមមួយនិងធ្វើឲ្យប្រជាជនរបស់ខ្លួនធ្លាក់ចូលឋាននរក ។

## ការចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ ១៩៧៦ រហូតដល់បច្ចុប្បន្ន

បន្ទាប់ពីអត្តសញ្ញាណរបស់អ៊ឹង ស៊ីម៉េងត្រូវបានបញ្ជាក់រួចរាល់ គាត់ត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ និងបញ្ជូនមកទីក្រុងភ្នំពេញតាមឡានខ្មែរក្រហមនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ទីក្រុងភ្នំពេញមានសភាពទទេស្អាតនៅពេលនោះ ។ គាត់ត្រូវបានបញ្ជូនផ្ទាល់ទៅកាន់ស្ថានទូតចិន ។ ដោយសារតែផ្អែកផ្អួនទៅនឹងបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងការព្រួយបារម្ភពីសុវត្ថិភាពរបស់សមាជិកគ្រួសារ គាត់ស្នើសុំស្ថានទូតឲ្យបញ្ជូនគាត់ទៅប្រទេសចិនវិញ ។ ក្រោយមកមិនយូរប៉ុន្មាន រូបគាត់និងក្រុមគ្រួសារត្រូវបានដឹកបញ្ជូនតាមយន្តហោះទៅកាន់ទីក្រុងប៉េកាំង ។ នៅលើយន្តហោះមិនមានមនុស្សណាច្រើនទេ ក្រៅពីអ្នកជំនាញការជនជាតិចិនប៉ុន្មាននាក់ប៉ុណ្ណោះ ។

វាមិនមានភាពច្បាស់លាស់នោះទេ ថាតើការពន្យល់រ៉ាយរ៉ាប់អំពីមតិយោបល់របស់គាត់ស្តីពីពួកខ្មែរក្រហមបានជះឥទ្ធិពលប៉ុនណាទៅលើការសម្រេចចិត្តរបស់ទីក្រុងប៉េកាំង ។ ប្រាកដណាស់ដែលថា ទាំងនេះគឺមិនគ្រប់គ្រាន់នោះទេ ។ អ៊ឹង ស៊ីម៉េង នេះបច្ចុប្បន្នរស់នៅខេត្តក្វាងទុងជាមួយក្រុមគ្រួសាររបស់គាត់ ។ គាត់ជារឿយៗធ្វើការងារទាក់ទងនឹងកិច្ចការរដ្ឋដែលជាប់ពាក់ព័ន្ធនឹងប្រទេសកម្ពុជា ។ អ៊ឹង ស៊ីម៉េង និងភរិយាតែងតែមកលេងប្រទេសកម្ពុជាជាញឹកញយដើម្បីមកមើលប្រទេសដែលគាត់ស្រឡាញ់យ៉ាងខ្លាំង ហើយក៏ជាកន្លែងដែលគាត់បានមើលឃើញដោយផ្ទាល់ភ្នែកនូវរឿងរ៉ាវដ៏គួរឲ្យខ្លោចផ្សាជាច្រើន ។

អ៊ឹង ស៊ីម៉េង បានចាប់ផ្តើមសរសេររឿងរ៉ាវនេះនៅក្នុងសៀវភៅមួយដែលមានចំនួនជាង៦០០.០០០ពាក្យនៅក្នុងឆ្នាំ១៩៩៨ ដើម្បីជាផ្នែកមួយនៃសេចក្តីស្រឡាញ់មិនផុតរលត់របស់គាត់ចំពោះផ្ទះកំណើតទីពីររបស់គាត់ និងប្រទេសកម្ពុជា ។ គាត់ក៏មានបំណងធ្វើការចែករំលែកបទពិសោធន៍ និងសាច់រឿងប្រវត្តិសាស្ត្រផ្ទាល់ខ្លួននាសម័យកាលនោះរបស់គាត់ ។ ជាងនេះទៅទៀត អ៊ឹង ស៊ីម៉េង ចង់ប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ដើម្បីអប់រំក្មេងជំនាន់ក្រោយ ។ នៅពេលដែលសៀវភៅនេះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៨ គាត់បានរៀបចំយុទ្ធនាការឧបត្ថម្ភសៀវភៅនេះជាច្រើនក្បាលទៅឲ្យវិទ្យាស្ថានបច្ចេកទេស

ទាស័រ ដែលជាមហាវិទ្យាល័យមានមុខមាត់មួយនៅក្នុងតំបន់ទាជីវ និងទៅឲ្យអនុវិទ្យាល័យជាងម្ភៃកន្លែងនៅស្រុកដូវឡេង ។

## សេចក្តីអត្ថាធិប្បាយបញ្ចប់

ការបោះពុម្ពផ្សាយជាភាសាចិនស្តីអំពីសម័យខ្មែរក្រហម ត្រូវបានដកចេញពីការសិក្សាស្រាវជ្រាវនៅលើប្រធានបទនេះ ដែលភាគច្រើនត្រូវបានធ្វើឡើងតែជាភាសាអង់គ្លេស និងភាសាបារាំង ។ មិនមានការប្រាស្រ័យទាក់ទងគ្នាច្រើននោះទេរវាងអ្នកនិពន្ធជនជាតិចិន និងអ្នកស្រាវជ្រាវដទៃទៀត លើកលែងតែយូរៗម្តងមាននៅក្នុងថ្នាក់សិក្សាតែប៉ុណ្ណោះ ។ «នៅលើទឹករលកនៃទន្លេមេគង្គ» បានលើកឡើងវិញនូវការយល់ដឹងកាលពីមុនស្តីអំពីរបបខ្មែរក្រហម ប៉ុន្តែនេះគ្រាន់តែចេញពីការគិតដោយឡែក និងផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ សៀវភៅនេះបានផ្តល់នូវការពិពណ៌នាយ៉ាងលម្អិតជាច្រើនអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយចំនួន ។ ការបោះពុម្ពនេះបានចូលរួមចំណែកនៅក្នុងការយល់ដឹងឲ្យកាន់តែល្អិតល្អន់ទៅលើសម័យកាលដ៏ព្រៃផ្សៃហួសពីការគិតនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក៏ដូចជាសកលលោក ។

ការចេញផ្សាយសៀវភៅនេះផ្ទាល់មិនមានតម្លៃអ្វីនោះទេ ។ អ្នកដែលមានហេតុផលក្នុងការលើកតម្កើងសៀវភៅនេះនៅប្រទេសចិន ប្រហែលជាមានការប្រុងប្រយ័ត្នក្នុងការរៀបចំការនិយាយ ។ ទីក្រុងប៉េកាំងតែងតែមានការសង្ស័យទៅលើសេចក្តីយោងទាំងឡាយណាទាក់ទិនទៅនឹងសម័យខ្មែរក្រហម ជាពិសេសវិធីសាស្ត្រដែលមិនគួរឲ្យសាទរមួយកាលពីអតីតកាលស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែ នៅពេលដែលសៀវភៅនេះបានរៀបចំកម្មវិធីសម្ពោធជាផ្លូវការនៅក្នុងឆ្នាំ២០០៨ មានកម្មាភិបាលបក្សកុម្មុយនីស្តចិនជាន់ខ្ពស់ចូលនិវត្តន៍ជាច្រើនរូប រួមទាំងមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្នមួយចំនួនក៏បានមកចូលរួមក្នុងកម្មវិធីនេះផងដែរ ។ មួយចំនួននៃអ្នកទាំងនោះបានចូលរួមផ្តល់នូវមតិយោបល់ខ្លះៗ ។ ម្នាក់ក្នុងចំណោមនោះបានបញ្ចប់សេចក្តីថា «សៀវភៅនេះមានតម្លៃជាផ្នែកអប់រំ ប្រវត្តិសាស្ត្រ និងជាឯកសារ ដែលមិនអាចជំនួសបានសៀវភៅនេះគឺជាសម្ភារបង្រៀនដ៏ល្អមួយសម្រាប់ក្មេងជំនាន់ក្រោយ» ។

ច្បាស់ណាស់ថា ការនិយាយនិងពិភាក្សាអំពីទំនាក់ទំនងរវាងខ្មែរក្រហមនិងទីក្រុងប៉េកាំងគឺមិនមែនជាការហាមប្រាមផ្នែកសង្គមនោះទេ ។ ទោះបីជាមានការលំបាកនិងឈឺចាប់យ៉ាងនេះក្តី ខ្ញុំសង្ឃឹមថាប្រទេសចិននិងមេដឹកនាំរបស់ខ្លួនអាចបោះជំហានចូលកាន់តែងវែងឆ្ងាយជាងនេះ ដោយធ្វើការកត់ចំណាំទុកដោយស្មោះត្រង់អំពីមេរៀនដែលទទួលបានពីប្រវត្តិសាស្ត្រមួយផ្នែកនេះ និងដោយចូលរួមរំលែកនៅក្នុងការផ្សះផ្សានៅប្រទេសកម្ពុជា ។ ដូចដែលមិត្តគួរជាទីពឹងពាក់ម្នាក់បានលើកឡើង គាត់សរសេរនៅក្នុងបរិបទប្រទេសកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែគំនិតនេះអាចយកមកប្រើប្រាស់ទូទាំងសកលលោក) ថា ៖

> ប្រជាជនកម្ពុជាជាច្រើនព្យាយាមបំភ្លេចបទពិសោធន៍ដ៏ឈឺចាប់ដែលខ្លួនបានជួបប្រទះនៅក្នុងរបបនេះ ។ ប៉ុន្តែយើងមិនអាចរីកចម្រើនទៅមុខបានទេ (ប្រសិនបើគ្មានការផ្សះផ្សាជាមួយខ្លួនឯង និងជាមួយអ្នកដទៃ) រហូតទាល់តែយើងបានប្រឈមមុខនឹងអតីតកាលទាំងនេះ ហើយស្វែងយល់ឲ្យច្បាស់អំពីអ្វីដែលបានកើតឡើង និងមូលហេតុដែលនាំឲ្យកើតមាន រឿងរ៉ាវបែបនោះ ។ លុះត្រាយើងស្វែងយល់អំពីប្រវត្តិកាលពីអតីតឲ្យបានច្បាស់លាស់ ទើបយើងអាចចាប់ផ្តើមដំណើរការផ្សះផ្សាពិតប្រាកដមួយបាន ។

ទោះជាយ៉ាងណា អ្នកដែលសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជាលើកដំបូងបង្អស់កាលពីជាងប្រាំបីរយឆ្នាំមុនគឺជាអគ្គទូតជនជាតិចិនម្នាក់ឈ្មោះ ជីវ តាក្វាន់ ។ អ្វីដែលមានប្រយោជន៍ដល់ស្ថានភាពបច្ចុប្បន្នគឺថា ទោះបីជាសៀវភៅរបស់គាត់បានកត់ត្រានូវរឿងរ៉ាវដ៏គួរឲ្យរន្ធត់ដែលគាត់បានជួបប្រទះនៅអង្គរធំដែលដូចនេះហើយតែងតែត្រូវបានជំទាស់ក៏ដោយ សៀវភៅនេះក៏បានធ្វើឲ្យសកលលោកនាពេលបច្ចុប្បន្ននេះ បានមើលឃើញពីរឿងរ៉ាវជីវិតមនុស្សផ្ទាល់ដែលរស់នៅក្រោមអាណាចក្រអង្គរដ៏អស្ចារ្យមួយនេះ ដែលនេះប្រហែលជាកំណត់ត្រាតែមួយគត់ដែលបន្សល់ទុកតាំងពីសម័យនោះមក ។ ដូច្នេះ វាគ្មានហេតុផលនោះទេដែលថា អ្នកបន្តវេនជំនាន់ក្រោយពីគាត់ដែលប្រកបដោយមោទកភាពនេះ មិនយកតម្រាប់តាមប្រពៃណីដ៏ខ្ពង់ខ្ពស់នេះនោះ ។

**ម៉ៃខល លីច**

# រៀនប្រវត្តិសាស្ត្រដើម្បីស្គាល់ខ្លួនឯង


ឆន ឆេងលន់

ឆន ឆេងលន់ អាយុ៤៦ កើតនៅឆ្នាំ១៩៦៧ ជាកូនទីពីរក្នុងចំណោមបងប្អូនប្រុសស្រីប្រាំពីរនាក់មានស្រុកកំណើតនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។ សព្វថ្ងៃ គាត់មានកូនប្រុសប្រាំនាក់ ។ លន់ ជាគ្រូបង្រៀននៅវិទ្យាល័យហ៊ុនសែនចំបក់ ខេត្តកំពង់ស្ពឺដោយបង្រៀនមុខវិជ្ជាអក្សរសាស្ត្រ ។ ប៉ុន្តែដោយសារ គាត់មកប្រឡងនៅវិទ្យាស្ថានជាតិអប់រំនេះតម្រូវឲ្យមានឯកទេសពីរ គាត់ក៏បានជ្រើសរើសយកមុខវិជ្ជាប្រវត្តិវិទ្យាជាមុខវិជ្ជាទីពីរ ។ គាត់ជ្រើសរើសយកប្រវត្តិវិទ្យាជាមុខវិជ្ជាទីពីរព្រោះមុខវិជ្ជានេះមានសារសំខាន់ណាស់ក្នុងនាមជាពលរដ្ឋក្នុងប្រទេសជាតិមួយ គប្បីដឹងពីប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍របស់ជាតិខ្លួន «បើកាលណាយើងមិនដឹងពីប្រវត្តិកំណើតជាតិរបស់ខ្លួនទេ ហាក់បីដូចជាយើងជាពលរដ្ឋម្នាក់ដែលមិនស្គាល់ពីខ្លួនដែរ» ។

ស្ថិតក្នុងឯកសណ្ឋានជាគរុនិស្សិត ដែលបានទទួលការអញ្ជើញមកចូលរួមវគ្គបណ្តុះបណ្តាលគរុនិស្សិតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ លន់ បានរំឭកពីកុមារភាពរបស់ខ្លួនដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។

កាលពីសម័យខ្មែរក្រហម លន់ ជាកុមារដែលទើបតែមានវ័យប្រាំបួនឆ្នាំ ។ គ្រួសាររបស់គាត់រស់នៅទីរួមខេត្តកំពង់ស្ពឺ ។ ដើមខែមេសា ឆ្នាំ១៩៧៥ ឪពុកម្តាយរបស់គាត់បាននាំគ្រួសារចេញពីផ្ទះទៅរស់នៅវាលស្រែវិញ ដោយកាប់មែកឈើធំៗធ្វើជាជម្រក ព្រោះដើម្បីគេចពីគ្រាប់ផ្លោងពីសំណាក់ខ្មែរក្រហម ។ បន្ទាប់ពីការប្រយុទ្ធគ្នាតាំងពីយប់រហូតដល់ម៉ោងប្រាំបួនព្រឹក ក៏បានឮដំណឹងតាមវិទ្យុខ្មែរក្រហមដែលបានផ្សាយថា ទីក្រុងភ្នំពេញបានបែកហើយ ។ បន្តិចក្រោយមកខ្មែរក្រហមដណ្តើមបានខេត្តកំពង់ស្ពឺ និងបានប្រកាសស្រែកតាមមេក្រូ ព្រមទាំងឲ្យប្រជាជនចាកចេញពីលំនៅស្ថានមួយរយៈដោយប្រាប់ថា ចេញពីទីរួមខេត្តឬលំនៅស្ថានសិន ព្រោះខ្លាចអាមេរិកកាំងមកទម្លាក់គ្រាប់បែក ។ លន់ បន្តថាពេលនោះម្នាក់ៗដែលបោះជំរំនៅវាលស្រែ រួមទាំងគ្រួសាររបស់គាត់ផងនឹកស្មានថា ខ្មែរក្រហមឲ្យត្រឡប់មកផ្ទះវិញ តែតាមពិតខ្មែរក្រហមមិនបានឲ្យត្រឡប់មកផ្ទះទេ ។ គ្រួសាររបស់ លន់ ក៏ធ្វើដំណើរទៅកន្លែងផ្សេង ។

សមាជិកបងប្អូនដែលធ្វើដំណើរទៅជាមួយគ្រួសារ លន់ មានប្រហែលម្ភៃនាក់ និងរទេះបីបួន ។ ក្នុងការធ្វើដំណើររយៈពេលប្រាំថ្ងៃ គ្រួសាររបស់ លន់ បានទៅដល់ក្រាំងចេក ដែលមានចម្ងាយប្រហែលជាង២៥គីឡូម៉ែត្រពីខេត្តកំពង់ស្ពឺ ដោយនៅទីនោះ គាត់រស់នៅតាមទីទួលតាមព្រៃ តាមវាល ។ នៅតាមផ្លូវធ្វើដំណើរ លន់ ឃើញមានមនុស្សស្លាប់ជាច្រើន ភាគច្រើនអ្នកទាំងនោះស្លាប់ដោយសារខ្វះអាហារ ព្រោះនឹកស្មានថា ចេញតែរយៈពេលខ្លីក៏មិនបានរៀបចំអ្វីមកជាមួយទេ ។

រហូតដល់ពាក់កណ្តាលខែឧសភា ទើបអង្គការចាប់ផ្តើមបង្កើតមានមេក្រុម មេកង ក៏ដូចជាសហករណ៍ ប៉ុន្តែមិនទាន់បង្កើតជាភូមិនៅឡើយទេ គឺរស់នៅតាមព្រៃ ហើយអ្វីដែលសំខាន់គឺយោធាខ្មែរក្រហមចាប់ផ្តើមឆែកឆេរ ប៉ុន្តែមិនទាន់ប្រមូលរបស់ទ្រព្យនោះទេ គ្រាន់តែឆែកឆេររកអ្នកធ្វើការនៅសម័យ លន់ នល់ ដូចជា

មន្ត្រីរាជការ ឬទាហាន ។ ពេលដែលយោធាខ្មែរក្រហមឆែកឆេរផ្ទះរបស់គ្រួសារគាត់ស្រាប់តែរកឃើញគ្រាប់កាំភ្លើងអ៊ឹម៧៩មួយគ្រាប់នៅក្នុងបន្ទប់ខោអាវរបស់ឪពុកគាត់ ។ តាមការពិតគ្រាប់កាំភ្លើងនោះមិនមែនជារបស់ឪពុកគាត់ទេ គឺជារបស់បងប្អូនជីទួតមួយរបស់ឪពុកគាត់ដែលធ្វើទាហាន ហើយមិនដឹងថាហេតុអ្វីបានជាឃើញគ្រាប់នោះមកនៅក្នុងផ្ទះឪពុកគាត់ដូច្នេះ ។ ការរកឃើញនេះធ្វើឲ្យគ្រួសារ លន់ ភ័យខ្លាំងណាស់ ព្រោះកាលណាខ្មែរក្រហមរកឃើញនឹងចាត់ទុកថា គ្រួសារទាហាន លន់ នល់ហើយ ដូច្នេះខ្មែរក្រហមនឹងយកទៅដាក់នៅជំរំឈើយសឹកមិនខាន ។ ជាសំណាងបានគុណបុណ្យអ្នកមូលដ្ឋាន ក៏ដូចជាអ្នកមកធ្វើប្រវត្តិរូបអ្នកទាំងនោះជួយបិទបាំងរឿងនេះ ដោយសារតែការអាណិតអាសូរចំពោះឪពុក លន់ ដែលមានកូនចៅច្រើន និងមានសមាជិកជាច្រើនដែលរួមដំណើរទៅជាមួយ បន្ទាប់ពីស្តាប់ការរៀបរាប់របស់ឪពុកគាត់ដែលមិនដឹងថាគ្រាប់កាំភ្លើងនេះមកពីណា ទើបអ្នកធ្វើប្រវត្តិរូបលុបឈ្មោះចេញពីបញ្ជីដែលឆែកឆេរឃើញ និងបានយកគ្រាប់នោះទៅកប់ចោល ។ គ្រួសាររបស់ លន់ ក៏បានរួចជីវិតតាំងពីពេលនោះមក ។

នៅខែឆ្នាំដដែល បន្ទាប់ពីបង្កើតជាសហករណ៍ហើយ អង្គការបានឲ្យគ្រួសារ លន់ ត្រលប់មកដល់ភូមិអង្គរជា ឃុំញាយ ស្រុកថ្ពង ឬស្រុក២៨ តំបន់៣២ (គ្រួសារ លន់ រស់នៅ ទីនោះរហូតដល់ឆ្នាំ១៩៧៩) ។ នៅឆ្នាំ១៩៧៦ អង្គការចាប់ផ្តើមជម្លៀសប្រជាជននៅក្នុងសហករណ៍ដែល លន់ រស់នៅទៅខាងខេត្តបាត់ដំបង ប៉ុន្តែគ្រួសារគាត់មិនត្រូវបានអង្គការជម្លៀសទៅទេ ដោយសារតែអង្គការស្រលាញ់ឪពុកគាត់ព្រោះគាត់ចេះដាំដំណាំបានល្អគ្រប់រដូវកាលសម្រាប់ផ្គត់ផ្គង់ដល់សេដ្ឋកិច្ចនៅសហករណ៍ ។ ទោះបីជានៅទីនោះរហូតមិនបានជម្លៀសទៅកន្លែងផ្សេងក៏ដោយ ក៏គ្រួសាររបស់គាត់មិនបានរស់នៅជួបជុំគ្នានោះទេ ។ ដំបូងឪពុករបស់ លន់ រស់នៅបែកពីម្តាយគាត់ដោយម្តាយត្រូវឲ្យទៅធ្វើស្រែនៅកន្លែងផ្សេងដែលមានចម្ងាយប្រហែលដប់គីឡូម៉ែតពីផ្ទះ ហើយល្ងាចទៅត្រឡប់មកផ្ទះវិញ បន្ទាប់ពីនៅកន្លែងដំណាំខ្វះកម្លាំងពលកម្មដើម្បីស្រោចទឹកដំណាំ អង្គការក៏ចាត់តាំងម្តាយ លន់ មកធ្វើការជាមួយប្តីវិញ ។ សម្រាប់ លន់ ជាកុមារមិនបាននៅជាមួយឪពុកម្តាយទេ គឺទៅនៅតាមកងកុមារ ។ លន់ បានឲ្យដឹងថា រោងកុមារនៅក្នុងសហករណ៍នោះ អង្គការធ្វើដូចជា សាលារៀនមួយវែងដែលអង្គការប្រមូលកុមារទាំងអស់ប្រហែលជាដប់ភូមិមកនៅជុំគ្នា មានរោងក្មេងប្រុសមួយ រោងក្មេងស្រីមួយ ។

នៅកងកុមារនោះពីខែឧសភា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៥ ពេលព្រឹក អង្គការឲ្យរៀនអក្សរប្រហែលបីម៉ោង ។ រាល់ព្រឹករៀនពីព្យញ្ជនៈ ស្រៈខ្មែរ ដោយមានគ្រូអាចារ្យម្នាក់ដែលធ្លាប់បានបួសរៀនជិតនាំមុនបង្រៀន ។ ចាប់ពីឆ្នាំដើមឆ្នាំ១៩៧៦ អង្គការបានឈប់ឲ្យកុមាររៀនហើយ កុមារទាំងអស់ត្រូវអង្គការចាត់តាំងឲ្យទៅរែកដីនៅទំនប់ ប្រឡាយ កាប់ដីដំបូកជញ្ជូនដាក់ស្រែ ឬក៏ទៅឃ្វាលគោដែលមានចំនួនរាប់ពាន់ក្បាល តាមតែអង្គការនឹកឃើញ ។

ភ្នែកសម្លឹងមើលផ្ទៃខ្នុរដែលនៅពីមុខ លន់ និយាយបន្តដោយហួសចិត្តពីអនុស្សាវរីយ៍នៃកុមារឃ្វាលគោម្នាក់កាលពីរបបខ្មែរក្រហម ។ គោមួយក្រោលដែលព័ទ្ធរបងឫស្សីជុំវិញទំហំដីប្រហែលមួយហិចតា មានប្រហែលបួនពាន់ទៅប្រាំពាន់គោ ក្មេងអ្នកមើលគោមានពីរបីនាក់ និងតាចាស់ពីរនាក់ប៉ុណ្ណោះ ។ ការឃ្វាលនេះគឺឃ្វាលគោទៅកន្លែងណាដែលឆ្ងាយដែលគោមិនអាចចូលស៊ីស្រូវក្នុងសហករណ៍បាន តាំងពីព្រលឹមទល់ព្រលប់ ។ មានពេលមួយ លន់ ទៅឃ្វាលគោ ដោយសារគោច្រើនពេកក៏បាត់គោប្រហែលប្រាំក្បាលទៅស៊ីស្រូវសហករណ៍ផ្សេងដែលនៅក្បែរនោះ (លន់ បញ្ជាក់ថាសហករណ៍នីមួយៗនៅរបបខ្មែរក្រហមគឺមិនសូវត្រូវគ្នាទេ) ។ ពេលដែលគោរបស់ លន់ ទៅស៊ីស្រូវសហករណ៍នោះ ប្រធានសហករណ៍នោះរករឿងខ្លាំងណាស់ ព្រមទាំងស្នើយកក្រុមរបស់គាត់ទៅដាក់


លន់ កំពុងរៀបរាប់រឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម

ទណ្ឌកម្មទៀតផង តែដោយមានការសម្រួលពី តាចាន់ ប្រធានសហករណ៍របស់លន់ ទើបមិនមានការធ្វើទារុណកម្ម តែក្រុមរបស់គាត់នៅតែមានទទួលពិន័យដដែល ។ តាចាន់ បានបញ្ជាឲ្យយាយៗនៅភូមិ ត្បាញធ្វើជាសំពៀតឲ្យទៅក្រុមឃ្វាលគោ លន់ពីរៗម្នាក់ ។ ការឲ្យស្ពាយសំពៀតនេះគឺជាសញ្ញាថា ជាអ្នកឃ្វាលគោធ្វើការធ្វេសប្រហែសដែលបណ្តាលឲ្យគោទេស៊ីស្រូវ ស៊ីដំណាំអ្នកដទៃ គឺស្ពាយបានប្រហែលពីរ បីខែ ផុតរដូវឃ្វាលគោ ទើបដោះចេញបាន ។

នៅរោងកុមារក្រៅពីការងារដែលអង្គការដាក់ឲ្យធ្វើ គឺ លន់ និងកុមារមួយចំនួនទៀតត្រូវអង្គការចាត់តាំងឲ្យទៅសម្តែងសិល្បៈ ដូចជាច្រៀង រាំ ឲ្យតា ចាន់ ដែលជាប្រធានសហករណ៍មើលរៀងរាល់បីថ្ងៃម្តង ។ ក្រុមរបស់គាត់ត្រូវដើរកាត់ព្រៃទៅផ្ទះតាចាន់ ប្រហែលបួនគីឡូម៉ែតទើបដល់ ហើយយប់ប្រហែលម៉ោង១១ ទើបដើរត្រលប់មករោងកុមារវិញ ។ ក្រៅពីថ្ងៃដែលទៅសម្តែងនៅផ្ទះតាចាន់ ជារៀងរាល់ម៉ោង៦ល្ងាច លន់ និងកុមារក្នុងកងម្នាក់ទៀត ត្រូវអង្គការចាត់តាំងឲ្យទៅរវៃឌីណាម៉ូកង់ដើម្បីបើកមេក្រូឲ្យចាស់ៗដែលត្រឡប់មកពីធ្វើការស្តាប់វិទ្យុអង្គការដែលផ្សាយចេញពីផ្សាយពីភ្នំពេញ ដូចជាចម្រៀង និងព័ត៌មានជាដើម ។ លន់ ត្រូវអង្គុយរវៃរហូតដល់ម៉ោង១០ ឬ១១យប់ទើបបានសម្រាក ។ កុមារផ្សេងទៀតត្រូវអង្គការចាត់តាំងឲ្យទៅរែកដី ឬទៅធ្វើអ្វីផ្សេង តាមអង្គការចាត់តាំង ។

បន្តដោយសម្លេងអួលដើមក លន់ រំឭកថា ថ្វីត្បិតតែទណ្ឌកម្មដែលមានមកលើរូបគាត់មានកម្រិតមធ្យម ប៉ុន្តែកុមារខ្លះទៀតត្រូវអង្គការដាក់ទណ្ឌកម្មដោយឲ្យរែកដី បី បួនម៉ែត្រគូប ខ្លះចងឲ្យស្រមោចខាំ ខ្លះឲ្យរកជំឡូង ខ្លះឲ្យកាប់រណ្តៅដី ខ្លះចងនៅសរសររោងបាយ ដោយសារតែអ្នកទាំងនោះលួចរត់ទៅជួបឪពុកម្តាយ ។ ឆ្នាំ១៩៧៨ ទណ្ឌកម្មផ្លូវចិត្តបានធ្វើឲ្យកុមារដូច លន់ បានសម្រេចចិត្តសម្លាប់ខ្លួន តែមិនបានសម្រេច ។ កាលណោះ លន់ បានយកកូនសត្វលលកដែល តាជា ទុកចិញ្ចឹមមកចិញ្ចឹម ដោយមិនបានដឹងថាជារបស់គាត់ទេ ។ តាជា ដើរសួរក្មេងៗគ្រប់គ្នា ហើយអ្នកទាំងនោះក៏ប្រាប់ថា លន់ជាអ្នកយក ។ ក្រោយពី តាជា ដឹងថាជា លន់គាត់តែងតែចង់វៃ និងរករឿង លន់ គ្រប់ពេលរហូតដល់ លន់ សម្រេចចិត្តសម្លាប់ខ្លួន ។ ថ្ងៃមួយ ម៉ោងប្រហែល ៥ល្ងាច លន់ បានដើរឆ្ងាយពីអ្នកដទៃ ហើយក៏ឡើងចុងដើមអំពិលរួចយកខ្សែចងកសម្លាប់ខ្លួន ប៉ុន្តែមិនដឹងមកពីអ្វីនោះទេ បែរជាមិនស្លាប់ទោះបីជាដើងផុតពីដីហើយ ក៏ដោយ គឺនៅយោលទៅយោលមកតែម្តង បន្ទាប់មកដោយមិនស្លាប់បែបនេះធ្វើឲ្យលន់មានគំនិតមួយថា មិនត្រូវសម្លាប់ខ្លួនទៀតទេ គាត់ក៏ខំប្រឹងយោលទៅតោងនឹងមែកអំពិល ហើយស្រាយចំណងចេញពីកបាន ។

ឆ្នាំ១៩៧៧ គឺជាឆ្នាំដែលលំបាកបំផុត ។ នៅសហករណ៍របស់ លន់ អង្គការឲ្យយកប្រេង ដែលជាប្រទាលម៉្យាងមានមើមធំៗប្រហាក់ប្រហែលនឹងក្តួចដែរច្រើនដុះនៅក្នុងព្រៃភ្នំ មកធ្វើជាអាហារ ។ អង្គការចាត់តាំងឲ្យតាៗក្នុងភូមិទៅព្រៃភ្នំគាស់ប្រេង ប្រហែលជាកន្លះខែទើបមកវិញ ។ ពេលដែលយកប្រេងមកដល់គឺយកមកចិតសំបកឲ្យអស់នៅសល់តែបណ្តូលខ្ទីទំហំប្រហែលប៉ុនក្លៀមនុស្សចាស់ ហើយចិតជាចំណិតស្តើងល្មមរួចចិញ្រ្ចាំ ហើយយកទៅត្រាំទឹកប្រហែលជាងដប់ថ្ងៃដើម្បីឲ្យអស់ជាតិពុលទើបយកមកលាយជាមួយនឹងអង្ករដាំបាយ ។

ទោះបីជានៅក្នុងឆ្នាំ១៩៧៩ តំបន់មួយចំនួនត្រូវបានកងទ័ពវៀតណាមរំដោះហើយក៏ដោយ តែតំបន់ដែល លន់ រស់នៅមិនទាន់បានរំដោះនៅឡើយទេ ។ ពេលនោះ កងកុមាររបស់ លន់ ត្រូវបានរំសាយ ហើយឲ្យត្រឡប់មករកឪពុកម្តាយរបស់ខ្លួនវិញ ។ គ្រួសាររបស់ លន់ ក៏ដូចជាប្រជាជននៅតំបន់នោះ ត្រូវបានខ្មែរក្រហមកៀរឲ្យឡើងទៅខាងភ្នំព្រះរហូតដល់ខែមីនា ទើបកងទ័ពវៀតណាមស្ទាក់តាមផ្លូវរំដោះបានគ្រួសារមួយចំនួនក្នុងនោះក៏មានគ្រួសាររបស់ លន់ ដែរ ។ បន្ទាប់មក គ្រួសាររបស់ លន់ បានត្រឡប់មកទីរួមខេត្តកំពង់ស្ពឺវិញ ។ ស្នាក់នៅទីនោះដល់ខែឧសភា ពេលដែលមានសន្តិសុខហើយ ទើបចាប់ផ្តើមឲ្យការរំសាយប្រជាជនទៅនៅភូមិស្រុករៀងៗខ្លួនវិញ ។ គ្រួសាររបស់ លន់ ក៏សម្រេចចិត្តត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ។

ក្រោយឆ្នាំ១៩៧៩ លន់ បានចាប់ផ្តើមរៀនថ្នាក់ទី២ ដោយសារតែកាលពី លន់ ជម្លៀសទៅដំបូង គាត់បានរៀនអក្សរបានបីបួនខែ ដែលអាចចេះអាន ចេះសរសេរបានខ្លះដែរ ហើយក៏រៀនបន្តៗរហូតដល់ ឆ្នាំ១៩៨៥ បានប្រលងឌីប្លូមចប់ ដោយគ្មានលទ្ធភាពមកបន្តការសិក្សានៅភ្នំពេញនឹងគេ លន់ ក៏បានប្រឡងចូល

ធ្វើគ្រូអនុវិទ្យាល័យ ក្រោយមកបានបន្តយកបរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ហើយរហូតមកដល់សព្វថ្ងៃ លន់ ក៏បានប្រលងជាប់ជាគ្រូថ្នាក់ឧត្តមសិក្សាដែលកំពុងតែរៀននៅវិទ្យាស្ថានជាតិអប់រំសព្វថ្ងៃ ។

ការដែលលោកគ្រូបានចូលរួមវគ្គបណ្ដុះបណ្ដាលគ្រូស្ដីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩) លន់ យល់ឃើញថា ពិតជាល្អណាស់ ថ្វីត្បិតតែគាត់បានអានឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យច្រើនដងហើយ មិនមែនទើបតែមករៀននៅវគ្គនេះទេ ប៉ុន្តែពេលនេះ គាត់បានអានឯកសារហើយ និងមានគ្រូឯកទេសមកបង្រៀនទៀត ដូច្នេះគឺល្អណាស់ ។ លន់ បន្តទៀតថា ថ្វីត្បិតតែ លន់ បានរស់នៅក្នុងរបបខ្មែរក្រហមមែន ប៉ុន្តែក្នុងជំនាន់ប៉ុល ពត តាមតំបន់នីមួយៗមានលក្ខណៈខុសគ្នាបន្តិចបន្តួច ទោះបីជាមានលក្ខណៈរួមមួយគឺអំណាចផ្ដាច់ការតែមួយ ។ បន្ទាប់ពីបានទទួលការបណ្ដុះបណ្ដាលពីគ្រូដែលមានបទពិសោធន៍ក្នុងផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហម ធ្វើឲ្យគាត់មានចំណេះដឹងកាន់តែច្រើន ។ ជាពិសេស បានជួបជុំជាមួយនឹងមិត្តភក្តិដែលរស់នៅតំបន់នានានៃរបបខ្មែរក្រហម ព្រមទាំងបានផ្លាស់ប្ដូរបទពិសោធន៍ ក៏ដូចជាបានប្រមូលនូវព័ត៌មានកាន់តែច្រើនថែមទៀត ដើម្បីការចេះដឹងដូច្នេះការរៀនវគ្គនេះគឺល្អណាស់ ព្រោះដើម្បីជាប្រយោជន៍ក្នុងការបង្ហាត់បង្រៀនសិស្សានុសិស្ស នៅពេលដែលគាត់ត្រលប់ទៅវិញ ។

មកដល់សព្វថ្ងៃនេះ ក្នុងអារម្មណ៍របស់ លន់ មិនដែលមានគំនិតគំគួនជាមួយអ្នកដែលធ្លាប់ធ្វើបាបគាត់ ក៏ដូចជាគ្រួសារគាត់នៅក្នុងរបបខ្មែរក្រហមនោះទេ ។ ពេលខ្លះ លន់ រាប់អានអ្នកទាំងនោះ


លន់ (ឆ្វេង) កំពុងពិភាក្សាក្រុមអំឡុងពេលចូលរួមវគ្គបណ្ដុះបណ្ដាល

ដល់សព្វថ្ងៃទៀតផង ។ គាត់យល់ថា ពេលខ្លះអ្នកទាំងនោះធ្វើតាមការបញ្ជារបស់ថ្នាក់លើដែរ គឺធ្វើដើម្បីរស់ដូចគ្នា ។ ប៉ុន្តែ បើទាក់ទងទៅនឹង នួន ជា, ខៀវ សំផន ពេលដែល លន់ មើលសវនាការម្ដងៗ គាត់តែងតែមានអារម្មណ៍ខឹងនឹងមេដឹកនាំទាំងនោះឆ្លើយបដិសេធនូវអ្វីដែលកើតមានឡើងក្នុងរបបប៉ុល ពត ថា ខ្លួនមិនបានដឹងពីការកាប់សម្លាប់នោះទេ ។ លើសពីនេះទៅទៀត ពេលដែលគាត់តាមដានសវនាការ បើ ឌុច និយាយគឺមានការពិតច្រើន តែបើដូចជាមេដឹកនាំទាំងបួនដែលមាន អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងនួន ជា នោះ លន់ មិនជឿនោះទេ ។

ចំពោះដំណើរការតុលាការខ្មែរក្រហមសព្វថ្ងៃនេះ លន់យល់ថាល្អ ប៉ុន្តែយឺតពេក អូសបន្លាយពេក រហូតដល់បុគ្គលដែលជាជនរងគ្រោះខ្លះស្លាប់ជាបន្តបន្ទាប់ ក៏ដូចជាជនជាប់ចោទក៏ត្រូវស្លាប់អស់មួយចំនួន ។ ប៉ុន្តែគាត់នៅតែបង្ហាញសុទិដ្ឋិនិយមចំពោះតុលាការខ្មែរក្រហមថា «យើងមានតុលាការនេះ គឺយើងមានយុត្តិធម៌ច្រើនដែរតាមរយៈតុលាការនេះធ្វើឲ្យជនជាប់ចោទដឹងថា ក្រុមរបស់ខ្លួនបានដឹកនាំខុស ហើយធ្វើឲ្យស្លាប់ប្រជាជនរាប់លាននាក់ ថ្វីត្បិតតែមេដឹកនាំទាំងនោះមិនបានសម្លាប់ដោយផ្ទាល់ដៃ ប៉ុន្តែដោយសារការដឹកនាំ និន្នាការនយោបាយរបស់ក្រុមខ្លួន ទើបធ្វើឲ្យមានការកាប់សម្លាប់ដូច្នេះ សូមកុំបដិសេធរាល់អ្វីដែលបានកើតឡើង» ។ ប្រកបដោយទឹកមុខមុតមាំ លន់ បន្តថា មេដឹកនាំទាំងនោះមិនមែនមិនដឹងទេ ប៉ុន្តែមនុស្សកាលណាមានកំហុសមិនដែលដឹងថា ខ្លួនឯងមានកំហុសទេ គឺឆ្លើយយកតែរួចខ្លួនប៉ុណ្ណោះ ។

ជាចុងក្រោយ លន់ សំណូមពរឲ្យតុលាការមេត្តាកាត់ទោសឲ្យបានលឿន មិនចាំបាច់ឲ្យមានការបំភ្លឺពីអ្នកនេះ អ្នកនោះច្រើនពេកទេ ព្រោះសាក្សីខ្មែរ ប្រជាជនខ្មែររាប់លាននាក់ជាសាក្សីរស់ច្រើនពេកហើយ រួមទាំងឯកសារច្រើនរាប់មិនអស់ផង ។ លើសពីនេះទៀត មកដល់សព្វថ្ងៃនេះគាត់ជឿថា រណ្ដៅសាកសពមួយចំនួនមិនទាន់រកឃើញអស់ផង ហើយប្រជាជនខ្មែរមួយចំនួនបែកពីក្រុមគ្រួសារមិនទាន់រកគ្នាឃើញផង ទាំងអស់នេះហើយគឺជាភស្តុតាងច្បាស់លាស់មួយ ។

**ឆាយ សារៈមុនិន្ទ**

# បទពិសោធន៍ជីវិតរបស់អ្នកទោសស-២១ ឈ្មោះ ជុំ ម៉ី នឹងលាតត្រដាង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចេញផ្សាយសៀវភៅមួយលេខទៀតដែលត្រូវបានសរសេរឡើងជាភាសាអង់គ្លេសមានចំណងជើងថា Survivor: The Triumph of an Ordinary Man in the Khmer Rouge Genocide ឬមានន័យជាភាសាខ្មែរថា «អ្នករួចជីវិតៈ ភាពជោគជ័យរបស់បុរសសាមញ្ញម្នាក់នៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម» ។ សៀវភៅនេះគឺជាសៀវភៅទី១៨ដែលបានបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅនេះត្រូវបានប្រែសម្រួលដោយ គីម ស្រួយ សុខវិសាល និង ស៊ីម សូរិយ៉ា ចេញពីចម្លើយសារភាព និងតាមរយៈការធ្វើបទសម្ភាសន៍អស់រយៈពេលជាច្រើនឆ្នាំ ។ សៀវភៅនេះរៀបរាប់ពីជីវិតរបស់បុរសម្នាក់ឈ្មោះ ជុំ ម៉ី ដែលបានរួចរស់ជីវិតពីមន្ទីរស-២១ ។ ជុំម៉ី ដែលពេលនេះមានអាយុ៨១ឆ្នាំគឺជាមនុស្សមួយចំនួនតូចដែលបានរស់រានមានជីវិតពីមន្ទីរនេះ ក្រោមការគ្រប់គ្រងរបស់សមមិត្ត កាំង ហ្គេចអ៊ាវ ហៅ ឌុច ។ នៅមន្ទីរស-២១ ជុំ ម៉ី ត្រូវបានថតរូប សួរចម្លើយ ធ្វើទារុណកម្ម និងក្រោយមកត្រូវបានចាត់តាំងឲ្យជួសជុលម៉ាស៊ីនអង្គុលីលេខ ដើម្បីជាផលប្រយោជន៍របស់អង្គការបដិវត្តន៍ ។ កិច្ចការនេះហើយដែលជួយ ជុំ ម៉ី ឲ្យមានជីវិតរស់រហូតដល់សព្វថ្ងៃនេះ ។




តាមរយៈសៀវភៅនេះ ជុំ ម៉ី បានបង្ហាញពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្លួនដូចជា ការរស់រានមានជីវិតពីការវាយប្រហារដោយកាំភ្លើង និងគ្រាប់រ៉ុក្កែតនៅក្នុងសម័យសង្គ្រាមស៊ីវិល ការបាត់បង់ និងព្រាត់ប្រាស់ប្រពន្ធនិងកូន ការចាប់បិទមុខ និងបញ្ជូនចូលក្នុងមន្ទីរស-២១ ។ មានតែអ្នកទោសមួយចំនួនតូចប៉ុណ្ណោះដែលបានរស់រានមានជីវិត ហើយសាច់រឿងរបស់ ជុំ ម៉ី ឆ្លុះបញ្ចាំងពីទិដ្ឋភាពដ៏កម្រមួយអំពីការសម្លាប់មនុស្សជាប្រព័ន្ធនៅក្នុងគុកដ៏ធំបំផុតរបស់ខ្មែរក្រហម ។

ជុំ ម៉ី រស់រានមានជីវិតដោយសារតែគាត់មានជំនាញខាងជួសជុលម៉ាស៊ីន ។ ក្រោយពីទទួលនូវការធ្វើទារុណកម្ម និងឆក់ខ្សែភ្លើងអស់ជាច្រើនលើកច្រើនសារ គាត់ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមអ្នកទោសដទៃទៀត និងចាត់តាំងឲ្យជួសជុលម៉ាស៊ីនអង្គុលីលេខដែលអ្នកសួរចម្លើយរបស់គាត់ផ្ទាល់បានប្រើប្រាស់ដើម្បីកត់ត្រាចម្លើយសារភាពរបស់អ្នកទោស ។

ជុំ ម៉ី ខ្លួនឯងផ្ទាល់បានឆ្លើយសារភាពទាំងស្រមើស្រមៃពីសកម្មភាពប្រឆាំងនឹងបដិវត្តន៍របស់គាត់សម្រាប់បម្រើឲ្យក្រុមស៊ើបការសម្ងាត់របស់សហរដ្ឋអាមេរិក សេ.អ៊ី.អា ជាស្ថាប័នមួយ

ដែលគាត់មិនដែលបានស្គាល់ទាល់តែសោះនៅមុនពេលដែលគាត់ទទួលរងទារុណកម្ម ។ គាត់បានឆ្លើយនឹងសំណួរគ្រប់បែបយ៉ាងដើម្បីកុំឲ្យខ្មែរក្រហមធ្វើទារុណកម្មមកលើរូបគាត់ទៀត ។ ចម្លើយសារភាពរបស់គាត់ត្រូវបានបកប្រែទៅជាភាសាអង់គ្លេស និងបានដាក់បញ្ចូលទៅក្នុងសៀវភៅនេះ ហើយដែលជាចម្លើយសារភាពដំបូងបំផុតក្នុងចំណោមចម្លើយសារភាពរាប់ពាន់ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ ។

ជាច្រើនឆ្នាំក្រោយមក ជុំ ម៉ី បានយល់ និងមានចិត្តអាណិតដល់អ្នកដែលបានធ្វើទារុណកម្មលើរូបគាត់ជាជាងថ្កោលទោសលើអ្នកទាំងអស់នោះ ។ ជុំ ម៉ី បាននិយាយនៅក្នុងសេចក្ដីផ្ដើមរបស់សៀវភៅនេះថា «ខ្ញុំចាត់ទុកអ្នកដែលធ្វើទារុណកម្មមកលើខ្ញុំជាជនរងគ្រោះដូចខ្ញុំដែរ ពីព្រោះអ្នកទាំងនោះត្រូវតែធ្វើតាមបញ្ជារបស់អ្នកដទៃ ។ តើនរណាទៅហ៊ានល្មើសនឹងបញ្ជារបស់អង្គការនោះ? ។

ជុំ ម៉ី បានរួចផុតពីការស្លាប់តែគាត់ នៅតែមិនអស់ចិត្ត ។ «នេះគឺជាភ័ព្វសំណាងដ៏កម្របំផុតមួយដែលខ្ញុំបានរស់រានមានជីវិតពីកន្លែងនោះ ខណៈពេលដែលមនុស្សជាច្រើនត្រូវបានសម្លាប់» ។ គាត់បន្តទៀតថា «ខ្ញុំតែងតែគិតជារៀងរាល់យប់ថាហេតុអ្វីបានជាខ្ញុំមានសំណាងម្ល៉េះដែលបានរស់រានមានជីវិត ។ហេតុអ្វីបានជាខ្ញុំនៅរស់?»

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ដំណឹងស្វែងរកបងស្រី

ខ្ញុំបាទឈ្មោះ សេក ធា ភេទប្រុស ជាមន្ត្រីរាជការនៅក្រសួងបរិស្ថាន សព្វថ្ងៃរស់នៅផ្ទះលេខៈ គេ១៣៦ ភូមិ៩ ផ្លូវសុធារសសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ នៅក្នុងរបប ប៉ុល ពត ខ្ញុំនិងគ្រួសាររស់នៅភូមិខ្វយ ឃុំអូម្ចូ ស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម ។ ខ្ញុំសូមប្រកាសរកបងស្រីឈ្មោះ សេក សារិន ភេទស្រី កើតនៅឆ្នាំ១៩៥៦ (ឆ្នាំរកា) ។

ខ្ញុំបាទមានឪពុកឈ្មោះ សេក ពិន (ស្លាប់នៅឆ្នាំ១៩៧៨) និងម្ដាយឈ្មោះ គីក វ៉ាន់ (នៅរស់) ព្រមទាំងបងប្អូនបង្កើតចំនួន៧នាក់ ដែលមានរាយនាមខាងក្រោមៈ

១) សេក វន ភេទស្រី

២) សេក ប្រាក់ ភេទប្រុស

៣) សេក សារិន ភេទស្រី (បាត់ខ្លួន)

៤) សេក ឡៃ ភេទស្រី

៥) សេក សារឿន ភេទស្រី

៦) សេក ស៊ីណា ភេទស្រី (ស្លាប់ឆ្នាំ១៩៩៣)

៧) សេក ធា ភេទប្រុស (ពៅ)

នៅសម័យ ប៉ុល ពត សេក សារិន ជានារីពេទ្យនៅឃុំអូម្ចូ ដោយបានប្ដូរឈ្មោះថា មិត្ត មួន ។ ក្រោយឆ្នាំ១៩៧៥ សារិន ត្រូវបានបញ្ជូនទៅនៅមន្ទីពេទ្យព្រះកេតុមាលា ក្រុងភ្នំពេញ មួយរយៈ ។ តមក នៅឆ្នាំ១៩៧៧ ក្រុមគ្រួសារខ្ញុំបានជួបគាត់ចំនួនពីរដងពេលដែលក្រុមគ្រូពេទ្យទៅកាប់អំបោសនៅភូមិខ្វយ ។ នៅឆ្នាំ១៩៧៨ ក្រុមគ្រួសារខ្ញុំបានឮដំណឹងថាក្រុមគ្រូពេទ្យមិត្ត មួន ត្រូវរំសាយឲ្យទៅនៅកងចល័ត ដោយមិនដឹងមូលហេតុ ហើយចាប់តាំងពីនោះមកគាត់ក៏បាត់ដំណឹងរហូត ។

ប្រសិនបើបងប្អូនណាបានឮ ឬស្គាល់ឈ្មោះដូចខាងលើ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈ អាសយដ្ឋានដូចមានរៀបរាបខាងលើ ឬតាមរយៈទូរស័ព្ទលេខៈ ០ ១២ ៦០០ ៩៦៦ ឬ ០ ១៦ ៨៧៦ ៦៩២ ។ ***សូមអរគុណ!***

# ការពិចារណាអំពីទំហំនៃ«សវនាការតូច»លើកដំបូងនៅក្នុងករណីប្រឆាំងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម

កាលពីខែកញ្ញា ឆ្នាំមុន អង្គជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបំបែករឿងក្តីរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិតជាគោលនយោបាយឧក្រិដ្ឋកម្មសំខាន់ៗចំនួនប្រាំក្នុងគោលបំណងបើកអង្គសវនាការខ្លីៗតាមលំដាប់លំដោយជាច្រើនដែលអង្គជំនុំជម្រះយល់ថា សមស្រប ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងករណីជួបប្រទះនូវរឿងរ៉ាវស្មុគស្មាញដូចគ្នានៅ និងតុលាការអន្តរជាតិផ្សេងទៀត ភាគច្រើនត្រូវចំណាយពេលដប់ឆ្នាំទើបអាចចេញសាលក្រមបាន ។ ដោយទទួលស្គាល់ពីវ័យកាន់តែចំណាស់របស់ជនជាប់ចោទក្នុងករណី០០២ និងជនរងគ្រោះ អង្គជំនុំជម្រះបានធ្វើការ «កំណត់ចំនួនតិចតួចនៃចំនួនសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវអញ្ជើញ» ដែលការធ្វើបែបនេះ «និងផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះចេញសាលក្រមបានបន្ទាប់ពីការជំនុំជម្រះខ្លីនេះ ការពារបាននូវផលប្រយោជន៍សារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនរងជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង ០០២» ។

ដោយយោងតាមដីកាសម្រេចបំបែកកិច្ចដំណើរការនិតិវិធីករណី០០២កំពុងតែទទួលរងនូវការដេញដោលអំពីគោលនយោបាយឧក្រិដ្ឋ ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនដោយបង្ខំនៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យក្នុងអំឡុងពីឆ្នាំ១៩៧៥ដល់១៩៧៧ ។ អង្គជំនុំជម្រះបានបង្ហាញថា ៖

> អង្គហេតុពាក់ព័ន្ធនិងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធ និងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី៣ និងមិនត្រូវបានលើកយកមកដេញដោលនៅក្នុងការជំនុំជម្រះលើកដំបូងទេ ។ លើសពីនេះទៀត បទចោទប្រកាន់ទាំងអស់ ដូចជាបទប្រល័យពូជសាសន៍ ការធ្វើទុកបុកម្នេញដោយមូលហេតុសាសនាដែលជាឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀតនៅក្នុងសំណុំរឿង០០២ ។

គ្មានភាគីណាមួយត្រូវបានស្នើសុំយោបល់ជាមុន មុននឹងធ្វើចេញសេចក្តីសម្រេចនេះទេ ដោយសារតែអង្គជំនុំជម្រះយល់ឃើញថា ការពិគ្រោះយោបល់អាចបង្ករឲ្យមានពន្យាពេលណាមួយដែលមិនអាចទទួលយកបាន ។ ទោះបីជាមានការគាំទ្រចំពោះគោលបំណងនៃដីកានោះក៏ដោយ សហព្រះរាជអាជ្ញាបានជំទាស់យ៉ាងខ្លាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ សហព្រះរាជអាជ្ញាបានអះអាងថា៖

> បទចោទដែលបានជ្រើសរើសសម្រាប់សវនាការដែលនិងទំនងជាសវនាការលើកទីមួយនៃជនជាប់ចោទអាចនឹងមិនតំណាងឲ្យសកម្មភាពបទឧក្រិដ្ឋដែលចោទប្រកាន់ទេ ដែលផ្ទុយទៅនឹងការអនុវត្តជាអន្តរជាតិ ហើយនេះមិនបានលើកកំពស់កំណត់ហេតុប្រវត្តិសាស្ត្រពិតទេ ហើយក៏អាចបន្ទាបកេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះទៅវិញទេ ក្នុងការលើកកំពស់ការបង្រួបបង្រួមជាតិ ។

សហព្រះរាជអាជ្ញាបានអះអាងថា សវនាការដំបូងគួរតែបូកបញ្ចូលនូវ «ទម្រង់នៃការធ្វើទុក្ខទោសបុកម្នេញដ៏ធ្ងន់ធ្ងរដែលប្រជាជនកម្ពុជាភាគច្រើនលើសលប់បានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ដោយមិនមែនត្រឹមតែការជម្លៀសប្រជាជនដោយបង្ខំប៉ុណ្ណោះទេ តែក៏ត្រូវគិតអំពីទីតាំងពិឃាត មន្ទីរសន្តិសុខ ការដ្ឋានការងារ និងសហករណ៍ដែរ ។

អង្គជំនុំជម្រះបានជំទាស់ទៅនឹងសំណើរបស់ភាគីព្រះរាជអាជ្ញា

តែអង្គជំនុំជម្រះបានអនុញ្ញាតផ្តល់លទ្ធភាពដល់ការចោទប្រកាន់បន្ថែមទៀតនៅពេលក្រោយ ។ ក្នុងខែមករា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅអង្គជំនុំជម្រះថា ខ្លួនបានស្នើឲ្យដាក់ទីតាំងសម្ងាប់ដែលពាក់ព័ន្ធត្រឹមតែពីកន្លែង និងមន្ទីរសន្តិសុខស-២១ និងវាលពិឃាតជើងឯកប៉ុណ្ណោះ ហើយព្រះរាជអាជ្ញាបានស្នើដល់អង្គជំនុំជម្រះឲ្យចាត់វិធានការចំពោះសំណើរនេះឲ្យបានឆាប់រហ័ស ។

នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះបានប្រកាសថា ខ្លួននឹងរៀបចំកិច្ចប្រជុំមួយស្តីអំពីការគ្រប់គ្រងសវនាការនៅចុងខែនេះ គឺបន្ទាប់ពីសវនាការបានចាប់ផ្តើមរយៈពេលប្រាំបួនខែ ដើម្បីពិភាក្សាអំពីសំណើសុំរបស់សហព្រះរាជអាជ្ញាក្នុងការកំណត់អំពីវិសាលភាពនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ។

ក្រោយពីវាយតម្លៃនូវសំណើររបស់ព្រះរាជអាជ្ញាដោយលម្អិតអង្គជំនុំជម្រះបានយល់ស្របថា ការបន្ថែមទីតាំងបទឧក្រិដ្ឋចំនួនបីកន្លែងទៀតអាចជារឿងសមរម្យ ។ តែអង្គជំនុំជម្រះមានជំនឿថា ការស្តាប់សក្ខីកម្មពីសាក្សីទាំងអស់ដែលស្នើដោយព្រះរាជអាជ្ញាអាចនិងមិនមានភាពចាំបាច់ ហើយអាចនឹងកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងក្នុងការ "ធ្វើឲ្យរលូន" នូវដំណើរការ និងធានាថា រាល់ភស្តុតាងទាំងអស់ត្រូវបានបង្ហាញត្រឹមចុងឆ្នាំ២០១៣ ។

ដោយដឹងថា សាក្សីដប់នាក់ក្នុងចំណោមសាក្សីទាំងអស់ ដែលស្នើដោយព្រះរាជអាជ្ញាត្រូវបានកោះហៅមកធ្វើសក្ខីកម្មរួចហើយ ហើយថា អង្គជំនុំជម្រះមិនចង់ចំណាយពេលកោះហៅសាក្សីនោះមកវិញនោះ អង្គជំនុំជម្រះបានស្នើថា ប្រសិនបើទីតាំងត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងហើយនោះ មានតែសាក្សីថ្មីៗ ដែលគ្រោងនឹងមកធ្វើសក្ខីកម្មនាពេលថ្មីៗខាងមុខនេះប៉ុណ្ណោះនិងត្រូវបានសួរទាក់ទងទៅនឹងបទចោទប្រកាន់ថ្មីនេះ ។ ជាមួយគ្នានោះដែរ អង្គជំនុំជម្រះបានស្នើទៅសហព្រះរាជអាជ្ញាឲ្យផ្តល់យោបល់ថា តើប្រសិនបើបន្ថែមទីតាំងឧក្រិដ្ឋកម្មថ្មីបន្ថែមជាមួយភស្តុតាងដែលមានកំណត់នេះអាចជួយព្រះរាជអាជ្ញាទទួលបាននូវភស្តុតាង និង "បន្ថែមភាពប្រថុយប្រថាន" បន្ថែមពេលវេលាសវនាការចំនួនបីខែទៀត ។

ដោយហេតុផលដូចគ្នាដែលអង្គជំនុំជម្រះចង់ធ្វើសកម្មភាពភ្លាមៗ ដើម្បីប្រកាសសាលក្រមបឋមលើកដំបូងមុននឹងជនជាប់ចោទណាម្នាក់ស្លាប់ឬបាត់បង់សម្បទាណាមួយ គ្រប់ភាគីក្នុងករណី ០០២ទាំងអស់ និងអ្នកតាមដានដំណើរការ០០២នេះយល់ស្របថា វ័យកាន់តែចាស់ និងសុខភាពទន់ខ្សោយរបស់ជនជាប់ចោទអាចនឹងមិនទំនងទាល់តែសោះថា "សវនាការតូច" បន្ថែមនឹងមិនអាចធ្វើបានទេ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការឧក្រិដ្ឋកម្មដំបូងដ៏ធំមានបំណងចង់បើកសវនាការបន្តបន្ទាប់គ្នា ដោយផ្អែកទៅលើពិរុទ្ធភាព ហើយសវនាការដំបូងមិនមែនជាដំណើរការទេ ។ ដំណើរការទាយយកភស្តុតាងសម្រាប់ករណី០០២មិនត្រូវធ្វើឲ្យលើសពីរយៈពេលពីរឆ្នាំទេ ។

បញ្ហានីតិវិធីក៏ទំនងជាអាចរាំងស្ទះនូវការចាប់ផ្តើមសវនាការទីពីរដែរ ។ អង្គជំនុំជម្រះបានជូនដំណឹងថា អង្គជំនុំជម្រះបានជ្រើសរើសប្រធានបទនៃដំណាក់កាលទីមួយនៃករណី០០២ "ដើម្បីធានាថា បញ្ហាទាំងឡាយដែលបានពិនិត្យនៅក្នុងសវនាការទីមួយបានផ្តល់នូវមូលដ្ឋានមួយ ដើម្បីពិចារណាអំពីតួនាទីនិងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងអស់និងដើម្បីផ្តល់មូលដ្ឋានគ្រឹះសម្រាប់បទចោទប្រកាន់ដែលនៅសេសសល់៦ទៀតដើម្បីយកទៅសវនាការនៅពេលក្រោយ ទៀត" ។ ប៉ុន្តែដូចដែលព្រះរាជអាជ្ញាបានគូសបញ្ជាក់ច្បាស់ហើយថា វិធីតែមួយគត់ដែលអង្គជំនុំជម្រះអាចរកឃើញអង្គហេតុពិតដែលបង្កើតឡើងក្នុងដំណាក់កាលទីមួយគឺតាមរយៈការជូនដំណឹងតាមផ្លូវច្បាប់នៃហេតុការណ៍ពិត ។ វានៅតែមិនច្បាស់លាស់ទេថា តើអង្គជំនុំជម្រះមានលទ្ធភាពជូនដំណឹងផ្លូវច្បាប់នៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់កាលពីមុនថា "មិនមាននូវមូលដ្ឋានផ្លូវច្បាប់ឡើយ នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការរកត់សម្គាល់នូវអង្គហេតុដែលអាចវិនិច្ឆ័យរួចហើយឬអង្គហេតុនៃការដឹងឮជាទូទៅ យកមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ" ។ លើសពីនេះទៅទៀត មិនមានយន្តការណាមួយអាចយកមកអនុវត្តបាននៅក្នុងករណី០០២ សវនាការទីពីរទេរហូតដល់អង្គជម្រះសាលាកំពូលចេញដីកាចុងក្រោយពេលដែលសេចក្តីណែនាំរបស់អង្គជំនុំជម្រះត្រូវបានបដិសេធ ។

នៅក្នុងករណីទីមួយរបស់តុលាការ រយៈពេលនៃការចាប់ដំណើរការតំបូងនិងការចេញសេចក្តីសម្រេចវិនិច្ឆ័យគឺមានរយៈ

ពេលមួយឆ្នាំកន្លះ ។ តែទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមានជំនឿថា មិនមានខុសបសគ្គក្នុងការប្រើប្រាស់សាលក្រមជាមូលដ្ឋានផ្លូវច្បាប់ និងអង្គហេតុពិតសម្រាប់សវនាការទីពីរដោយមិនចាំបាច់រង់ចាំអង្គជំនុំជម្រះតុលាការកំពូលដើម្បីចេញសាលក្រមចុងក្រោយ ។ ទោះបីជា រឿងនេះអាចទៅរួចក៏ដោយ នៅតែមានការចោទជាសំណួរដដែលថា តើអង្គជំនុំជម្រះអាចពង្រាងសេចក្តីវិនិច្ឆ័យមូលដ្ឋានគ្រឹះដ៏ស្មុគស្មាញនេះដោយរបៀបណាខណៈពេលដែលអង្គជំនុំជម្រះកំពុងតែធ្វើកិច្ចការជាមួយសវនាការថ្មីនោះ ។ ក្រោយពីសវនាការទីមួយដែលទាក់ទងទៅនឹងជនជាប់ចោទម្នាក់ដែលសារភាពថា បានប្រព្រឹត្តិដូចអ្វីដែលបានចោទប្រកាន់មកលើគាត់ អង្គជំនុំជម្រះប្រើរយៈពេលជាងប្រាំបីខែដើម្បីពង្រាងសេចក្តីវិនិច្ឆ័យទោសកន្លងទៅ ។

ដើម្បីធ្វើការឈានទៅរកប្រកាសសាលក្រមប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ដែលជាជនជាប់ចោទ និងដើម្បីធានាថា ជនរងគ្រោះនិងទទួលបានវិធានការណ៍យុត្តិធម៌ខ្លះៗបន្ទាប់ពីរយៈពេលជាង៣០ឆ្នាំ អង្គជំនុំជម្រះបានកំណត់ដោយយល់ខុសអំពីការចូលរួមពាក់ព័ន្ធរបស់សវនាការសម្រាប់ជនរងគ្រោះ ដោយសារតែសវនាការនោះមិនបានបូកបញ្ចូលបទឧក្រិដ្ឋច្រើនដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមានការបង្ខំឲ្យធ្វើការលើសកម្លាំងការដាក់ចូលក្នុងសហករណ៍ដោយបង្ខំ ការរៀបការដោយបង្ខំដោយគ្មានការយល់ព្រមពីសាម៉ីខ្លួន និងអំពើប្រល័យពូជសាសន៍ ។ ការបន្ថែមទីតាំងឧក្រិដ្ឋកម្មបីទៀតដែលបានស្នើដោយព្រះរាជអាជ្ញាអាចមានលទ្ធភាពច្រើនដើម្បីសម្រួលនូវបន្ទុកភស្តុតាងរបស់ព្រះរាជអាជ្ញាជាជាងបន្ថែមនូវការពាក់ព័ន្ធនៃដំណើរការសម្រាប់ជនជាងគ្រោះភាគច្រើន ។

ដោយសារតែការចោទប្រកាន់ដែលមានលក្ខណៈតូចចង្អៀតនៅក្នុងករណី០០២ដំណាក់កាលទីមួយ និងភាពមិនទំនងនៃករណីផ្សេងទៀតដែលនឹងអាចនាំទៅរកសវនាការរួមទាំងសវនាការប្រឆាំងនឹងជនជាប់ចោទសព្វថ្ងៃ និងជនសង្ស័យនៅក្នុងករណី០០៣ និង០០៤ដ៏ចម្រូងចម្រាសក្នុងនោះមានហេតុផលដ៏រឹងមាំជាច្រើនដើម្បីខ្លាចថា ភាពឃោរឃៅជាច្រើននៃរបបខ្មែរក្រហមនិងមិនយកមកនិយាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។

**អាន ហាញឌុល**



និស្សិតសកលវិទ្យាល័យន័រតុនកំពុងសួរសំណួរអំពីដំណើរការសាលាក្តីខ្មែរក្រហមជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា

# បញ្ហាប្រឈម និងលទ្ធភាពដែលនឹងកើតមានចំពោះការសម្រេច អំពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ

បញ្ហាសុខភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការនៅក្នុងសំណុំរឿង០០២ គឺនៅតែជាបញ្ហាចម្បងមួយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងប្រឈមពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតែវ័យចំណាស់ និងរោគព្យាធិយាយីជនជាប់ចោទ ។ បញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់កិច្ចដំណើរការនីតិវិធីស្វែងរកយុត្តិធម៌ និងការពិតជូនប្រជាជនកម្ពុជា ដែលទទួលរងនូវផលប៉ះពាល់ពីរបបខ្មែរក្រហម ។ ជាញឹកញាប់ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកសវនាការ ដោយសារតែបញ្ហាសុខភាពរបស់ជនជាប់ចោទ ។ ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកយកករណីជនជាប់ចោទ អៀង ធីរិទ្ធ មកបើកសវនាការសួរដេញដោលដើម្បីពិនិត្យ និងវាយតម្លៃបន្ថែមអំពីកាយសម្បទារបស់ជនជាប់ចោទរូបនេះក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ។

អត្ថបទនេះនឹងពន្យល់ត្រួសៗអំពីកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ និងបញ្ហាប្រឈម ឬលទ្ធភាពមួយចំនួនដែលនឹងអាចកើតមានដើម្បីឲ្យអ្នកតាមដានងាយស្រួលយល់ ។

**ប្រវត្តិសាវតារនៃការសម្រេចសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ**

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងដោយគ្មានលក្ខខណ្ឌ ។ សេចក្តីសម្រេចនេះធ្វើឡើងស្របពេលដែលអង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីទាំងមូលក្នុងសំណុំរឿង០០២ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ជនជាប់ចោទ



អៀង ធីរិទ្ធ នៅបន្ទប់សវនាការ (រូបថត៖ (អ.វ.ត.ក)

អៀង ធីរិទ្ធ មានការបាត់បង់ការចងចាំរយៈពេលវែង និងរយៈពេលខ្លី ដែលបណ្តាលឲ្យជនជាប់ចោទរូបនេះនឹងមិនអាចយល់កិច្ចដំណើរការនីតិវិធីរបស់តុលាការ និងណែនាំមេធាវីរបស់ខ្លួនឲ្យបានពេញលេញ ។ មួយថ្ងៃក្រោយមកសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខនឹងសេចក្តីសម្រេចដោះលែងនេះ ទៅអង្គជំនុំជម្រះតុលាការកំពូល ។ ព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយផ្អែកលើមូលដ្ឋានអង្គហេតុ និងអង្គច្បាប់ដែលមានកំហុស ហើយបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនសមស្រប ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានចេញដីកាសម្រេចប្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការដោះលែងនេះ ។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់តាំងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រផ្នែកវិកលចរិក និងផ្នែកចិត្តសាស្ត្រ ឲ្យព្យាបាល និងវាយតម្លៃបន្ថែមអំពីបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីកំណត់ពីសម្បទាក្នុងការចូលរួមសវនាការ ។

## សវនាការពិនិត្យឡើងវិញអំពីសម្បទាជនជាប់ចោទ អៀង ធីរិទ្ធ

នៅថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិតចំនួនបួនរូប ដើម្បីវាយតម្លៃឡើងវិញអំពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមកិច្ចដំណើរការសវនាការ ។ វេជ្ជបណ្ឌិតទាំងបួនរូបនោះរួមមាន លោកស្រី ចក់ ធីតា, លោក ហ៊ួត លីណា, លោក ចន ខាំប៊ែល និង លោក ស៊ីណា ហ្វាហ្សែល ដែលសុទ្ធតែជាអ្នកមានជំនាញ និងបទពិសោធជាច្រើនឆ្នាំពាក់ព័ន្ធនឹងការពិនិត្យព្យាបាលជំងឺវិកលចារិក ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីសួរដេញដោលវេជ្ជបណ្ឌិតទាំងបួនរូបអំពីការវាយតម្លៃសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដូចមានក្នុងរបាយការណ៍ដែលវេជ្ជបណ្ឌិតទាំងនោះបានផ្តល់ជូនភាគី និងអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះបានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់លោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា ដែលបានផ្តល់របាយការណ៍ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងកិច្ចដំណើរការរបស់តុលាការ ។ បន្ទាប់មកស្តាប់សក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត ហ៊ួត លីណា, លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល និងលោកវេជ្ជបណ្ឌិត ចន ខាំប៊ែល ដែលរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការរបស់តុលាការ ។

## លទ្ធផលដែលផ្តល់ដោយលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា

យោងតាមរបាយការណ៍ និងការផ្តល់សក្ខីកម្មរបស់លោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា បញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺមានភាពប្រសើរជាងមុន ។ ពោលគឺមិនមានសញ្ញាណណាមួយដែលបញ្ជាក់ថា អៀង ធីរិទ្ធ មានជំងឺវិកលចរិកឡើយ គឺមានតែជំងឺភ្លេចភ្លាំង ឬវង្វេងវង្វាន់កម្រិតស្រាលប៉ុណ្ណោះ ។ ជនជាប់ចោទអាចគ្រប់គ្រងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន ដូចជា ការសម្អាតខ្លួនប្រាណ ការ ស្លៀកពាក់បានយ៉ាងត្រឹមត្រូវ ។ ជាងនេះទៅទៀត អៀង ធីរិទ្ធ អាចអានកាសែត ឯកសារផ្សេងៗ ជាភាសាបរទេស និងអាចនិយាយទំនាក់ទំនងយ៉ាងល្អជាមួយលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា ។ លោកស្រីវេជ្ជបណ្ឌិតបានសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការសវនាការ ។ ការសន្និដ្ឋាននេះលោកស្រីវេជ្ជបណ្ឌិតបានយោងទៅលើលទ្ធផលដែលបានមកពីការវាយតម្លៃអំពីស្ថានភាពបញ្ញាស្មារតី (Mini-Mental State Examination, "MMSE") របស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ការវាយតម្លៃនេះទទួលបានពិន្ទុ២៨ លើ ៣០ ដែលពិន្ទុនេះបង្ហាញថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់កម្រិតស្រាលតែប៉ុណ្ណោះ ។ គួរបញ្ជាក់ថា ការវាយតម្លៃអំពីសមត្ថភាពបញ្ញាស្មារតីរបស់អ្នកជំងឺដោយអនុលោមតាមគោលការណ៍ "MMSE" គឺត្រូវបានទទួលស្គាល់ដោយអង្គការ សុខភាពពិភពលោក ។

## លទ្ធផលដែលផ្តល់ដោយវេជ្ជបណ្ឌិតបីរូបផ្សេងទៀត

ផ្ទុយពីការបញ្ជាក់របស់លោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល អះអាងថា ស្ថានភាពសុខភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺមិនមានភាពធូរស្រាលឡើយ ពោលគឺជំងឺវង្វេងវង្វាន់របស់ អៀង ធីរិទ្ធ កាន់តែមានសភាពធ្ងន់ធ្ងរជាងមុន ។ សភាពវង្វេងវង្វាន់នេះ ត្រូវបានចាត់ថ្នាក់ថាស្ថិតនៅក្នុងស្ថានភាពពីមធ្យមទៅរកភាពធន់ធរ ។ ស្ថានភាពនេះនឹងធ្វើឲ្យជនជាប់ ចោទ អៀង ធីរិទ្ធ មិនអាចចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះប្រកបដោយប្រសិទ្ធិភាពបានឡើយ ពោលគឺមិនអាចយល់ពីបទចោទប្រកាន់មកលើខ្លួន មិនអាចផ្តល់សក្ខីកម្មបានពេញលេញ

មិនអាចណែនាំមេធាវីរបស់ខ្លួន មិនអាចយល់ពីកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ល ។ ប្រសិនបើ អៀង ធីរិទ្ធ នៅតែត្រូវបានតម្រូវឲ្យចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះក្តីនោះ តុលាការនឹងត្រូវប្រឈមមុខចំពោះសំណុំរឿងមួយដែលមានជនជាប់ចោទជាមនុស្សវង្វេងវង្វាន់ ។ លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បន្ថែមថា ពុំមានលទ្ធភាព ឬវិធីណាមួយដែលអាចធ្វើឲ្យសុខភាព បញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានភាពប្រសើរឡើងវិញឡើយ ពោលគឺការវង្វេងវង្វាន់ដែលបណ្តាលមកពីការបាត់ការចងចាំនឹងមានការកើនឡើងជាបន្តបន្ទាប់ ។ ស្របពេលជាមួយគ្នានេះ លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បានអះអាងថា ក្នុងការវាយតម្លៃអំពីបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា មិនបានអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍របស់ "MMSE" ឡើយ ពីព្រោះប្រភេទសំណួរដែលបានកំណត់នៅក្នុងគោលការណ៍នេះគឺមិនអាចប្តូរបានឡើយ ។ ប្រសិនបើអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍ "MMSE" នោះនឹងមិនអាចទទួលបានពិន្ទុ២៤ នោះទេ ពោលគឺអាចទទួលបានខ្ពស់បំផុតត្រឹមតែ១៥ តែប៉ុណ្ណោះ ។ ជាក់ស្តែង ក្រុមរបស់ខ្លួនដែលបានអនុវត្តតាម "MMSE" ដើម្បីវាយតម្លៃពីបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែរនោះ គឺទទួលបានពិន្ទុចន្លោះពី១២ ទៅ១៨ប៉ុណ្ណោះ ដែលកម្រិតពិន្ទុនេះបង្ហាញថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់កំរិតមធ្យម និងកម្រិតធ្ងន់ ។

## បញ្ហាប្រឈមក្នុងការសម្រេចអំពីសម្បទារបស់ជនជាប់ចោទ

តើអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចដូចម្តេចចំពោះសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលដែលរបាយការណ៍ពិនិត្យសុខភាពរបស់ជនជាប់ចោទរូបនេះមានលក្ខណៈខុសគ្នាដូច្នេះ ?

អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវប្រឈមចំពោះបញ្ហានេះ ពីព្រោះការសម្រេចរបស់អង្គជំនុំជម្រះគឺត្រូវផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខហើយ ដែលភស្តុតាងទាំងនោះត្រូវបានឆ្លងកាត់ការសួរដេញដោលដូចគ្នា ។ វេជ្ជបណ្ឌិតទាំងបួនរូបត្រូវបានតម្រូវឲ្យធ្វើសម្បថដូចគ្នាមុននឹងផ្តល់សក្ខីកម្មអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ជូនអង្គជំនុំជម្រះ ។ ដូច្នេះតម្លៃនៃភស្តុតាងទាំងនោះនឹងត្រូវបានចាត់ទុកថាមានទម្ងន់ដូចគ្នាក្នុងការពិចារណាអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

មានការចោទប្រកាន់ពីវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល ថា លោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា មិនបានអនុវត្តត្រឹមត្រូវតាមគោលការណ៍របស់ "MMSE" ក្នុងការវាយតម្លៃបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ពោលគឺសំណួរទាំងឡាយនៅក្នុងគោលការណ៍នេះមិនអាចកែប្រែឡើយ ។ ដូច្នេះលទ្ធផលដែលចេញមកពីការអនុវត្តមិនត្រឹមត្រូវនេះ គឺមិនអាចទទួលយកបានឡើយ ។ គួររំឭកឡើងវិញនូវសក្ខីកម្មរបស់លោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា ដែលបានបញ្ជាក់អំពីបញ្ហានេះថា ជនជាប់ចោទ អៀង ធីរិទ្ធ ជាបុគ្គលម្នាក់ដែលរៀនសូត្របានជ្រៅជ្រះមានបទពិសោធន៍ការងារជាច្រើន និងស្ថិតក្នុងឋានៈជាជនជាប់ចោទម្នាក់ ដូច្នេះក្នុងការធ្វើកោសល្យវិច័យលើបញ្ញាស្មារតី គឺត្រូវមានការប្រុងប្រយ័ត្ន និងតម្រូវឲ្យមានការផ្លាស់ប្តូរសំណួរខ្លះដើម្បីបត់បែនតាមស្ថានភាពជាក់ស្តែង ប៉ុន្តែខ្លឹមនៃសំណួរទាំងនោះមិនមានការផ្លាស់ប្តូរឡើយ ។ លោកស្រីបានបន្ថែមថា មុននឹងសម្រេចផ្លាស់ប្តូរសំណួរទាំងនោះ គឺលោកស្រីបានពិភាក្សាជាមួយវេជ្ជបណ្ឌិតបរទេសផ្សេងៗ ទៀត ដែលជំនាញផ្នែកវិកលវិទ្យា អំពីផលប៉ះពាល់លើខ្លឹមសាររបស់គោលការណ៍ "MMSE" ដែលអាចកើតចេញពីការផ្លាស់ប្តូរនេះ ។ ជាលទ្ធផលមានការទទួលស្គាល់ពីវេជ្ជបណ្ឌិតទាំងនោះថា ការផ្លាស់ប្តូរនេះមិនមានផលប៉ះពាល់លើខ្លឹមសាររបស់ "MMSE" ឡើយ ។ បន្ថែមលើនេះទៀត តំណាងសហព្រះរាជអាជ្ញាបានលើកឡើងពីការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញផ្នែកជំងឺមនុស្សចាស់ នៅប្រទេសអូស្ត្រាលីដែលបានបញ្ជាក់ថា «លទ្ធផលនៃការវាយតម្លៃពីបញ្ញាស្មារតីតាមរយៈ ការប្រើប្រាស់គោលការណ៍ "MMSE" គឺអាចមានការលម្អៀងទៅតាមវប្បធម៌របស់ប្រទេសនីមួយៗ ។ សំណួរមួយចំនួនអាចត្រូវបានកែសម្រួលដើម្បីឲ្យស្របតាមវប្បធម៌ របស់ប្រទេសទាំងនោះ» ។

ទោះបីជាមានការខ្វែងគំនិតគ្នារវាងលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា និងវេជ្ជបណ្ឌិតបីរូបទៀតអំពីសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមកិច្ចដំណើរការសវនាការក៏ដោយ ប៉ុន្តែវេជ្ជបណ្ឌិតទាំង៤រូបបានរកឃើញស្របគ្នាថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានជំងឺវិកលចរិកនោះទេ ។ លោក វេជ្ជបណ្ឌិត ហ៊ួត លីណា ដែលជាសហការីរបស់វេជ្ជបណ្ឌិត

ស៊ីណា ហ្វារហែវូល និង វេជ្ជបណ្ឌិត ចន ខាំប៉ែល បានបញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់បញ្ញាស្មារតី ប៉ុន្តែមិនមានសញ្ញាណណាមួយដែលបញ្ជាក់ថាមានជំងឺវិកលចរិកឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ ។ អង្គជំនុំជម្រះអាចសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ មាន ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយផ្អែកលើរបាយការណ៍ណាមួយក្នុងចំណោមរបាយការណ៍របស់វេជ្ជបណ្ឌិតទាំងពីរក្រុមដែលបានរកឃើញលទ្ធផលខុសគ្នានេះ ។ ប៉ុន្តែការសម្រេចនេះនឹងជះឥទ្ធិពលមួយចំនួនដូចខាងក្រោម៖

ទី១) ក្នុងករណីអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ មានសម្បទាគ្រប់គ្រាន់នោះ ជនជាប់ចោទ អៀង ធីរិទ្ធ នឹងត្រូវដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំងបន្ត និងបញ្ជូនទៅជំនុំជម្រះទោសនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ប៉ុន្តែការជំនុំជម្រះនេះនឹងត្រូវប្រឈមមុខនឹងការផ្អាកនីតិវិធីជាញឹកញ៉ាប់ក្នុងករណីសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានការប្រែប្រួលមិនអាចតាមដានកិច្ចដំណើរការសវនាការបាន ។ វិធាន៨១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះបានកំណត់ថា ការជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ ។ ក្នុងករណីជនជាប់ចោទមានបញ្ហាសុខភាព សវនាការអាចដំណើរការទៅបានលុះត្រាតែជនជាប់ចោទយល់ព្រមលះបង់“សិទ្ធិមានវត្តមាន”ចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះក្នុងករណីជនជាប់ចោទមានបញ្ហាសុខភាពមិនអាចតាមដានកិច្ចដំណើរការនីតិវិធីរបស់តុលាការ ហើយមិនព្រមលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការនោះ អង្គជំនុំជម្រះមិនអាចដំណើរការនីតិវិធីជំនុំជម្រះបានឡើយ ពោលគឺត្រូវផ្អាកជាបណ្តោះអាសន្ន ។ បញ្ហានេះត្រូវបានអនុវត្តជាក់ស្តែង ចំពោះជនជាប់ចោទ អៀង សារី ។ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកកិច្ចដំណើរការសវនាការរបស់ខ្លួនជាច្រើនលើកច្រើនសារ គឺដោយសារតែមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បញ្ជាក់ថា កូនក្តីរបស់ខ្លួនមានបញ្ហាសុខភាពមិនអាចតាមដានកិច្ចដំណើរការសវនាការបាន ហើយ កូនក្តីរបស់ខ្លួនមិនមានបំណងលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការឡើយ ។

ទី២) ក្នុងករណីអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការនោះការជំនុំជម្រះក្តីប្រឆាំងនឹងជនជាប់ចោទរូបនេះនឹងត្រូវផ្អាក ។ ក្នុងករណីនេះ ជនជាប់ចោទ អៀង ធីរិទ្ធ អាចនឹងត្រូវបានដោះលែងពីមន្ទីរឃុំឃាំងឲ្យមានសេរីភាព ។

ទោះបីជាយ៉ាងណាក៏ដោយ ការផ្អាកកិច្ចដំណើរការនីតិវិធី និងការដោះលែងឲ្យមានសេរីភាពនេះគឺមិនមានអានុភាពបញ្ចប់សំណុំរឿងប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ឡើយ ។ អំណះអំណាងនេះត្រូវបានលើកឡើងដោយលោក តារីក អាប់ឌុកហាក់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ លោកបានផ្តល់នូវរឿងក្តីមួយចំនួនដែលបានកើតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដូចជាសំណុំរឿងរបស់ជនជាប់ចោទ ដូហ៊្គិក ។ ជនជាប់ចោទរូបនេះត្រូវបានតុលាការរកឃើញ ថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ បន្ទាប់ពីមានការសម្រេចនេះ រដ្ឋអាជ្ញាស្នើសុំឲ្យបញ្ចប់រឿងក្តីដោយដកការចោទប្រកាន់លើជនជាប់ចោទរូបនេះ ប៉ុន្តែត្រូវបានតុលាការបដិសេធ ។ ក្រោយមកសំណុំរឿងនេះត្រូវបានតុលាការប្រកាសបិទបញ្ចប់បន្ទាប់ពីជនជាប់ចោទ ដូហ៊្គិក ទទួលមរណភាព ។

ដូច្នេះមានន័យថា ទោះបីជនជាប់ចោទ អៀង ធីរិទ្ធ អាចនឹងត្រូវបានតុលាការប្រកាសថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ហើយត្រូវបានដោះលែងឲ្យមានសេរីភាពក៏ដោយ ក៏បទចោទប្រកាន់ និងអត្ថិភាពនៃសំណុំរឿងប្រឆាំងនឹងជនជាប់ចោទរូបនេះ នៅតែអាចបន្តរហូតដល់ជនជាប់ចោទទទួលមរណភាព ។ ក្នុងករណីសំណុំរឿងមិនទាន់ត្រូវបានបិទបញ្ចប់នោះនៅគ្រប់ដំណាក់កាលនៃរឿងក្តី វិធាន៣២នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានអនុញ្ញាតឲ្យភាគីទាំងអស់មានសិទ្ធិស្នើសុំអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញឲ្យត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រវិកលចរិក និងចិត្តសាស្ត្រ លើជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីកំណត់អំពីសម្បទាខាងផ្លូវកាយ និងបញ្ញាស្មារតីរបស់ជនជាប់ចោទរូបនេះក្នុងការចូលរួមសវនាការ ។

**ចាន ប្រាជ្ញា**

# សេចក្តីសម្រេចរបស់សាលាដំបូងលើសម្បទាផ្នែកបញ្ញាស្មារតី របស់ជនជាប់ចោទ អៀង ធីរិទ្ធ

នៅថ្ងៃទី១៣ ខែកញ្ញាឆ្នាំ២០១២អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យនៅក្រៅមន្ទីរឃុំឃាំង និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង០០២ដោយមិនកំណត់រយៈពេលដោយសារអង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលសវនាការបានឡើយ ។

ជាងនេះទៅទៀត អង្គជំនុំជម្រះនឹងរៀបចំឲ្យមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញជារៀងរាល់ឆ្នាំចាប់ពីខែមិនា ឆ្នាំ២០១៣ ក្នុងរយៈពេលអត្ថិភាពរបស់តុលាការ ដើម្បីធ្វើការតាមដានសុខភាពបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងគោលបំណងបញ្ជាក់ពីជំរើសនៃការព្យាបាលជនជាប់ចោទបន្តទៀត ។

នៅក្នុងសេចក្តីសម្រេចនោះទៀតសោត អង្គជំនុំជម្រះបានកំណត់នូវលក្ខខណ្ឌចំនួនពីរគឺ ១) មិនឲ្យជនជាប់ចោទធ្វើការជ្រៀតជ្រែកដល់សាក្សី អ្នកជំនាញ ឬជនរងគ្រោះនៅចំពោះមុខអ.វ.ត.ក និងជនជាប់ចោទដទៃទៀត លើកលែងតែជនជាប់ចោទ អៀង សារី ជាស្វាមី និង ២) មិនឲ្យជនជាប់ចោទជួបជាមួយប្រព័ន្ធសារព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។

សេចក្តីនេះ បានធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះបានបើកសវនាការនៅថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១២ ដើម្បីធ្វើការសាកសួរអ្នកជំនាញបួនរូបគឺលោកស្រីវេជ្ជបណ្ឌិត ចក់ ធីតា, វេជ្ជបណ្ឌិត ចន ខាំប៉ែល, លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល និងលោកវេជ្ជបណ្ឌិត ហ្វូត លីណា ទាក់ទងនឹងលទ្ធផលនៃការពិនិត្យបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

បន្ទាប់ពីមានការពិភាក្សាដេញដោលអ្នកជំនាញទាំងបួននាក់រួចមក ភាគីសហព្រះរាជអាជ្ញាបានស្នើសុំឲ្យតុលាការធ្វើការដោះលែងជនជាប់ចោទដោយមានលក្ខខណ្ឌមួយចំនួនដូចជា ១) ស្ថិតនៅទីកន្លែង ដែលមានអស័យដ្ឋានជាក់លាក់ដែលត្រូវមានការជូនដំណឹងមកអង្គជំនុំជម្រះ ២) មានការពិនិត្យពីសុវត្ថិភាពជនជាប់ចោទដោយអាជ្ញាធរ ឬមន្ត្រីណាមួយដែលតុលាការចាត់តាំងរៀងរាល់សប្តាហ៍ ៣) ប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណមកតុលាការ ៤) មិនឲ្យមានការទាក់ទងដោយផ្ទាល់ ឬប្រយោលជាមួយជនជាប់ចោទផ្សេងទៀតលើកលែងតែជនជាប់ចោទ អៀង សារី ៥) មិនឲ្យទាក់ទងផ្ទាល់ ឬប្រយោលជាមួយសាក្សី ឬជនរងគ្រោះដែលត្រូវមកធ្វើសក្ខីកម្ម ៦) មិនឲ្យរំខានដល់ដំណើរការនៅតុលាការ ។ ផ្ទុយទៅវិញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើរសុំឲ្យអង្គជំនុំជម្រះធ្វើការបន្តឃុំខ្លួនជនជាប់ដោយមានការតែងតាំងអ្នកជំនាញថ្មី ដើម្បីធ្វើការតាមដានស្ថានភាពបញ្ញាស្មារតីជនជាប់ចោទបន្តទៀត ។ ចំណែកមេធាវីការពារក្តីជនជាប់ចោទវិញ បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌឡើយ ។

សូមបញ្ជាក់ថា ទោះបីជាកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានផ្អាកដោយមិនកំណត់ពេលវេលាដោយសារតែករណីខាងលើក៏ដោយ ក៏បទចោទប្រឆាំងនឹងជនជាប់ចោទនៅតែបន្តជារៀងរហូត ហើយជនជាប់ចោទក៏នឹងត្រូវនាំយកមកជំនុំជម្រះក្នុងករណីដែលជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ។

**ឆាយ ឈុនលី**

- **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ភាពអាចទទួលបាននៃកំណត់ហេតុស្ដាប់ចម្លើយសាក្សីជំនួសឱ្យការផ្ដល់សក្ខីកម្មផ្ទាល់មាត់

រយៈពេលជាងមួយឆ្នាំកន្លងទៅ ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអះអាងថា ជនជាប់ចោទក្នុងសំណុំរឿង០០២មិនមានសិទ្ធិដាច់ខាតណាមួយក្នុងការកោះហៅ និងសាកសួរសាក្សីនៅក្នុងពេលសវនាការទេ ។ ព្រះរាជអាជ្ញាបាន ស្នើសុំស្វែងរកឲ្យមានការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីដែលមានចំនួនច្រើនសន្ធឹកសន្ធាប់ដែលផ្ដល់នូវភស្តុតាងបន្ថែមប៉ុន្តែមិនស្ថិតនៅក្នុងគោលបំណងផ្ដល់សក្ខីកម្មអំពីអំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទជំនួសឲ្យការស្ដាប់ការផ្ដល់សក្ខីកម្មផ្ទាល់មាត់ ។ ព្រះរាជអាជ្ញាបានកត់សម្គាល់ថា សំណើនេះគឺស្របជាមួយនឹងនីតិវិធីនៃប្រព័ន្ធច្បាប់ស៊ីវិលជាធរមាននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលសង្កត់ធ្ងន់យ៉ាងសំខាន់ទៅលើការប្រើប្រាស់នូវកំណត់ត្រាជាលាយលក្ខណ៍អក្សរនានា ដែលចៅក្រមស៊ើបអង្កេតបានប្រមូល និងអំពាវនាវឲ្យមានវិធីសាស្ត្រមួយដែលមានលក្ខណៈ "បត់បែន" នៅក្នុងករណីនានាដែលមានបទឧក្រិដ្ឋដ៏ធំធេង :

*គោលបំណងនៃសំណើសុំនេះ គឺដើម្បីពន្លឿនសវនាការតាមរយៈការដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវភស្តុតាងរបស់សាក្សីដែលពាក់ព័ន្ធដែលមិនមានឱកាសមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងតុលាការបាន ។ ភស្តុតាងទាំងនេះនឹងជួយដល់អង្គជំនុំជម្រះនៅក្នុងការស្វែងរកការពិតចំពោះបទចោទជាច្រើនដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាកម្មវត្ថុនៃការជំនុំជម្រះនៅពេលបច្ចុប្បន្ននេះ ។ ការទទួលយកដូច្នេះ គឺសំខាន់ណាស់ដើម្បីឲ្យការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពចំពោះសវនាការមួយដែលមានទំហំដូច្នេះ បើសិនជាអង្គជំនុំជម្រះត្រូវការកំណត់សម្រេចអំពីការពិតនៃការចោទប្រកាន់ ។ ប៉ុន្តែផ្ទុយទៅវិញ ក្រុមមេធាវីការពារក្ដីទាំងអស់បានទាមទារនូវសិទ្ធិដាច់ខាតដែលមានចែងនៅវិធានផ្ទៃក្នុង និងក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីសាកសួរសាក្សីទាំងឡាយដែលមិនទាន់អាចកំណត់បាននៅក្នុងដំណាក់កាលស៊ើបអង្កេតថាគួរប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីទាំងនោះធ្វើជាភស្តុតាងឬទេ ។*

វិធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានអនុញ្ញាតឲ្យទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីទេ ។ ទោះបីជាទូទៅ ភស្តុតាងដែលមានភាពជាប់ពាក់ព័ន្ធគឺអាចទទួលយកបានក៏ដោយក៏វិធាន៨៤(១) បានធានាអំពីសិទ្ធិក្នុងការសាកសួរសាក្សី ។ ជាការប្រៀបធៀបវិធានដែលអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីអនុញ្ញាតឲ្យមានការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីជំនួសឲ្យការផ្ដល់សក្ខីកម្មផ្ទាល់មាត់ នៅខណៈពេលដែលវិធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា ភាពអាចទទួលយកបាននៃកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីមុនៗ អាចធ្វើទៅបានតែនៅពេលដែលព្រះរាជអាជ្ញានិងមេធាវីការពារក្ដីមានឱកាសដូចគ្នាក្នុងការសួរដេញដោលលើសាក្សីប៉ុណ្ណោះ ។

ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសំណើសុំរបស់ព្រះរាជអាជ្ញាដោយសម្រេចថា សិទ្ធិក្នុងការតទល់ចំពោះសាក្សីដាក់បន្ទុកមិនមែនជាសិទ្ធិដាច់ខាតនោះទេ ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា នៅពេលដែលមិនមានឱកាសក្នុងការតទល់ចំពោះសាក្សីដាក់បន្ទុកត្រូវបានចែងជាទូទៅនីតិវិធីអន្តរជាតិប្រានចោលការទទួលយកនូវកំណត់ហេតុដែលនឹងផ្ដល់សក្ខីកម្មអំពីអំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទ ។ ម្យ៉ាងវិញទៀត តុលាការអន្តរជាតិគាំទ្រដល់ការទទួលយកភស្តុតាងផ្សេងៗដែលមានភាពជាប់ពាក់ព័ន្ធ ជាពិសេសនៅពេលភស្តុតាងនោះមានលក្ខណៈត្រួតគ្នាលើភស្តុតាងរបស់សាក្សីដទៃ មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលពាក់ព័ន្ធនឹងភស្តុតាងនៃទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើងឬផ្ដល់សក្ខីកម្មអំពីកម្រិត

ធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ មានការវិភាគជាទូទៅ ឬជាស្ថិតិពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ ឬមិនអាចដាក់ឲ្យស្ថិតនៅក្រោមការតទល់គ្នា ពីព្រោះក្រោយមកសាក្សីផ្តល់ចម្លើយនោះមិនអាចតាមរកឃើញ ។ ដូច្នេះ អង្គជំនុំជម្រះកាត់បន្ថយនូវអត្ថប្រយោជន៍ជាច្រើនពីការចេញសេចក្តីសម្រេចចំពោះព្រះរាជអាជ្ញានៅពេលដែលខ្លួនរកឃើញថា អវត្តមាននៃការផ្តល់សក្ខីកម្មផ្ទាល់មាត់ និងឱកាសតទល់គ្នានៅក្នុងសវនាការ តម្លៃជាភ័ស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅឲ្យភ័ស្តុតាងបែបនេះ អាចត្រូវបានកម្រិតនៅក្នុងកាលៈទេសៈជាច្រើន ។

ការទទួលយកនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះនូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតគឺជារឿងដែលគួរឲ្យកត់សម្គាល់ ។ ចៅក្រមស៊ើបអង្កេតត្រូវបានចាត់ទុកថាជាអ្នកស្វែងរកការពិតដោយប្រមូលទាំងភ័ស្តុតាងដាក់បន្ទុក និងភ័ស្តុតាងដោះបន្ទុក ជាលទ្ធផលដែលបានមកពីការស៊ើបអង្កេតមានរយៈពេលដ៏យូរ ប៉ុន្តែចាំបាច់ត្រូវមានដំណើរការសវនាការដ៏មានប្រសិទ្ធភាពមួយបន្ថែមទៀត ។ ទោះបីជាយ៉ាងណានៅក្នុងវិធាន៦០(២) បានប្រានចោលដោយមិនមានការទទួលខុសត្រូវនូវការសម្ភាសរបស់ភាគីជាមួយសាក្សី និងហាមឃាត់មិនឲ្យមានការតទល់នៅមុនពេលសវនាការ ។ នៅក្នុងអនុស្សរណៈដែលធ្វើឡើងនៅក្នុងឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា មិនមានសិទ្ធិដាច់ខាតណាមួយ ដើម្បីធ្វើការតទល់នៅដំណាក់កាលស៊ើបអង្កេត និងដោយសារមូលហេតុនេះហើយ វិធាន៨៤(១) ទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងដំណាក់កាលជំនុំជម្រះក្នុងការតទល់សាក្សីដាក់បន្ទុក ដែលជនត្រូវចោទមិនទាន់បានតទល់នៅក្នុងដំណាក់កាលស៊ើបអង្កេត ។

ការធ្វើសវនាការឡើងវិញដើម្បីស្តាប់ការផ្តល់សក្ខីកម្មរបស់សាក្សីទាំងអស់ដែលធ្លាប់ត្រូវបានសាកសួរដោយចៅក្រមស៊ើបអង្កេត គឺកិច្ចខិតខំប្រឹងប្រែងច្រំដែល ប៉ុន្តែរឿងដែលអង្គជំនុំជម្រះសាលាដំបូងជឿជាក់យ៉ាងប្រាកដគឺភាពចាំបាច់ដែលត្រូវធ្វើដើម្បីការពារនូវសិទ្ធិរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា ទោះបីជាកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតត្រូវបានសន្មតថា មានភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បានក៏ដោយ ប្រសិនបើសាក្សីមិនបានចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការម្តងទៀត កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះអាចមានតម្លៃជាភ័ស្តុតាងឬមានទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមានដោយសារតែកង្វះឱកាសដើម្បីតទល់គ្នាឬដោយសារមានចំណុចខ្វះខាតជាសារវន្តនានានៅក្នុងកំណត់ហេតុ ។ ប្រសិនបើកំណត់ត្រារបស់ចៅក្រមស៊ើបអង្កេតដែលចងក្រងទុកដើម្បីផ្តល់សក្ខីកម្មមានទម្ងន់តិចតួចមែននោះ គឺមិនច្បាស់ទេថាតើព្រះរាជអាជ្ញានឹងធ្វើការបង្ហាញដោយរបៀបណាអំពីធាតុផ្សំនៃអង្គហេតុ និងបទចោទដែលមានសភាពស្មុគស្មាញដោយមិនមានការកោះហៅសាក្សីជាច្រើនឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។

ការប្រុងប្រយ័ត្នរបស់អង្គជំនុំជម្រះសាលាដំបូងទំនងជាបណ្តាលមកពីផលវិបាកនៃការទទួលស្គាល់ថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេត មិនមានភាព គួរឲ្យជឿជាក់បានទាំងស្រុង និងប្រហែលជាមានការបារម្ភថាការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរដែលមានការប្រឆាំងតវ៉ាច្រើន អាចនឹងធ្វើឲ្យតុលាការជួបនឹងបញ្ហាជាមួយនឹងការស្នើសុំនូវប្រតិចារិត និងការបកប្រែពីខ្សែអាត់ថតសម្លេងដើមជាច្រើន ។ ដូចជាការលើកឡើងរបស់ អៀង ធិរិទ្ធ មុនពេលត្រូវបានបំបែកចេញពីសំណុំរឿងនេះ ៖

> *អ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេតបានស្តាប់ចម្លើយសាក្សីនិងធ្វើការថតសម្លេងតាមខ្សែអាត់សម្លេងពីបទសម្ភាសជាភាសាដើម ។ ដោយមិនធ្វើប្រតិចារឹកពេញលេញនៃការស្តាប់ចម្លើយសាក្សី អ្នកស៊ើបអង្កេតជាញឹកញាប់ធ្វើសេចក្តីសង្ខេបដោយផ្អែកលើការបកស្រាយផ្ទាល់ខ្លួនពីការស្តាប់ចម្លើយបន្ទាប់ពីបានពិភាក្សាជាមួយនឹងសាក្សី និងភាពពាក់ព័ន្ធនៃចម្លើយសាក្សីនោះ ។ ចុងក្រោយកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿង ហើយនៅពេលនេះ សហព្រះរាជអាជ្ញាចាត់ទុកកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះថាជា «ចម្លើយសាក្សី» ។*

> មេធាវីការពារក្តីសន្និដ្ឋានថា ពាក្យ “ចម្លើយសាក្សី” នេះ មិនតំណាងឲ្យបានត្រឹមត្រូវនូវឯកសារដែលជាកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ពីព្រោះថាឯកសារទាំងនេះមិនមែនជា “ចម្លើយ” របស់សាក្សីឡើយ ។

សេចក្តីសម្រេចក្នុងការបង្កើតឲ្យមានប្រតិចារិកសង្ខេបជំនួសឲ្យប្រតិចារិកពេញលេញទំនងជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាដែលយកគំរូតាមប្រព័ន្ធច្បាប់ប្រទេសបារាំងដែលអនុវត្តផ្សេងគ្នាពីនីតិវិធីអនុវត្តដោយតុលាការអន្តរជាតិនានា ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីជាដើម ។ ដោយសារប្រវែងនៃបទសម្ភាសនៅក្នុងករណីដែលមានបទឧក្រិដ្ឋដ៏ធំរវ្គល និងការទាមទារឲ្យមានការបកប្រែភាពប្រឈមនៃការសង្ខេបឲ្យខ្លី ទំនងជាអាចនាំឲ្យមានការយល់ខុសក្នុងការបកស្រាយ និងមានកំហុសកើតឡើង ។ ក្រុមមេធាវីការពារក្តីបានប្រៀបធៀប ការសង្ខេបចេញពីខ្សែអាត់ថតសម្លេងដែលនៅអាចរកបានទៅនឹងកំណត់ហេតុដែលមានភាពខ្វះចន្លោះដោយរាប់បញ្ចូលទាំងការចោទប្រកាន់ពីការប្រានចោលភ័ស្តុតាងដោះបន្ទុក ។ ព្រះរាជអាជ្ញាបានទទួលស្គាល់ថា ពិតជាមានកំណត់ត្រាលាយលក្ខណ៍អក្សរនៃបទសម្ភាសខ្លះ មានព័ត៌មានមិនសុក្រឹត ប៉ុន្តែបានសង្កត់ធ្ងន់ថា ទោះបីជាដូច្នេះក្តី មិនមែនមានន័យថា ត្រូវតែតម្រូវឲ្យមានការផ្តល់សក្ខីកម្មជាស្វ័យប្រវត្តិពីសំណាក់សាក្សីទាំងអស់ក្នុងសវនាការនោះទេ ។ សហព្រះរាជអាជ្ញាបានអះអាងថា ៖

> ខណៈពេលដែលកំណត់ហេតុស្តាប់ចម្លើយមិនមែនជាប្រតិចារិកពេញលេញនៃការស្តាប់ចម្លើយសាក្សី ឯកសារនេះ បានកត់ត្រាថា កំណត់ហេតុស្តាប់ចម្លើយជាច្រើនត្រូវបានធ្វើឡើងនៅក្រោមសម្បថដោយអនុលោមតាមវិធាន២៤ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថាទម្រង់សង្ខេបនៃបទសម្ភាស ត្រូវបានអានជូន ឬអានឡើងវិញដល់សាក្សីនិងមានការយល់ព្រម និងចុះហត្ថលេខាដើម្បីបញ្ជាក់ពីការពិតនៃការផ្តល់បទសម្ភាស ។ ដើម្បីធានាបន្ថែមអំពីភាពគួរឲ្យទុកចិត្តបានការចុះហត្ថលេខាគឺត្រូវបាននិយាយភ្ជាប់នៅក្នុងខ្សែអាត់សម្លេង ។ ភាពសុក្រឹតនៃកំណត់ហេតុសង្ខេបជាលាយលក្ខណ៍អក្សរទាំងនោះត្រូវបានបញ្ជាក់បន្ថែមដោយការផ្តល់សក្ខីកម្មរបស់សាក្សីជាច្រើនដើម្បីបញ្ជាក់អំពីភាពពិតប្រាកដនៃកំណត់ហេតុស្តាប់ចម្លើយមុនៗរបស់ពួកគេ ។ រហូតមកទល់ពេលនេះ មិនទាន់មានសាក្សីណាម្នាក់ដែលអះអាងថាចម្លើយរបស់ពួកគេដែលបានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានធ្វើឡើងក្រោមការណែនាំ ឬបង្ខិតបង្ខំឡើយ ។

អង្គជំនុំជម្រះសាលាដំបូងទំនងជាយល់ស្របជាមួយនឹងចំណុចមួយនេះ ។ អង្គជំនុំជម្រះបានសម្រេចថា”នៅពេលមានការចោទប្រកាន់អំពីភាពខ្វះចន្លោះនៅក្នុងកំណត់ហេតុប្រការនេះនឹងត្រូវបានពិចារណានៅពេលដែលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់និងមានភាពពាក់ព័ន្ធជាក់ស្តែងទៅនឹងសវនាការតែប៉ុណ្ណោះ ។

អង្គហេតុនេះអង្គជំនុំជម្រះសង្កត់ធ្ងន់ថា ការអះអាងផ្ទាល់មាត់ពីភាពសុក្រឹតនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីគឺមានការផ្តល់ជូននូវការការពារបន្ថែមទៀត ដោយហេតុថា សាក្សីដែលត្រូវបានកោះហៅឲ្យមកផ្តល់ភ័ស្តុតាងនៅសវនាការអាចត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះឬគ្រប់ភាគីទៅលើខ្លឹមសារនៃកំណត់ហេតុពីមុនរបស់ពួកគាត់ ។ ហេតុនេះទំនងថា សក្តានុពលដែលមានប្រសិទ្ធភាពជាច្រើនដែលពង្រាងចេញពីការដឹកនាំដោយចៅក្រមស៊ើបអង្កេតត្រូវបានកាត់បន្ថយដោយសេចក្តីសម្រេចភ្លោះដើម្បីកុំឲ្យមានការតទល់នៅមុនពេលសវនាការ និងដើម្បីប្រើប្រាស់ចម្លើយសង្ខេបរបស់សាក្សីជំនួសឲ្យការត្រៀមរៀបចំប្រតិចារិតពេញលេញ ។

បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង គឺកំពុងពិចារណាអំពីសំណើរបស់ភាគីទាំងអស់ចំពោះភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីសម្រាប់សវនាការដំណាក់កាលទាំងពីរដំបូង ហើយនៅក្នុងពេលវេលាសមស្របអង្គជំនុំជម្រះនឹងចេញកាលវិភាគសម្រាប់បើកសវនាការស្តាប់ការជំទាស់របស់ក្រុមមេធាវីការពារក្តី ។

**អាន ហាញឌុល**

# ការប្រើចូរស័ព្ទ : បញ្ហាការបកប្រែក្នុងសំណុំរឿង០០២

ការធានាឲ្យមានការបកប្រែភាសាផ្លូវការទាំងបីមាន ខ្មែរ អង់គ្លេស និងបារាំង នៅលើក្រដាស និងផ្ទាល់មាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅតែជាបញ្ហាប្រឈមផ្នែករដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុជាបន្តបន្ទាប់ ។ ភាសាផ្លូវការនៅតុលាការអន្តរជាតិភាគច្រើន គឺភាសាអង់គ្លេស និងភាសាបារាំង ។ ប្រទេសបារាំងធ្លាប់ជាប្រទេសដែលត្រួតត្រានៅកម្ពុជា និងជាអ្នកផ្តល់ជំនួយមួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីការកកើតនៃតុលាការនេះ ។ ទោះបីជាយ៉ាងនេះក្តី ភាសាបារាំង មិនមែនជាភាសាដែលពេញនិយមក្នុងការសិក្សា ឬការនិយាយ ដូចជាភាសាអង់គ្លេសនោះទេនាពេលបច្ចុប្បន្ន ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលរងនូវភាពខ្វះខាតអ្នកបកប្រែពីភាសាខ្មែរទៅបារាំងផ្ទាល់មាត់ជារៀងរហូតមក ។ ជាផលវិបាកមួយ គឺអង្គជំនុំជម្រះមានការលំបាកយ៉ាងខ្លាំងក្នុងការផ្តល់ជូនអ្នកបកប្រែភាសាបារាំងផ្ទាល់មាត់ដែលប្រកបដោយសមត្ថភាព និងបង្ខំចិត្តអង្គជំនុំជម្រះទទួលយកប្រព័ន្ធបញ្ជូនបន្តក្នុងកំឡុងពេលសវនាការដែលធ្វើឲ្យមានការបកប្រែប្រដេញពីភាសាខ្មែរទៅអង់គ្លេស រួចភាសាបារាំង និងបញ្ច្រាសមកវិញ ។

ក្រុមមេធាវីការពារក្តី ខៀវ សំផន គឺជាក្រុមការពារក្តីតែមួយគត់នៅក្នុងសំណុំរឿង០០២ដែលមានសហមេធាវីជនជាតិបារាំងបានលើកបញ្ហាប្រឈមដដែលៗលើភាពមិនគ្រប់គ្រាន់ និងភាពមិនយល់ដឹងច្បាស់លាស់ចំពោះការបកប្រែឯកសារទៅជាភាសាបារាំង ។ ថ្មីៗនេះ ក្រុមការពារក្តី ខៀវ សំផន បានដាក់បណ្តឹងតវ៉ាមួយបញ្ជាក់ពីការព្រួយបារម្ភចំពោះការបកប្រែផ្ទាល់មាត់ទៅជាភាសាបារាំងអំឡុងពេលសវនាការថាៈ

*ដោយសារតាំងពីការចាប់ផ្តើមដំណើរការសវនាការលើអង្គសេចក្តី មេធាវីការពារក្តីលោក ខៀវ សំផន បាន និងកំពុងជួបប្រទះបញ្ហាបកប្រែប្រដេញតាមប្រព័ន្ធបញ្ជូនបន្តនៅក្នុងដំណើរការនីតិវិធី ទោះបីជាទាក់ទងនឹងការសន្ទនាជាភាសាខ្មែររវាងអ្នកនិយាយពីរនាក់ ឬការសន្ទនារវាងអ្នកនិយាយភាសាខ្មែរ និងអ្នកនិយាយភាសាអង់គ្លេសក្តី គឺអ្នកបកប្រែភាសាបារាំងផ្ទាល់មាត់ រមែងមិនអាចបកប្រែឲ្យបានពេញលេញទេ មុនពេលការឆ្លើយចាប់ផ្តើម ។ ភាពលំបាកបែបនេះបង្កើតឲ្យមានការភ័ន្តច្រឡំនៅក្នុងការបកប្រែភាសាបារាំងផ្ទាល់មាត់ដែលនាំឲ្យប៉ះពាល់ដល់ខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី ។*

មូលហេតុសំខាន់ដែលនាំដល់ការភ័ន្តច្រឡំនិងអូសបន្លាយពេលវេលាមានជាឧទាហរណ៍តាមរយៈការឆ្លើយឆ្លងនៅក្នុងពេលផ្តល់សក្ខីកម្មដោយសាក្សីម្នាក់ៈ

**លោកប្រធានអង្គជំនុំជម្រះ :** សាក្សីមិនបាច់ឆ្លើយតបទេ ។ សំណួរច្រំដែលទេ ។ សាក្សីបានឆ្លើយរួចហើយអម្បាញ់មិញនេះ ។

**លោកមេធាវី វែរគិន :** លោកប្រធាន ភាសាបារាំង ខ្ញុំមិនយល់ទេ ដូច្នេះបានខ្ញុំសួរបញ្ជាក់ឲ្យគាត់ច្បាស់ ។ លោកប្រធានប្រហែលជាយល់ជាភាសាខ្មែរ ក៏ប៉ុន្តែជាភាសាបារាំង ខ្ញុំអត់យល់ទេ ប្រសិនបើខ្ញុំមិនយល់ ខ្ញុំមិនអាចបន្តទៅទៀតបានទេ ។ ខ្ញុំទាល់តែដឹងច្បាស់សិន ។

**លោកប្រធានអង្គជំនុំជម្រះ :** សំណួរនេះសាក្សីឆ្លើយរួចហើយ ហើយច្រើនដងទៀតផង ។ សំណួរច្រំដែល ។ យើងកត់សម្គាល់ឃើញលោកសួរច្រំដែលច្រើនណាស់ព្រឹកនេះ ។

**លោកមេធាវី វែរគិនៈ** លោកប្រធាន ខ្ញុំសូមរំឭកថា យើងធ្វើការជាបីភាសានៅទីនេះ ប្រសិនបើខ្ញុំ ខ្ញុំមិនយល់ការបកប្រែរបស់ខ្ញុំនោះគឺថា ខ្ញុំមិនអាចបន្តការងារជាមេធាវីរបស់ខ្ញុំបានទៀតទេ ។ លោកប្រធានអាចស្តាប់បានច្បាស់ជាភាសាខ្មែរយល់ច្បាស់ ប៉ុន្តែខ្ញុំជាភាសាបារាំង គឺអត់យល់សោះ ។ ដូច្នេះ ខ្ញុំត្រូវការការបំភ្លឺអំពី

សាក្សី ។ បើសិនជាលោកប្រធានឲ្យខ្ញុំបន្តទៅមុខទៀត ហើយគ យ៉ាងម៉េចកើតបើខ្ញុំអត់ទាំងយល់ផងហ្នឹង ។ ដូច្នេះចំណុចកន្លែងនេះ គឺសំខាន់ ខ្ញុំសួរគាត់បញ្ជាក់ឲ្យបានច្បាស់ថា គាត់ស្តាប់ឮនៅពីលើ មាត់ទ្វារ ឬក៏ថានៅក្របខ័ណ្ឌនៃការងាររបស់គាត់នោះ គឺថាគាត់ត្រូវ តែដឹងខ្លឹមសារនៃកិច្ចប្រជុំរបស់គាត់តែប៉ុណ្ណឹងទេ លោកប្រធាន ។

**លោកប្រធានអង្គជំនុំជម្រះ** ៖ យើងសម្រេចរួចហើយ ។ លោកអាចតាំងសំណួរផ្សេងទៀត ។ យើងបានកត់សម្គាល់ឃើញថា លោកតាំងសំណួរច្រំដែលច្រើន ។ នេះជាវិធីសាស្ត្រថ្មីដែលយើង បានកត់សម្គាល់តាំងពីម្សិលមិញមក ។

**លោកមេធាវី វែរកិន** ៖ លោកប្រធាន សហភាតាខ្មែររបស់ ខ្ញុំ គាត់បានជួយប្រាប់ហើយ ។ អ៊ីចឹងខ្ញុំយល់ហើយ ។ អ៊ីចឹងខ្ញុំសូម ចូលទៅចំណុចផ្សេងទៀត ។

យោងតាមក្រុមការពារក្តី ខៀវ សំផន កង្វះខាតនៃភាព ច្បាស់លាស់សម្រាប់អ្នកនិយាយភាសាបារាំង នៅអំឡុងពេលផ្តល់ សក្ខីកម្មដោយសាក្សីត្រូវរួមបញ្ចូលដោយការភ័ន្តច្រឡំ និងការគ្មាន និយាយនៅក្នុងប្រតិចារិកជាផ្លូវការ ។ វិធាន ផ្ទៃក្នុងនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា លើកលែងតែសំណើជាក់លាក់ សម្រាប់ការកែតម្រូវត្រូវបានធ្វើ «កំណត់ហេតុជាលាយលក្ខណ៍


លោក និល ណុន

អក្សរប្រចាំថ្ងៃនៃដំណើរការនីតិវិធីដែលធ្វើឡើងដោយក្រឡាបញ្ជី ត្រូវចាត់ទុកថា មានភាពត្រឹមត្រូវឆ្លុះបញ្ចាំងពីការប្រព្រឹត្តទៅពិត ប្រាកដនៃសវនាការ» ។ ក្រុមការពារក្តីបានប្រៀបធៀបសេចក្តី ថ្លែងការណ៍មួយចំនួនរបស់សាក្សីជាភាសាខ្មែរ និងបារាំង និងបាន គូសបញ្ជាក់ផ្នែកមួយចំនួនដែលព័ត៌មានសំខាន់ៗបានបាត់បង់ គឺ មានមុននោះបាត់អស់ប្រាំល្បះឯណោះឬត្រូវបានបកប្រែផ្លាស់ប្តូរ នៅពេលបកជាភាសាបារាំង ។ ឧទាហរណ៍ប្រតិចារិកផ្លូវការជាភាសា បារាំងមួយបានសរសេរថា ៖

*នៅឆ្នាំ១៩៦៦ ដូចដែលលោកបានដឹងរួចមកហើយ ព្រឹត្តិការណ៍សំខាន់ៗខ្លះបានកើតឡើង ។ ព្រឹត្តិការណ៍នោះ បានធ្វើឲ្យយើងយល់ថារដ្ឋប្រហារមួយអាចកើតឡើងនៅ គ្រប់កាលៈទេសៈទាំងអស់នៅពេលនោះ ។*

ផ្ទុយទៅវិញ នៅក្នុងភាសាខ្មែរសរសេរថា ៖

*នៅឆ្នាំ១៩៦៦ ដូចដែលយើងអាចនឹកឃើញនីតិបញ្ញត្តិ ឆ្នាំ១៩៦៦-៧០ ត្រូវបានបង្កើតឡើង ។ បន្ទាប់មកកម្លាំង របស់ព្រឹទ្ធសភា និងរដ្ឋសភា កាលនោះជាកម្លាំងរបស់ លន់ នល់ សុទ្ធសាធ ។ ខ្ញុំសូមនិយាយពីពាក្យសុទ្ធសាធនេះ គឺ លើកលែងតែជនចម្រើនបីនាក់គឺ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ក្រៅពីនោះមានកម្លាំងកណ្តាលពីរដូចជា កៅ សាន ។ នៅសល់ប៉ុន្មានគឺជាកម្លាំងរបស់ លន់ នល់ ទាំងអស់ ។ ដូច្នេះ សភាពការណ៍ទាំងនេះនាំឲ្យយើងយល់ឃើញថា រដ្ឋប្រហារ អាចកើតឡើងគ្រប់កាលៈទេសៈនៅពេលនោះ ។*

ដោយស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យឡើងវិញពីភាពត្រឹម


មេធា វែរកិន

ត្រូវនៃប្រតិចារិកជាភាសាបារាំងទាំងអស់នោះ ក្រុមការពារក្តី ខៀវ សំផន បានអះអាងថាទោះបីជាក្រុមរបស់ខ្លួនរួមទាំងមេធាវី ដែលនិយាយភាសាខ្មែរ កិច្ចការនេះមិនស្ថិតក្នុងទទួលខុសត្រូវរបស់ ខ្លួនទេ ហើយវាប្រើពេលវេលាច្រើនណាស់សម្រាប់ក្រុមខ្លួនក្នុងការ ទទួលរ៉ាប់រងការងារនេះ ក្នុងអំឡុងពេលដែលតុលាការកំពុងបន្ត

នីតិវិធី ។ ដោយកត់សម្គាល់ឃើញថា កន្លងមកសំណើដដែលៗ ដោយលោកប្រធានអង្គជំនុំជម្រះដែលបង្គាប់ឲ្យសាក្សីនិយាយយឺតៗ នៅតែមិនមានប្រសិទ្ធភាពនៅឡើយ ក្រុមការពារក្ដីបានស្នើបន្ថែមភ្លាមៗឲ្យអនុវត្តវិធានការបច្ចេកទេសមួយចំនួនដើម្បីការពារការពិភាក្សាគ្នាលឿនពេករវាងអ្នកសួរ និងអ្នកឆ្លើយ ធ្វើឲ្យការបកប្រែមិនអាចពេញលេញរួមទាំង «ការដាក់ភ្លើងសញ្ញាមួយសម្រាប់អ្នកបកប្រែភាសាផ្ទាល់មាត់ ដែលនៅចុងក្រោយគេ ដើម្បីឲ្យមានលទ្ធភាពបង្ហាញថាខ្លួនបានបញ្ចប់ការបកប្រែរួចរាល់ និងប្រគល់ឧបករណ៍បំពងសម្លេងទៅឲ្យភាគីផ្សេងដើម្បីនិយាយ» ។

ជាការឆ្លើយតប អង្គជំនុំជម្រះបានបញ្ជាក់ថា «រាល់ប្រតិចារឹករបស់តុលាការថ្មីៗនេះ ត្រូវបានរៀបចំទៅតាមការចម្លងនិងបកប្រែតាមស្ដង់ដារដែលអាចទទួលយកបាននៅចំពោះមុខតុលាការអន្តរជាតិទាំងអស់ រួមទាំងការប្រើប្រាស់ការបញ្ជូនភាសាទៀតផង» ។ ដូច្នេះអង្គជំនុំជម្រះសុំឲ្យបណ្ដឹងតវ៉ារបស់ក្រុមការពារក្ដីបញ្ជូនទៅឲ្យអង្គភាពអ្នកបកប្រែផ្ទាល់មាត់ និងលើកឡើងជាសម្រេចការពន្យល់ និងធ្វើកំណត់សម្គាល់ថា សំណើដាក់លាក់សម្រាប់ការកែតម្រូវប្រតិចារឹក គួរតែដាក់ជូនអង្គភាពអ្នកបកប្រែភាសា មិនមែនអង្គជំនុំជម្រះសាលាដំបូងទេ ។ យើងរង់ចាំមើលថាតើសំណើរបស់ក្រុមការពារក្ដី ខៀវ សំផន នឹងទទួលដោយអង្គភាពបកប្រែភាសា និងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ គឺការិយាល័យរដ្ឋបាលដែរឬយ៉ាងណា? ដោយសារតែប្រភពថវិកា និងបុគ្គលិកខ្វះខាតខ្លាំង ការតម្រូវឲ្យមានការពិនិត្យប្រតិចារឹកក្នុងរយៈពេលប្រាំបួនខែឡើងវិញទំនងជាមិនអាចធ្វើទៅរួចទេ ។

ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឲ្យឃើញថា កង្វះខាតនៃការប្រែសម្រួលជាភាសាបារាំង ជាបញ្ហាបច្ចេកទេសជាជាងបញ្ហាជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ រឿងនេះអាច ឬមិនអាចគឺអាស្រ័យលើស្ថានភាពទូទៅ និងការណ៍ដែលនាំឲ្យខាតបង់ប្រយោជន៍ដែលកើតចេញពីសេចក្ដីសម្រេចដែលអាចចេញដោយអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ មិនមែនស្ថាប័នរដ្ឋបាលនោះទេ បន្ទាប់ពីការវាយតម្លៃមួយយ៉ាងហ្មត់ចត់ ។ ជាការកត់សម្គាល់ លោកចៅក្រម ឡាវើញ នៃអង្គជំនុំជម្រះ សាលាដំបូងក៏ជាជនជាតិបារាំងម្នាក់ដែរ ។ បញ្ហាបកប្រែភាសាផ្ទាល់មាត់ គឺអាចប៉ះពាល់ មិនត្រឹមតែគុណភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ក្នុងការពារកូនក្ដីរបស់ខ្លួននោះទេ ក៏ប៉ុន្តែអាចប៉ះពាល់ដល់ការវាយតម្លៃផ្លូវច្បាប់មួយក្នុងចំណោមចៅក្រមទាំងប្រាំរូប ដែលលោកពឹងផ្អែកលើប្រតិចារឹកជាភាសាបារាំងក្នុងការចេញសេចក្ដីសម្រេច និងចេញសាលក្រមចុងក្រោយ ។

**អាន ហាញឌុល**

## ដំណឹងស្វែងរកគ្រួសារ

*ចេន ឈុន អៀង អាយុ៦៦ឆ្នាំ មានស្រុកកំណើតសង្កាត់បឹងរាំងពីសង្គមសង្កាត់លេខ៤ ក្រុងភ្នំពេញ ។ សព្វថ្ងៃនេះរស់នៅសែនអេម៉ានទីក្រុងបារីស* Seineet Marne *ប្រទេសបារាំង ។ ចេន ឈុន អៀង ជាប្អូនបង្កើតរបស់ ចេន ឈុន ស្រេង ។ ឈ្មោះ ង្លួន អេង (ហៅ តានី) មានតួនាទីជាវិស្វករ មានប្រពន្ធឈ្មោះ ចេន ឈុន ស្រេង ។ ចេន ឈុន ស្រេង ជាបងបង្កើតរបស់ឈ្មោះ ចេន ឈុន អៀង ។ ចំណែក ចេន ឈុន ស្រេង ជាម្ដាយរបស់ក្មេងទាំងនាក់មានឈ្មោះដូចខាងក្រោម ដូច្នេះ ចេន ឈុន អៀង ដែលត្រូវជាឪពុកមាបង្កើតសូមប្រកាសរកក្មួយបង្កើតឈ្មោះ ១) ង្លួន សៅយុត ភេទប្រុស ឆ្នាំ១៩៧០-១៩៧១(មានអាយុប្រហែល ជា ១០ឆ្នាំ) បានចេញទៅតាមម្ដាយដើម្បីរកឪពុកឈ្មោះ ង្លួន អេង ចាប់តាំងពីនោះមកបាត់ដំណឹងរហូត ។ ២) ង្លួន វុត្ថា ភេទប្រុស ៣) ង្លួន ចាន់បុប្ផា ភេទស្រី ៤) ង្លួន វុត្ថារី ភេទស្រី ៥) មិនចាំឈ្មោះ ។ ប្រសិនបើនរណាម្នាក់ក្នុងចំណោមក្មេងទាំងប្រាំនាក់ដែលរៀបរាប់ខាងលើឮពីដំណឹងនៃការស្វែងរកនេះ សូមទំនាក់ទាក់ទងទូរស័ព្ទលេខ ០១២ ២២៧ ៩៣៦ ។*

***សូមអរគុណ!***

# បេះដូងក្រហមរបស់យុវជន ដាំ ផេង

### ដកស្រង់ចេញពីទស្សនាវដ្ដី«យុវជន-យុវនារីបដិវត្តន៍» លេខ៣-ឆ្នាំ១៩៧៣

យុវជន ដាំ ផេង កើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ក្នុងត្រកូលគ្រួសារកសិករក្រមួយ ។ ឪពុកម្ដាយ ដាំ ផេង ក៏ដូចកសិករក្រដទៃផ្សេងទៀតនៅទូទាំងប្រទេសកម្ពុជាដែរ ម្យ៉ាងត្រូវអាណានិគមបារាំងជិះជាន់សង្កត់សង្កិនទាំងខាងសិទ្ធិសេរីភាពនយោបាយ ទាំងខាងជីវភាពស្មារតី និងសម្ភារ ។ ហើយម្យ៉ាងទៀត ត្រូវពួកសក្តិភូមិនាយទុននៅក្នុងប្រទេសជិះជាន់ ឆក់ប្លន់ និងកេងប្រវ័ញ្ចជារៀងរាល់ថ្ងៃ ថែមពីលើនេះមួយជាន់ទៀត ។ ម្ល៉ោះហើយគ្រួសារ ដាំ ផេង និងគ្រួសារកសិករក្រឯទៀត ទាំងអស់ត្រូវរស់នៅក្នុងរណ្ដៅទុក្ខវេទនា ក្រខ្សត់អត់ឃ្លាន ខ្វះមុខខ្វះក្រោយ យ៉ាងសែនឈឺចាប់ខ្លោចផ្សាជាអចិន្ត្រៃយ៍គ្មានពេលល្ហែឡើយ ។ តាំងពីកើតឃើញពន្លឺព្រះអាទិត្យកាលណាមក ដាំ ផេង បានដឹង បានឃើញ និងបានស្គាល់តែរសជាតិនៃជីវភាពគោកយ៉ាកខ្លោចផ្សានេះ ។ ដោយជីវភាពលំបាលវេទនាខ្លាំងពេក ម្ហូបអាហារក៏មិនគ្រប់គ្រាន់ សម្លៀកបំពាក់ក៏ខ្វះខាត ក្មេងៗស្រាតខ្លួនទទេ វាល់ព្រឹកវាល់ល្ងាច ហើយថ្នាំសង្កូវក៏គ្មានសោះតែម្ដង បងប្អូនប្រុសស្រីរបស់ ដាំ ផេង ក៏ឈឺស្លាប់ឲ្យរពុយជាបន្តបន្ទាប់ ។ បន្ទាប់មក ឪពុកម្ដាយ ដាំ ផេង ក៏ឈឺស្លាប់ជាបន្តបន្ទាប់ទៀត ។ ទីបុងបំផុត គ្រួសារនៅសល់តែមនុស្សពីរនាក់គឺបងស្រីម្នាក់ និងដាំ ផេង ។ ពេលនោះ ដាំ ផេង មានអាយុប្រហែល ៧-៨ឆ្នាំប៉ុណ្ណោះ ។ ឯបងស្រីក៏ទើបតែជំទង់ដែរ ។ ដូច្នោះទាំងពីរនាក់បងប្អូនត្រូវធ្លាក់ខ្លួនទៅជាក្មេងកំព្រាមួយជាន់ទៀត គ្មានទីពុំនឹងពឹងពាក់អ្វីសោះ ។ បងស្រីត្រូវបានប្រជាជននៅក្នុងភូមិរើសយកទៅចិញ្ចឹមនៅវត្ត ហើយក៏បានរៀនអក្សរ រៀនលេខជាមួយព្រះសង្ឃតែម្ដងទៅ ។

ក្នុងការរៀនសូត្រ ក៏ដូចក្នុងគ្រប់កិច្ចការបម្រើព្រះសង្ឃ កុមារ ដាំ ផេង ពិតមែននៅតូចក្មេងខ្ចី តែមានបញ្ញាវាងវៃ ហើយខស្បាហ៍ព្យាយាមម៉ត់ចត់ទៀងទាត់ជានិច្ច ធ្វើឲ្យព្រះសង្ឃក្នុងវត្តអាណិតស្រឡាញ់ពេញហប្ញទ័យគ្រប់អង្គ ។ ក្រោយពេលរៀនចប់សាលាបឋមសិក្សាហើយ ដោយឃើញថាកុមារ ដាំ ផេង រៀនពូកែផង ព្រះសង្ឃដែលទទួលខុសត្រូវចិញ្ចឹមកុមារនេះ ក៏បាននាំយកកុមារ ដាំ ផេង មកផ្ញើនឹងព្រះសង្ឃនៅវត្តសារាវ័ន្ត ដើម្បីឲ្យបន្តវិជ្ជានៅភ្នំពេញទៀត ។ ពេលនោះ កុមារ ដាំ ផេង ធំជំទង់ហើយ ។ កុមារបានប្រឡងចូលរៀនថ្នាក់ទី៦ នៅវិទ្យាល័យយុគន្ធរ ។

ពេលរស់នៅក្នុងវត្តសារាវ័ន្ត ដើម្បីបន្តការសិក្សានៅមធ្យមសិក្សាទៀត យុវជន ដាំ ផេង ត្រូវគិតគូរដោះស្រាយជីវភាពសិក្សាខ្លួនដោយខ្លួនឯងទាំងអស់ ។ ក្នុងសង្គមអាណានិគមសក្តិភូមិនាយទុន រដ្ឋវាគ្មានគិតគូរជួយឧបត្ថម្ភអីដល់យុវជនសិក្សាបន្តិចសោះឡើយ ។ ពួកវាមានតែពង្វក់បំពុលយុវជនឲ្យភ្លើតភ្លើនទៅតាមមនោគមវិជ្ជជិះជាន់របស់វាឲ្យដក់ចិត្តដក់គំនិតលង់ខ្លួនទៅតាមវប្បធម៌ពុករលួយរវើយរវាយ លន្ងង់លន្ងោចតែប៉ុណ្ណោះ ។ ហើយម្យ៉ាងទៀត វាធ្វើឲ្យច្បាប់តឹងតែងកៀបគៀតយុវជនដែលជាកូនចៅប្រជាជនក្រីក្រកុំឲ្យរៀនសូត្របានវែងឆ្ងាយ ដូចកូនចៅពួកវា ។ ម្ល៉ោះហើយ យុវជន ដាំ ផេង ក៏ដូចយុវជនក្រីក្រផ្សេងទៀតដែលចង់បន្តការសិក្សាទៅទៀត ត្រូវបង្ខំចិត្តលក់កម្លាំងឲ្យពួកសក្តិភូមិ នាយទុន ពេលសម្រាកពីការរៀនសូត្រ ដើម្បីបានប្រាក់បន្តិចបន្តួចគ្រាន់ទិញសៀវភៅរៀន ទិញខោអាវស្លៀកពាក់ និងទិញម្ហូបចំណីខ្លះៗ ។ យុវជន ដាំ ផេង ពេលថ្ងៃទៅរៀននៅសាលាពេលយប់ឆ្លៀតលក់នំប័ុង ឬដួលស៊ីក្លូគេរត់ គ្រាន់បានកម្រៃខ្លះផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ។ ពេលបុណ្យទាន ឬវិស្សមកាលដែលឈប់សម្រាកយូរថ្ងៃ យុវជន ដាំ ផេង ទៅស៊ីឈ្នួលរែកកំបោររែកឥដ្ឋនៅការដ្ឋានសំណង់ផ្សេងៗជាមួយកម្មករឯទៀត ។ ណាខំរៀនឲ្យទាន់គេនៅសាលា ណាខំរកស៊ីចិញ្ចឹមជីវិត ។ ម្ល៉ោះហើយ យុវជនយើងត្រូវហត់នឿយទាំងផ្លូវកាយផ្លូវចិត្ត និងបញ្ញាទាំង

យប់ទាំងថ្ងៃគ្មានដែលបានសម្រាកឡើយ ។ ម្យ៉ាងដោយហត់នឿយហួសកម្លាំង ម្យ៉ាងទៀត ដោយការស៊ីចុកក៏ខ្វះខាត ដេកក៏មិនគ្រប់គ្រាន់ទៀត ម្នាក់ៗទម្រាំបានសញ្ញាបត្រឌីប្លូម ឬបាសូវាមួយសន្លឹកៗ ខូចខ្លួនខូចប្រាណអស់ ។ ខ្លះរបេងស៊ីស្ងួត ខ្លះទៀតទៅជាឆ្កួតឡប់សតិ ខ្លះទៀតសុខភាពចុះខ្សោយរហូត ។

ឆ្នាំ១៩៦០ អង្គការយុវជនបដិវត្តន៍នៅពេលនោះមានឈ្មោះថា "សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ" បានចាប់បដិសន្ធិឡើង ។ ក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍កម្ពុជាចលនាយុវជនសិក្សានៅទីក្រុងភ្នំពេញក៏ចាប់ផ្ដើមផុលផុសកក្រើករំពើកឡើងទៅ ។ យុវជន ដាំ ដេង បានចូលក្នុងអង្គការយុវជនបដិវត្តន៍នេះនៅឆ្នាំ១៩៦១ ។ ហើយចាប់ពីនោះមក យុវជនដាំ ដេង បានទទួលការអប់រំថែបំប៉នទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍អំពីអង្គការបដិវត្តន៍ជាប់រហូតមក ។ យុវជនដាំ ដេង បានរីកចម្រើនធំធាត់យ៉ាងឆាប់រហ័សទាំងរូបកាយទាំងគំនិតបញ្ញា ទាំងទស្សនៈទាំងគោល ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ក្រោមការជួយណែនាំអប់រំ និងការជួយឧបត្ថម្ភ សព្វបែបយ៉ាងអំពីអង្គការបដិវត្តន៍ ។ យុវជនយើងចាប់ មានភ្នែកភ្លឺហើយមើលឃើញវែងឆ្ងាយច្បាស់លាស់ជាងផ្ទះកែវយិតទៅទៀត ។ គេឃើញទុក្ខវេទនាមួយរយមួយពាន់ជំពូករបស់ប្រជាជនក្រោមការជិះជាន់ដ៏សែនធ្ងន់របស់ចក្រពត្តិ សក្តិភូមិ នាយទុន ។ តាមរយៈនេះ គេយល់ច្បាស់នូវមូលហេតុនៃទុក្ខវេទនារបស់គ្រួសារម៉ែឪ បងប្អូនគេកាលពីពេលមុនរហូតដល់ស្លាប់បាត់បង់ជីវិតនិរាសព្រាត់ ប្រាស់គ្នាអស់ និងយល់នូវការលំបាកវេទនាតរបស់គេសព្វថ្ងៃ ។ ម្យ៉ាងទៀត គេមើលឃើញច្បាស់នូវគ្រោះអាសន្នដែលប្រទេសជាតិគេកំពុងស្ថិតនៅក្រោមការគំរាមកំហែងជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាមេរិកជារៀងរាល់ថ្ងៃ ។

នៅតាមព្រំដែន ឈាមប្រជាជន ស្រី ប្រុស ចាស់ ក្មេងត្រូវហូររាល់ថ្ងៃដោយសារអំពើឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារព្រៃនគរ បាងកក ទាំងតាមជើងគោក និងជើងអាកាស ។ សម្រែកមាតុភូមិជាទីស្នេហាដែលដង្ហោយហៅ កុលបុត្រ កុលធីតា ឲ្យក្រោកឈរឡើងការពារទឹកដីបានលាន់ឮកងរំពងដល់បេះដូងដ៏ក្មេងខ្ចីនិងបរិសុទ្ធរបស់ប្រជាជនដាំ ដេង និង យុវជនយុវនារីកម្ពុជាឯទៀតទាំងអស់ ។ យុវជនដាំ ដេង ក៏ចាប់ផ្ដើមត្រួតពិនិត្យមើលអាត្មាខ្លួនឡើងវិញ ហើយក៏បានឃើញនឹងបានយល់ច្បាស់ថា អាត្មាខ្លួនដែលបានខិតខំចំណាយពេលវេលាចំណាយកម្លាំងកាយចិត្តគំនិតនិងបញ្ញា និងចំណាយយុវវ័យរបស់ខ្លួនយ៉ាងពេញទំហឹងសព្វថ្ងៃនេះ ដើម្បីបានសញ្ញាបត្រ បានបុណ្យសក្តិ លាភសក្ការៈផ្ទាល់ខ្លួនទៅថ្ងៃក្រោយទៀតនោះ គឺជាការឥតប្រយោជន៍ ព្រោះគ្មានបម្រើប្រទេសជាតិ គ្មានផលប្រយោជន៍អ្វីដល់ប្រជាជនបន្តិចសោះ ។ ហើយផ្ទុយទៅវិញគំរិះវិជ្ជា និងការយល់ដឹងរបស់ខ្លួននេះ វាបម្រើចក្រពត្តិសក្តិភូមិ នាយទុនក្នុងការជិះជាន់ឆក់ប្លន់ កាប់សម្លាប់ប្រជាជនឯងប៉ុណ្ណោះ ។ ដោយបានអង្គការបដិវត្តន៍ឃោសនា អប់រំពន្យល់ណែនាំ យុវជន ដាំ ដេង ក៏ដូចយុវជន យុវនារី ផ្សេងទៀតបានភ្ញាក់ខ្លួនទាន់ពេលវេលា និងចំពេលដែលប្រទេសជាតិមាតុភូមិកំពុងស្រែកដង្ហោយហៅគេទាំងឡាយផង ។ យុវជនដាំ ដេង បានបង្វែរសកម្មភាពរបស់ខ្លួនទាំងអស់ ការខំប្រឹងប្រែងព្យាយាមស្វិតស្វាញរបស់ខ្លួន ទាំងអស់ ការបម្រើប្រទេសជាតិ បម្រើប្រជាជន និងបម្រើវណ្ណៈក្រីក្រវិញ ។ ដោយមានចរិតស្លូតបូត សុភាពរាបសាផង ដោយមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជនខ្ពស់ ពិសេសប្រជាជនក្រីក្រ ហ៊ានលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនទាំងអស់ ដើម្បីបុព្វហេតុឧត្តុង្គឧត្តមនេះ និងដោយមានគោលជំហរប្រយុទ្ធដាច់ខាតជាមួយចក្រពត្តិ និងពួកវណ្ណៈជិះជាន់ទាំងអស់ក៏ដូចជាជាមួយឧបសគ្គតូច ធំ ក្នុងការបំពេញភារកិច្ចផង យុវជន ដាំ ដេង បានទៅជាគំរូលះបង់ និងគំរូសាមគ្គីឯកភាពក្នុងផ្ទៃអង្គការយុវជនបដិវត្តន៍នៅក្នុងទីក្រុងភ្នំពេញទាំងមូល ។ នៅក្នុងវិទ្យាល័យយុគន្ធរ ក៏ដូចជាវិទ្យាល័យ និងអនុវិទ្យាល័យផ្សេងទៀតក្នុងទីក្រុងភ្នំពេញ យុវជន ដាំ ដេង មានការប្រាស្រ័យទាក់ទងជិតស្និទ្ធល្អជាមួយយុវជន និងយុវនារីឯទៀតទាំងអស់ ។ ដោយមានអប្បកិរិយាស្លូតបូត និងសុភាពរាបសា ហើយយល់ដឹងសុខទុក្ខ យល់អធ្យាស្រ័យ និងចេះជួយយកអាសាយុវជនដទៃទៀតក្នុងការរៀនសូត្រ ក៏ដូចជាក្នុងជីវភាពរស់នៅរបស់គេដែលមានការលំបាក យុវជន ដាំ ដេង ត្រូវបានយុវជន យុវនារីជាច្រើនស្រឡាញ់រាប់អាន និងកោតសរសើរ ។

ចុងឆ្នាំ១៩៦៣ និងដើមឆ្នាំ១៩៦៤ ចក្រពត្តិអាមេរិក និងបរិវារព្រៃនគរ បាងកក ធ្វើការគំរាមកំហែង និងកៀបសង្កត់យ៉ាង

ខ្លាំងមកលើឯករាជភាព សន្តិភាព អព្យាក្រឹតភាព និងបូរណភាព ទឹកដីនៃកម្ពុជា ។ ប្រទេសជាតិកម្ពុជា ស្ថិតនៅចំពោះមុខគ្រោះអាសន្ន នៃរដ្ឋប្រហារយោធារបស់ភ្នែចក្រពត្តិអាមេរិក ដែលមានលន់ នល់ និងបក្សពួកជាមេ ជាអចិន្ត្រៃយ៍ ។ តែពួកវណ្ណៈកាន់អំណាចជំនាន់នោះ បែរជាចង់សារភាពខ្លាំងសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិក បរិវារដើម្បីសុំសេចក្តីសុខសាន្តអំពីវាទៅវិញ ទោះបីប្រទេសជាតិ ធ្លាក់ទៅជាខ្ញុំគេ ក៏មិនខ្វល់ដែរ ។ ដូច្នោះ អង្គការបដិវត្តន៍កម្ពុជាក្នុង ឋានៈជាអ្នកតំណាង និងការពារផលប្រយោជន៍ប្រទេសជាតិ និង ប្រជាជនកម្ពុជាទាំងមូល បានដឹកនាំប្រជាជនយុវជនយុវនារីកម្ពុជា នៅទូទាំងប្រទេសឲ្យក្រោកឈរឡើងធ្វើការតស៊ូតាមគ្រប់រូបភាព ប្រឆាំងចក្រពិត្តអាមេរិក និងបរិវារព្រៃនគរ បាងកក ហើយកៀប សង្កត់និងអូសទាញពួកវណ្ណៈកាន់អំណាចជំនាន់នោះកុំឲ្យសារភាព ខ្លាំង ។ យុវជន ដាំ ដេង ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការ បដិវត្តន៍បានចុះប្រឡូកជាប់ជិតស្និទ្ធនឹងមជ្ឈដ្ឋានយុវជន យុវនារី សិក្សាក្នុងទីក្រុងភ្នំពេញ ធ្វើការឃោសនាអប់រំ បកអាក្រាត និង វែកញែកនូវឧបាយកល និងបទឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក និង បរិវារព្រៃនគរ បាងកក ដែលប៉ុនប៉ងសម្លាប់ ឯករាជ្យ សន្តិភាព អព្យាក្រឹតនៃកម្ពុជាយើង ។ យុវជន ដាំ ដេង បានបំផុសបំផុល ចលនាយុវជនសិក្សាយ៉ាងសកម្មក្លៀវក្លាបំផុត ហើយបានចូលរួម ដឹកនាំចលនាយុវជន យុវនារី តស៊ូប្រឆាំងចក្រពត្តិអាមេរិកបរិវារ យ៉ាងអង់អាចក្លៀវក្លា និងគគ្រឹកគគ្រេងបំផុត ។ មានចលនាបាច ខិតប័ណ្ណ ចលនាបាតុកម្ម កូដកម្ម មីទីង ជាដើម ។

ដោយយុវជន យុវនារីកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ នៃអង្គការបដិវត្តន៍កម្ពុជាបានធ្វើការតស៊ូខ្លាំងក្លាគគ្រឹកគគ្រេងនៅ ទូទាំងប្រទេសទាមទារនិងកៀបសង្កត់ខ្លាំង ពួកវណ្ណៈកាន់អំណាច ពេលនោះក៏ត្រូវបង្ខំចិត្តផាត់ជំនួយដ៏មានពិសពុលរបស់ចក្រពត្តិ អាមេរិក ទាំងក្តីសោកស្តាយ នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ នេះជាជ័យ ជម្នះដ៏ត្រចេះត្រចង់មួយរបស់ប្រជាជនយុវជន យុវនារីកម្ពុជា ក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃអង្គការបដិវត្តន៍កម្ពុជា ។ ហើយក៏ជា បរាជ័យអាម៉ាស់មួយរបស់ចក្រពត្តិនិងបរិវារ ក្នុង និងក្រៅវានៅ កម្ពុជា ។ ដោយហេតុឃោរឃៅហ្វាស៊ីស និងចចេសក្បាលរឹង របស់វា ចក្រពត្តិអាមេរិក និងបរិវារខំរិះរកឧបាយកលខ្មៅងងឹត លើផែនការឧក្រិដ្ឋមួយ ហើយមួយទៀតប៉ងសម្លាប់កម្ពុជាឯករាជ្យ សន្តិភាព អព្យាក្រឹត្យ យ៉ាងមមាញឹកទៀត ។ តាមការណែនាំរបស់ អង្គការបដិវត្តន៍នៅខែវិច្ឆិកា ឆ្នាំ១៩៦៤ យុវជនដាំ ដេង បានចូល រួមបំផុសនិងដឹកនាំចលនាយុវជនសិក្សាធ្វើកូដកម្ម ធ្វើមីទីងនៅ វាលមេរុ នៅមុខវាំង នៅមុខរដ្ឋសភា ដើម្បីវែកញែកបកអាក្រាតនូវ ផែនការ និងសកម្មភាពឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក បរិវារដែល ប៉ុនប៉ងសម្លាប់ឯករាជ្យ សន្តិភាព អព្យាក្រឹតនៃកម្ពុជា ប្រកាសថ្កោល ទោសនូវអំពើជ្រៀតជ្រែកឈ្លានពានរបស់វាដែលបាញ់រះទម្លាក់ គ្រាប់បែកទៅលើភូមិករ ទ្រព្យសម្បត្តិផលដំណាំប្រជាជននៅតាម ព្រំដែននិងសម្លាប់ប្រជាជនស្លូតត្រង់ទាំងស្រី ប្រុស ចាស់ក្មេងនៅតាម ព្រំដែនជារៀងរាល់ថ្ងៃ ហើយទាមទារឲ្យពួកវណ្ណៈកាន់អំណាចនោះ ផ្តាច់ចំណងទូតជាមួយចក្រពត្តិអាមេរិកនិងបរិវារទាំងអស់ ។ តែពួក វណ្ណៈកាន់អំណាចប្រតិកិរិយាវាមិនត្រឹមតែមិនគោរពតាមធ្វើ សំណូមពររបស់ប្រជាជន យុវជន យុវនារីយើងប៉ុណ្ណោះទេ វាថែម ទាំងបង្កើនសកម្មភាពតាមដាន លួចចាប់ចង និងចាប់សម្លាប់បំបាត់ ដាន គំរាមគំហែងដល់សន្តិសុខរបស់ប្រជាជន យុវជន យុវនារី ស្នេហាជាតិទៀតផង ។

ទោះជាសន្តិសុខផ្ទាល់ខ្លួនត្រូវគំរាមគំហែងគ្រប់ពេលវេលា យ៉ាងនេះក៏ដោយ ក៏យុវជនដាំ ដេង នៅតែបន្តសកម្មភាពបដិវត្តន៍ ធ្វើការឃោសនាអប់រំចាត់តាំងយុវជនសិក្សាយ៉ាងមមាញឹក ហើយ បំផុសនិងដឹកនាំចលនាតស៊ូ នៅក្នុងទីក្រុងតាមគ្រប់រូបភាព និង លទ្ធភាពដែលធ្វើបានយ៉ាងឈ្លាសវៃប៉ិនប្រសប់ និងងអង់អាច ក្លៀវក្លាបំផុត ។ ចលនាតស៊ូរបស់ យុវជន យុវនារី ជាកូដកម្ម បាតុកម្ម មីទីង តូច មធ្យម ធំ ប្រឆាំងចក្រពត្តិអាមេរិក និងបរិវារចេះតែ ផ្ទុះឡើងជាបន្តបន្ទាប់ នៅតាមសាលា អនុវិទ្យាល័យ និងមហាវិទ្យាល័យ ពាសពេញទីក្រុងភ្នំពេញ ។ រហូតដល់ខែមីនា ឆ្នាំ១៩៦៤ មហា បាតុកម្មយ៉ាងសម្បើមអស្ចារ្យមួយរបស់យុវជន យុវនារី សិក្សារួម ផ្សំជាមួយប្រជាជន ពិសេសកម្មករ ប្រជាពលករទីក្រុងភ្នំពេញ ក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍បានផ្ទុះឡើងកណ្តាលទីក្រុង បីដូចភ្នំភ្លើងវាយកម្ទេចស្ថានទូតចក្រពត្តិអាមេរិកខ្ទេចខ្ទីអស់គ្មាន សល់ ។ នេះជាមហាជ័យជម្នះរបស់យើងមួយទៀតដែលខ្ទរខ្ទារនៅ ទូទាំងប្រទេសកម្ពុជា និងទូទាំងសកលលោកធ្វើឲ្យចក្រពត្តិអាមេរិក

និងបរិវារអាម៉ាស់មុខយ៉ាងខ្លាំង ។

បន្ទាប់ពីមហាបាតុកម្មដ៏ល្បីល្បាញនេះមក ពួកវណ្ណៈកាន់អំណាចបានបង្កើតសកម្មភាពតាមដាន សំឡុតគំរាម ចាប់ចងអ្នកស្នេហាជាតិកាន់តែខ្លាំង ។ តែចលនាតស៊ូរបស់យុវជន យុវនារីយើងកាន់តែផុសផុលឆាបឆេះសន្ធោរសន្ធៅខ្លាំងឡើង ហើយរីករាលដាលពីទីក្រុងភ្នំពេញ រហូតដល់ទីរួមខេត្តនានាទូទាំងប្រទេស ។ អង្គការបដិវត្តន៍អំពាវនាវដល់កម្មាភិបាលនិងយុវជនបដិវត្តន៍មួយចំនួនឲ្យលះបង់ការសិក្សា ដើម្បីចេញធ្វើសកម្មភាពជាសម្ងាត់ ដឹកនាំ និងគ្រប់គ្រងអង្គការយុវជន និងចលនាយុទ្ធជនដែលកំពុងតែផុលផុសសម្បើមអស្ចារ្យ ។ ពេលនោះ យុវជនដាំ ផេង កំពុងរៀននៅថ្នាក់ទី៧ នៃវិទ្យាល័យយុគន្ធរ ។ ឆ្លើយតបតាមសេចក្តីអំពាវនាវរបស់អង្គការបដិវត្តន៍ យុវជនដាំ ផេង បានស្ម័គ្រចិត្តលះបង់ការសិក្សាដោយរីករាយ ហើយចូលទៅរស់នៅសម្ងាត់ធ្វើសកម្មភាពបដិវត្តន៍ជាសម្ងាត់ជាបន្តទៀតតាមការណែនាំរបស់អង្គការបដិវត្តន៍នៅចុងឆ្នាំ១៩៦៤ ។ ដោយពិនិត្យឃើញនូវស្មារតីអង់អាចក្លាហានសកម្មប្រយុទ្ធ ស្មារតីលះបង់ទ្រាំទ្រការលំបាកវេទនាខ្ពស់ និងគោលជំហរដាច់ខាតប្រយុទ្ធរបស់យុវជន ដាំ ផេង អង្គការក៏បានប្រគល់តួនាទីជាលេខាសម្ព័ន្ធយុវកកក្រុងភ្នំពេញ ។ ទោះមាននាទីជាលេខាសម្ព័ន្ធយុវកកក្រុងហើយក៏ដោយ យុវជន ដាំ ផេង នៅតែរក្សាសុភាពស្លូតបូត និងសុភាពរាបសាចំពោះមិត្ត និងចំពោះប្រជាជនជានិច្ច ហើយរឹតតែចងកំហឹងចំពោះចក្រពត្តិអាមេរិក បរិវារ និងពួកវណ្ណៈកាន់អំណាចប្រតិកិរិយាកាន់តែពុះពារថែមទៀត ។

ទោះបីជា មិត្តត្រូវរស់នៅក្នុងបន្ទប់បួនជ្រុង គ្មានបានដើរហើរទៅនេះ ទៅនោះតាមចំណង់ដូចកាលមិត្តនៅជាយុវជនសិក្សាក៏ដោយ ក៏មិត្តគ្មានធុញថប់ គ្មានទើសទាល់នឹងជីវភាពថ្មីនេះដែរ ។ តែផ្ទុយទៅវិញ មិត្តបានខិតខំរៀនសូត្រលត់ដំខ្លួន ហ្វឹកហ្វឺនខ្លួនក្នុងចលនាដើម្បីកសាងពង្រឹង និងពង្រីកគោលជំហាននយោបាយសតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ឲ្យដល់ខ្លួនមិត្តជាលំដាប់ ។ ព្រមជាមួយគ្នានេះ មិត្តបានខិតខំគិតគូរពិចារណាលើការអប់រំណែនាំរបស់អង្គការ ខិតខំយល់ និងចូលជ្រៅទៅក្នុងចលនាយុវជនយុវនារី ដែលកំពុងតែផុសផុលសម្បើមអស្ចារ្យនេះ ។ ដើម្បីពង្រឹងពង្រីក និងកែលម្អនូវការដឹកនាំគ្រប់គ្រងអង្គការយុវជនដោយស្មារតីម្ចាស់ការច្នៃប្រឌិត និងទទួលខុសត្រូវខ្ពស់ចំពោះបដិវត្តន៍ និងប្រជាជនជានិច្ច ។

អង្គការយុវជនទីក្រុង ក៏ដូចនៅទូទាំងប្រទេសបានរីង និងរីកធំធាត់យ៉ាងឆាប់រហ័ស ។ ចលនាតស៊ូប្រឆាំងចក្រពត្តិអាមេរិក និងបរិវាររបស់ប្រជាជន យុវជន យុវនារីកម្ពុជា ក្រោមការដឹកនាំដ៏វាងវៃ នៃអង្គការបដិវត្តន៍កម្ពុជាទាំងនៅទីក្រុង និងទីប្រជុំជនផ្សារ ទាំងនៅជនបទស្រែចម្ការ ចុងកាត់មាត់ញកបានឆាបឆេះពុះកញ្ជ្រោលកាន់តែខ្លាំងឡើងៗ នៅទូទាំងប្រទេស ។ សម្រែកបដិសេធចក្រពត្តិអាមេរិក បរិវារ និងសម្រែកទាមទារឲ្យកាត់ចំណងទូតជាមួយពួកវា បានលាន់ឮកងរំពងកាន់តែខ្លាំងឡើងៗ នៅពាសពេញទាំងផ្ទៃប្រទេសកម្ពុជា ធ្វើឲ្យចក្រពត្តិអាមេរិក បរិវារមានការព្រួយបារម្ភជាខ្លាំងចំពោះដោគវាសនាវានៅកម្ពុជា និងរឹតតែភ័យញ័ររន្ធត់នៅចំពោះមុខចលនាតស៊ូរបស់ប្រជាជន យុវជន និងយុវនារីយើង ។ ពួកវណ្ណៈកាន់អំណាចពេលនោះក៏មានការភិតភ័យដែរ ហើយខំរិះរកគ្រប់វិធីទាំងក្តៅទាំងត្រជាក់ដើម្បីពន្លត់ភ្លើងកំហឹងជាតិនេះ ។ ពួកវាពន្លត់មិនបាន ។ ហើយផ្ទុយទៅវិញ ភ្លើងកំហឹងជាតិនេះកាន់តែឆាបឆេះសន្ធោរសន្ធៅខ្លាំងឡើងៗ រហូតដល់ចាប់បង្ខំឲ្យពួកវណ្ណៈកាន់អំណាច ពេលនោះត្រូវកាត់ចំណងទូតជាមួយចក្រពត្តិអាមេរិក និងបរិវារទាំងអស់នៅខែមេសា ឆ្នាំ១៩៦៥ ដោយអាឡោះអាល័យបំផុត ។ នេះជាមហាជ័យជម្នះថ្មីមួយទៀតរបស់យើងដែលល្បីខ្ទរខ្ទារទូទាំងសកលលោក ។

ចក្រពត្តិអាមេរិកនិងបរិវារទាំងអស់ត្រូវបរាជ័យយ៉ាងធ្ងន់និងយ៉ាងអាម៉ាសបំផុតនៅកម្ពុជា ។ ម៉្លោះហើយវាខំរិះគ្រប់ឧបាយកលពិសពុលខ្មៅងងឹតដោយរួមផ្សំជាមួយពួកអាវណ្ណៈ កាន់អំណាចប្រតិកិរិយាក្នុងប្រទេសជាសម្ងាត់ ដើម្បីកម្ទេចចលនាស្នេហាជាតិ និងកម្លាំងស្នេហាជាតិនៅកម្ពុជាទាំងអស់ ។ ដូច្នោះហើយ បានជានៅចុងឆ្នាំ១៩៦៦ រដ្ឋសភាឃោរឃៅហ្វាស៊ីសក្បត់ជាតិមួយ បានត្រូវឧបត្តិឡើងនៅទីក្រុងភ្នំពេញក្រោមការញ៉ាក់ខ្សែរបស់សេ.អ៊ី.អា ។ ក្រោយនោះភ្លាមរដ្ឋសភាក្បត់ជាតិនេះក៏បានតែងតាំងអា លន់ នល់ ឲ្យធ្វើជានាយករដ្ឋមន្ត្រីក្រោមកិច្ចបញ្ជារបស់ចក្រពត្តិអាមេរិកផ្ទាល់តែម្តង ។ នេះជារដ្ឋប្រហារស្របច្បាប់មួយដែលចក្រពត្តិអាមេរិក–បរិវារនិងពួកអាក្បត់ លន់ នល់

វាធ្វើឡើងដើម្បីដណ្តើមអំណាចត្រួតត្រាគ្រប់គ្រងនៅប្រទេសកម្ពុជាយើងជាលើកដំបូង ។ គ្រាន់តែកើតមានរូបមានរាងឡើងភ្លាម រដ្ឋាភិបាលក្បត់ជាតិនេះ ក៏ចាប់ផ្តើមសកម្មភាពបង្ករឿងហេតុធ្វើទុកបុកម្នេញនិងបង្ក្រាបរាតត្បាតចាប់ចងកាប់សម្លាប់ប្រជាជនស្លូតត្រង់ និងអ្នកស្នេហាជាតិដោយទ្រង់ទ្រាយធំភ្លាមដែរ ។ នៅខែមីនា ឆ្នាំ១៩៦៧ វាបានបង្កសង្គ្រាមផ្ទៃក្នុងឲ្យឆេះសន្ធោរសន្ធៅនៅខេត្តបាត់ដំបងតាមបញ្ជារបស់ចក្រពត្តិអាមេរិកទាំងស្រុង ។ តែអង្គការបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងវៃឈ្លាសបានបំផុសបំផុលចលនាតស៊ូនយោបាយយ៉ាងគគ្រឹកគគ្រេងនៅទូទាំង ប្រទេសដើម្បីទប់ទល់និងវាយបំបាក់នូវផែនការខគ្រិដ្ឋនេះរបស់ខ្មាំង ។ ពិសេសនៅដើមខែឧសភា ឆ្នាំ១៩៦៧ ចលនាតស៊ូយ៉ាងធំសម្បើមអស្ចារ្យរបស់យុវជន យុវនារីនៅទីក្រុងភ្នំពេញដែលជាប់នឹងក្បាលម៉ាស៊ីនដឹកនាំរបស់ខ្មាំងបានវែកញែកបកអាក្រាត និងវាយបំបែកផែនការខគ្រិដ្ឋនេះរបស់ចក្រពត្តិអាមេរិក បរិវារ និងពួកក្បត់ លន់ នល់, សិរិ មតៈ, សឹង ង៉ុកថាញ់ និងអ៊ិន តាំ ដោយជោគជ័យ ធ្វើឲ្យរដ្ឋាភិបាលក្បត់ជាតិព្រមទាំងបុគ្គលអាក្បត់ នល់ លន់ ត្រូវរលំដួលបះជើងនៅខែឧសភា ឆ្នាំ១៩៦៧ នេះយ៉ាងទាន់ហន់ភ្លាមដែរ ។

ចក្រពត្តិអាមេរិក បរិវារ និងពួកអាក្បត់ជាតិត្រូវបរាជ័យយ៉ាងអាម៉ាសមួយលើកទៀត ។ ពួកវណ្ណៈកាន់អំណាចចក្រពត្តិប្រតិកិរិយាក្បត់ជាតិក្រោមបញ្ជារបស់ចក្រពត្តិអាមេរិកបានខិតខំរកវិធីនិងឧបាយកលផ្សេងទៀតដើម្បីពន្លត់ភ្លើងធំជាតិ និងភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈដែលកំពុងតែឆាបឆេះយ៉ាងខ្លាំងនេះ ហើយរំងាប់នូវចលនាតស៊ូរបស់ប្រជាជន យុវជន យុវនារីយើងរួចឈានទៅកម្ទេចកម្លាំងបដិវត្តន៍ស្នេហាជាតិទាំងអស់ ។ ដូច្នោះវាក៏ចាប់ផ្តើមអនុវត្តនយោបាយហ្វាស៊ីសសភាវូបនីយកម្មទុរគតិ៍ភាវូបនីយកម្ម និងពាលាភាវូបនីយកម្ម យ៉ាងសកម្មមមាញឹកទាំងនៅទីក្រុង ទាំងនៅជនបទស្រែចម្ការចុងកាត់មាត់ញក ។ អង្គការបដិវត្តន៍បានដឹកនាំប្រជាជន យុវជន យុវនារីកម្ពុជាវាយកំចាត់នយោបាយខគ្រិដ្ឋទាំងបីខាងលើនេះរបស់ខ្មាំងយ៉ាងអង់អាចក្លៀវក្លានៅទូទាំងប្រទេសទៀត ធ្វើឲ្យខ្មាំងសម្រេចគោលបំណងដ៏ខ្មៅងងឹតរបស់វាមិនបាន ។

នៅដើមឆ្នាំ១៩៦៨ ខ្មាំងក៏បង្កសង្គ្រាមផ្ទៃក្នុងមួយជងទៀត ប៉ុនប៉ងកម្ទេចកម្លាំងបដិវត្តន៍ និងចលនាតស៊ូស្នេហាជាតិទាំងអស់តែមួយព្រឹប ។ តែផ្ទុយទៅវិញ ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងត្រឹមត្រូវនៃអង្គការបដិវត្តន៍ សង្គ្រាមបដិវត្តន៍ប្រឆាំងនឹងសង្គ្រាមផ្ទៃក្នុងដែលចក្រពត្តិអាមេរិក និងបរិវារក្បត់ជាតិ វាបង្កឡើងបានរីករាលដាលពីខេត្តមួយឆ្លងទៅខេត្តមួយយ៉ាងឆាប់រហ័ស ហើយវាយសម្រុកទៅលើខ្មាំងវិញយ៉ាងខ្លាំងក្លា ។ នៅក្នុងទីក្រុងភ្នំពេញ អង្គការបដិវត្តន៍បានបំផុសនិងដឹកនាំចលនាតស៊ូនយោបាយតទៅទៀតតាមគ្រប់រូបភាព ទាំងចំហស្របច្បាប់ ទាំងពាក់កណ្តាលចំហ ពាក់កណ្តាលស្របច្បាប់ ទាំងសម្ងាត់មិនស្របច្បាប់ស្អេកស្អះពេញទាំងទីក្រុងភ្នំពេញ ។ ខ្មាំងដែលចង់កម្ទេចកម្លាំងបដិវត្តន៍យើងតែមួយព្រឹបអស់រលីងនោះ វាមិនត្រឹមតែកម្ទេចយើងមិនបានប៉ុណ្ណោះទេ តែវាត្រូវធ្លាក់ក្នុងសភាពរងដំបងការពារខ្លួន ស្លុតស្លាញ វិណ្ឌកទាំងខាងយោធា ទាំងខាងនយោបាយ ទាំងខាងសេដ្ឋកិច្ច ។ ម្លោះហើយវាគិតតែបង្កើននយោបាយហ្វាស៊ីសសភាវូបនីយកម្មដល់កម្រិតខ្ពស់បំផុតដោយផុតបំផ្លាញខ្ទេច ចាប់ខ្ទេច សម្លាប់ខ្ទេចដោយឥតរើសមុខឬជំនុំជម្រះឡើយ ។

នៅទីក្រុងភ្នំពេញ ក៏ខ្មាំងធ្វើការរាតត្បាតទាំងយប់ទាំងថ្ងៃដោយទ្រង់ទ្រាយធំសម្បើម ។ តែទោះជាសភាពការណ៍ទីក្រុងភ្នំពេញមានការតឹងតែងចង្អៀតចង្អល់យ៉ាងនេះក៏ដោយ ទោះជាគ្រោះថ្នាក់ដល់អាយុជីវិតតាមប្រកិតជាប់ទាំងយប់ទាំងថ្ងៃ យ៉ាងណាក៏ដោយ ក៏មិត្ត ដាំ ផេង និងមិត្តផ្សេងទៀតទាំងអស់ដែលមានភារៈធ្វើការនៅទីក្រុងភ្នំពេញនៅតែពុះពារគ្រប់ឧបសគ្គប្រយុទ្ធបំពេញភារកិច្ចដែលអង្គការប្រគល់ឲ្យបានជាប់ជានិច្ច ។ នៅខែសីហា ឆ្នាំ១៩៦៨ ក្នុងពេលដែលកំពុងតែបំពេញភារកិច្ចដ៏រុងរឿងរបស់ខ្លួននៅទីក្រុងភ្នំពេញ មិត្ត ដាំ ផេង ត្រូវខ្មាំងចាប់បាន ។ ពួកអាក្បត់ខ្ញុំកញ្ជះដាច់ថ្លៃ របស់ចក្រពត្តិអាមេរិក វាគ្មានសង្ស័យអ្វីឡើយព្រោះវាធ្លាប់ស្គាល់មុខ ស្គាល់ឈ្មោះ និងស្គាល់ប្រវត្តិ តស៊ូរបស់យុវជន ដាំ ផេង កាលនៅជាសិស្សវិទ្យាល័យយុគន្ធរច្បាស់លាស់ណាស់ហើយ ។ វាគ្មានចាំបាច់សួរបញ្ជាក់អ្វីទៀតទេ តែវាត្រូវការចង់ដឹង និងចង់កម្ទេចខ្សែដឹកនាំខាងលើទៀត ។ ដូច្នោះវាចាប់យកមិត្តដាំ ផេង ទៅធ្វើទារុណកម្មលើរូបរាងកាយ និងលើផ្លូវចិត្តយ៉ាងសែនឃោរឃៅព្រៃផ្សៃអស្ចារ្យដើម្បីជំរិតយកចម្លើយសំខាន់ៗពីមិត្ត ។

នៅចំពោះមុខទារុណកម្មព្រៃផ្សៃគ្រប់បែបយ៉ាងរបស់ខ្មាំង មិត្តគ្មានភិតភ័យ គ្មានតក់ស្លុតបន្តិចសោះឡើយ ។ មិត្តគិតថា "ជីវិតបដិវត្តន៍របស់មិត្តត្រូវចប់ត្រឹមនេះហើយ" តែយុទ្ធមិត្តឯទៀតនឹងបន្តលើកជ្រោងទង់ប្រយុទ្ធកម្ទេចខ្មាំងជាបន្តទៀតរហូតដល់ជ័យជម្នះទីអវសាន្ត ដូច្នោះត្រូវតែស្លាប់ក្នុងឋានៈជាជនបដិវត្តន៍ ជាយុវជនស្នេហាជាតិ ។ ពោលគឺស្លាប់ក្នុងកិត្តិយសរុងរឿងខត្តុង្គឧត្តម ។ដាច់ខាតមិត្តមិនស្លាប់ក្នុងឋានៈជាជនក្បត់ជាតិ ជាជនកំសាកសារភាពខ្មាំងក្បត់បងប្អូនរួមវណ្ណៈឯងឡើយ ។ មិត្តប្តេជ្ញានឹងប្រយុទ្ធជាមួយខ្មាំងរហូតដល់ដង្ហើមចុងក្រោយបំផុត គិតដូច្នោះហើយមិត្តរក្សាជំហរ និងអាកប្បកិរិយា នឹងនរតែមោះមុតក្នុងឋានៈជាអ្នកវាយសម្រុកខ្មាំងវិញលើគ្រប់បញ្ហា ។ ហើយមិត្តពើងទ្រូងដើរចូលទៅក្នុងកន្លែងធ្វើទារុណកម្មយ៉ាងអង់អាចក្លាហាន ។ ភ្នែកទាំងគូរបស់មិត្តសម្លក់សម្លឹងពួកអាពេជ្ឈឃាតដែលរស់នៅវេចាំក្នុងទីនោះស្ទើរធ្លុះដល់ឆ្អឹងដោយក្តីស្អប់ខ្ពើមជាទីបំផុត ។

ពេលខ្មាំងចាប់ផ្តើមសួរចម្លើយជាលើកដំបូងមិត្តឆ្លើយតបទៅវិញដោយភ្លើងកំហឹងពុះពោរពេញឱរ៉ាថា "ពួកអាឯងជាជនក្បត់ជាតិ ជាឆ្កែបម្រើដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក ពួកអញជាអ្នកស្នេហាជាតិ ជាអ្នកការពារប្រទេសជាតិ ជាអ្នកសង្គ្រោះជាតិ និងរំដោះប្រជាជនឲ្យរួចផុតពីអំពើជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាមេរិក-បរិវារ និងឲ្យរួចផុតពីការជិះជាន់សង្កត់សង្កិនរបស់ពួកអាវណ្ណៈកាន់អំណាចប្រតិកិរិយាក្បត់ជាតិឯងរាល់គ្នា! នេះជាព្រំដែនយ៉ាងច្បាស់លាស់រវាងពួកអាឯង និងពួកអញ! ដូច្នេះអញគ្មានពាក្យអី និយាយថា ជាមួយពួកអាឯងរាល់គ្នាទេ! ចង់ធ្វើអ្វីធ្វើទៅ មិនបាច់សួរអញទេ!" ថាហើយមិត្តស្តោះទឹកមាត់រួចងាកមុខចេញធ្វើវាហីលែងនិយាយឆ្លើយឆ្លងនឹងវារហូត ។ ខ្មាំងចាប់ផ្តើមធ្វើទារុណកម្មយ៉ាងព្រៃផ្សៃលើរូបរាងកាយមិត្តទាំងយប់ទាំងថ្ងៃ ជាប់បីយប់ បីថ្ងៃ ។ មិត្តខាំមាត់ អត់គ្មានស្រែកថ្ងូរមួយម៉ឺុសទេ ។ ក្នុងមួយថ្ងៃៗ មិត្តត្រូវវាយដំច្រំធាក់បញ្ច្រុកទឹក សាប៊ូ ទឹកត្រី សន្លប់បាត់ស្មារតីរាប់មិនអស់ទេ ។ តែឲ្យតែដឹងខ្លួនពេលណា មិត្តតែងតែវែកញែកបកអាក្រាតនិងប្រកាសកាត់ទោសខ្ញុំក្រិដ្ឋទៅលើខបាយកលនិងសកម្មភាពជ្រៀតជ្រែកឈ្លានពានបំផ្លិចបំផ្លាញប៉ុនប៉ងសម្លាប់កម្ពុជាឯករាជ្យ សន្តិភាព អព្យាក្រឹតរបស់ចក្រពត្តិអាមេរិក-បរិវារ និងប្រកាសទោសពួក អាក្បត់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកមិញ និង អ៊ិន តាំ ដែលបម្រើចក្រពត្តិអាមេរិកក្នុងការបំផ្លិចបំផ្លាញ និងសម្លាប់ប្រទេសជាតិ និងប្រជាជនឯងជានិច្ច ។ មិត្តស្វាត់មាត់តែពេលសន្លប់បាត់ស្មារតីប៉ុណ្ណោះ ។ ខ្មាំងទ័លចំណេះ ព្រោះវាធ្វើទារុណកម្មសព្វគ្រប់បែបយ៉ាងអស់ហើយ នៅតែយកការណ៍អ្វីពីមិត្តមិនបានសោះ ។ ដូច្នោះវាដូរវិធីត្រជាក់មួងវិញ ។ វាលួងលោមបញ្ចុកបញ្ចុះគ្រប់បែបយ៉ាង វាយកស្រីញីមកទាក់ទាញទឹកចិត្ត វាសន្យាឲ្យបុណ្យសក្តិសន្យាឲ្យទៅបន្តវិជ្ជានៅបរទេសទៀត មានប្រទេសបារាំង និងសហរដ្ឋអាមេរិកជាដើម ឲ្យតែមិត្តសុខចិត្តប្រាប់ឈ្មោះប្រាប់កន្លែង និងប្រាប់ខ្សែអ្នកដឹកនាំដល់វា ។ តែនៅចំពោះមុខឧបាយកលដ៏ផ្អែមល្ហែមរបស់ខ្មាំងទាំងអស់ មិត្តបានវែកញែកបកអាក្រាត និងវាយសម្រុកទៅខ្មាំងវិញយ៉ាងអង់អាចនិងឈ្លាសវៃបំផុតធ្វើឲ្យខ្មាំងទ័លប្រាជ្ញសុញគំនិតញីកញាប់ ។

ខ្មាំងប្រើល្បិចកលក្តៅ ត្រជាក់ សព្វគ្រប់អស់ហើយនៅតែមិនបានការទៀត វាក៏ចាប់ប្រើធម៌ក្តៅផ្តាច់ព្រ័ត្រតែម្តង ។ តាំងពីចាប់យកទៅខ្មាំងមិនហ៊ានដាក់ មិត្ត ដាំ ផេង ជុំជាមួយគេឯងទេ វាដាក់ឃុំឃាំងមិត្តនៅក្នុងបន្ទប់ងងឹតតូចមួយដាច់ឆ្ងាយពីគេឯងជានិច្ច ។ ក្នុងប៉ុន្មានថ្ងៃនេះ ខ្លួនប្រាណមិត្តនៅតែរឹងចចេសជាងដែកថែបទៅទៀត ។ ពេលខ្មាំងបញ្ចេញមិត្តពីបន្ទប់ងងឹតយកទៅកន្លែងធ្វើទារុណកម្មសួរចម្លើយរាល់ដង មិត្តត្រូវបានដើរការត់មុខបន្ទប់ឃុំឃាំងដទៃទៀត ។ យុទ្ធមិត្តឯទៀតដែលបានដឹងព្រឹត្តិការណ៍របស់មិត្តហើយមានការព្រួយបារម្ភចំពោះអាយុជីវិតរបស់មិត្ត បាននាំគ្នារត់ស្រមកអើតមើលមិត្ត ។ មិត្ត ដាំ ផេង ស្ទើរលើកជើងដើរមិនរួចណាវាហត់ហេវឈឺចុកចាប់ពេញទាំងខ្លួនប្រាណ ណាវាធ្ងន់នឹងច្រវ៉ាក់ដែកដែលខ្មាំងចងជាប់នៅជើង និងដៃទាំងពីរ ។ តែនៅពេលដែលមិត្តក្រឡេកឃើញមុខ និងភ្នែកច្រើនគូរបស់យុទ្ធមិត្តដទៃដែលត្រូវខ្មាំងចាប់មកពីតំបន់នានាទូទាំងប្រទេសសម្លឹងមើលមិត្ត ដោយក្តីព្រួយបារម្ភនិងដោយមនោសញ្ចេតនាបដិវត្តន៍កក់ក្តៅបំផុត មិត្តមានកម្លាំងព្រឹសឡើងវិញ ភ្លេចអស់នូវការឈឺចុកចាប់ក្នុងខ្លួន ។ មិត្តយើងលើកដៃទាំងគូដែលជាប់ច្រវ៉ាក់ឡើងលើ ហើយស្រែកយ៉ាងខ្លាំងៗថា "ជយោ! បដិវត្តន៍កម្ពុជាដ៏រុងរឿង! ជយោ! ប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន! បដិវត្តន៍កម្ពុជាពិតជាឈ្នះ! បរាជ័យ!

ចក្រពត្តិអាមេរិក-បរិវាររនិងពួកអាឆ្កែបម្រើវា! » ពេលនោះ សម្រែកជ័យឃោស និងសម្រែកបដិសេធចក្រពិត្តអាមេរិកបរិវារ បានលាន់ឮកងរំពងចេញពីគ្រប់បន្ទប់ឃុំឃាំងទាំងអស់ ។ រួចហើយ មិត្តខំផាកមកញញឹមដាក់យុទ្ធជនមិត្តឯទៀតដើម្បីលើទឹកចិត្តកុំឲ្យព្រួយបារម្ភអីចំពោះរូបមិត្តហើយឲ្យបន្តការប្រយុទ្ធដាច់ខាតជាមួយខ្មាំងទៀត ។

យប់មួយ បន្ទាប់ពីត្រូវខ្មាំងធ្វើទារុណកម្មយ៉ាងសាហាវគ្រប់បែបយ៉ាងមកមិត្តដាំ ដេង សន្លប់បាត់ស្មារតី ។ ខ្មាំងវាអូសមិត្តមកបោះចោលនៅក្នុងបន្ទប់ងងឹតវិញ ។ ពេលភ្ញាក់ខ្លួនពីសន្លប់ មិត្តក្អួតធ្លាក់ឈាមទាំងដុំៗ ។ មិត្តដឹងខ្លួនថាមិនរស់ទេ មិត្តខំប្រវេប្រវា ប្រគោងជញ្ជាំងសរសេរចារិកលើថ្មដោយឈាមស្រស់របស់មិត្តនូវកំណាព្យមួយដែលមានន័យតទៅៈ

«បេះដូងក្រហម ខ្ញុំថ្នាក់ខ្ញុំថ្នម លត់ដំរាល់ថ្ងៃ
ទុកជូនបដិវត្តន៍ ដ៏មានតម្លៃ ជូនអ្នកក្រក្រី
វណ្ណៈអធន ។
ពេលនេះហើយណា ជនកម្ពុជា ត្រូវការទាន់ហន់
យកបេះដូងខ្ញុំ ទៅដោះទុក្ខធ្ងន់ បុត្រប្រជាជន
រីករាយបូជា»

ដើម្បីសម្តែងនូវមនោសញ្ចេតនាដ៏ល្អបរិសុទ្ធ និងជ្រាលជ្រៅរបស់មិត្តចំពោះអង្គការវបដិវត្តន៍ប្រជាជន និងវណ្ណៈក្រីក្រដែលមិត្តគោរពបម្រើស្មោះត្រង់ និងស្រឡាញ់លើសអាយុជីវិតរបស់មិត្តទៅទៀត ។

ព្រឹកស្អែកឡើង មិត្ត ដាំ ដេង បានពលីជីវិតដ៏ក្មេងខ្ចីនៅក្នុងបន្ទប់ងងឹតយ៉ាងរុងរឿងឧត្តុង្គឧត្តមអស្ចារ្យដើម្បីបុព្វហេតុការពារប្រទេសជាតិ និងរំដោះប្រជាជនពិសេសប្រជាជនក្រីក្រឲ្យចាកផុតពីស្នាកខ្ញុំកញ្ជះបរទេស និងចាកផុតពីទុក្ខវេទនាសព្វបែបយ៉ាង ។

ខ្មាំងអាចវាយប្រំផាក់លើរូបរាងកាយមិត្តបានអាចវាយបែកសាច់ហូរឈាមបាក់ឆ្អឹងឆ្អែងខ្ទេចខ្ទាំអស់រហូតដល់ផ្តាច់ផ្តិលអាយុជីវិតមិត្តទៀតបាន ។ តែខ្មាំងពុំអាចវាយបំបាក់ឬធ្វើឲ្យរង្គោះរង្គើឲ្យឆន្ទៈប្រយុទ្ធដាច់ខាតរបស់មិត្តដាំ ដេង បានឡើយ ។ នៅចំពោះមុខគោលជំហរប្រយុទ្ធដាច់ខាតរបស់មិត្តយ៉ាងនេះ ខ្មាំងទោះមានគ្រឿងសព្វាវុធទំនើបមានមធ្យោបាយ និងឧបករណ៍ឃោរឃៅហួសហេតុច្រើនយ៉ាងណាក៏ត្រូវតែចាញ់ ។ រីឯមិត្តដាំ ដេង គឺឈ្នះ! មិត្តស្លាប់ក្នុងឋានៈជាអ្នកវាយសម្រុក ជាអ្នកឈ្នះ ហើយឈ្នះជារៀងរហូតទៅ! យុទ្ធមិត្តឯទៀត រាប់ម៉ឺន រាប់សែន រាប់លាននាក់ដែលនៅឯក្រោយ បានបេ្តជ្ញាលើកជ្រោងទង់ប្រយុទ្ធនេះតាមគន្លងដ៏ល្អប្រពៃរបស់មិត្តប្រយុទ្ធវាយសម្រុកកម្ទេចខ្មាំងរហូតដល់បានរំដោះទឹកដីកម្ពុជាជាទីស្នេហាទាំងស្រុងនិងជាស្ថាពរ ។ នេះជាមហាជ័យជម្នះរបស់បដិវត្តន៍ និងប្រជាជនកម្ពុជាយើងតែក៏ជាមហាជ័យជម្នះរបស់វិញ្ញាណក្ខន្ធមិត្តដាំ ដេង និងយុទ្ធជនកម្មាភិបាល យើងឯទៀតទាំងអស់ដែលបានពលីជីវិតនៅលើសមរភូមិប្រយុទ្ធនឹងខ្មាំងនៅគ្រប់ទិសទី ។

ជីវិតរបស់ មិត្ត ដាំ ដេង គឺជាជីវិតតស៊ូ តស៊ូរហូតដល់ដង្ហើមចុងក្រោយបំផុត ដោយឈរលើគោលជំហរដាច់ខាតប្រយុទ្ធគ្មានខ្លាចលំបាក គ្មានខ្លាចស្លាប់ និងជំហរវាយសម្រុកខ្មាំងជាប់ជានិច្ចទោះត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មាំងហើយក៏ដោយ ។ នេះជាគោលជំហររបស់ជនបដិវត្តន៍ដែលរស់នៅថ្លៃថ្លា ហើយស្លាប់ទៅក៏អស្ចារ្យរុងរឿង ឧត្តុង្គឧត្តមបំផុត ។

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*

# ស៊ីវ ធួនៈ ដំណើរឆ្លងកាត់របបខ្មែរក្រហម



ស៊ីវ ធួន

**(តពីលេខមុន)**

***លោកកុហកថាត្រឡប់ទៅស្រុក***

*នៅរដូវប្រាំងឆ្នាំ១៩៧៧ អង្គការបានដើរប្រមូលជនជាតិវៀតណាមដែលនៅសេសសល់ឲ្យមកប្រជុំនៅមុខរោងសេដ្ឋកិច្ច ដោយប្រកាសប្រាប់ថា អង្គការនឹងបញ្ជូនត្រឡប់ទៅស្រុកកំណើតវិញ ។ នៅពេលនោះ ដោយសារគាំទ្រនឹងការលត់ដំមិនបានខ្មែរកម្ពុជាក្រោមមួយចំនួនបានចុះឈ្មោះថាជនជាតិយួនដើម្បីបានត្រឡប់ទៅជួបបងប្អូនវិញ ។ ថ្ងៃមួយ ពេលខ្ញុំកំពុងយួរស៊ីម៉ងត៍ចាក់គ្រឹះស្ពាននៅខាងលិចភូមិរោក ស្រាប់តែខ្ញុំឮស្នូរសម្លេង “ភូស១” គឺជាសម្លេងវាយសម្លាប់អ្នកទោសខ្មែរកម្ពុជាក្រោមទាំងនោះនៅក្នុងព្រៃដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីកន្លែងខ្ញុំធ្វើការ ។ ក្រោយពីដឹងរឿងនេះភ្លាម ខ្ញុំមានការតក់ស្លុត និងភ័យខ្លាចយ៉ាងខ្លាំងស្ទើរតែគ្មានកម្លាំងដើម្បីធ្វើការងារបន្តទៀត ។ ព្រឹកឡើង ខ្ញុំឃើញឈ្លបខ្មែរក្រហមក្មេងៗដើរទៅឆែកបង្ខេចជនរងគ្រោះយកសារុងសូត្រ នាឡិកា មាស និងត្បូង មកចែកគ្នាដោយសើចក្អាកក្អាយ ។*

*នៅថ្ងៃបុណ្យ១៧មេសា ជិតចូលមកដល់ គណៈឃុំព្រះនេត្រព្រះ ឈ្មោះតាក្រក, ប្រធានយោធាឃុំឈ្មោះ សន អាយុប្រហែល៤០ឆ្នាំ និងគណៈស្រុកព្រះនេត្រព្រះឈ្មោះ ម៉ោង ប្រកាសប្រាប់ប្រជាជនឲ្យមកជុំស្តាប់មីទ្ទីងនៅវត្តព្រះនេត្រព្រះដោយនិយាយថា អង្គការនឹងអនុញ្ញាតឲ្យអ្នកជម្លៀសមកទីនេះទាំងអស់ត្រឡប់ទៅស្រុកកំណើតវិញ ។ ឮដំណឹងនេះភ្លាម ប្រជាជនដែលរស់នៅក្នុងសហករណ៍ប៉ោយក្បឿង ប៉ោយតាប៉ែន ប៉ោយសំរោង ប៊ុស្តិ៍ចាស់ត្រពាំងកក់ ត្រពាំងវែង ជើងវត្ត ភូមិកណ្តាល ចក្រី ដកពរ សប្បាយចិត្តយ៉ាងខ្លាំង អ្នកខ្លះបានហៅបងប្អូនដែលនៅសហករណ៍ផ្សេងឲ្យមកប្រជុំដែរ ។ ម្នាក់ៗដេកមិនលក់ ហើយបន់ស្រន់ឲ្យថ្ងៃប្រជុំមកដល់ឆាប់ដើម្បីបានស្តាប់ដំណឹងអំពីការវិលត្រឡប់ទៅស្រុក ។ ពេលនោះគេនឹងបានរួចទុក្ខទោសពីកម្ម នរក អវចី ដោយសារការសណ្តោសរបស់អង្គការ ប្រទេសយើងនឹងវិលត្រឡប់ទៅរករបបសង្គមចាស់មិនខាន ។ យើងនៅតែនឹកឃើញរបបសង្គមរាស្ត្រនិយមដែលពេលនោះប្រទេសយើងសម្បូរសប្បាយពុំមានខ្វល់អ្វីឡើយ ។ នេះគឺជាការស្រម៉ៃនៃប្រជាជន ១៧ មេសា ។*

***វត្តព្រះនេត្រព្រះកន្លែងកាត់ទោសមនុស្ស***

*វេលាម៉ោង១០ព្រឹក មានប្រជាជនប្រមាណ៣០០នាក់បានមកអង្គុយផ្ទាល់ដីក្នុងបរិវេណវត្តព្រះនេត្រព្រះ ដោយនៅជួរខាងមុខមានយាយៗ និងតាៗអង្គុយពាសពេញ ព្រោះចង់ស្តាប់ឲ្យច្បាស់ពីដំណឹងនេះ ។ នៅពេលចាប់ផ្តើមកម្មវិធី មិត្ត សន បាននិយាយគោរពពុកម៉ែ និងនិយាយពីវិន័យរបស់អង្គការចំពោះខ្មាំងដែលប្រព្រឹត្តខុសពីសីលធម៌បដិវត្តន៍ បន្ទាប់មកមិត្ត សន បានស្រែកសួរទៅអង្គប្រជុំថា បើមានខ្មាំងក្បត់បដិវត្តន៍ តើបងប្អូនបេ្តជ្ញាកម្ទេចខ្មាំងដែរឬទេ? ហើយគាត់ក៏ហៅមនុស្សពីរ បីនាក់ ក្នុងអង្គប្រជុំមកបេ្តជ្ញាកម្ទេចខ្មាំងរបស់អង្គការ ។ ស្រែកបេ្តជ្ញាចប់ កងឈ្លបចំនួនប្រាំនាក់បានចងស្លាបសេកមនុស្សប្រុស ស្រីពីរនាក់បណ្តើរចូលមកខាងមុខអង្គប្រជុំ ។ ភ្លាមនោះមិត្ត សន ក៏ស្ទុះយកចបជីកវាយចំក្បាលបុរសនោះបណ្តាលឲ្យ*

ដួលផ្កាប់មុខទៅដី រួចហើយក៏វាយស្ត្រីដែលមានផ្ទៃពោះនោះទៀត ។ អ្នកទាំងពីររស់នៅក្នុងភូមិស្រមោចស្ថិតនៅចម្ងាយប្រមាណបួនគីឡូម៉ែត្រពីភូមិស្រែះ ដែលជាខណ្ឌបែងចែកព្រំប្រទល់រវាងតំបន់៥ និងតំបន់៣ បុរសនោះជាអ្នកមូលដ្ឋាន និងជាប្រធានកងភួរនៅជិតភ្នំកូនដំរី ឬកូនថ្មី ចំណែកនារីជាប្រជាជនថ្មី បានលួចស្រលាញ់គ្នារហូតមានផ្ទៃពោះ ។ បន្ទាប់ពីឃើញហេតុការណ៍នោះភ្លាម ប្រជាជនទាំងអស់ភិតភ័យយ៉ាងខ្លាំង រួចហើយក៏នាំគ្នារត់បែកខ្ញែកត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ ។

## សហករណ៍មរណៈ

នៅឆ្នាំ១៩៧៧ ប្រជាជនថ្មីដែលរស់នៅក្នុងសហករណ៍ស្ពានស្រែង ជាប់មាត់ស្ទឹងក្រឡាញ់ ចាប់ផ្តើមស្លាប់ក្នុងមួយថ្ងៃៗប្រមាណពី៨-១០នាក់ ដោយសារអត់អាហារ និងជំងឺ ។ ឃើញដូច្នេះ ខ្មែរក្រហមបានចាត់តាំងអ្នកដែលនៅរស់ឲ្យចាំប្រមូលសាកសពទាំងនោះយកទៅកប់ចោល ។ នៅថ្ងៃខ្លះ ដោយសារសាកសពនៅតាមផ្ទះមានចំនួនតិច (ពីរ-បីនាក់) ទើបអ្នកដើរប្រមូលរង់ចាំរហូតដល់ពេលថ្ងៃត្រង់ដើម្បីឲ្យបានសាកសពច្រើនទៀត ។ អ្នកកប់ខ្មោចដែលមានកម្លាំងខ្សោយមិនបានជីករណ្តៅជ្រៅទេបណ្តាលឲ្យឆ្កែទៅកកាយធំក្លិនស្អុយអសោចពេញភូមិ ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ពេលខ្ញុំវែកដីចាក់បំពេញទំនប់ដែលភ្លៀងហូរច្រោះ ខ្ញុំឃើញខ្មែរក្រហមបណ្តើរអ្នកទោសពីសហករណ៍ស្ពានស្រែដើរតាមទំនប់ទើបនឹងលើកថ្មីឈ្មោះ អាយក្សរ ដែលមានស្នាមសាក់ពេញខ្លួន ត្រូវឈ្លបនាំយកទៅសម្លាប់នៅគល់ស្ពានធំដោយអង្គការចោទប្រកាន់ថា គ្រូសិល្ប៍ ហើយបានសម្លាប់ប្រពន្ធ និងក្លួយខ្លួនឯងស៊ី ។ ពួកនៅសហករណ៍ស្ពានស្រែងបានដំណាលថា ដោយសារការអត់ឃ្លានធំធេងពេក បុរសម្នាក់បានស៊ីក្មួយស្រីខាងប្រពន្ធ ។ ក្មួយនោះ គឺជាកូនកំព្រាម្តាយឪពុក រស់នៅជាមួយម្តាយ មីង (ប្រពន្ធអាយក្សរ) ។

ថ្ងៃមួយអង្គការបានចាត់តាំងក្មេងស្រីនោះឲ្យទៅមុខព្រួញឆ្ងាយអស់រយៈពេលជាងមួយឆ្នាំ ។ ដោយសារសេចក្តីនឹករឭកមកម្តាយមីង ក្មេងស្រីនោះក៏មកលេង ប៉ុន្តែមិនបានជួបម្តាយមីង ព្រោះគាត់ត្រូវទៅមុខព្រួញនៅឆ្ងាយពីភូមិដែរ ជួបតែពូថ្លៃ (យក្សរ) ប៉ុណ្ណោះ ។ ចាប់តាំងពីថ្ងៃនោះមក ក្មេងស្រីនោះក៏បាត់ខ្លួនមិនឃើញត្រឡប់ទៅមុខព្រួញវិញ ។ អស់រយៈពេលជាច្រើនខែ ម្តាយមីងក៏ត្រឡប់មកផ្ទះដេកនៅជាមួយប្តី ស្រាប់តែនឹកភ្នកថា ខ្ញុំដូចជានឹកក្មួយហើយវាទៅណាមិនដែលឃើញមកលេងផ្ទះ ។ ពេលនោះ ប្តីក៏នៅស្ងៀមមិនឆ្លើយ ។

ថ្ងៃមួយស្រាប់តែគេឮសម្លេងឆ្កែខាំគ្នានៅក្រោមផ្ទះបុរសនោះ ហើយថែមទាំងធំក្លិនស្អាបឈាម ទ្រាំមិនបានប្រធានភូមិក៏ចាត់ឲ្យគេរត់ទៅមើលស្រាប់តែឃើញឈាមហូរតត់ៗចេញពីរនាបផ្ទះ ។ ឃើញដូច្នេះកងឈ្លប ក៏ស្ទុះរត់ទៅផ្ទះប្រធានភូមិវិញទាំងត្រហេបត្រហប ។ ពេលនោះប្រធានភូមិ ក៏ឆ្ងល់ ហើយឆោឡោរត់មកមើលស្រាប់តែឃើញទ្វារបិទជិតក៏នាំគ្នាគោះទ្វារ ប៉ុន្តែដោយពុំមានអ្នកបើកទ្វារឲ្យ ក៏នាំគ្នាធាក់ទម្លុះចូលទៅ ។ ភ្លាមនោះ ស្រាប់តែឃើញបុរសនោះកំពុងអង្គុយមុខឆ្នាំងស៊ុបមួយដែលមានទឹកកំពុងពុះហុយទ្រលោម ។ នៅក្នុងឆ្នាំងនោះគេឃើញមានក្បាលមនុស្ស និងគ្រឿងក្នុងមានថ្លើម និងពោះវៀន ចំណែកឯឆ្អឹងជំនី សាច់ និងដៃជើងគេចងព្យួរនៅតាមជញ្ជាំង ។ ឃើញដូច្នេះ ម្នាក់ៗមានការតក់ស្លុត និងភ្ញាក់ផ្អើលជាខ្លាំង ក៏ចាប់បុរសនោះចងស្លាបសេក រួចបណ្តើរចុះមកដី ហើយត្រូវគេវាយទាត់ធាក់យ៉ាងខ្លាំង ជាំពេញខ្លួន ។ ប៉ុន្តែបុរសនោះពុំមានការតក់ស្លុតបន្តិចឡើយ ហើយគាត់សារភាពថា បានកាប់ប្រពន្ធ និងក្មួយស៊ី ព្រោះថាសាច់មនុស្សឆ្ងាញ់ ។ ឈ្លបបានចាប់ចង និងបណ្តើរមនុស្សកំណាចនេះចេញពីភូមិមកដល់ទំនប់នៅម៉ោងប្រហែល១០កន្លះ ឃើញដូច្នេះ កងចល័តក៏ផ្អាកសកម្មភាពឈប់វែកដី រួចនាំគ្នារត់ទៅមើល ។ លុះដឹងហេតុការណ៍ហើយ ក៏នាំគ្នាវាយបុរសម្នាក់នោះនឹងដងវែក អ្នកខ្លះទៀតក៏ទះកំផ្លៀង ។ បុរសនោះត្រូវឈ្លបបណ្តើរទៅសម្លាប់នៅស្ពានធំ ។

## កងតា វ៉ន

រដូវវស្សា ឆ្នាំ១៩៧៦ ខ្ញុំនៅក្នុងកង តាវ៉ន មានគ្នា១៧នាក់ ។ កងខ្ញុំត្រូវអង្គការដកទុកឲ្យនៅប្រចាំការដើម្បីជួសជុលទំនប់ដែលមានប្រវែងប្រហែលដប់គីឡូម៉ែត ។ ចំពោះរបបហូបក៏សមល្មមដែរ គឺមួយពេលបាយបីវែក ។ ចំណែកម្ហូបនៅទីនោះក៏មិនសូវខ្វះខាតដែរ គឺគ្រាន់តែយើងដើររកតាមប្រឡាយក្បែរទំនប់ក៏មិនខ្វះត្រីក្តាម និងខ្យងដែរ ។ យើងនៅឆាយពីសហករណ៍ អាចឆ្លៀតរកម្ហូបបានដោយសារមិនមានប្រជាជនតាមដាន និងរាយការណ៍ ។ ចំណែក

កន្លែងសម្រាកវិញ យើងស្នាក់នៅផ្ទះតូចមួយនៅក្បែរជើងទំនប់ ។ ផ្ទះនោះសង់អំពីឈើ ដំបូលប្រក់ស្បៀង ប៉ុន្តែមាន ជញ្ជាំងក្តារតែមួយចំហៀង ដូចជាសាលាដំណាក់មួយនៅលើកំណាត់ដីស្ងាត់ដែលជាជម្រកដ៏តូចចង្អៀតសម្រាប់ពួកយើង ។

នៅទីនោះ យើងពុំសូវមានការងារធ្វើច្រើនប៉ុន្មានទេ គឺយើងធ្វើផងសម្រាកផង ។ បើសិនមានកន្លែងណាមានទឹកហូរជ្រោះជើងទេរទំនប់ ឬក៏មានក្រឡុកទឹកដក់លើខ្នងទំនប់ យើងត្រូវរែកដីចាក់បំពេញ ។ កន្លែងណាដែលជ្រោះខ្លាំងយើងត្រូវធ្វើការរហូតដល់បីទៅបួនថ្ងៃក៏សឹងមាន ។ ប្រធានកងតូចឈ្មោះ តាវ៉ន គាត់ជាមនុស្សចិត្តល្អ មានការសន្តោសប្រណីច្រើន គាត់តែងតែឲ្យច្បាប់ដល់មិត្តយើងណាដែលមានជំងឺឲ្យឈប់សម្រាក ឬដល់អ្នកដែលនឹករឭកបងប្អូនចង់ទៅសួរសុកទុក្ខនៅតាមសហករណ៍ ហើយជួនកាលទៀតឲ្យច្បាប់ទៅអ្នកដែលស្ម័គ្រស្វែងតាមរកដំណឹងគ្រួសារដែលបែកគ្នា ។ តាវ៉ន ចិត្តល្អ សម្រាប់តែអ្នកនិយាយត្រង់ គាត់មិនចូលចិត្តអ្នកកុហក គាត់ជាអ្នកមូលដ្ឋានមានដើមកំណើតនៅភូមិកំបោរ ស្ថិតនៅតាមដងស្ទឹងកំបោរ ដែលហូរចាក់ទៅស្ទឹងមង្គលបុរីប៉ែកខាងក្រោម ។

## អង្គការភ្នែកម្នាស់

នៅក្នុងអារម្មណ៍ ខ្ញុំបានចាត់ថា មនុស្ស១៧នាក់នេះ ជាអ្នកចេះជួយរក្សាជីវិត និងដឹងសុខទុក្ខគ្នាយ៉ាងល្អបំផុត ព្រោះមិនចេះស្អប់គ្នារាយការណ៍ពីគ្នា ដោយគេយល់ថា ការបែកបាក់គ្នានេះហើយ គឺជាការចូលដៃជើងជាមួយខ្មែរក្រហមនាំឲ្យយើងជាអ្នក១៧មេសារងទុក្ខវេទនា ជាពិសេសនៅតាមសហករណ៍ ដូច្នេះយើងត្រូវចេះស្រឡាញ់គ្នា ។ មនុស្សដែលខ្ញុំស្រឡាញ់ចូលចិត្ត គឺមិត្ត ថន និង លឹម សព្វថ្ងៃនេះ មិត្តទាំងពីរនាក់នៅរស់ទាំងអស់ ហើយខ្ញុំជឿថា មិត្តដទៃទៀតនឹងរួចជីវិតដូចគ្នាដែរ ពិតមែនតែយើងមិនដែលជួបគ្នាក៏ដោយ ។

នៅសម័យ ប៉ុល ពតគេប្រើពាក្យស្លោកថាអង្គការភ្នែកម្នាស់ នេះគឺជាការបន្លាចមិនឲ្យយើងហ៊ានធ្វើអ្វីដែលក្បត់ និងវិន័យរបស់ខ្មែរក្រហម ។ តាមការពិតអ្វីដែលខ្មែរក្រហមដឹងបណ្តាលមកពីមានអ្នករាយការណ៍ បើពុំដូច្នោះទេ ការងារអ្វីមិនអាចខូចខាតឡើយ ពីព្រោះកម្មាភិបាលខ្មែរក្រហមមិនមែនមានភ្នែកទិព្វ ត្រចៀកទិព្វ នោះទេគឺអាស្រ័យលើការចេះរក្សាការសម្ងាត់ផ្ទាល់ខ្លួនម្នាក់ៗ ។

ជួនកាល ការរាយការណ៍ច្រើនតែមិនមានការពិត គឺច្រើនតែមួលបង្កាច់គ្នាធ្វើឲ្យជីវិតមនុស្សផុយស្រួយដូចជីវិតសត្វមាន់ ។ មានមនុស្សជាច្រើនត្រូវស្លាប់ដោយសារតែទឹកមាត់ដ៏ស្អុយរបស់អ្នករាយការណ៍អាក្រក់ដោយមិនចេះអាណិតអាសូរដល់ជីវិតខ្មែរដូចគ្នា ។ នៅតាមទំនប់ ប្រឡាយ ឬនៅតាមសហករណ៍ អ្នកខ្លះត្រូវអង្គការហៅទៅរៀនសូត្រ ឬដាក់ទិសឲ្យទាំងគ្រួសារឲ្យទៅនៅភូមិថ្មី ឬទៅកាប់ពោត ឬទៅធ្វើចម្ការជាដើមសុទ្ធជាពាក្យបោកបញ្ឆោត ដើម្បីយកមនុស្សទៅសម្លាប់ចោលតែប៉ុណ្ណោះ ។

## ចាត់តាំងទាំងមិនខ្លួន

នៅរដូវទឹកស្រកឆ្នាំ១៩៧៦ ប្រហែលម៉ោង១០ព្រឹក មានកម្មាភិបាលម្នាក់មកពីអង្គភាព តាវ៉ាល់ មករើសយកកម្លាំងទៅនេសាទ ដោយឃើញខ្ញុំជាមនុស្សមាឌធំ គាត់ជ្រើសយកខ្ញុំតែម្តង ធ្វើឲ្យខ្ញុំមានការរារែកក្នុងចិត្តមិនចង់ទៅទាល់តែសោះ ព្រោះអាឡោះអាល័យមិត្តភក្តិ ម្យ៉ាងទៀត ខ្លាចអាកាសធាតុត្រជាក់មិនចង់ចុះទឹកនៅរដូវរងារ ។ ក្រៅពីខ្ញុំ អង្គការជ្រើសរើសមនុស្សចំនួនបួននាក់ទៀតក្នុងចំណោមកងចល័តតំបន់ឲ្យចុះទៅនេសាទត្រីនៅឯព្រៃរនាមដែលស្ថិតនៅតាមដងស្ទឹងក្រឡាញ់ត្រើយខាងលិច ។ ក្រុមយើងមានគ្នាប្រាំនាក់គឺមាន ខ្ញុំ, ខន, ធី, ថុល, អុល និងមិត្ត ឌុល សុទ្ធតែត្រូវដកយកពីកងខុសៗគ្នា រួមទាំងយោធាភាគ ដែលគេដកសិទ្ធិចំនួនបីនាក់ទៀត គឺ មិត្តលឿម, ចក់ និងមិត្តឌឿន ។

យើងចេញដំណើរពីភ្នំកូនដំរីពីព្រលឹម ទៅសម្រាកនៅវត្តតាប៉ុនមួយយប់ ។ ទីនោះមិនមែនជាភូមិសាស្ត្រចម្លែកទេ វាជាកន្លែងដែលខ្ញុំធ្លាប់មកធ្វើប្រព័ន្ធភ្ជួរយៈពេលខ្លីចាប់ពីភ្នំលៀបរហូតដល់តាប៉ុនទឹកដោរជាវាលស្រូវវស្សាដែលទទួលទឹកជំនន់ពីដងស្ទឹងក្រឡាញ់ ។ នៅត្រើយខាងកើត គឺជាក្រឡាញ់ កំពង់ថ្កូវក្នុងទឹកដីខេត្តសៀមរាប ដែលនៅប៉ែកខាងជើង គឺជាភ្នំទ្រង់បាត ជាមន្ទីរប្រល័យពូជសាសន៍ដ៏សាហាវបំផុត (ខ្មែរក្រហមយកមនុស្សទៅដុតធ្វើជីសម្រាប់ដាក់ស្រែ) ក្នុងសម័យខ្មែរក្រហម លើសមន្ទីស-២១ ឬគុកទួលស្លែងទៅទៀត ។ ដោយសារការហត់នឿយខ្លាំង ក្រោយពីហូបបាយល្ងាចរួច យើងក៏ដេកហាលវាលនៅវត្តតាប៉ុនមួយយប់ដោយមិនដឹងទាំងមូសខាំផង ។

## ដងស្ទឹងក្រឡាញ់

លុះស្អែកឡើង យើងត្រូវស្រូតដំណើរពីព្រលឹម ដើម្បី

សម្រេចតាមទិសដៅអង្គការកំណត់ ។ យើងដើរកាត់តាមភូមិស្ងាយល្អ សំដៅទៅទិសខាងត្បូងដោយត្រូវឆ្លងកាត់ពីភូមិមួយទៅភូមិមួយ ដែលមិនស្គាល់ឈ្មោះអស់ ស្ថិតនៅតាមដងស្ទឹងក្រឡាញ់ត្រើយខាងលិច ។ នៅពេលធ្វើដំណើរ យើងបានចោលភ្នែកមើលដំណាំដើមឈើហូបផ្លែដែលមានស្លឹកពណ៌បៃតង និងប្រជាជននៅក្នុងភូមិ ។ ទឹកដីមាត់ស្ទឹង ពិតជាមានដីរជាតិល្អ ដំណាំហូបផ្លែមានដើមខ្ពស់ៗ ចោលម្លប់ត្រឈឹងត្រឈៃគ្របលើដំបូលផ្ទះដែលមានទម្រង់ជាផ្ទះខ្មែរបុរាណសម័យខត្តុង្គបែរមុខទៅរកមាត់ស្ទឹងក្រឡាញ់ ។ នៅក្នុងភូមិមានភាពស្ងប់ស្ងាត់ យើងឃើញមានតែប្រជាជនថ្មី ចំណែកប្រជាជនចាស់មានចំនួនតិចតួចប៉ុណ្ណោះនៅតាមភូមិប៉ែកខាងលើ ។ ប្រជាជនចាស់មួយចំនួន ត្រូវខ្មែរក្រហមជម្លៀសចេញទៅកន្លែងផ្សេងអស់ហើយ ព្រោះកាលពីមុនតំបន់នោះស្ថិតនៅក្រោមការកាន់របស់ លន់ នល់ ។

នៅតាមផ្លូវយើងឃើញមានវត្តអារាម លាលារៀន និងផ្សារដែលហាក់ទើបនឹងបិទទ្វារថ្មីៗ ។ តើមានព្រះសង្ឃប៉ុន្មានអង្គត្រូវខ្មែរក្រហមផ្សឹក? សិស្សប៉ុន្មាននាក់ត្រូវចាកចោលសាលា? ទីផ្សារទៀតសោតដែលជាកន្លែងដោះដូរតវ៉ាន់ត្រូវបិទទ្វារ ព្រោះខ្មែរក្រហមបានបំបាត់ក្រដាស់ប្រាក់ ដូច្នេះប្រទេសកម្ពុជាត្រូវវិលទៅរកសម័យបុព្វកាល ដោយសារអំពើឆ្គួតលីលារបស់មេដឹកនាំខ្មែរក្រហម នៅពេលដែលមនុស្សជាតិបានឈានជើងជាន់លើឋានព្រះច័ន្ទរួចស្រេចទៅហើយ ។

ខ្ញុំគិតថា នៅតាមបណ្តោយមាត់ស្ទឹងក្រឡាញ់ដីមានជីជាតិល្អណាស់ ប្រសិនបើប្រទេសកម្ពុជា ពុំមានការប្រែក្រលាស់ទេនោះ ជីវភាពប្រជាជននៅតំបន់នេះមិនដឹងជាធូរធារយ៉ាងណាទេ ។

## អាហារថ្ងៃត្រង់

ថ្ងៃត្រង់ជាក់ទៅហើយ ពេលដែលយើងធ្វើដំណើរមកដល់មុខសាលាសង្កាត់ប្រាសាទ ស្រាប់តែឮស្នូរជួងចែកបបរ ។ ពេលនោះយើងឃើញក្មេងៗឈរដំរៀបគ្នាកាន់ចាន និងស្លាបព្រា ខ្លះទៀតកាន់កាតូរង់ខ្ញុំចាំវេនបើកបបរពាវម្នាក់មួយវែកកន្ទះ ។ លុះបើកបានហើយក្មេងៗទាំងនោះយួរបបរមកផ្ទះវិញដើម្បីលាយផ្សំនឹងបន្លែដែលម្ដាយរបស់គេបេះតាមមុខព្រួញពេលទៅធ្វើការ ឬតាមរបងផ្ទះលាយជាមួយក្តាមខ្យងដើម្បីហូបឲ្យបានតឹងពោះ ។ កុមារ និងអ្នកភូមិមានសម្លៀកបំពាក់រហែករយ៉ៃ ស្លេក ស្លាំង និងស្គមស្គាំងដូចអ្នកសុំទានដែលយើងធ្លាប់ឃើញនៅក្នុងសៀវភៅភូមិវិទ្យាភាសាបារាំងថ្នាក់ទីបីទំនើប និយាយពីទីក្រុងកាល់គុតា នៅពេលរទេះភ្លើងឈប់នៅតាមស្ថានីយ៍មួយកន្លែង ។

ភ្លាមនោះ មិត្តខន និង មិត្តឌុល បានត្អូញត្អែរថា ហេវបាយណាស់ ប៉ុន្តែយើងមិនអាចលាកញ្ចប់បាយនៅក្នុងភូមិបានទេ ព្រោះខ្លាចប្រជាជនឃើញ ។ យើងក៏ធ្វើដំណើរចេញពីទីនោះឆ្ងាយបន្តិចមកដល់ខាងត្បូងភូមិ ត្រង់ផ្លូវលំវាងពីមាត់ស្ទឹងដែលនៅដាច់ឆ្ងាយពីផ្ទះប្រជាជនទើបយើងឈប់ហូបបាយនៅក្រោមម្លប់ឈើមួយដើម ។ នៅតាមផ្លូវនោះស្ងាត់ណាស់ យើងមិនឃើញមនុស្សម្នាដើរដូចនៅសង្កាត់ប្រាសាទឡើយ ។ លើកលែងតែសម្លេងបុរសម្នាក់ស្រែក និងគោះប៉ោតដើម្បីបង្អើលហ្វូងចាបពូកប្រហែល២០ក្បាលដែលតែងតែចុះស៊ីស្រូវទុំប្រហែលពីបីអំពកប៉ុណ្ណោះ ។ គាត់ប្រហែលជាអ្នក១៧មេសា ចុងក្រោយដែលនៅសេសសល់ពីការសម្លាប់ ហើយគាត់ខិតខំស្រែកឲ្យឮខ្លាំងទៅដល់ផ្ទះប្រធានភូមិដើម្បីជាថ្នូរនឹងបបរមួយចាន ។

ពេលនោះ ថ្ងៃកំពុងតែបណ្តើរកូនព្រិចៗនៅឯនាយ ធ្វើឲ្យខ្លួនអាវរបស់យើងឡើងផ្កាអំបិល និងធំក្លិនជូរ ដោយសារបែកញើស ។ លុះបាយរួច យើងក៏ដើរចូលទៅក្នុងភូមិតាមផ្លូវក្រោយដើម្បីរកទឹកហូប រំពេចនោះយើងបានជួបដូនចាស់ម្នាក់ យើងក៏សួរគាត់ថា អ្នកម៉ែនេះជាភូមិឪម៉ាល់ឬ? គាត់ក៏ឆ្លើយថា មិនមែនទេភូមិនេះគឺ ភូមិបត់ត្រង់ ។ ចំណែកភូមិឪម៉ាល់ នៅខាងមុខហើយត្រូវធ្វើដំណើរប្រហែលបីគីឡូម៉ែត្រទៀតទើបដល់ ។ ថ្ងៃជ្រេរប្រហែលម៉ោងបី ដោយរោយជើងខ្លាំងពេក យើងក៏ឈប់សម្រាក ដើម្បីសំណេះសំណាលឲ្យបានច្រើនពីភូមិឪម៉ាល់ មុននឹងយើងទៅដល់ ។

## ភូមិឪម៉ាល់

មួយសន្ទុះក្រោយមក យើងក៏ចេញដំណើរបន្តទៅទៀតទាំងលើកជើងមិនចង់រួច ដើរផងឈប់ផង ទំរាំដល់ភូមិឪម៉ាល់ ។ ភូមិនេះមិនសូវខុសគ្នាពីភូមិបត់ត្រង់ឡើយ មានសុទ្ធតែគុម្ពឫស្សីដើមត្នោតដើមសណ្តាន់ និងដើមអ៊ីម្ប៉ាងដូចជាដើមទំពូង ។ នៅខាងក្រោយភូមិជាវាលបឹង និងវាលស្រូវឡើងទឹកផុតកន្ទុយភ្នែក ហើយចុះទៅខាងក្រោមប៉ែកខាងត្បូងភូមិជាល្បាស់ព្រៃនាមខៀវស្រងាត់ ។ បន្ទាប់មក យើងក៏ចូលបង្ហាញខ្លួនចំពោះមុខប្រធានភូមិឈ្មោះមិត្ត ហ៊ុំសម្បុរស រាងទាបទ្រនាប់ និងប្រពន្ធរបស់គាត់រាងតូចល្អិតមានធ្មេញ

ខ្មៅដោយសារហូបស្ពារជាប់នឹងមាត់ សំដីរួសរាយ និងមិនចេះប្រកាន់ខ្លួនដែលផ្ទុយពីអ្វីដែលយើងគិតថា ភូមិនោះប្រហែលសម្បូរទៅដោយមនុស្សចិត្តអាក្រក់ ។

យើងចោលកន្ទុយភ្នែកសព្វកន្លែងនៅខាងក្រោមផ្ទះប្រធានភូមិ ជាផ្ទះកន្ដាំងពីរខ្នង ប្រក់ក្បឿង មានលប និងព្រួលដាក់គរចោលមិនសូវមានសណ្ដាប់ធ្នាប់ ព្រមទាំងមានបង្គោលឈ្មោះគរជាពំនូក ។ នៅខាងមុខផ្ទះ គឺជារោងឆ្អើរត្រីដែលមានផ្សែងហុយ និងមានត្រីជាងពីរពាន់ចង្កាក់កំពុងធំក្លិនឈ្ងៀមដោយផ្សែងភ្លើងនៅឡើយ ។ រីឯនៅខាងមុខផ្ទះជាប់មាត់ស្ទឹង គឺជាដែសម្រាប់ធ្វើត្រីប្រហុក និងផ្អក (ដែលមានខាប់ ពាងតូចៗ) និងក្រឡជាច្រើនរៀបជាជួរ ដែលចោលក្លិនឆ្អាប ហើយនៅក្បែរនោះ ក៏មានពាងធំៗពីរ បីដែរ ដែលដាក់សុទ្ធតែខ្លាញ់ត្រី ។ ចំណែកនៅក្នុងស្ទឹងមានទូកអុំ ទូកចែវ ព្រមទាំងទូកឌុបចែវបួនចំនួនពីរគ្រឿងសម្រាប់ដឹកត្រី ភូមិនេះមានផ្ទះធំ និងផ្ទះតូចដទៃទៀតប្រហែល៣០ខ្នងទៀត ប៉ុន្តែភាគច្រើនជាផ្ទះប្រក់ស្លឹក ។

## ជំនាញរាយមង

ខ្ញុំធ្លាប់តែរាយមង ប៉ុន្តែសម្រាប់តែទឹកដែលជម្រៅពីមួយម៉ែត្រកន្លះទៅពីរម៉ែត្រប៉ុណ្ណោះ ។ ការដាក់មងនេះ ដំបូងខ្ញុំចេះតែដាក់ទាំងទទឹងទទែង ពេលខ្លះដាក់បានត្រី ខ្លះមិនបានត្រី ប៉ុន្តែក្រោយមកខ្ញុំរៀនមើលមេឃ មើលផ្កាយ ដើម្បីឲ្យដឹងថាយប់ណាត្រីដើរ យប់ណាត្រីមិនដើរ ។ តាមចំណាំ នៅពេលខែភ្លឺ ឬមេឃមានផ្កាយច្រើន ខ្ញុំនឹងរកត្រីបានច្រើន តែបើមេឃស្រអ័ព្ទឬចង់ភ្លៀងខ្ញុំរកត្រីពុំសូវបានឡើយ ។ ប៉ុន្តែនៅភូមិឪម៉ាល់គេមិនសូវប្រើមង នៅរដូវសម្រក អ្នកភូមិនៅទីនោះ ចាប់ត្រីដោយ ហ៊ុំអួន និងរាយព្រួលតាមបណ្ដោយមាត់ស្ទឹង បិទមាត់ទំនាប់ធំៗ ដើម្បីចាប់ត្រីនៅរដូវទឹកស្រក ។

## ត្រីនៅព្រៃរនាម

នៅរដូវសម្រក ខ្យល់ត្រជាក់ធ្លាក់ត្រសៀកៗ ហ្វូងត្រីដែលទៅនៅបង្កប់ខ្លួនក្នុងព្រៃរនាមនៅរដូវទឹកគម្លើង បានរស់នៅទីនោះរហូតដល់ទឹកសម្រក ។ ពេលដែលទឹកស្ទឹងហូរចាក់ទៅបឹងទន្លេសាប ទឹកដែលនៅទំនាបក្បែរនោះក៏ចាប់ហូរធ្លាក់មកដែរដែលនាំមកជាមួយនូវហ្វូងត្រីរាប់លានក្បាល ។ ប្រសិន បើយើងចោលកន្ទុយភ្នែកទៅ យើងនឹងឃើញខ្នងត្រីពណ៌ខ្មៅហែលប្រជ្រៀតគ្នាសម្រុកចេញពីក្នុងព្រៃ ឬហៅថា ទំនាប (ទំនាបធំៗ នៅតំបន់នោះមានពីរគឺទំនាបហាយ និងទំនាបរាំង) មកកាន់ស្ទឹងដែលមានខ្សែទឹកហូរយ៉ាងលឿនចាក់ទៅទន្លេសាប ។ លុះត្រីហែលមក ដល់ច្រកចេញ ក៏ពើបប្រទះនឹងព្រួលយ៉ាងវែងដែលអន្តកាពនេសាទតំបន់៩រាយ នៅតាមបណ្ដោយមាត់ស្ទឹងដែលទប់ដោយចម្រឹងបង្គោលឈើខ្លឹមរាប់រយដើម ដើម្បីទប់ជើងព្រួលកុំឲ្យបាក់នៅពេលដែលហ្វូងត្រីកំពុងសម្រុកចេញ ។ ព្រួលនោះមានបណ្ដោយទៅតាមមាត់ទំនាបធំតូច ហើយគេទុកមាត់ច្រកឲ្យត្រីចេញតែមួយ ឬពីរប៉ុណ្ណោះ ។ នៅពេលចាប់ត្រី កងនេសាទបានយកលបទៅដាក់នៅតាមច្រកដែលគេទុកឲ្យត្រីចេញតែរយៈពេលមិនដល់ប្រាំនាទីផង ត្រីចូលពេញមួយលប ទើបគេទាញបិទមាត់ព្រួលវិញ ។ បន្ទាប់មក មនុស្ស៦ទៅ៧នាក់ លើកលបចាក់ត្រីចូលទៅក្នុងទូកឌុប (ជាទូកដែលមានឃ្មុបកណ្ដាលជ្រៅ ហើយធំ ជាប្រភេទទូកចែវបីចំណុះ២-៣តោន) ជាច្រើនសាររហូតដល់ពេញ ទើបគេចែវទូកប្រញាប់ប្រញាល់តម្រង់មកភូមិវិញ ដើម្បីកុំឲ្យត្រីអន់សាច់ ។

## កងធ្វើត្រី

ពេលមកដល់ ក្រុមស្ត្រី និងនារីបាននាំគ្នាចុះទៅក្នុងទូកដើម្បីចូកត្រីដាក់ជាលតូចៗយកឡើងមកលើ ។ ពេលដែលចុះទៅក្នុងទូកគ្រាដំបូង ម្នាក់ៗបានលាន់មាត់នឹងត្រីច្រើន និងត្រីខ្លះដែលយើងមិនដែលឃើញទាល់តែសោះ ដូចជាត្រីឆ្ដោរមួយទម្ងន់ចាប់ពី៥ ទៅ១២គីឡូក្រាម ។ ត្រីទាំងនោះមាន ចម្រុះគ្នា មានទាំងត្រីក្រោសខ្នងវែង, ត្រីក្រោសមេម៉ាយ, ត្រីរៀល, ត្រីលិញ, ត្រីកញ្ចុនដៃ, ត្រីរ៉ស់, សណ្ដាយ, ឆ្ពិន, ក្រហែ, ឆ្លាត, លលកស, ក្រាញ់, កន្ធ្រប់, ត្រីតាឱន, ត្រីកេះ, ក្អែក, ក្ញាន់, អណ្ដែង និងត្រីកញ្ចុះ ជាដើម ។ ប៉ុន្តែគេជ្រើសយកត្រីទាំងនោះភាគច្រើនជាត្រីក្រោស ត្រីរៀល ឬត្រីលិញ ដែលនៅស្រស់ៗទៅយកឆ្អើរ ។ ក្នុងមួយថ្ងៃមួយយប់គេឆ្អើបាន២០០០ចង្កាក់ ។

ចំណែកត្រីដែលអន់សាច់ គេយកទៅធ្វើជាប្រហុក ។ ត្រីឆ្ពិន ឬត្រីក្ញាន់ គេយកទៅធ្វើផ្អក ចំណែកត្រីឆ្ដោរ និងត្រីរ៉ស់ធំៗយកទៅវះងៀតសម្រាប់កម្មាភិបាល និងអន្តកាពយោធា ។ នៅពេលចុះចូកត្រីពីក្នុងទូកម្ដងៗ គេរមែងខ្លាចត្រីកញ្ចុះដែលនៅលាយឡំជាមួយត្រីផ្សេងទៀត តែងតែមុតដៃនឹងឆ្អឹងរបស់វាដែលធ្វើឲ្យចុកចាប់ដល់គល់ក្លៀក ។ ត្រីកញ្ចុះក៏ត្រូវគេប្រមូលប្រឡាក់ហាល ដើម្បីហូបនៅរដូវប្រាំងពេលដែលខ្វះត្រី ។ **ស៊ីម ឆួន** **(នៅមានត)**

# ៣៦ឆ្នាំក្រោយមក ជោគវាសនារបស់សម្លាញ់ ឡាំ វ៉ារី ត្រូវបានរកឃើញ

នៅទីក្រុងម៉ូស្គូ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំបាននិយាយពាក្យថា "លាហើយ" ទៅកាន់មិត្តខ្ញុំម្នាក់ដែលជាជនជាតិខ្មែរ គឺបណ្ឌិត ឡាំ វ៉ារី ។ ពេលនោះ ខ្ញុំបានជូនពរឲ្យសម្លាញ់ វ៉ារី សូមធ្វើដំណើរតាមផ្លូវទៅកាន់ប្រទេសកំណើតវិញប្រកបដោយសុវត្ថិភាពដោយមិនដឹងថាខ្ញុំនឹងរងចាំគាត់រហូតដល់មរណភាពរបស់គាត់យ៉ាងដូច្នេះសោះ ។

ក្នុងខែធ្នូ ឆ្នាំ១៩៧៦ ខ្ញុំ និងមិត្តភក្តិជនជាតិនេប៉ាល់ម្នាក់ឈ្មោះ ម៉ានីក គ្រាន់តែទទួលដំណឹងថា សម្លាញ់ វ៉ារី បានចាកចេញពីសណ្ឋាគារមួយនៅទីក្រុងម៉ូស្គូក្នុងខែកក្កដា ឆ្នាំ១៩៧៦ នឹងធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា ។

ពេលនេះខ្ញុំទើបតែដឹងដំណឹងតាមរយៈទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបញ្ជាក់ថា សម្លាញ់ វ៉ារី របស់ខ្ញុំត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរស-២១តាំងពីខែតុលា ឆ្នាំ១៩៧៦ មកម្ល៉េះ ។ ទីបំផុត វ៉ារី ត្រូវបានសម្លាប់ក្នុងខែមីនា ឆ្នាំ១៩៧៧ ។ ក្តីឈឺចាប់នៅតែមានជាប់ជានិច្ច ។ ខ្ញុំបានខិតខំស្វែងរកដំណឹង វ៉ារី ព្រោះប្រពន្ធនិងកូនស្រីរបស់គាត់ពេលនេះកំពុងរស់នៅទីក្រុងម៉ូស្គូ ហើយអ្នកទាំងពីរក៏កំពុងតែចង់ដឹងដំណឹងអំពីប្តីនិងឪពុករបស់ខ្លួនយ៉ាងអន្ទះសារដែរ ។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២នេះ ខ្ញុំបានជួបជាមួយកូនស្រី និងចៅប្រុសរបស់សម្លាញ់ វ៉ារី ឈ្មោះ អេនតុន ។ អេនតុន ទទួលបានជោគជ័យ និងធ្លាប់ទទួលបានពានរង្វាន់មួយនៅប្រទេសអាល្លឺម៉ង់ ក្នុងនាមជាអ្នករាំដីប៉ិនប្រសប់ម្នាក់ ។ កូនស្រីនិងចៅប្រុសរបស់ វ៉ារី ជាមនុស្សរួសរាយរាក់ទាក់ ។ អ្នកណាក៏ស្រលាញ់និងចូលចិត្ត អេនតុន ដែរ ។ វ៉ារី នឹងមានមោទកភាពចំពោះកូនស្រី និងចៅប្រុសជាក់ជាមិនខាន ។ ខ្ញុំសប្បាយចិត្តដែលសម្លាញ់ វ៉ារី បានបន្សល់ទុកនូវកូនស្រី និងចៅប្រុសប្រកបទៅដោយភាពឆ្លាតវាងវៃបែបនេះ ។

**ពីខ្ញុំ ហានស៍ កូច**

***បញ្ជាក់ :*** *ឡាំ វ៉ារី ទទួលសញ្ញាបត្រខាងវិស្វកម្មវារីអគ្គិសនីនៅទីក្រុងម៉ូស្គូ ។ វ៉ារី គឺជាបញ្ញាវន្តម្នាក់ដែលត្រូវបានអញ្ជើញឲ្យត្រលប់មកប្រទេសកម្ពុជាវិញក្រោយពីខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសដើម្បីកសាងប្រទេសជាតិឡើងវិញ ។ ពេលមកដល់ប្រទេសកម្ពុជា វ៉ារី ត្រូវបានចោទប្រកាន់ថាជាជនក្បត់របស់កម្ពុជាប្រជាធិបតេយ្យ ហើយគាត់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ និងក្រោយមកត្រូវបានសម្លាប់នៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧៧ ។*



ចៅប្រុសរបស់ វ៉ារី (ឆ្វេង) ឈ្មោះ អេនតុន និង លោក ហានស៍ កូច

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 153, September 2012 ◆ Funded by Norway and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.